# អ្នកដឹកនាំ
# ស្ត្រីនៅកម្ពុជា

## ២១ អត្ថបទអំពីការតស៊ូ និង ភាពអំណត់

woomentum

KONRAD
ADENAUER
STIFTUNG

# អ្នកដឹកនាំស្ត្រីនៃកម្ពុជា

## ២១ អត្ថបទអំពីការតស៊ូ និងភាពអំណត់

២០១៩

woomentum

KONRAD
ADENAUER
STIFTUNG

# មាតិកា













៨ **លោកជំទាវវេជ្ជបណ្ឌិតអ៊ឹង កន្ថាផាវី**
**រដ្ឋមន្ត្រី** | ក្រសួងកិច្ចការនារី

១២ **លោកជំទាវឧកញ៉ា លីម ឈីវហួរ**
**ប្រធាន** | ក្រុមហ៊ុន អ៊ែត វូត អាហារ័ណ នីហារ័ណ

១៦ **លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវហ្គិច**
**ស្ថាបនិក និងប្រធាន** | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

២០ **លោកជំទាវ ភឿង សកុណា**
**រដ្ឋមន្ត្រី** | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងប្រធានអាជ្ញាធរជាតិអប្សរា

២៤ **លោកស្រី ឧន្ទបណ្ឌិត អេង លីគង់**
**ប្រធាន** | សមាគមសហគ្រិនស្ត្រីកម្ពុជា

២៦ **លោកស្រី លឹម សូលីន**
**នាយិកាប្រចាំប្រទេស** | អុកហ្វាមកម្ពុជា

៣២ **លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការ** | ក្រសួងមហាផ្ទៃ

៣៦ **លោកស្រី ខៀវ មាលី**
**ដៃគូអាជីវកម្ម** | SokSiphana & Associates និងជាសមាជិកនៃ ZICO Law

៤២ **លោកស្រី ហ៊ុន បូរមី**
**នាយិកាប្រចាំប្រទេស**| អង្គការអាក់សិនអេតកម្ពុជា

៤៦ **លោកជំទាវ តឹករ៉េត កំរេង**
**រដ្ឋលេខាធិការ**| ក្រសួងពាណិជ្ជកម្ម















៥០ **ឧកញ៉ា កែវ មុំ**
**ស្ថាបនិក និងប្រធាន** | ក្រុមហ៊ុនផលិតនំស្រួយ លីលី

៥៤ **លោកស្រី ស៊ុយ ចាន់ណេ**
**នាយិកាគ្រប់គ្រង** | InSTEDD iLab Southeast Asia

៥៨ **លោកជំទាវ គីម សេដ្ឋានី**
**រដ្ឋលេខាធិការ** | ក្រសួងអប់រំ យុវជន និងកីឡា

៦៦ **លោកស្រី ឆាយ ស៊ីវលីន**
**ប្រធាន** | សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា

៧០ **លោកស្រី នួន តិមាន**
**ស្ថាបនិក និងនាយិកាប្រតិបត្តិ** | អង្គការលើកស្ទួយប្រជាពលរដ្ឋ

៧៤ **លោកជំទាវ ជា ស៊ុនដាណែត**
**អនុរដ្ឋលេខធិការ** | ក្រសួងព័ត៌មាន

៧៨ **លោកស្រី សេង តក្កនារី**
**ស្ថាបនិក និងនាយិកាគ្រប់គ្រង**| សន្ទុសាសៀល

៨៤ **លោកស្រី ដាំ ចន្ធី**
**នាយិកាប្រតិបត្តិ**| អង្គការសមាគមខ្មែរលើ

៨៨ **លោកជំទាវ ជា សេរី**
**ជំនួយការទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស**| ធនាគារជាតិនៃកម្ពុជា

៩២ **លោកស្រី តាំង ហ្គេចលៀង**
**ប្រធានក្រុមប្រឹក្សាភិបាល**| អេច អេន អិល

៩៦ **លោកស្រី ប៉ុង លីមសាន**
**ស្ថាបនិក និងនាយិកាប្រតិបត្តិ**| ក្រុមហ៊ុន ហ្វីស វិម៉ិនថេក អេស៊ា

# បុព្វកថា

ការវិវត្តនៃតួនាទីរបស់ស្ត្រីនៅក្នុងសង្គម គឺជាការផ្លាស់ប្តូរមួយដ៏សំខាន់បំផុតដែលយើងបានឃើញក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ នេះជាការរីកចម្រើនមួយដែលយើងមានមោទនភាពបំផុត។

ត្រឹមតែ ៨០ឆ្នាំប៉ុណ្ណោះបន្ទាប់ពីស្ត្រីត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតជាលើកដំបូង ពួកគេមិនត្រឹមតែត្រៀមរួចរាល់ក្នុងការចូលរួមក្នុងកម្លាំងការងារយ៉ាងពេញលេញប៉ុណ្ណោះទេ ពួកគេថែមទាំងស្វែងរកតួនាទី និងភាពជាអ្នកដឹកនាំយ៉ាងសកម្មផងដែរ។ ស្ត្រីនាពេលបច្ចុប្បន្ននេះគឺជារដ្ឋមន្ត្រី អភិបាលខេត្ត ប្រតិបត្តិករសាជីវកម្ម សហគ្រិន វិនិយោគិន វិស្វករ អ្នកបង្កើត និងអ្នកច្នៃប្រតិដ្ឋ។ សង្គមរីកចម្រើនតាមរយៈភាពជោគជ័យរបស់ពួកគេ។

ជោគជ័យទាំងនេះមិនមែនបានមកដោយងាយស្រួលទេ ហើយបញ្ហាប្រឈមជាច្រើនសម្រាប់ស្ត្រីនៅតែមាន។ បញ្ហាប្រឈមនីមួយៗជាច្រើនក្នុងចំណោមនោះ គឺកើតមកពីការរំពឹងទុករបស់សង្គមដែលបានចាក់ឫសយ៉ាងជ្រៅលើស្ត្រីតាំងពីពួកគេនៅវ័យក្មេង ដូចជានិយមន័យជាស្ត្រី របៀបដែលស្ត្រីគួរតែដឹកនាំជីវិតរបស់ខ្លួន ឋានៈរបស់ស្ត្រីនៅក្នុងសង្គម និងរបៀបដែលស្ត្រីគួរតែទាក់ទងជាមួយអ្នកដទៃ។

នាពេលបច្ចុប្បន្ន សូម្បីតែនៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួននៅលើពិភពលោកក៏មានស្ត្រីវ័យក្មេងជាច្រើន បានត្រូវគេប្រាប់ថា ពួកគេមិនអាចទៅណាឆ្ងាយបានទេ ពីព្រោះពួកគេនឹងមិនអាចចិញ្ចឹម ឬមើលថែសមាជិកគ្រួសារដទៃទៀតបានទេ។ គ្មាននរណាប្រាប់ពួកគេថា ស្ត្រីជាច្រើនដូចជាពួកគេដែរ បានសម្រេចគោលដៅរបស់ពួកគេបានយ៉ាងល្អប្រសើរ។ នេះគឺជាមូលហេតុដែលសៀវភៅដែលមានឈ្មោះថា"អ្នកដឹកនាំស្ត្រីនៃកម្ពុជា" ២១អត្ថបទអំពីការតស៊ូ និង ភាពអំណត់បានត្រូវបោះពុម្ព។ យើងចង់បង្ហាញយុវនារីនៅក្នុងប្រទេសកម្ពុជា និងនៅជុំវិញពិភពលោកថា ទោះបីជាមានឧបសគ្គប៉ុនណា ក៏ដោយ ពួកគេអាចមានក្តីសុបិនធំៗ ហើយពួកគេអាចតាមរកក្តីសុបិនទាំងនោះ ដោយមិនចាំបាច់មានការសោកស្តាយទេ។



ការបោះពុម្ពផ្សាយនេះនាំមកជូននូវស្ត្រី ២១រូបដែលជាអ្នកដឹកនាំ ដែលមានរឿងជាច្រើនដើម្បីចែករំលែក អំពីភាពអំណត់អត់ធន់ ការបរាជ័យ និងភាពជោគជ័យរបស់ពួកគេ។ រឿងពិតទាំងនេះមានតម្លៃណាស់សម្រាប់ជាសក្ខីកម្មដល់ក្មេងជំនាន់ក្រោយដែលចងក្រងជាឯកសារថា ស្ត្រីដូចជាខ្លួនគេអាចដឹកនាំបាន និងនៅតែអាចមានក្រុមគ្រួសារមួយ មានសមត្ថភាពដូចបុរស មានសំឡេង ហើយ មានអំណាចធ្វើការសម្រេចចិត្តសំខាន់ៗដែលកំណត់អនាគតរបស់ពួកគេនិងកូនៗ របស់ពួកគេបាន។ យើងសូមកោតសរសើរយ៉ាងខ្លាំងចំពោះភាពជោគជ័យ និងភាពបរាជ័យរបស់ថ្នាក់ដឹកនាំស្ត្រីកម្ពុជា។ ដោយសាររឿងរ៉ាវពិតរបស់ពួកគេ ស្ត្រីវ័យក្មេងនឹងមានអំណាចក្នុងការគិតធំ សុបិនធំ និងសម្រេចការធំបាន។

យើងក៏សូមថ្លែងអំណរគុណចំពោះ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ដែលជាអ្នកឧបត្ថម្ភ និងជាអ្នកគាំទ្ររបស់យើងនៅក្នុងបេសកកម្មដ៏សំខាន់នេះក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅជុំវិញពិភពលោក។

លោកស្រី ម៉ូណា អេរី
*ស្ថាបនិកនៃ Woomentum*
*និង*
កញ្ញា ទូច សុជាតិតា
*ប្រធាន Woomentum ប្រចាំប្រទេសកម្ពុជា*

woomentum

# វាចាពីអ្នកនិពន្ធ

តាំងតែពីខ្ញុំនៅក្មេងម្ល៉េះខ្ញុំប្រាថ្នាចង់ក្លាយជាអ្នកដឹកនាំ។ ខ្ញុំបានប្រាប់ខ្លួនឯងថាខ្ញុំចង់បានការងារដែលមានប្រាក់ខែច្រើន ហើយក្លាយជាអ្នកដឹកនាំគំរូសម្រាប់បងប្អូនរបស់ខ្ញុំ និងជួយដល់ស្ត្រីនិងសហគមន៍កម្ពុជាក្នុងការរួមចំណែកដល់សេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក។ រហូតមកដល់ពេលនេះក្នុងជីវិតខ្ញុំ ខ្ញុំធ្លាប់ជាសិស្សនិស្សិត គ្រូបង្រៀន អ្នកនិពន្ធ អ្នកតស៊ូមតិផ្នែកសិទ្ធិស្ត្រី បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកយុទ្ធសាស្ត្រផ្នែកជំនួញ សហគ្រិន និងជាប្រធានប្រចាំប្រទេសកម្ពុជា នៃសមាគមពាណិជ្ជកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ខ្ញុំយល់ថា សង្គមរបស់យើងត្រូវការមេដឹកនាំពិតប្រាកដដែលបន្តផ្លាស់ប្តូរក្រុមនិងសង្គមរបស់ពួកគេដើម្បីធ្វើឱ្យពិភពលោកមានភាពប្រសើរឡើង។ នៅក្នុងអាជីពការងាររបស់ខ្ញុំ ខ្ញុំមានសំណាងណាស់ដែលបានធ្វើការជាមួយសន្តប័នសាធារណៈ និងឯកជនក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលដែលមានការដឹកនាំរឹងមាំនិងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

ដោយគ្មានការស្ទាក់ស្ទើរ ខ្ញុំបានទាក់ទងស្ត្រីអ្នកដឹកនាំឆ្នើមចំនួន ២១រូបដែលមានចរិតតស៊ូធ្វើការ និងមិនចេះខ្លាច ដើម្បីសុំឱ្យពួកគាត់ចូលរួមចំណែកដល់គម្រោងអំពីស្ត្រីជាអ្នកដឹកនាំនេះដែរ។ នៅក្នុងសៀវភៅនេះ ពួកគាត់បានចែករំលែកគ្រប់រសជាតិ (ផ្អែម ល្វីង ជូរចត់) នៃដំណើរជីវិតនិងការដឹកនាំរបស់ពួកគាត់។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាប្រភពនៃការផ្តល់អំណាចដល់ស្ត្រីនិងកុមារីនៅតាមបណ្តាឧស្សាហកម្មនិងប្រទេសផ្សេងៗ។ ខ្ញុំសូមឧទ្ទិសសៀវភៅនេះដល់ម្តាយជាទីស្រឡាញ់របស់ខ្ញុំដែលតែងតែផ្តល់ជាកម្លាំងចិត្តចិញ្ចឹមបីបាច់ និងដល់ឪពុកដែលតែងគាំទ្រខ្ញុំ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មេដឹកនាំស្ត្រីគ្រប់រូបដែលមានវត្តមាននៅក្នុងសៀវភៅនេះ ចំពោះពេលវេលាដ៏មានតម្លៃ និងការចែករំលែករឿងរ៉ាវដែលគួរឱ្យចាប់អារម្មណ៍របស់ពួកគាត់។ ដូចគ្នានេះផងដែរខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ Woomentum, មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរនិងក្រុមការងារដែលបានបោះពុម្ពផ្សាយសៀវភៅនេះ។

កញ្ញា ទូច សុជាតិតា
*ប្រធាន Woomentum ប្រចាំប្រទេសកម្ពុជា*

## អំពី WOOMENTUM ™



មានស្នាក់ការកណ្តាលនៅប្រទេសសិង្ហបុរី Woomentum គឺជាវេទិកាសហប្រតិបត្តិការដែលមាន សមាជិកភាពចូលរួមផ្សារភ្ជាប់សហគ្រិន អ្នកជំនាញក្នុងឧស្សាហកម្ម អ្នកដឹកនាំក្រុមហ៊ុននិងអ្នកវិនិយោគដើម្បីចែករំលែកចំណេះដឹង ដោះស្រាយបញ្ហាប្រឈម និងទទួលបានឱកាស ដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ។ បេសកកម្មរបស់ Woomentum គឺដើម្បីជួយដល់សហគ្រិន និងក្រុមដែលដឹកនាំដោយស្ត្រីដើម្បីចាប់ផ្តើមបង្កើត និងបណ្តុះក្រុមហ៊ុនប្រកបដោយនិរន្តរភាព និងរកប្រាក់ចំណេញបាន។

ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ២០១៤ Woomentum បានក្លាយជាកន្លែងសំខាន់មួយសម្រាប់សហគ្រិនស្ត្រីរាប់ពាន់នាក់មកពី៤៥ប្រទេសក្នុងទ្វីបទាំង៥ ដើម្បីទទួលបាននូវដំបូន្មានជាក់ស្តែង ចំណេះដឹង និងដើមទុន។

នៅឆ្នាំ២០១៦ស្ថានិករបស់ Woomentum បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយបានជួបជាមួយសុជាតិតា ដែលមានការចាប់អារម្មណ៍ខ្លាំងពីវេទិកា Woomentum។ សុជាតិតាបានកំណត់គោលដៅរបស់គាត់ក្នុងការកសាងសមត្ថភាពរបស់សហគ្រិនស្ត្រីនឹងផ្សារភ្ជាប់សហគ្រិនភាពរបស់ពួកគាត់ទៅកាន់ទីផ្សារតំបន់និងសកលតាមរយៈវេទិកាWoomentum។ Woomentum ត្រូវបានប្រកាសជាផ្លូវការនៅប្រតិបត្តិការណ៍របស់ខ្លួននៅចុងឆ្នាំ២០១៨។ Woomentum ប្រចាំនៅប្រទេសកម្ពុជានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី សមាគមពាណិជ្ជកម្មនិងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព។
វេបសាយ: http://woomentum.com

# ការបដិសេធ

អត្ថបទដែលបានបោះពុម្ពនេះ មិនបានឆ្លុះបញ្ចាំងពីយោបល់និងទស្សនៈរបស់ក្រុមការងារ Woomentum និងមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) ទេ។ ហេតុដូច្នេះការសន្មតដែលបានធ្វើនៅក្នុងអត្ថបទនេះមិនឆ្លុះបញ្ចាំងពីអង្គភាពណាមួយផ្សេងទៀតក្រៅពីអ្នកនិពន្ធទេ ហើយដោយសារតែយើងជាមនុស្សដែលមានការគិតបែបស៊ីជម្រៅ ទស្សនៈទាំងនេះតែងតែអាចមានការផ្លាស់ប្តូរ ពិនិត្យឡើងវិញនិងគិតឡើងវិញ។

# មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

សេរីភាព យុត្តិធម៌ និងសាមគ្គី ជាគោលការណ៍ក្នុងការកំណត់សកម្មភាពរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) គឺជាមូលនិធិនយោបាយមួយដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សសហភាពប្រជាធិបតេយ្យគ្រិស្ត (Christian Democratic Union) របស់ប្រទេសអាល្លឺម៉ង់។ លោកខុនរ៉ាដ អាដិនណៅអ៊ែរ (១៨៧៦-១៩៦៩) គឺជាសហស្ថាបនិកនៃគណបក្ស CDU និងជាអធិការបតីដំបូងគេបង្អស់នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានបង្រួបបង្រួមពួកគ្រិស្តនិយម ពួកអភិរក្សនិយម និងពួកសេរីនិយមទាំងឡាយ។ កិត្តិនាមរបស់លោក មានន័យដូចគ្នាទៅនឹងការកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ការយល់ស្របគ្នាលើគោលនយោបាយការបរទេសទៅនឹងគុណតម្លៃនៃសហគមន៍មហាសមុទ្រអាត្លង់ទិក ចក្ខុវិស័យនៃការបង្រួបបង្រួមអឺរ៉ុប និងការតម្រង់ទិសឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសង្គម។ KAS បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសេដ្ឋកិច្ចទីផ្សារសង្គម នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប និងអន្តរជាតិ តាមរយៈការិយាល័យរបស់ខ្លួននៅបរទេស ជិត៨០ការិយាល័យ និងមានគម្រោងនានានៅក្នុងប្រទេសជាង ១២០ប្រទេស។

KAS បានធ្វើការនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩៤ ដោយខិតខំគាំទ្រដល់ប្រជាជនកម្ពុជាក្នុងការជំរុញកិច្ចសន្ទនា កសាងបណ្តាញ និងលើកស្ទួយគម្រោងវិទ្យាសាស្ត្រ។ ដោយហេតុនេះមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ធ្វើការឆ្ពោះទៅរកការបង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ កម្មវិធីទាំងអស់ត្រូវបានបង្កើត និងអនុវត្តដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូកម្ពុជានៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ។


# ©រក្សាសិទ្ធិ២០១៩



**Woomentum, Cambodia,** កម្ពុជា
ផ្ទះលេខ ៦ ផ្លូវ ៣៦ ពោធិ៍សែនជ័យ
ភ្នំពេញ រាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ១២ ៦៧២ ៣៦៧
អ៊ីម៉ែល៖ socheata@woomentum.com
វេបសាយ៖ http://woomentum.com
ហ្វេសប៊ុក៖ www.facebook.com/Woomentum



**Konrad-Adenauer-Stiftung**, កម្ពុជា
ផ្ទះលេខ ៤ ផ្លូវ ៤៦២ ខណ្ឌចំការមន
P.O box ៩៤៤ ភ្នំពេញ រាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៦៦ ១៧៦
អ៊ីម៉ែល៖ Office.PhnomPenh@kas.de
វេបសាយ៖ www.kas.de/cambodia
ហ្វេសប៊ុក៖ www.facebook.com/kaskambodscha


# បុព្វកថា

សមភាពយេនឌ័រ គឺពិតជាបញ្ហាមួយក្នុងចំណោមបញ្ហាឈានមុខគេ និងសំខាន់បំផុតក្នុងពេលបច្ចុប្បន្ន។ រៀងរាល់ថ្ងៃ ស្ត្រីនៅទូទាំងពិភពលោកបានកំពុងប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិ និងការតំណាងរបស់ពួកគេក្នុងសេដ្ឋកិច្ចនយោបាយ និងសង្គមស៊ីវិល។ ការតស៊ូដើម្បីយុត្តិធម៌ សមភាព និងការសម្រេចចិត្តដោយខ្លួនឯង ត្រូវបានធ្វើឡើងនៅក្នុងគ្រួសារ កន្លែងការងារ សភា មណ្ឌលកីឡា សាលារៀន និងនៅក្នុងចិត្តរបស់មនុស្សផងដែរ។

ការគិតឡើងវិញអំពីសង្គម និងការបង្កើតវិធីថ្មីសម្រាប់យើងរៀបចំសង្គម ត្រូវរួមបញ្ចូលការឆ្លុះបញ្ចាំងពីតួនាទីរបស់ស្ត្រី និងបុរស។ សេរីភាព យុត្តិធម៌ និងសាមគ្គីភាពមិនមែនជាសិទ្ធិផ្តាច់មុខរបស់បុរសទេ។ នោះហើយជាមូលហេតុដែលសមភាពយេនឌ័រគឺជាប្រធានបទពីរភាគី ដែលជាបញ្ហាស្មើគ្នាសម្រាប់ស្ត្រីនិងបុរស។ ភាគីទាំងសងខាងត្រូវតែធ្វើការរួមគ្នាដើម្បីភាពរីកចម្រើន និងការពង្រឹងអំណាចបន្ថែម។ ការសន្ទនាអំពីសមភាពយេនឌ័រ វេទិកាត្រូវតែបង្កើតឡើងដើម្បីឱ្យមានគោលនយោបាយ យុទ្ធនាការនិងយុទ្ធសាស្ត្រល្អប្រសើរជាងមុន ក៏ដូចជាការអនុវត្តច្បាប់ផងដែរ។ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ទេសម្រាប់ ឱ្យអ្នកជំនាញ និងឥស្សរជនមានឥទ្ធិពលលើសុន្ទរកថាអំពីសមភាពយេនឌ័រ។ វាត្រូវតែជាកិច្ចខិតខំប្រឹងប្រែងពហុភាគីដែលគ្របដណ្តប់គ្រប់កម្រិត គ្រប់ស្រទាប់សង្គម និងក្រុមមនុស្ស។ សមភាពយេនឌ័រចាប់ផ្តើម និងបញ្ចប់នៅក្នុងខួរក្បាលរបស់មនុស្ស។

ដូចនេះហើយ KAS មានសេចក្តីសោមនស្សរីករាយណាស់ដែលបានបោះពុម្ពសៀវភៅណែនាំស្តីពីភាពជាអ្នកដឹកនាំស្ត្រីនាពេលបច្ចុប្បន្នរួមគ្នាជាមួយ Woomentum។ វាមិនត្រឹមតែជាការចងក្រងបទសម្ភាសន៍អំពីស្ត្រីរឹងមាំ និងជោគជ័យនៅក្នុងមុខតំណែងផ្សេងៗទេ វាក៏និយាយពីរឿងរ៉ាវអំពីជីវិតរស់នៅរបស់ស្ត្រីដែលប្រឈមនឹងឧបសគ្គជាច្រើន និងបញ្ហាប្រឈមនៅក្នុងសង្គមបិតាធិបតេយ្យ និងមានឋានានុក្រមខ្លាំង ហើយនៅតែយកឈ្នះពួកគេបាន។ វាគឺជាការយកចិត្តទុកដាក់របស់ពួកគេចំពោះមនុស្សជំនាន់ក្រោយដើម្បីបង្ហាញថា ភាពជោគជ័យមិនត្រូវបានចងភ្ជាប់ទៅនឹងភេទឬប្រវត្តិទេ វាត្រូវបានចងភ្ជាប់ទៅនឹងភាពរឹងមាំ ភាពប៉ិនប្រសប់ និងភាពក្លាហាន។

ខ្ញុំមានការស្ងើចសរសើរ និងក្តុកក្តួលយ៉ាងខ្លាំងចំពោះរឿងរ៉ាវទាំងនេះ។ ខ្ញុំសូមជូនពរឱ្យសៀវភៅនេះជំរុញទឹកចិត្តដល់យុវជននិងមនុស្សចាស់ ស្ត្រីនិងបុរស អ្នកមាននិងអ្នកក្រ ហើយជាមួយគ្នានោះនាំឱ្យមានសង្គមមួយបើកចំហ និងឱ្យតម្លៃដល់គុណសម្បត្តិ។

*សូមរីករាយក្នុងការអាន!*




បណ្ឌិត ដាញ៉ែល ស្ទូគឃីង
*តំណាងប្រចាំប្រទេស*
*Konrad-Adenauer-Stiftung*
*ព្រះរាជាណាចក្រកម្ពុជា*

# លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី

## រដ្ឋមន្ត្រី | ក្រសួងកិច្ចការនារី



អ្នកដឹកនាំ ស្ត្រីនៅកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ( គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំនិងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត ?*

ខ្ញុំកើតក្នុងគ្រួសារមួយដែលមានលោកឪពុកជាមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាល ឯអ្នកម្តាយខ្ញុំជាស្ត្រីមេផ្ទះម្នាក់ដែលស្រឡាញ់ការសិក្សា។ លោកទាំងពីរ ជាពិសេសអ្នកម្តាយខ្ញុំ មានតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនខ្ញុំនិងបងប្អូនទៅសាលារៀនទៅតាមលទ្ធភាពរបស់ពួកខ្ញុំ។ ពួកលោកបានផ្តល់ឱកាសមាសដល់ខ្ញុំដើម្បីសិក្សា មិនត្រឹមតែនៅប្រទេសកម្ពុជាទេគឺនៅប្រទេសបារាំងផងដែរ។ ខ្ញុំមានបងប្អូនប្រាំពីរនាក់ (ស្រីបួននិងប្រុសបី) ហើយពួកគេបច្ចុប្បន្នកំពុងធ្វើការជាវិស្វករ គណនេយ្យករ ឱសថការី និងអ្នកវិទ្យាសាស្ត្រ ។ល។ ខ្ញុំបានរៀបការជាមួយសេដ្ឋកិច្ចវិទូម្នាក់ហើយពេលនេះយើងមានកូនស្រីម្នាក់។ ខ្ញុំបានចាកចេញ ពីប្រទេសកម្ពុជានៅឆ្នាំ១៩៧២ទៅសិក្សានៅប្រទេសបារាំង។ ខ្ញុំទទួលបានសញ្ញាបត្រពីរ បណ្ឌិតវេជ្ជសាស្ត្រ(ពីប៉ារីស)និងសញ្ញាបត្រឌីប្លូមពី Ecole Nationale d'Administration (ENA-Paris) ដោយខ្ញុំសិក្សាវគ្គប្រតិបត្តិ"Leaders in Development: Managing Political and Economic Reform" នៅសាលា John F. Kennedy School of Government នៃសាកលវិទ្យាល័យ Harvard (២០០៤)។




## “ ត្រូវជឿជាក់លើខ្លួនឯង លើសមត្ថភាពនិងចក្ខុវិស័យយើង! ត្រូវចេះដាក់ខ្លួន ហើយហ៊ានទទួលយកមតិរិះគន់

ខ្ញុំចំណាយពេលជិត១0ឆ្នាំធ្វើការនៅប្រទេសបារាំងជាវេជ្ជបណ្ឌិតឯកជនដំបូងនៅមន្ទីរពេទ្យបារាំង និងក្រោយមក ខ្ញុំមានបន្ទប់ពិគ្រោះខ្លួនឯង។ បន្ទាប់មកខ្ញុំបានក្លាយជាប្រធានផ្នែកឱសថសម្រាប់ការសាកល្បងក្នុងក្រុមហ៊ុនបារាំងមួយ។ ក្នុងទសវត្សរ៍១៩៩0 ខ្ញុំក្លាយជាអគ្គលេខាធិការរងនៃ "Association des MédecinsCambodgiens" ដែលមានគោលដៅផ្តល់ជំនួយផ្នែកបច្ចេកទេសនិងឱសថដល់ប្រទេសកម្ពុជាដូចជា ថ្នាំនិងឧបករណ៍ពេទ្យព្រមទាំងការបណ្តុះបណ្តាលដើម្បីពង្រឹងជំនាញដល់ក្រុមវេជ្ជបណ្ឌិត។ ខ្ញុំបានត្រលប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៩៥ រួចបានធ្វើការជាទីប្រឹក្សាបច្ចេកទេសដល់ក្រសួងអភិវឌ្ឍន៍ជនបទ។ ក្នុងអំឡុងពេលនោះ ខ្ញុំបានទទួលខុសត្រូវលើការអភិវឌ្ឍសហគមន៍ ដោយផ្តោតលើសុខុមាលភាពនៅជនបទ ការបង្កើនអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងការបង្កើតឡើងវិញនៅវិស័យសូត្រនិងការទទួលបានទឹកស្អាត។ក្នុងឆ្នាំ១៩៩៨ ខ្ញុំបានប្តូរមកក្រសួងកិច្ចការនារី ហើយបម្រើការងារជារដ្ឋលេខាធិការចំនួនប្រាំឆ្នាំមុនត្រូវបានដំឡើងតំណែងជារដ្ឋមន្ត្រីក្រសួងកិច្ចការនារីក្នុងខែមិថុនាឆ្នាំ២០០៤។ អ្វីដែលខ្ញុំមានមោទនភាពបំផុតគឺការដែលខ្ញុំមានបទពិសោធន៍ទាំងវិស័យឯកជននិងសាធារណៈ។ បរិយាកាសការងារមានភាពប្រកួតប្រជែងពេលនៅក្នុងវិស័យឯកជន យើងត្រូវតែពូកែជាងនិងមានគំនិតផ្តួចផ្តើមជាងអ្នកដទៃទៀត។ ផ្នត់គំនិតនិងការដឹកនាំគឺឆ្ពោះទៅរកផលប្រយោជន៍របស់ក្រុមហ៊ុន។ ចំណែកក្នុងវិស័យសាធារណៈវិញ យើងមានគោលបំណងផ្សេងដោយសារយើងធ្វើការសម្រាប់ប្រយោជន៍របស់ប្រជាជនទូទៅ។

*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ ?*

ខ្ញុំចាប់ផ្តើមអាជីពខ្ញុំដំបូងនៅប្រទេសបារាំងហើយខ្ញុំដូចជាចុះសម្រុងល្អណាស់។ ប៉ុន្តែ ខ្ញុំក៏ជួបឧបសគ្គមួយចំនួននៅពេលដំបូងដោយសារភាពខុសគ្នារវាងវប្បធម៌និងផ្នត់គំនិតក៏ដូចជាក្នុងនាមជាស្ត្រីនិងជាជនបរទេស (រូបរាងខ្ញុំខុសពីជនជាតិបារាំង)។ អ្វីដែលលំបាកនោះគឺពេលត្រូវបង្ហាញថាខ្ញុំជាអ្នកគ្រប់គ្រងនិងដឹកនាំ។ ខ្ញុំត្រូវធ្វើការខ្លាំងជាងមុនដើម្បីទទួលបានការគោរពពីដៃគូនិងបុគ្គលិកខ្ញុំ។

ជាចុងក្រោយ ខ្ញុំអាចនិយាយថាដោយសារតែភាពអំណត់និងការប្រឹងប្រែងខ្ញុំអាចគ្រប់គ្រងនិងជោគជ័យក្នុងអាជីពរបស់ខ្ញុំ។

បន្ទាប់ពីប្រទេសបារាំងបានចូលជាសមាជិកសហភាពអឺរ៉ុបខ្ញុំសង្កេតឃើញថាមានការផ្លាស់ប្តូរវិជ្ជមានច្រើនពីប្រជាជន។ ពួកគេហាក់បើកចិត្តទូលាយជាងមុនហើយទទួលយកភាពផ្សេងៗគ្នាជាងមុន។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ខ្ញុំចង់ចែករំលែកមេរៀនមួយចំនួនដែលខ្ញុំបានរៀនពីបទពិសោធន៍ពីមុន និងបច្ចុប្បន្នរបស់ខ្ញុំក្នុងវិស័យឯកជននិងសាធារណៈដើម្បីធានាជោគជ័យរបស់ខ្ញុំ៖

- តើយើងកំពុងដឹកនាំនរណា? វាជាការសំខាន់ណាស់ដែលយើងត្រូវស្គាល់មនុស្សដែលយើងត្រូវដឹកនាំហើយផ្តល់បទបញ្ជាឱ្យបានច្បាស់លាស់ដល់ពួកគេ
- ត្រូវប្រាកដថាអ្នកនិងបុគ្គលិករបស់អ្នកមានចក្ខុវិស័យដូចគ្នា
- ត្រូវប្រាកដថាពួកគេគាំទ្រនិងជឿជាក់លើអ្នក
- អ្នកដឹកនាំត្រូវគិតឱ្យបានច្បាស់លាស់អំពីការដាក់មនុស្សឱ្យចំកន្លែងដោយផ្អែកលើជំនាញទន់(ទំនាក់ទំនង ការបត់បែន និងការកែប្រែ) និងជំនាញរឹង។
- យើងត្រូវបង្កើតឱ្យមានទំនាក់ទំនងពីរផ្លូវរវាងយើងជាអ្នកដឹកនាំនិងបុគ្គលិក
- អ្នកដឹកនាំត្រូវយល់ឱ្យច្បាស់អំពីការរំពឹងទុករបស់បុគ្គលិកមុនពេលធ្វើការប្តេជ្ញាអ្វីមួយ។ មិនត្រូវបន្ទោសពេលមានបញ្ហាកើតឡើង ទំនួលខុសត្រូវគឺចាំបាច់ណាស់សម្រាប់អ្នកដឹកនាំ។

*តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើលោកជំទាវធានាថាក្រុម/បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច ?*

ក្នុងគ្រួសារ ប្តីនិងប្រពន្ធគឺជាដៃគូស្នេហានិងជីវិត។ ខ្ញុំមិនដែលគិតពីតំណែងដឹកនាំឬអ្នកដើរតាមទេក្នុងគ្រួសារ ព្រោះខ្ញុំតែងតែគិតថាខ្ញុំនិងស្វាមីខ្ញុំមានសិទ្ធិស្មើគ្នា។ មុនខ្ញុំរៀបការ ខ្ញុំបានពិភាក្សាជាមួយគាត់អំពីក្តីស្រមៃរបស់ខ្ញុំដែលចង់ធ្វើជាស្ត្រីចេញទៅធ្វើការខាងក្រៅមិនមែនស្ត្រីមេផ្ទះទេ។ គាត់អនុញ្ញាតឱ្យខ្ញុំមានអាជីពមួយហើយពួកយើងមានគោលដៅរួមទាក់ទិននឹងការងារ។

អ្វីជាតម្លៃស្នូលរបស់ខ្ញុំ?

- មិនត្រូវបោះបង់ជាដាច់ខាត! ត្រូវព្យាយាមនិងប្រឹងប្រែង។ មិនត្រូវប្រកាន់ខ្លួន! ពេលអ្នកប្តេជ្ញាធ្វើអ្វីមួយ អ្នកត្រូវតែធ្វើទោះមានឧបសគ្គឬការបំបាក់ទឹកចិត្តពីអ្នកផ្សេងក៏ដោយ។ ត្រូវហ៊ានតស៊ូទៅមុខ។
- ខ្ញុំផ្តល់តម្លៃដល់ការចរចា។ វាជាជំនាញដ៏មានថាមពលមួយដែលអាចឱ្យផ្លូវដើររបស់អ្នករលូនបាន។
- កុំខ្មាសអៀននៅពេលអ្នកត្រូវការសួររកជំនួយពីអ្នកដទៃ
- ស្ត្រីអាចឡើងតំណែងក្នុងអាជីពនៅពេលស្វាមីពួកគេជួយគាំទ្រ ជួយចែករំលែកទំនួលខុសត្រូវក្នុងគ្រួសារ ការងារផ្ទះសម្បែង និងមិនច្រណែនជាមួយដៃគូពួកគេ។ យើងអាចនិយាយថា “សុភមង្គលនិងជោគជ័យក្នុងគ្រួសារនាំឱ្យមានភាពជោគជ័យក្នុងការងារឬជំនួញ”។ វាជាការពិតចំពោះស្ត្រីនិងបុរស។ ការមានឪពុកម្តាយជាគំរូល្អក៏នឹងមានឥទ្ធិពលល្អដល់អនាគតកូនរបស់ខ្លួនដែរ
- ស្ត្រីត្រូវគាំទ្រស្ត្រី។ ស្ត្រីគួរមានទំនុកចិត្តខ្លួនឯងនិងគាំទ្រស្ត្រីដទៃទៀតក្នុងកន្លែងធ្វើការ។




*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

ខ្ញុំគិតថាចំណុចអវិជ្ជមាននោះគឺការដាក់ផលប្រយោជន៍ខ្លួនឯងមុនប្រយោជន៍របស់ក្រុមការងារ ក្រុមហ៊ុន ឬស្ថាប័ន។ ការមានចិត្តចង្អៀតចង្អល់និងគិតខ្លី។ ការបោះបង់ការងារពេលមានឧបសគ្គ ការមិនសម្រេចចិត្តនិងមិនទទួលខុសត្រូវចំពោះសកម្មភាពរបស់យើង។

*តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ( គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ ) ?*

- ជឿជាក់លើខ្លួនអ្នកនិងសមត្ថភាពរបស់អ្នក
- ជឿលើចក្ខុវិស័យនិងការប្តេជ្ញារបស់អ្នក
- មិនត្រូវប្រកាន់ខ្លួននិងហ៊ានទទួលមតិរិះគន់

*តើអ្វីខ្លះជាហានិភ័យធំៗមួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ហានិភ័យធំបំផុតក្នុងអាជីពខ្ញុំគឺនៅពេលដែលខ្ញុំត្រូវសម្រេចចិត្តបោះបង់ជីវិតការងារដ៏សុខស្រួលរបស់ខ្ញុំនៅប៉ារីសក្នុងទសវត្សរ៍១៩៩០ហើយនាំគ្រួសារទាំងមូលរបស់ខ្ញុំត្រលប់មកប្រទេសកម្ពុជាវិញ ក្រោយការចាកចេញអស់រយៈ២៣ឆ្នាំមកហើយ។ ស្ថានភាពក្នុងប្រទេសកម្ពុជាពេលនោះគឺលំបាកណាស់សម្រាប់ខ្ញុំ។ ប្រាក់ខែខ្ញុំទាបជាងមុនមួយរយដងនេះមានន័យថាខ្ញុំមិនអាចបង់លុយឱ្យកូនស្រីខ្ញុំរៀនបានផង។ ការយល់ដឹងនិងទំនាក់ទំនងរបស់ខ្ញុំជាមួយមនុស្សទូទៅគឺត្រូវបានកែប្រែទៅតាមបរិស្ថានថ្មីនេះ។

ឥឡូវនេះ បន្ទាប់ពីរយៈ២៣ឆ្នាំនៃការអំណត់ប្រឹងប្រែង និងភាពក្លាហានដើម្បីចូលរួមក្នុងការកសាងឡើងវិញនៅកម្ពុជានិងជួយដល់ការកសាងធនធានមនុស្សខ្ញុំក្លាយជារដ្ឋមន្ត្រីក្នុងក្រសួងកិច្ចការនារី។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ខ្ញុំគិតថាកម្ពុជាផ្តល់ឱកាសមាសជាច្រើនសម្រាប់អ្នកធ្វើការក្នុងស្រុកនិងជនបរទេស សហគ្រិន និងវិនិយោគិននានាដោយសារយើងមានតម្រូវការខ្លាំងខាងការអភិវឌ្ឍ។ ប្រជាជនកម្ពុជានៅវ័យក្មេង ហើយចង់បានឱកាស។

## “ ស្ត្រីគួរមានទំនុកចិត្តលើខ្លួនឯងហើយគាំទ្រស្ត្រីដទៃទៀតក្នុងកន្លែងការងារនិងសង្គម

- ប្រជាជនកម្ពុជាធ្លាប់ឆ្លងកាត់សម័យប្រល័យពូជសាសន៍ ហើយពេលនេះពួកគាត់ធន់និងការលំបាកឧបសគ្គ និងស្ថានភាពលំបាកលំបិន។ ប្រជាជនយើងគាត់ងាយសម្របតាមស្ថានការណ៍ផ្សេងៗ។
- ប្រជាជនយើងគាត់រួសរាយ ថាមពល និងចេះច្នៃប្រតិដ្ឋក្នុងការដោះស្រាយបញ្ហាឬផ្តួចផ្តើមធ្វើអ្វីមួយ

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

បើតាមខ្ញុំគិត សព្វថ្ងៃនេះយុវតីខ្មែរជាច្រើនជាមនុស្សខ្លាំង។ ខ្ញុំចង់ចែករំលែកដំបូន្មានមួយចំនួនដល់អ្នកដែលកំពុងប្រកបអាជីវកម្មក៏ដូចជាក្នុងផ្នែកផ្សេងទៀត៖

- កុំខ្លាចក្នុងការស្រមៃខ្ពស់! ត្រូវសង្ឃឹមជានិច្ចថាអ្នកនឹងសម្រេចក្តីប្រាថ្នារបស់អ្នក
- ពេលគិតថាខ្លួនយើងកំពុងធ្វើរឿងត្រឹមត្រូវ សូមបន្តការងារយើងទៅតាមគោលដៅនិងចក្ខុវិស័យយើង
- លើកទឹកចិត្តខ្លួនឯងនិងអ្នកដទៃ។ ការធ្វើអាជីវកម្មជាដំណើរវែងឆ្ងាយហើយផ្លូវក៏រលាក់។ ត្រូវទុកចិត្តលើខ្លួនឯង ហើយនាំគេឱ្យចូលរួមគាំទ្រយើង
- កុំស្តាយរឿងពីមុន បើអ្នកត្រូវតែផ្លាស់ប្តូរផ្លូវដើរ។ ជីវិតតែងដើរទៅមុខជានិច្ច ហើយជីវិតតែងមានឡើង មានចុះ។ អ្នកត្រូវមានជំនឿលើខ្លួនឯង។ អ្នកនឹងចេញផុតពីឧបសគ្គ បើអ្នកតស៊ូ។ អ្នកត្រូវសន្សំកម្លាំងហើយដើរទៅមុខជានិច្ច! WK

អ្នកដឹកនាំស្ត្រីនៃកម្ពុជា

# លោកជំទាវឧកញ៉ា លឹម ឈីវហួរ

## ប្រធាន | ក្រុមហ៊ុន អ៊ែត វូត អាហារ៍ណ នីហារ៍ណ



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់ជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលមានមោទនភាពបំផុត?*

ខ្ញុំកើតនៅក្រុងព្រះសីហនុ នៅថ្ងៃទី១ តុលា ១៩៦១។ ខ្ញុំមានបងប្អូន១០នាក់ តែពួកគាត់ពាក់កណ្តាលរួមទាំងឪពុកខ្ញុំនិងសាច់ញាតិមួយចំនួនផងបានបាត់បង់ជីវិតក្នុងរបបប៉ុលពត។ ខ្ញុំនៅសល់បងប្អូនប្រាំនាក់ ហើយខ្ញុំជាកូនទី៣។ ក្នុងសម័យខ្មែរក្រហមកាន់អំណាច នៅឆ្នាំ១៩៧៥គ្រួសាររបស់ខ្ញុំបានបែកខ្ញែកគ្នា ហើយខ្ញុំត្រូវបានគេដាក់បញ្ចូលក្នុងជំរំប្រមូលផ្តុំមួយជាមួយក្មេង២៧៥នាក់ផ្សេងទៀត។ ពេលនោះខ្ញុំមានអាយុ១១ឆ្នាំហើយត្រូវបានគេបង្ខំឱ្យធ្វើការលើកទំនប់ដោយគ្មានការសម្រាកទេ។ ពួកខ្មែរក្រហមតែងយកមនុស្សទៅសម្លាប់រាល់ថ្ងៃជាពិសេសអ្នកដែលមានសាច់ឈាមជាជនជាតិចិន និងជាអ្នកចេះដឹង សំណាងល្អ ខ្ញុំបានស្ថិតក្នុងចំណោមក្មេងស្រី៥នាក់ដែលបាននៅរស់រានមានជីវិត។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានជួបម្តាយ បងស្រី និងប្អូនប្រុសខ្ញុំវិញ។ ក្នុងពេលទ័ពវៀតណាមកំពុងតែគ្រប់គ្រងកម្ពុជា គ្រួសារខ្ញុំនិងខ្ញុំបានចាប់ផ្តើមរកស៊ីដំបូងដោយធ្វើស្រែ លក់ស្រូវនិងស្រាសឱ្យទ័ពវៀតណាម និងដូរសត្វយកមាស។

ម្តាយខ្ញុំបានរៀបចំឱ្យខ្ញុំរៀបការជាមួយអ្នកនេសាទម្នាក់ដែលប្រើទូករបស់គាត់ដើម្បីយកគ្រឿងអេឡិចត្រូនិច ស្រា និងបារី ដឹកមកកោះថ្មសតាមកប៉ាល់ធំៗពីសិង្ហបុរី ខ្ញុំចាំថា កាលនោះខ្ញុំនៅផ្ទះលក់មី។ ប្តីខ្ញុំត្រូវបានគេចាប់ឃុំឃាំងដោយសារគាត់លក់ម៉ូតូពីប្រទេសថៃមកកម្ពុជាដោយគ្មានប៉ាស្ព័រ។ នេះជាលើកទីមួយដែលខ្ញុំចូលរួមខ្លាំងក្នុងរបរជំនួញ វាជាការចាប់ផ្តើមរបស់ក្រុមហ៊ុនអេតវូដអាហារ៍ណ នីហារ៍ណ ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤។

មកដល់បច្ចុប្បន្ននេះ ខ្ញុំមានសិទ្ធិផ្តាច់មុខក្នុងការលក់ស្រាដែលមានម៉ាកល្បីៗ ដូចជាHennessy និង Johnie Walkerហើយជំនួញផ្សេងទៀតរបស់ខ្ញុំគឺក្នុងការអភិវឌ្ឍអចលនទ្រព្យ សណ្ឋាគារ ទេសចរណ៍ និងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ ដោយសារតែជោគជ័យលើផ្នែកជំនួញ ខ្ញុំត្រូវបានជ្រើសរើសជាអនុប្រធាននៃសភាពាណិជ្ជកម្មភ្នំពេញនិងសភាពាណិជ្ជកម្មកម្ពុជា។




*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ?*

ឧបសគ្គដ៏ធំបំផុតដែលខ្ញុំបានជួបពេលធ្វើជំនួញគឺរៀនបែងចែករវាងគ្រួសារ និងជំនួញ។ ធម្មជាតិនៃជំនួញគឺងាយប្រែប្រួល ពេលខ្លះចំណេញពេលខ្លះខាត ត្រឹមមួយពព្រិចភ្នែកដូច្នេះខ្ញុំត្រូវតែយកចិត្តទុកដាក់តាមដានជានិច្ច តែគ្រួសារ ខ្ញុំក៏ត្រូវការការយកចិត្តទុកដាក់ដូចគ្នាដែរ។ និយាយដោយត្រង់ ខួរក្បាលខ្ញុំគឺតែងតែនឹករកគំនិតជំនួញជានិច្ច។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

នៅពេលខ្ញុំចាប់ផ្តើមធ្វើការលើគម្រោងតំបន់សេដ្ឋកិច្ចពិសេស ឧកញ៉ាទាំងអស់បានសើចចំអកឱ្យខ្ញុំ ពួកគាត់ប្រាប់ថាខ្ញុំឆ្កួតហើយតែខ្ញុំមិនខ្វល់ថាគេគិត ឬនិយាយយ៉ាងណានោះទេ ខ្ញុំនៅតែរក្សាការប្តេជ្ញានិងបន្តការងារជំនួញរបស់ខ្ញុំ។ មេរៀនដ៏មានតម្លៃដែលខ្ញុំទទួលបានពេលខ្ញុំឈឺចាប់គឺថា ខ្ញុំអាចកែប្រែក្លាយខ្លួនឯងឱ្យខ្លាំងជាងមុនហើយខ្ញុំអាចបង្ហាញដល់ពិភពលោកថាខ្ញុំអាចធ្វើបានល្អ។ ខ្ញុំចង់ឱ្យស្ត្រីទាំងអស់មានទំនុកចិត្តលើខ្លួនឯង ហើយអាចធ្វើអ្វីដែលខ្ញុំធ្វើ។

*តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើលោកជំទាវធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច?*

តម្លៃស្នូលរបស់ខ្ញុំគឺត្រូវមានឆន្ទៈមោះមុតហើយធ្វើឱ្យចក្ខុវិស័យទៅជាការពិតក្នុងជំនួញ។ ចក្ខុវិស័យនោះគួរតែជួយឱ្យក្រុមហ៊ុនរីកចម្រើន និងបង្កើតការងារក្នុងប្រទេសរបស់យើង។ ពេលធ្វើការជាមួយវិនិយោគិនមកពីប្រទេសដូចជាសិង្ហបុរីនិងជប៉ុន តម្លៃស្នូលរបស់ខ្ញុំគឺសុចរិតភាព។ ពេលយើងរកបានដៃគូល្អត្រឹមត្រូវយើងត្រូវតែធ្វើការឱ្យស្អិតជាមួយគ្នា បើអ្នកចង់ឱ្យជោគជ័យ។ វាក៏ដូចគ្នាដែរជាមួយនិងអតិថិជននិងបុគ្គលិក យើងជាស្ត្រីជំនួញ ត្រូវតែមានផែនការរក្សាទុកបុគ្គលិកដើម្បីអាចរក្សាទុកអតិថិជនដែលស្មោះត្រង់។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

- និយាយហើយមិនធ្វើ៖ អ្នកដឹកនាំដែលខ្សោយបំផុតគឺអ្នកដែលតែងតែ

“

# ស្ត្រីត្រូវតែរឹងប៉ឹងនិងប្រឈមមុខជាមួយបញ្ហាដើម្បីដឹកនាំអាជីវកម្មរបស់ពួកគេ




និយាយហើយប្រើបុគ្គលិកឱ្យធ្វើនេះធ្វើនោះ តែមិនចូលរួមធ្វើ។ បើគាត់ចង់ធ្វើជា “អ្នកដឹកនាំដ៏អស្ចារ្យ”ចាំបាច់គាត់ត្រូវតែ “ធ្វើអ្វីដែលនិយាយ” មានន័យថាពួកគាត់ធ្វើនូវអ្វីដែលគាត់បាននិយាយប្រាប់បុគ្គលិក ពេលនោះក្រុមរបស់គាត់អាចធ្វើតាមអ្នកដឹកនាំបានហើយ។

- គ្មានគោលដៅនិងគោលបំណងច្បាស់លាស់៖ អ្នកដឹកនាំត្រូវតែមានគោលដៅ និងទិសដៅច្បាស់លាស់សម្រាប់បុគ្គលិករបស់ខ្លួន។ បើពួកគាត់គ្មានគោលដៅច្បាស់លាស់ទេ ពួកគាត់មិនអាចជំរុញក្រុមការងារ ហើយមិនអាចដឹងថាពេលណាពួកគេបានសម្រេចហើយចុងក្រោយសម្រេចបានអ្វីឡើយ។ ក្នុងករណីខ្លះក្រុមហ៊ុនមានគោលដៅនិងយុទ្ធសាស្ត្រច្បាស់លាស់ តែវាមិនត្រូវបានបង្ហាញច្បាស់ដល់អ្នកដើរតាមនិងក្រុមការងារ វាអាចជាមហន្តរាយសម្រាប់ក្រុមហ៊ុន។
- ខ្វះទំនួលខុសត្រូវ៖ ក្នុងក្រុមការងារ បើគ្មាន “វប្បធម៌ទទួលខុសត្រូវ”ក្រុមនឹងមិនអាចបំពេញ និងបញ្ចប់ការងាររបស់ពួកគេបានទេ ព្រោះសមាជិកក្រុមរវល់តែ “ពន្លត់ភ្លើង” គឺមានន័យថាពួកគាត់រងចាំតែបញ្ហា។

*តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

- បង្កើតវប្បធម៌បង្ហាត់បង្រៀន ជាពិសេសដោយស្ត្រីសហគ្រិនដែលជោគជ័យទៅកាន់អាជីវកម្មដែលទើបចាប់ផ្តើម
- យល់អំពីបុគ្គលិករបស់ខ្ញុំនិងផ្តល់ឱកាសឱ្យពួកគេបង្ហាញសមត្ថភាពរបស់ពួកគេ
- ផ្តល់ផលប្រយោជន៍ដល់បុគ្គលិករបស់ខ្ញុំទៅតាមសមត្ថភាពការងារពួកគេ
- ក្នុងរបរជំនួញ វាជាការសំខាន់ណាស់ក្នុងការរើសដៃគូត្រឹមត្រូវ។ ខ្ញុំត្រូវតែសិក្សាឱ្យដិតដល់អំពីអ្នកដែលអាចជាដៃគូខ្ញុំ អំពីប្រវត្តិនិងអតីតជំនួញរបស់ពួកគេ។ វាមិនមែនសម្រាប់តែលុយទេ តែអំពីតម្លាភាព សេចក្តីទុកចិត្ត និងកិត្តិនាមនៃជំនួញរបស់ពួកគេ។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា?*

ខ្ញុំចាំថាហានិភ័យធំបំផុតសម្រាប់ខ្ញុំគឺនៅពេលដែលចាប់ផ្តើមរបរជំនួញ ស្វាមីរបស់ខ្ញុំកំពុងជាប់ឃុំឃាំងក្នុងឆ្នាំ១៩៨៥។ ជាស្ត្រីមេផ្ទះម្នាក់ហើយទើបចាប់ផ្តើមជំនួញជំនួសស្វាមី ខ្ញុំជួបឧបសគ្គច្រើនណាស់។ ខ្ញុំរស់នៅលើកោះរយៈពេល៥ឆ្នាំហើយធ្វើការជាមួយក្រុមប្រុសៗដើម្បីដឹកទំនិញពីកប៉ាល់មកឆ្នេរ។ នៅពេលនោះ កប៉ាល់ពីសិង្ហបុរីមិនអាចចូលមកឆ្នេរកម្ពុជាដោយផ្ទាល់ទេ។ វាមិនមានសុវត្ថិភាពដោយសារមានទាហានខ្មែរនិងវៀតណាម។ រាល់យប់ក្រុមប្រុសៗរបស់ខ្ញុំតែងយកទូកតូចៗ ដឹកអីវ៉ាន់ទៅលក់នៅក្រុងព្រះសីហនុ។ ឈ្មោះខ្ញុំត្រូវគេស្គាល់ច្រើនហើយមានគេជួយខ្ញុំធ្វើជំនួញ ល្ងាចឡើងខ្ញុំធ្វើម្ហូបឱ្យពួកគាត់ពិសារ។ ជោគជ័យរបស់ខ្ញុំចាប់ផ្តើមពីទំនុកចិត្តលើខ្លួនឯងនិងឆន្ទៈក្នុងការធ្វើការជាមួយទាំងបុរសនិងស្ត្រី។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

កម្ពុជាជាកន្លែងដ៏ល្អមួយសម្រាប់ការវិនិយោគក្នុងតំបន់ ដោយសារតែទីផ្សារមានការបើកទូលាយខ្លាំងនិងស្វាគមន៍គ្រប់ជនជាតិទាំងអស់។ ឧទាហរណ៍ក្រុមហ៊ុនរបស់ខ្ញុំបានទទួលកុងត្រាជាច្រើនពីរដ្ឋាភិបាលដើម្បីអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស(SEZs) ក្នុងក្រុងព្រះសីហនុនិងបាវិត។ ដោយសារទីផ្សារសេរី ប្រជាជនរាក់ទាក់ សន្តិភាព និងស្ថិរភាពនយោបាយក្នុងប្រទេសកម្ពុជា ខ្ញុំអាចទាក់ទាញអ្នកវិនិយោគបន្ថែមទៀត។ ច្បាប់ស្តីអំពីការវិនិយោគនៅប្រទេសកម្ពុជាបានផ្តល់ប្រយោជន៍ដល់អ្នកវិនិយោគ។ ថ្មីៗនេះខ្ញុំបានចុះកិច្ចព្រមព្រៀងរួមគ្នាជាមួយក្រុមហ៊ុន Zephyr Co. ពីប្រទេសជប៉ុន ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយទៀតជិតទីក្រុងភ្នំពេញ។ ជាមួយការគាំទ្រខ្លាំងពីរដ្ឋាភិបាល តំបន់ទាំងនេះផ្តល់ឱកាសជំនួញដ៏ធំ ឧទាហរណ៍រួមមាន៖ មិនចាំបាច់បង់ពន្ធរយៈពេល៩ឆ្នាំ មិនបាច់បង់ពន្ធVATនិងការនាំចេញនាំចូលសម្រាប់ជំនួញទាំងក្នុងនិងក្រៅប្រទេស។

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

“បច្ចុប្បន្ននេះស្ត្រីអាចធ្វើអ្វីដែលបុរសធ្វើបានហើយអាចធ្វើអ្វីក៏បាន។ ខ្ញុំចង់បង្រៀនឱ្យស្ត្រីមានភាពរឹងមាំ របៀបធ្វើជំនួញ និងរបៀបធ្វើឱ្យរីកចម្រើន”។ ស្ត្រីកម្ពុជាត្រូវតែជឿលើខ្លួនឯងថាពួកគេអាចធ្វើអ្វីៗបានដូចដៃគូបុរសរបស់ពួកគេដែរ។ ពួកគេត្រូវតែសំលៀងជំនាញនិងចំណេះដឹងរបស់ខ្លួន បង្កើតក្រុមធនធានមនុស្ស រួចបង្វែរអាជីវកម្មគ្រួសារពួកគេឱ្យមានស្តង់ដារមួយដែលអាចទទួលការវិនិយោគពីអ្នកផ្សេង ក៏ដូចជាឧស្សាហកម្មរបស់កម្ពុជាទៅអនាគត។

ឆ្លៀតឱកាសនេះខ្ញុំចង់លើកទឹកចិត្តដល់យុវជនកម្ពុជាដែលត្រូវបន្តការសិក្សានៅក្នុងនិងក្រៅប្រទេសត្រូវរកបទពិសោធន៍បន្ថែម និងកសាងជំនាញរបស់ពួកគេ ដើម្បីបង្កើនការរីកចម្រើនដល់សេដ្ឋកិច្ចប្រទេស។ សំខាន់ជាងនេះ សហគ្រិនស្ត្រីត្រូវតែបូជាពេលវេលានិងការប្រឹងប្រែងរបស់ពួកគេដើម្បីបង្កើតជំនួញក្នុងក្តីស្រមៃរបស់ពួកគេ។ ពួកគេមិនគួរខ្វល់ខ្លាំងអំពីការតិះដៀលរបស់អ្នកដទៃ ហើយត្រូវឈររឹងមាំប្រឈមមុខនិងបញ្ហា។ ពួកគេត្រូវតែហ៊ាននិយាយនិងធ្វើសកម្មភាពដោយបង្ហាញពីសមិទ្ធផលរបស់ពួកគេឱ្យសាធារណជនបានឃើញ។ WK

# លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវហ៊ិច

## ស្ថាបនិក និងប្រធាន | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំជាស្ថាបនិកនិងជាប្រធានអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)។ ខ្ញុំជាវេជ្ជបណ្ឌិតដែលកើតក្នុងត្រកូលមន្ត្រីរាជការជាន់ខ្ពស់។ ឪពុករបស់ខ្ញុំធ្វើការក្នុងការិយាល័យរបស់សម្តេចនរោត្តមសីហនុ ពីឆ្នាំ១៩៧៩ដល់១៩៩៣។ អ្នកម្តាយខ្ញុំគឺជាស្ត្រីទីមួយដែលបានអង្គុយនៅកៅអីសភាជាតិកម្ពុជាក្នុងឆ្នាំ១៩៥៨និងមាននាទីជារដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រោយមកជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។ នៅក្រោមរបបសម្តេចសីហនុ គាត់មាននាទីជាប្រធានស្តីទីនៃរដ្ឋសភា ក្នុងអំឡុងឆ្នាំ១៩៦០។

ខ្ញុំត្រូវបាននិរទេសខ្លួនទៅប្រទេសបារាំងក្នុងឆ្នាំ១៩៧១បន្ទាប់ពីឪពុកម្តាយខ្ញុំចាកចេញទៅព្យាបាលខ្លួននៅក្រៅប្រទេស ហើយមិនត្រូវបានអនុញ្ញាតឱ្យត្រលប់មកវិញ។ ក្នុងទសវត្សរ៍១៩៨០ ដោយសារតែ គ្រួសារខ្ញុំស្និទ្ធស្នាលជាមួយព្រះបាទនរោត្តមសីហនុខ្ញុំបានរៀបចំជំនួបមួយរវាងព្រះអង្គនិងលោក ហ៊ុន សែន។ ជំនួបនេះធ្វើឡើងក្នុងថ្ងៃទី២ធ្នូ ១៩៨៧។ វាបានចាប់ផ្តើមដំណើរដែលនាំឱ្យមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅថ្ងៃ២៣តុលា ១៩៩១។ ខ្ញុំមកកម្ពុជាវិញនៅឆ្នាំ១៩៩២ និងបង្កើតលីកាដូដើម្បីលើកស្ទួយសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ខ្ញុំក៏ជាប្រធាននៃ NGO-CEDAW និង CAMBOW ផងដែរ។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

ពេលខ្ញុំចាប់ធ្វើការជាវេជ្ជបណ្ឌិត នៅក្នុងវិស័យនេះមានស្ត្រីតិចតួចណាស់។ មនុស្សចាស់បុរាណជាអ្នកកាន់តំណែងធំៗនិងសម្រេចចិត្តសំខាន់ៗ។ ខ្ញុំត្រូវតែពូកែជាងប្រុសៗដែលធ្វើការដូចខ្ញុំដែរដើម្បីបង្ហាញពីសមត្ថភាពនិងតម្លៃរបស់ខ្ញុំ សំណាងល្អ បុគ្គលិកខ្ញុំជាពិសេសស្ត្រី ពេញចិត្តយ៉ាងខ្លាំងដែលបានឃើញស្ត្រីចូលរួមការងារសង្គម។ ចុងក្រោយពួកគាត់ជោគជ័យ ហើយនាំឱ្យមានបុគ្គលិកបំណិនជំនាន់ថ្មី ទាំងពីរភេទ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*



ច្រើនឆ្នាំមកនេះ ខ្ញុំឃើញថាយើងមិនអាចមិនអើពើអំពីការលូតលាស់ណាមួយទេ។ រាល់ការដឹកនាំតែងជួបនៅការប្រឆាំងតបតវិញ។ ក្នុងសម័យថ្មីនេះ ដែលកម្ពុជាឈានចូលក្នុងដំណាក់កាលអភិវឌ្ឍន៍លឿន អ្នកដឹកនាំត្រូវតែពិនិត្យគោលជំហររបស់ខ្លួនវិញជានិច្ច ដើម្បីឱ្យដើរស្របជាមួយនឹងការលូតលាស់ដែលកំពុងកើតមានជាមួយលក្ខខណ្ឌខាងក្រៅរួមមាន មនុស្ស និងប្រតិបត្តិ។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច?*

សមភាពសម្រាប់មនុស្សគ្រប់រូប ប្រជាធិបតេយ្យ ឯករាជ្យនិងសេរីភាពមូលដ្ឋានគឺជាតម្លៃស្នូលរបស់ខ្ញុំ។ ខ្ញុំធានាថាក្រុមខ្ញុំមានតម្លៃដូចខ្ញុំដែរ តាមរយៈការរើសបុគ្គលិក និងការវាយតម្លៃឡើងវិញជាញឹកញាប់ការផ្លាស់ប្តូរគំនិតនិងការបណ្តុះបណ្តាល។

> **“ដើម្បីបង្ហាញពីសមត្ថភាពរបស់ខ្ញុំ ខ្ញុំត្រូវធ្វើការងារដូចគ្នាឱ្យល្អជាងបុរស**

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

ខ្ញុំគិតថាការមិនព្រមស្តាប់មតិ និងការរិះគន់មានផលអវិជ្ជមានដល់ការដឹកនាំ។ ការទទួលយកមតិរិះគន់ដោយមិនគិតពីបរិបទទាំងមូលនិងគ្មានការស្តាប់មតិផ្ទុយនឹងជះផលអាក្រក់ដល់ការសម្រេចចិត្ត។ ចំណុចមួយទៀតត្រូវចៀសវាងគឺការមិនព្រមផ្តល់ជាឧទាហរណ៍ល្អក្នុងសីលធម៌ការងារនិងទង្វើផ្សេងៗ។ ពិតណាស់ អ្នកដឹកនាំត្រូវតែដឹកនាំ និងអាចធ្វើការសម្រេចចិត្ត។ ការសម្រេចចិត្តមិនកើត គឺជាចំណុចខ្សោយនៃអ្នកដឹកនាំ។



*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញ និងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រី ឬសមភាពយេនឌ័រ)?*

ខ្ញុំព្យាយាមបង្ហាញដល់ស្ត្រីទាំងអស់នូវសារសំខាន់នៃការមិនបាក់ទឹកចិត្តពេលជួបបញ្ហា។ ពួកគេត្រូវធ្វើអ្វីដែលគាត់ធ្វើបានដើម្បីរក្សាសកម្មភាពរបស់គាត់បាន។ ខ្ញុំក៏ព្យាយាមជួយរៀបចំអនាគតដែលនឹងផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាល និងការបង្កើតមនុស្សជំនាន់ថ្មី។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា?*

ពេលខ្ញុំចេញធ្វើការដំបូង គេមិនសូវខ្វល់ពីខ្ញុំទេ។ គេគិតថាស្ត្រីវ័យក្មេងគួរតែរៀបការហើយនៅផ្ទះ ការព្យាយាមរកការងារធ្វើគឺមិនត្រូវបានសង្គមស្វាគមន៍ទេ។ ពេលខ្ញុំរៀបចំឱ្យមានជំនួបរវាងសម្តេចសីហនុ និងលោកហ៊ុន សែន គេមើលមកថាវាជារឿងដែលគ្មានអ្នកចង់បាននិងជាការលូកដៃចូលក្នុងកិច្ចការអន្តរជាតិពីសំណាក់ពលរដ្ឋធម្មតា។ តែដល់ទីបំផុតដោយជម្នះរាល់ពាក្យអ្នកដទៃទាំងអស់ លើកលែងតែម្តាយឪពុកនិងកូនស្រីទាំងបីរបស់ខ្ញុំ ខ្ញុំអត់ធ្មត់បន្តហើយចុងក្រោយនាំឱ្យមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស២៣ តុលា ១៩៩១។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាព និងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

ដោយសារតែប្រវត្តិសាស្ត្រទាំងបុរាណនិងសម័យ វប្បធម៌កម្ពុជាក្លាយជាផ្នែកមួយយ៉ាងសំខាន់នៃសតិអារម្មណ៍របស់ប្រជាជន។ តម្លៃបុរាណនិងគំនិតសម័យបានរួមគ្នាបង្កើតជាវប្បធម៌ស្នូលនៃកម្ពុជា ដូចជាតម្លៃស្ត្រីក្នុងសង្គម។ បន្ទាប់ពីសម័យខ្មែរក្រហម ដែលស្ទើរតែធ្វើឱ្យវប្បធម៌ខ្មែរវិនាស មានការកកើតឡើងវិញនូវមោទនភាពនិងការបើកចំហដល់លំហូរចូលនៃទំនើបកម្ម។ តម្លៃមកពីខាងក្រៅរួមជាមួយតម្លៃខាងក្នុងរបស់កម្ពុជាបានត្រូវបញ្ចូលទៅក្នុងវប្បធម៌ខ្មែរ ដែលធ្វើឱ្យវាមិនត្រឹមតែសម្របខ្លួនទៅថែមទាំងលូតលាស់ក្នុងពិភពទំនើបទៀតផង។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

ខ្ញុំអាចផ្តល់ដំបូន្មានដល់សហគ្រិនស្ត្រីកម្ពុជាថាត្រូវតែតស៊ូបើទោះមានឧបសគ្គក៏ដោយហើយត្រូវតែឱ្យគេឃើញនិងឮពីយើង។ បន្ថែមលើនេះ ខ្ញុំជំរុញឱ្យស្ត្រីវ័យក្មេងកុំរារែកក្នុងការចូលសិក្សាវគ្គស្តីពីសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ ហើយប្រើជំនាញខ្លួនឯង ក្នុងរបរអាជីវកម្មឬអាជីពខ្លួន។ WK

អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

# លោកជំទាវ ភឿង សកុណា

## រដ្ឋមន្ត្រី | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ប្រធានអាជ្ញាធរជាតិអប្សរា



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត?*

ខ្ញុំធំឡើងក្នុងប្រទេសកម្ពុជាពេលដែលប្រទេសនេះឆ្លងកាត់របបនយោបាយជាច្រើន។ ឪពុកខ្ញុំជាកងទ័ពហើយម្តាយខ្ញុំនៅផ្ទះ គាត់ទាំងពីរនាក់ស្រឡាញ់ការសិក្សាណាស់ហើយគាត់ចង់ផ្ទេរការស្រឡាញ់នេះមកកូនៗទាំងអស់។ ខ្ញុំមានបងប្អូន៣នាក់តែគួរឱ្យសោកស្តាយខ្ញុំបានបាត់បង់ពួកគាត់រួមទាំងឪពុកម្តាយខ្ញុំផង ទាំងអស់ក្នុងរបបប្រល័យពូជសាសន៍។ ពេលខ្មែរក្រហមឈ្លានពានកម្ពុជា ខ្ញុំទើបរៀនចប់ថ្នាក់ទី២។ ពេលនោះ គេមិនឱ្យនរណាចូលរៀនទៀតទេគេហាមមិនឱ្យមានការរៀនសូត្រ សិល្បៈនិងវប្បធមិ។ យ៉ាងណាមិញ ដោយមានឱកាសរស់នៅជាមួយឪពុកម្តាយដែលចូលចិត្តការរៀនសូត្រអស់រយៈពេល១៦ឆ្នាំខ្ញុំមិនដែលភ្លេចពីការស្រឡាញ់និងការស្រេកឃ្លានចំណេះដឹងរបស់ខ្ញុំទេ។ នៅទសវត្សរ៍ឆ្នាំ១៩៨០ ពេលរបបនោះបានបញ្ចប់ ខ្ញុំបានបន្តការសិក្សារបស់ខ្ញុំនៅអាយុ២០ឆ្នាំហើយត្រូវបានទទួលអាហារូបករណ៍ទៅប្រទេសរុស្ស៊ី ដែលខ្ញុំបានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិស្វករគីមី។

ពេលខ្ញុំរៀនចប់ភ្លាម ហើយខ្ញុំដឹងថាខ្ញុំមិនដែលចង់បើកអាជីវកម្មវាជារឿងសមហេតុផលដែលខ្ញុំត្រូវធ្វើការក្នុងវិស័យសាធារណៈ ដូច្នេះខ្ញុំក៏ចូលធ្វើការនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ITC) ជាគ្រូបង្រៀន។ គេដំឡើងតំណែងឱ្យខ្ញុំយ៉ាងលឿនឱ្យក្លាយជានាយករងនៅឆ្នាំ២០០០និង អគ្គនាយកនៅឆ្នាំ២០០២ បន្ទាប់ពីខ្ញុំទទួលបានសញ្ញាបត្របណ្ឌិតផ្នែកមីក្រូជីវសាស្ត្រនៅសាកលវិទ្យាល័យBourgogne ក្នុងប្រទេសបារាំង។ ការងារជាអគ្គនាយកនៃITC បានបើកឱកាសជាច្រើនដល់ខ្ញុំ រួមទាំងការជ្រើសតាំងជារដ្ឋលេខាធិការនៃក្រសួងអប់រំពីឆ្នាំ២០០៨ដល់២០១៣។ បន្ទាប់ពីអាណត្តិដ៏ជោគជ័យនេះ ខ្ញុំមានសំណាងត្រូវបានជ្រើសរើសឱ្យដឹកនាំក្រសួងវប្បធមិនិងវិចិត្រសិល្បៈតាំងពីឆ្នាំ២០១៣។ វាជាឱកាសសម្រាប់ខ្ញុំ ដែលបានធ្វើការថែរក្សាកេរដំណែលកម្ពុជា។ ខ្ញុំសង្ឃឹមថាវានឹងធ្វើឱ្យក្មេងជំនាន់ក្រោយគោរពស្រឡាញ់វប្បធមិយើង និងចែករំលែកវាជាមួយពិភពលោកទាំងមូល។

*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ?*

ក្នុងនាមជាស្ត្រីម្នាក់ ឧបសគ្គចម្បងមួយក្នុងពេលនោះ គឺប្រុសៗគេមិនជឿជាក់យើងទេ។ វាមានការលំបាកខ្លាំង តែខ្ញុំមិនដែលចុះចាញ់ឧបសគ្គដែលខ្ញុំឆ្លងកាត់ទេ។ ខ្ញុំតែងជឿលើសមត្ថភាពនៃការរៀននិងរីកចម្រើន។ ខ្ញុំមានសំណាងដែលមានមនុស្សអស្ចារ្យជាច្រើននៅជុំវិញខ្លួនដែលតែងតែបង្រៀនមេរៀនថ្មីនិងជួយខ្ញុំសម្របទៅតាមវប្បធមិថ្មី។

> **“ការរៀនសូត្រគឺជាដំណើរមួយជីវិតសម្រាប់ស្ត្រីដើម្បីដឹងថាអ្វីខុសអ្វីត្រូវ និងផ្ទេរវាទៅឱ្យក្មេងជំនាន់ក្រោយ**

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

តាមបទពិសោធន៍របស់ខ្ញុំជាច្រើនឆ្នាំមក ខ្ញុំរៀនមេរៀន៣សំខាន់៖

១ រាល់ផលគឺមានហេតុ។ ការដោះស្រាយបញ្ហាដោយមិនផ្តោតលើហេតុគឺមិនផ្តល់ចម្លើយត្រឹមត្រូវដល់អ្នកទេ។

២ ខ្វល់ពីមនុស្សដែលធ្វើការជាមួយអ្នក។ ការអាណិតអាសូរនិងការយល់ចិត្តជាអារម្មណ៍មូលដ្ឋានរបស់មនុស្សយើង ដែលយើងត្រូវតែមានបើយើងខ្វល់ពីអ្នកធ្វើការជាមួយយើង។

៣ ដូចលោកគ្រូឡៅ ជឺបាននិយាយ “រកការងារណាដែលអ្នកស្រឡាញ់ នោះអ្នកនឹងមិនចាំបាច់ធ្វើការទេក្នុងមួយជីវិត”។ ការងាររបស់យើងនឹងមានន័យប្រសិនបើយើងធ្វើដោយក្តីស្រឡាញ់និងចំណង់ចំណូលចិត្ត។





*តើអ្វីជាតម្លៃស្នូល របស់លោកជំទាវហើយតើលោកជំទាវធានាថា ក្រុម/ បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់អ្នក យ៉ាងដូចម្ដេច ?*

១ ចាំបាច់ត្រូវជឿលើសមត្ថភាពរបស់ក្រុមការងាររបស់អ្នក។ ដោយធ្វើជាអ្នកដឹកនាំពួកគេ អ្នកត្រូវតែជឿជាក់ថាក្រុមអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចបេសកកម្មដែលអ្នកបានដាក់។
២ ធ្វើជាអ្នកដឹកនាំដែលចេះដាក់ខ្លួន។ ត្រូវម៉ឺងម៉ាត់តែចេះគោរពច្បាប់និងវិន័យ ដោយធ្វើជាគំរូល្អមួយ។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

- ភាពឃោរឃៅ
- អំនួតខ្លាំងពេក
- ភាពអត្តានិយម

*តើលោកជំទាវនឹងធ្វើអ្វីទៀតដើម្បីបន្តធ្វើជាអ្នកដឹកនាំ ? (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការលើកកម្ពស់ការផ្ដល់សិទ្ធអំណាចសេដ្ឋកិច្ចដល់ស្ត្រី ឬ សមភាពយេនឌ័រ)*

១ ចែករំលែកបទពិសោធន៍ និងរឿងរ៉ាវរបស់ខ្ញុំដលក្មេងជំនាន់ក្រោយ
២ បន្តរៀនសូត្រ ហើយត្រូវដឹងថា "មានទ្រព្យសម្បត្តិដោយមិនចាំបាច់រកធ្វើពាណិជ្ជកម្ម ដោយមិនមានសីលធម៌" គឺមិនមែនជាមធ្យោបាយល្អក្នុងការរស់នៅឡើយ។
៣ ត្រូវមានភាពក្លាហានដើម្បីបើកចំហខ្លួនអ្នកសម្រាប់មនុស្សដទៃទៀត ដែលយើងមិនដែលស្គាល់

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលអ្នកបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ធ្វើការក្នុងវិស័យសាធារណៈ មិនដូចក្នុងវិស័យឯកជនទេ ដែលអ្នកតែងតែត្រូវវាយតម្លៃលើប្រភេទហានិភ័យដើម្បីប្រាកដថាអ្នកអាចចំណេញពីការវិនិយោគរបស់អ្នក។ យ៉ាងណាមិញ ក្នុងវិស័យសាធារណៈ សកម្មភាពរបស់យើងគឺជាទំនួលខុសត្រូវ ចំពោះប្រទេសនិងប្រជាជនយើង ហើយយើងតែងតែត្រូវគិតអំពីសារសំខាន់នៃការងាររបស់យើង។ ឧបសគ្គខ្ញុំគឺមកពីលក្ខណសម្បត្តិនិងគោលការណ៍ជីវិតផ្សេងគ្នា។



សម្រាប់ខ្ញុំផ្ទាល់ដែលជាពុទ្ធសាសនិកខ្ញុំជឿថាមហន្តរាយទាំងអស់គឺដូចជាព្យុះអ៊ីចឹង។ ពេលណា វាទៅផុត ជីវិតអាចចាប់ផ្ដើមឡើងវិញ។ អ្នកត្រូវតែអាចប្រើប្រាស់មេរៀនពីអតីតរបស់អ្នកមកប្រើឡើងវិញដើម្បីជួយអ្នកឱ្យដើរទៅមុខ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈ ប្លែកពីគេ ហើយតើលោកជំទាវគិតថាតើប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្ដេច ?*

១ កេរដំណែលខ្មែរគឺមានលក្ខណៈពិសេស។ យើងគួរមានមោទនភាពចំពោះវប្បធម៌និងអ្វីដែលដូនតាយើងបានបន្សល់ទុកឱ្យ។
២ ជាមនុស្ស យើងត្រូវរៀនពីអតីតកាលរបស់យើងនិងកុំធ្វើកំហុសដដែលៗដែលយើងធ្លាប់ធ្វើពីមុនមក។
៣ ពង្រឹងគោលនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលកម្ពុជា។ ការកសាងសន្តិភាពនិងវិបុលភាពដោយគ្មានជម្លោះផ្ទៃក្នុងដែលធ្វើឱ្យប្រជាជនទទួលទុក្ខ។

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

- ស្ត្រីមានតម្លៃផ្ទាល់ខ្លួនរបស់គាត់ទោះបីជាគាត់ជាមេផ្ទះ អ្នកដឹកនាំឬធុរជនក៏ដោយ
- ការសិក្សាជាដំណើរពេញមួយជីវិតសម្រាប់ស្ត្រីដើម្បីឱ្យដឹងថាអ្វីត្រឹមត្រូវនិងអ្វីដែលខុសហើយផ្ទេរបន្តឱ្យក្មេងជំនាន់ក្រោយ
- បរាជ័យគឺជាមេរៀនដ៏ល្អមួយសម្រាប់ឱ្យយើងធ្វើដំណើរទៅមុខ
- ស្ត្រីខ្មែរត្រូវតែយល់ដឹងអំពីវប្បធម៌និងតម្លៃរបស់យើងហើយបើកចំហដល់វប្បធម៌ផ្សេងដោយមិនភ្លេចអំពីវប្បធម៌និងតម្លៃរបស់ខ្លួនឯង។ WK

# លោកស្រី ទន្តបណ្ឌិត អេង លីគង់

## ប្រធាន | សមាគមសហគ្រិនស្ត្រីកម្ពុជា



អ្នកដឹកនាំ ស្ត្រីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំជាកូនទី២ក្នុងគ្រួសារដែលមានកូន៦នាក់ ប្រុស២ ស្រី៤។ ខ្ញុំបានរៀបការជាមួយស្វាមី ដែលជាអ្នកជំនួញហើយយើងបានកូនប្រុសម្នាក់និងស្រីម្នាក់។ ក្រោយបញ្ចប់ការសិក្សាឆ្នាំ១៩៩២ ខ្ញុំក្លាយជាទន្តបណ្ឌិត។ ខ្ញុំចាប់ផ្តើមជំនួញដំបូងរបស់ខ្ញុំនៅឆ្នាំ២០០៣ដោយប្រើជំនាញទន្តពេទ្យរបស់ខ្ញុំ ខណៈប្រជាជនកម្ពុជានៅមានការយល់ដឹងតិចអំពីសុខុមាលភាពនិងមិនទាន់ទុកចិត្តបុគ្គលិកសុខាភិបាលនៅឡើយ។ ពេលដែលរដ្ឋាភិបាលកំពុងផ្សព្វផ្សាយអំពីប្រព័ន្ធសុខាភិបាល និងការសិក្សាជាន់ខ្ពស់ខាងទន្តសាស្ត្រ ខ្ញុំបានឆ្លៀតបន្តការសិក្សានិងបញ្ចប់សញ្ញាបត្របណ្ឌិតផ្នែកវះកាត់ទន្តសាស្ត្រ (DDS) ក្នុងឆ្នាំ២០០២ និងបន្តយកសញ្ញាបត្រវិរូដូដិនវិទ្យានៅភ្នំពេញក្នុងឆ្នាំ២០០៥ និងវិញ្ញាបនបត្រខាង Oral Implantology ពីប្រទេសអាល្លឺម៉ង់ក្នុងឆ្នាំ២០០៨។
សព្វថ្ងៃខ្ញុំជាស្ថាបនិកនិងនាយិកាMaster Care Dental Clinic ដែលជាគ្លីនិកនាំមុខគេខាងទន្តសាស្ត្រជាមួយទន្តបណ្ឌិតមកពីបរទេស។ ខ្ញុំសកម្មក្នុងការងារសង្គមក្នុងការងារពង្រឹងសុខុមាលភាព ហើយខ្ញុំក៏ជាសហស្ថាបនិកនៃគណៈទន្តពេទ្យកម្ពុជា និងជាប្រធានទីបីនៃសមាគមសហគ្រិនស្ត្រីកម្ពុជាដែលបម្រើដល់សហគ្រិនស្ត្រីជាង៥០០នាក់។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ?*

ពេលខ្ញុំចាប់ផ្តើមរៀននិងធ្វើអាជីវកម្មខាងទន្តពេទ្យ មិនមានស្ត្រីច្រើនទេក្នុងវិស័យនេះ។ វាជាឧបសគ្គដ៏ធំហើយជាពេលដ៏លំបាកមួយសម្រាប់ខ្ញុំដែលជាស្ត្រីម្នាក់ក្នុងវិស័យដែលគ្រប់ដណ្តប់ដោយ ប្រុសៗ។ ពេលនោះស្វាមីខ្ញុំគាត់មិនបានជួយលើកទឹកចិត្តខ្ញុំទេ។ ប្រាក់ដែលគាត់ឱ្យមកគឺល្មមសម្រាប់តែចំណាយក្នុងផ្ទះនិងមើលថែកូនប៉ុណ្ណោះ។ ក្នុងនាមជាស្ត្រីអ្នកដឹកនាំនិងសហគ្រិនក្នុងវិស័យនេះ ខ្ញុំត្រូវដើរតួពីរក្នុងពេលតែមួយ ជាបុរសនៅក្នុងគ្លីនិករបស់ខ្ញុំ និងជាមេផ្ទះមើលថែកូននៅផ្ទះ។ ខ្ញុំធ្វើការពីរដងលើសប្រុសៗនិងតស៊ូរក្សាលំនឹងរវាងជំនួញនិងតួនាទីជាម្តាយនិងប្រពន្ធ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

តម្លៃនៃភាពជាអ្នកដឹកនាំដែលខ្ញុំបានរៀនគឺៈ

- ការដឹកនាំខ្លួនឯងៈ យើងត្រូវតែមានការប្តេជ្ញាម៉ឺងម៉ាត់និងកំណត់គោលដៅជីវិតយើង។ រួចហើយកុំបោះបង់ក្តីស្រមៃនិងគោលដៅនោះឱ្យសោះ។
- ការដឹកនាំក្នុងគ្រួសារៈ ធ្វើខ្លួនជាគំរូល្អដល់កូននិងសមាជិកគ្រួសារដទៃទៀត ដោយកុំចេះតែនិយាយ តែត្រូវធ្វើសកម្មភាពដែរ



- ការដឹកនាំក្នុងក្រុមហ៊ុនឬសង្គមៈ ឱ្យតម្លៃនិងការទុកចិត្តឱ្យដល់បុគ្គលិក ហើយផ្តល់ប្រាក់ខែឱ្យពួកគេសមស្របតាមសមត្ថភាព។ សំខាន់ជាងនេះទៀត យើងត្រូវដាក់បុគ្គលិកឱ្យចំកន្លែងនិងពេលវេលា។ ជាអ្នកដឹកនាំ យើងត្រូវតែទទួលខុសត្រូវជាងបុគ្គលិក។ ការងារសំខាន់គឺត្រូវបង្កើតឱ្យមានអ្នកដឹកនាំដែលមានគំនិតវិជ្ជមាន និងក្លាហានក្នុងការសាកល្បង។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកជំទាវធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច?*

ខ្ញុំមានតម្លៃស្នូលប្រាំសម្រាប់ខ្លួនឯងនិងក្រុមខ្ញុំៈ

- ទំនុកចិត្តៈ ទំនុកចិត្តគឺសំខាន់ណាស់ក្នុងការងារជាមួយគ្នានិងអាជីវកម្ម
- ការផ្តល់អំណាចៈ ខ្ញុំតែងតែផ្តល់អំណាចដល់ក្រុមការងាររបស់ខ្ញុំ ឱ្យសម្រេចចិត្តលើការងារដែលពួកគាត់ធ្វើ
- ការឡើងតំណែងៈ ពេលពួកគេអាចធ្វើការបានល្អ ក្រុមខ្ញុំតែងទទួលបានការតំឡើងប្រាក់ខែឬកម្រៃជើងសារផ្សេងទៀត
- តម្លៃនិងការពេញចិត្តៈ ត្រូវចេះពេញចិត្តនិងលើកទឹកចិត្តដល់បុគ្គលិកឱ្យស្រលាញ់ការងារ និងចង់នៅជាមួយយើងយូរអង្វែង
- ការចូលរួមនិងបង្ហាត់បង្រៀនៈ បើយើងចាប់ផ្តើមលើជំនួញដែលជាជំនាញយើង អត្រាជោគជ័យមានច្រើន ដោយសារយើងចេះដឹង ហើយងាយរកអ្នកដទៃមកជួយដោះស្រាយបញ្ហាគ្នា
- ឧបសគ្គៈ ត្រូវប្រតិកម្មដោយវិជ្ជមាន និង ទំនុកចិត្តបើមានឧបសគ្គ ដែលជាឱកាសសម្រាប់ជាមេរៀនឬជំនួញយើង។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

អត្តចរិតអវិជ្ជមានដែលខ្ញុំឃើញគឺៈ

- មិនផ្តល់ឱកាសដល់បុគ្គលិកនិងក្រុមការងារចែករំលែកគំនិតនិងបង្ហាញពីទេពកោសល្យពួកគេ
- ប្រតិកម្មលឿនពេកទៅកាន់បញ្ហា អាចនាំឱ្យមានការសម្រេចចិត្តខុស។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

- បន្តរៀនសូត្រដោយចូលរៀនវគ្គខ្លីនិងអានឯកសារទាក់ទងនិងជំនួញ
- ដើររកនិងបង្កើតមិត្តភាពជាមួយអ្នកដែលមានចំណេះដឹងនិងបទពិសោធន៍ជាងយើង
- អភិវឌ្ឍនិងកែប្រែគម្រោងអាជីវកម្មឱ្យទៀងទាត់រាល់៣ទៅ៥ឆ្នាំម្តង
- ស្ត្រីនិងបុរសអាចធ្វើការបានដូចគ្នា។ ស្ត្រីក៏ធ្វើការបានដូចបុរសដែរ។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលអ្នកបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា?*

ហានិភ័យដែលខ្ញុំកំពុងមានគឺការជ្រើសរើសបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដោយសារអាជីវកម្មខ្ញុំវាទាក់ទងដល់ជីវិតមនុស្ស។ អញ្ចឹងហើយយើងត្រូវតែមានវិជ្ជាជីវៈនិងជំនាញក្នុងឧស្សាហកម្មទន្តពេទ្យ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

អ្វីដែលធ្វើឱ្យកម្ពុជាយើងប្លែកពីគេ គឺភាពអំណត់ ដោយសារយើងបានឆ្លងកាត់សង្គ្រាមជាច្រើន និងភាពលំបាកលំបិនជាច្រើនជាងប្រជាជនជាតិដទៃ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

ខ្ញុំសូមផ្តល់យោបល់ដល់យុវជនទាំងអស់ថាពួកគេគួរតែអត់ធ្មត់និងព្យាយាមឱ្យអស់លទ្ធភាពក្នុងការធ្វើអាជីវកម្ម។ ដើម្បីឱ្យជោគជ័យក្នុងជំនួញ ពួកគេត្រូវចំណាយពេលក្នុងអាជីវកម្មរបស់ខ្លួននិងប្រឹងប្រែងកាត់បន្ថយការចំណាយច្រើនលើការពង្រីកអាជីវកម្ម។ ពួកគេត្រូវរៀនឱ្យចេះពីទម្លាប់ពន្យារការចង់បាន។ WK

# លោកស្រី លឹម សូលីន

## នាយិកាប្រចាំប្រទេស | អុកហ្វាមកម្ពុជា



អ្នកដឹកនាំ
ស្ត្រីនៅកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះ សូលីនហើយខ្ញុំកំពុងមានគ្រួសារយ៉ាងរីករាយមួយ ជាមួយនិងកូនប្រុសអាយុបីឆ្នាំម្នាក់ឈ្មោះជីយ៉ាវ៉ាន់។ ខ្ញុំកំពុងធ្វើការឱ្យអង្គការ អ៊ុកហ្វាម (Oxfam) ហើយយើងរស់នៅក្នុងប្រទេសកម្ពុជា។ ដូចជាស្ត្រីជាច្រើនផ្សេងទៀតក្នុងជំនាន់ខ្ញុំ ខ្ញុំបានកើតនិងធំធាត់ក្នុងសម័យសង្គ្រាម ភាពក្រីក្រ និងសង្គមបិតាធិបតេយ្យ។ ដូចពួកគាត់ដែរ ខ្ញុំបានប្រឈមមុននឹងឧបសគ្គផ្ទាល់ខ្លួននិងក្នុងការងារជាច្រើន។ ខ្ញុំត្រូវបានចិញ្ចឹមបីបាច់ដោយស្ត្រីរឹងមាំក្នុងគ្រួសារគឺលោកយាយសេង គីម អ្នកម្តាយថារី និងមីងៗខ្ញុំ ដែលជាស្ត្រីដែលរួចរស់ជីវិតពីខ្មែរក្រហម ដែលទុកឱ្យពួកគាត់ចិញ្ចឹមខ្ញុំបងប្រុសនិងប្អូនស្រីៗខ្ញុំ ដើម្បីជាជំនាន់ក្រោយរបស់ "អង្គការ"។

យើងក្រីក្រហើយយើងមិនមានអ្វីទេ។ កាលខ្ញុំទើបនឹងកើតជីដូនរបស់ខ្ញុំឱ្យខ្ញុំហូបបបរស្រមោចក្រហមជំនួសទឹកដោះម្តាយ។ ម្តាយ និងមីងរបស់ខ្ញុំត្រូវធ្វើការនៅវាលស្រែ ដោយជំនាញដែលពួកគាត់មាន ការរស់នៅជាអ្នកទីក្រុង បានត្រូវផ្លាស់ប្តូរក្នុងរយៈ៣ ឆ្នាំនៅក្នុងជំរំប្រមូលផ្តុំមួយនៅខេត្តកំពត។ ពួកគាត់គឺជាស្ត្រីដែលអត់ធ្មត់ដោយខ្លួនឯងដែលជាគំរូរបស់ខ្ញុំ។ ពួកគាត់បានធ្វើការយ៉ាងលំបាកសម្រាប់ការរស់រានមានជីវិត និងអនាគតរបស់យើង។ ខ្ញុំទទួលការអប់រំនៅប្រទេសកម្ពុជារហូតដល់សកលវិទ្យាល័យ។ នៅពេលខ្ញុំរៀននៅសាលា ខ្ញុំបានធ្វើកម្មសិក្សាជាច្រើន។ ហើយខ្ញុំបានការងារមានប្រាក់ខែដំបូងរបស់ខ្ញុំ(ការងារពីរកន្លែង និងការងារស្ម័គ្រចិត្តមួយពេល) នៅពេលដែលខ្ញុំមានអាយុ ១៧ឆ្នាំ ក្នុងពេលតែមួយដែលខ្ញុំបានចាប់ផ្តើមចូលរៀននៅសាកលវិទ្យាល័យពីព្រោះខ្ញុំពិតជាស្រេកឃ្លានចំណេះដឹងហើយចង់បានឯករាជ្យខ្លួនឯង យ៉ាងហោចណាស់ផ្នែកហិរញ្ញវត្ថុ។ ខ្ញុំតែងតែជាក្មេងដែលឆាប់ភ្ញាក់ផ្អើល (មិនមែនមានជំងឺទេ) ប៉ុន្តែខ្ញុំពិតជាឆាប់ធុញទ្រាន់ណាស់ប្រសិនបើខ្ញុំមិនធ្វើការលើគម្រោងជាច្រើនក្នុងពេលដំណាលគ្នា។ ខ្ញុំចង់រកលុយណាស់ដើម្បីឱ្យខ្ញុំអាចទ្រទ្រង់គ្រួសារខ្ញុំហើយខ្ញុំអាចរកបានការអប់រំខ្ពស់។

ជាសំណាងល្អ ខ្ញុំបានទទួលអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេសហើយបន្ទាប់មកខ្ញុំបានបន្តធ្វើការនៅស្ថាប័នអន្តរជាតិនៅទីនោះនិងនៅអាស៊ី។ ខ្ញុំមិនចាំបាច់ត្រលប់មកប្រទេសកម្ពុជាវិញទេព្រោះខ្ញុំមានការងារធ្វើដែលខ្ញុំតែងតែស្រមៃចង់បាន។ ប៉ុន្តែខ្ញុំមិនដឹងថាហេតុអ្វី ហើយសម្រាប់ហេតុផលផ្ទាល់ខ្លួនមួយចំនួន ខ្ញុំត្រូវត្រលប់មករកប្រភពដើមរបស់ខ្ញុំវិញ។

ខ្ញុំបានជួបឧបសគ្គផ្ទាល់ខ្លួនខ្លះ ដោយពេលខ្ញុំនៅក្មេងខ្ញុំត្រូវជ្រើសរើសយកជម្រើសដែលគ្រួសារនិងសង្គមអាចទទួលយកបាន។ ខ្ញុំបានបដិសេធការរៀបការពេលវ័យក្មេង ហើយវាមិនងាយស្រួលនោះទេខ្ញុំត្រូវប្រឆាំងនឹងការរើសអើងផ្សេងៗ ដើម្បីអាចជ្រើសរើសអាពាហ៍ពិពាហ៍ និងដៃគូជីវិតដែលខ្ញុំចង់បាន។ នៅពេលនោះវាលំបាកមែនទែន ប៉ុន្តែបើគិតឡើងវិញ ខ្ញុំមិនមានការសោកស្តាយទេ ហើយខ្ញុំរីករាយដែលខ្ញុំបានធ្វើអ្វីដែលខ្ញុំបានធ្វើ។ ប៉ុន្តែខ្ញុំមានសំណាងណាស់។ ខ្ញុំមានមិត្តភក្តិ និងគ្រួសារជាទីស្រឡាញ់ក៏ដូចជាស្វាមីដែលជាអ្នកតែងគាំទ្រខ្ញុំហើយពួកគេទាំងអស់ជំរុញឱ្យខ្ញុំសម្រេចបាននូវសក្តានុពលរបស់ខ្ញុំ។ នៅពេលខ្ញុំប្រឈមមុខនឹងបញ្ហាជីវិតធ្ងន់ធ្ងរពួកគេទាំងអស់គ្នាឈរនៅពីក្រោយខ្ញុំ ហើយប្រាប់ខ្ញុំឱ្យធ្វើតាមការប្តេជ្ញារបស់ខ្ញុំ។ បើគ្មានពួកគាត់ទេ ខ្ញុំនឹងក្លាយជាព្រលឹងដែលវង្វេងគ្មានគោលដៅ។

ទោះបីជាខ្ញុំជាស្ត្រីដែលមានចំណេះដឹង និងវ័យក្មេងមកពីជនជាតិម្ចាស់ផ្ទះគឺជនជាតិខ្មែរក៏ដោយ ខ្ញុំត្រូវតែចរចារកកន្លែងរបស់ខ្ញុំ រៀងរាល់ថ្ងៃនិងគ្រប់ទីកន្លែងពីសហគមន៍ទៅកន្លែងធ្វើការ។ ដូច្នេះខ្ញុំមិនអាចស្រមៃដឹងអំពីការតស៊ូរាល់ថ្ងៃរបស់ក្មេងស្រីស្រឡាញ់ភេទដូចគ្នាដែលមកពីក្រុមជនជាតិភាគតិចដែលត្រូវគេរើសអើង ហើយមានពិការភាពទៀត! យេនឌ័រ ពូជសាសន៍ ឬសាសនាមិនមែនជារឿងធម្មជាតិនោះទេ។ សង្គមជាអ្នកបង្កើតវាឡើង។

នេះហើយជាមូលហេតុដែលខ្ញុំបន្តរម្លឹកខ្លួនឯងរាល់ថ្ងៃពីអភ័យឯកសិទ្ធិរបស់ខ្ញុំ ហើយខ្ញុំដឹងគុណយ៉ាងខ្លាំងដល់អ្វីដែលខ្ញុំមាន។ ហើយសំខាន់ជាងនេះទៅទៀត ខ្ញុំចង់ព្យាយាមឱ្យអស់លទ្ធភាពក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវជីវិតរបស់មនុស្សដែលមិនសូវមានឱកាស។ ប្រហែលនោះហើយជាមូលហេតុដែលខ្ញុំវិលត្រលប់មករកប្រភពរបស់ខ្ញុំវិញបើទោះបីជាមានឱកាសការងារល្អប្រសើរជាងនេះនៅកន្លែងផ្សេងក៏ដោយ។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

ខ្ញុំប្រឈមនឹងបញ្ហាជាច្រើននៅពេលខ្ញុំចូលក្នុងទីផ្សារការងារ។ ខ្ញុំខ្វះបទពិសោធន៍ដែលគេត្រូវការ។ ខ្ញុំត្រូវបានគេវិនិច្ឆ័យដោយសារអាយុរូបរាងរបស់ខ្ញុំហើយអ្វីៗទាំងអស់នោះបានធ្វើឱ្យខ្ញុំមានអារម្មណ៍ខ្លាច និងមិនទុកចិត្តខ្លួនឯង។ នៅកន្លែងធ្វើការ អ្នករួមការងារភាគច្រើនជាបុរសចាស់ៗជាងខ្ញុំ។ ថ្ងៃមួយបន្ទាប់ ពីខ្ញុំបានចែករំលែកមតិយោបល់របស់ខ្ញុំនៅក្នុងកិច្ចប្រជុំ ជាជាងឆ្លើយតបទៅនឹងខ្លឹមសារនៃមតិយោបល់របស់ខ្ញុំ មនុស្សជាច្រើនបែរជានិយាយចំអកពីសំឡេងញ័រៗនិងការស្លៀកពាក់របស់ខ្ញុំដើម្បីច្រានចោលទស្សនៈរបស់ខ្ញុំ។

ក្នុងនាមជាយុវនារីម្នាក់ អ្នកត្រូវរៀនសម្របនឹងរឿងអយុត្តិធម៌។ ខ្ញុំមានអារម្មណ៍ថាគេហាក់ដូចជាមិនស្តាប់ខ្ញុំសោះ។ អ្វីដែលគួរឱ្យហួសចិត្តគឺពេលបុគ្គលិកបុរសនិយាយម្តងទៀតនូវទស្សនៈរបស់ខ្ញុំ គាត់បែរជាត្រូវបានសាទរចំពោះគំនិតឈ្លាសវៃរបស់គាត់។ ខ្ញុំតែងតែត្រូវគិតរកវិធីដើម្បីឱ្យគេស្តាប់ខ្ញុំ។ ខ្ញុំព្យាយាមខិតខំដើម្បីជម្នះនូវកង្វះបទពិសោធន៍របស់ខ្ញុំ ជួនកាលខំធ្វើទាំងឈឺ ដើម្បីជម្នះនូវឧបសគ្គមួយចំនួនដែលខ្ញុំត្រូវដោះស្រាយនៅវ័យក្មេង។ ខ្ញុំសូមលើកនូវឧទាហរណ៍ចំនួនពីរ។

> “ ខ្ញុំបានជួបឧបសគ្គផ្ទាល់ខ្លួនខ្លះ ពេលខ្ញុំនៅក្មេងត្រូវជ្រើសរើសជម្រើសដែលគ្រួសារនិងសង្គមអាចទទួលយកបាន។ ខ្ញុំបានបដិសេធការរៀបការពេលវ័យក្មេង ហើយវាមិនងាយស្រួលនោះទេ ខ្ញុំត្រូវប្រឆាំងនឹងការរើសអើងផ្សេងៗដើម្បីអាចជ្រើសរើសអាពាហ៍ពិពាហ៍និងដៃគូជីវិតដែលខ្ញុំចង់បាន។

នៅពេលខ្ញុំមានអាយុ ២២ឆ្នាំ ខ្ញុំបានធ្វើការងារជានាយិកាប្រតិបត្តិនៃអង្គការអភិរក្សអន្តរជាតិមួយនៅក្នុងប្រទេសកម្ពុជា។ អ្នកកាន់តំណែងមុន និងអ្នកណែនាំខ្ញុំដែលជាជនបរទេសមានអាយុ ៤០ឆ្នាំ ជាអ្នកមានគេគោរពនិងទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងវិស័យនេះ។ ការរំពឹងទុកមានកម្រិតខ្ពស់ណាស់ ហើយអង្គការនៅគ្រានោះមានតួនាទីតែមួយដ៏ចម្បងដោយសារយើងត្រូវព្យាយាមចរចាបញ្ហាគោលនយោបាយរសើបជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់។ នៅពេលនោះ ការយល់ដឹងនិងការគាំទ្រពីសាធារណជនគឺស្ទើរតែមិនមាន ហើយការអភិរក្សបរិស្ថានមិនមែនជាអាទិភាពចម្បងរបស់រដ្ឋាភិបាលទេចំណែកការរំលោភលើបរិស្ថានវិញគឺជារឿងធម្មតា។

ដំបូងឡើយ បើទោះខ្ញុំចង់បានយ៉ាងណាក៏ខ្ញុំមិនទទួលយកការងារនោះទេព្រោះខ្ញុំគិតថាវាហួសពីសមត្ថភាពរបស់ខ្ញុំ។ ប៉ុន្តែនៅពេលអ្នករួមការងារមួយចំនួនបានប្រាប់ខ្ញុំថា "ល្អហើយដែលខ្ញុំមិនទទួលយកការងារនោះ ព្រោះខ្ញុំនៅក្មេងហើយជាមនុស្សស្រីទៀត ហើយការងារនោះមានគ្រោះថ្នាក់ដល់ខ្ញុំខ្លាំងណាស់" ខ្ញុំបែរជាសម្រេចចិត្តធ្វើឱ្យពួកគាត់ដឹងថា ពួកគាត់យល់ខុសលើខ្ញុំ។ ខ្ញុំបានត្រលប់ទៅរកប្រធានខ្ញុំនិងក្រុមប្រឹក្សាភិបាល ហើយប្រាប់ពួកគាត់ថាខ្ញុំត្រៀមខ្លួនរួចរាល់ដើម្បីទទួលយកការប្រជែងនេះប៉ុន្តែខ្ញុំត្រូវការឱវាទរបស់ពួកគាត់។ ខ្ញុំបានធ្វើការងារនោះអស់រយៈពេល៤ឆ្នាំមកហើយ ហើយខ្ញុំបានរីកចម្រើនប្រាំដងលើសមុនលើផ្នែកហិរញ្ញវត្ថុហើយបន្ទាប់មកខ្ញុំបានទៅរកការប្រជែងបន្ទាប់ទៀតសម្រាប់ខ្ញុំ។

ឧទាហរណ៍មួយទៀតគឺជាឧបសគ្គផ្ទាល់ខ្លួន។ ខណៈពេលដែលខ្ញុំខិតខំកសាងអាជីពរបស់ខ្ញុំ ខ្ញុំត្រូវធ្វើការជ្រើសរើសយ៉ាងសំខាន់មួយគឺគួរត្រូវរៀបការនិងមានកូនដែលនេះជាអ្វីដែលសង្គមខ្មែរកំពុងដាក់សម្ពាធឱ្យយើងធ្វើតាម។ ខ្ញុំដឹងតាំងពីវ័យក្មេងថាខ្ញុំចង់ក្លាយជាម្តាយម្នាក់ ប៉ុន្តែខ្ញុំបានជ្រើសរើសយកអាជីពរបស់ខ្ញុំជាជាងអាពាហ៍ពិពាហ៍នៅអាយុ២០ឆ្នាំ។ ហើយខ្ញុំបានទុកពេលគ្រប់គ្រាន់សម្រាប់ខ្លួនឯងក្នុងការស្វែងរកបុរសដែលខ្ញុំស្រឡាញ់ដើម្បីត្រៀមខ្លួនធ្វើជាម្តាយដែលមានទំនួលខុសត្រូវម្នាក់។ ខ្ញុំបានសម្រេចចិត្តមិនអនុញ្ញាតឱ្យសំឡេងរំខាននៃការអភិរក្ស និងការរើសអើងប៉ះពាល់ដល់សមត្ថភាពរបស់ខ្ញុំក្នុងការបន្តជីវិតដែលខ្ញុំចង់បាន ហើយខ្ញុំមានសំណាងដែលមានមិត្តនិងក្រុមគ្រួសារដែលឈរជាមួយខ្ញុំជានិច្ច។

### *ប៉ុន្មានឆ្នាំកន្លងមកតើលោកលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ការស្តាប់អ្នកដទៃដោយប្រុងប្រយ័ត្នគឺជាមធ្យោបាយតែមួយគត់ក្នុងការយល់ដឹងពីបំណងពិតប្រាកដរបស់មនុស្ស។ ជាញឹកញាប់ យើងទាំងអស់គ្នាតែងខ្វះពេលវេលា និងការអត់ធ្មត់ ហេតុដូច្នេះយើងមិនបានស្តាប់គ្នាច្បាស់ទេ។ ការយល់ដឹងថា តើពួកគេជានរណា មកពីណា ហើយហេតុអ្វីបានជាពួកគេធ្វើអ្វីមួយ បានជួយខ្ញុំឱ្យប្រាកដប្រជានូវអ្វីដែលខ្ញុំគួរតែស្វែងរកពីពួកគេនិងរបៀបបង្ហាញពីបំណងខ្ញុំ។ នៅពេលខ្ញុំនៅក្មេង ខ្ញុំគិតពីលទ្ធផលខ្លាំង។ ខ្ញុំបានប្រាប់អ្នកហើយថាខ្ញុំជាមនុស្សដែលឆាប់បែកអារម្មណ៍ ហើយខ្ញុំមានអារម្មណ៍ថាគ្មានពេលវេលាដើម្បីខ្ជះខ្ជាយទេហើយដោយសារតែភាពអន្ទះអន្ទែងនេះខ្ញុំបានបាត់បង់មនុស្សមួយចំនួន។ ឥឡូវនេះខ្ញុំគិតពីដំណើរការច្រើនជាងខ្ញុំព្យាយាមធ្វើឱ្យមានលក្ខណៈទូលំទូលាយតាមដែលខ្ញុំអាច និងស្តាប់នូវអ្វីដែលមនុស្សត្រូវការនិងចង់បាន។ ការស្តាប់អ្នកដទៃដោយបើកបេះដូងស្តាប់ខ្លឹមសារពិតដោយក្តីអាណិតអាសូរនិងគ្មានការវិនិច្ឆ័យ។

ការអាណិតអាសូរគឺជាមធ្យោបាយដ៏សំខាន់មួយដើម្បីភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមកហើយវាជួយខ្ញុំឱ្យយល់ច្បាស់អំពីស្ថានភាពរបស់អ្នកដទៃហើយបន្ទាប់មកខ្ញុំគិតឱ្យបានម៉ត់ចត់ពីជម្រើសព្រមព្រៀងមួយទៀតដែលអាចជំរុញទាំងអស់គ្នាឱ្យរួចផុតពីភាពជាប់គាំងមិនថាមានជំហានទៅមុខនោះតូចប៉ុនណាទេ។

ខ្ញុំខ្លាចគេចាត់ទុកថាខ្ញុំជាស្ត្រីទន់ខ្សោយម្នាក់ពេលបង្ហាញពីអារម្មណ៍របស់ខ្ញុំ។ ខ្ញុំត្រូវការពារអ្វីៗគ្រប់យ៉ាងនិងគ្រប់ពេលដើម្បីមើលទៅរឹងមាំ។ ខ្ញុំបានផ្លាស់ប្តូរច្រើនហើយ។ នៅក្នុងបរិបទសង្គមរបស់ប្រទេសកម្ពុជាប្រធានត្រូវតែមានភាពរឹងមាំហើយអ្នកត្រូវតែក្តាប់ស្ថានការណ៍បានគ្រប់យ៉ាង។ នេះជារឿងឆោតល្ងង់របស់ខ្ញុំ។ ខ្ញុំបាននឹកចាំថា ខ្ញុំភ័យខ្លាចការពិនិត្យពិច័យ និងព្យាយាមលាក់ចំណុចខ្សោយរបស់ខ្ញុំព្រោះខ្ញុំគិតថា វាគឺជាវិធីល្អបំផុតដើម្បីការពារខ្លួនខ្ញុំខាងផ្លូវចិត្ត និងផ្នែកការងារ។ ជាញឹកញាប់ ខ្ញុំបានព្យាយាមទប់ទឹកភ្នែករបស់ខ្ញុំនៅពីមុខមិត្តរួមការងាររបស់ខ្ញុំ។ ជារឿយៗនៅពេលខ្ញុំស្ថិតនៅក្នុងទីសាធារណៈ ហើយខ្ញុំបានឮនូវមតិយោបល់លម្អៀងពីយែនឌ័រមួយចំនួនដែលបានជាន់ឈ្លីលើអ្វីគ្រប់យ៉ាងដែលខ្ញុំគាំទ្រវាធ្វើឱ្យខ្ញុំស្ទើរតែផ្ទុះអារម្មណ៍ តែខ្ញុំបានទប់អារម្មណ៍ហើយបង្ខំចិត្តញញឹមដោយសារ ខ្ញុំត្រូវបានគេបង្រៀនថា វាជាវិធីត្រឹមត្រូវដើម្បីដោះស្រាយបញ្ហាខ្លួនឯងហើយការដែលអនុញ្ញាតឱ្យខ្លួនខ្ញុំមានអារម្មណ៍វាយប្រហារ មានន័យថា ជាការប៉ះពាល់បន្ថែមទៀតលើខ្ញុំផ្ទាល់និងសំខាន់ជាងនេះទៅទៀត គឺលើអ្វីទាំងអស់ដែលខ្ញុំតំណាងឱ្យ។ ប៉ុន្តែអ្នកដឹងទេថា វាជាការគិតខុស។



*កិច្ចពិភាក្សារវាងក្រសួងរ៉ែ និងថាមពល និងអុកហ្វាមស្តីពីសក្តានុពលរ៉ែក្នុងប្រទេសកម្ពុជា ប្លូមេឌៀ ។* រូបថត: អុកហ្វាម

## “ ខ្ញុំពិតជាចង់រៀននិងមានឯករាជ្យខ្លាំងណាស់ ! យ៉ាងហោចណាស់ លើរឿងលុយកាក់

ឥឡូវនេះខ្ញុំបានដឹងថា ការមានចំណុចខ្សោយនិងបើកចំហខ្លួនឯងឱ្យគេពិនិត្យពិច័យគឺជាវិធីដ៏ល្អបំផុតដើម្បីអនុញ្ញាតឱ្យមនុស្ស និងអ្នកដែលយើងមិនធ្លាប់ស្គាល់ផ្លាស់ប្តូរការយល់ដឹងរបស់ពួកគេតាមល្បឿនរបស់ពួកគេផ្ទាល់។ ខ្ញុំមានការធ្លាក់ទឹកចិត្តជាមួយមិត្តរួមការងារនិងអ្នកក្រៅនៅពេលមានការប្រកែកគ្នាម្តងៗ។ គួរឱ្យភ្ញាក់ផ្អើលណាស់ ដែលអ្នកក្រៅទាំងនោះផ្តល់ដល់ខ្ញុំនូវការអាណិតអាសូរ និងផ្តល់ដំបូន្មានដល់ខ្ញុំថាខ្ញុំតឹងរឹងខ្លាំងណាស់ចំពោះខ្លួនឯង ហើយថាពួកគេក៏យល់ដឹងកាន់តែច្បាស់ពីបំណងនិងការប្តេជ្ញារបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ជួនកាលខ្ញុំអនុញ្ញាតឱ្យខ្លួនឯងមានចំណុចខ្សោយខ្លះ និងចាប់ទទួលយកការពិនិត្យពិច័យហើយខ្ញុំរៀនលះបង់ការនិយាយការពារខ្លួន។ ការបើកបង្ហាញចំណុចខ្សោយធ្វើឱ្យអ្នកដទៃស្គាល់ខ្ញុំយ៉ាងពិតប្រាកដ។

ការទុកចិត្តលើតម្លៃនិងវប្បធម៌របស់អង្គការ ដែលសំខាន់ជាងមនុស្សនិងមេដឹកនាំគឺជាគន្លឹះនៃភាពជោគជ័យរួម។ ខ្ញុំបានធ្វើកំហុសខ្លះដោយពន្យារពេលការសម្រេចចិត្តលំបាកៗនៅពេលដែលអារម្មណ៍របស់ខ្ញុំបានប្រាប់ខ្ញុំថាគួរធ្វើ។ គ្មាននរណាម្នាក់ចង់ធ្វើអ្វីដែលលំបាកនិងគេមិនចូលចិត្តឡើយ។ ការពន្យាពេលការសម្រេចចិត្តដ៏លំបាកទាំងនោះនៅទីបំផុតនឹងធ្វើឱ្យខាតបង់កាន់តែច្រើន។ ដោយភាពក្លាហាននិងការដោះស្រាយបញ្ហាលំបាកទាំងនោះ អ្នកដឹកនាំអាចកាត់បន្ថយការខូចខាតបាន។ ប៉ុន្តែជាការពិតណាស់ ជារឿយៗវាមិនមែនជារឿងច្បាស់ខ្មៅ ឬ សទេ ដូច្នេះខ្ញុំត្រូវតែតម្រង់ទិសការសម្រេចចិត្តរបស់ខ្ញុំដោយផ្អែកលើគុណតម្លៃស្នូលរបស់ខ្ញុំ សេចក្តីយោងពីខាងក្រៅ និងការទទួលខុសត្រូវរបស់ខ្ញុំ។ ហើយសំខាន់ជាងនេះទៅទៀត ខ្ញុំត្រូវតែត្រៀមខ្លួនដើម្បីទទួលខុសត្រូវចំពោះការសម្រេចចិត្តទាំងនោះ។

ខ្ញុំមានមោទនភាពចំពោះខ្លួនឯង ដែលខ្ញុំមានភាពម៉ឺងម៉ាត់និងយុត្តិធម៌ក្នុងការដោះស្រាយជាមួយការសម្រេចចិត្តលំបាកៗ។ ខ្ញុំមិនខ្វល់ថាមានអ្នកមិនយល់ស្របជាមួយខ្ញុំទេ ដរាបណាពួកគេដឹងខ្លួនថាការសម្រេចចិត្តនោះត្រឹមត្រូវ។ សំខាន់ជាងនេះទៅទៀត ខ្ញុំមិនអៀនខ្មាសក្នុងការទទួលខុសត្រូវទាំងស្រុងចំពោះការបរាជ័យរបស់ខ្ញុំ។ បាវចនារបស់ខ្ញុំគឺថា យើងទាំងអស់គ្នារស់និងរៀន។ ប៉ុន្តែចំណុចសំខាន់មួយគឺថា ការសម្រេចចិត្តដ៏ល្អគឺជាការសម្រេចចិត្តដែលមានព័ត៌មានគ្រប់ជ្រុងជ្រោយហើយជារឿយៗវាមិនមែនជាអ្វីដែលមានអត្ថប្រយោជន៍ដល់អ្នកតែម្នាក់ទេ ប៉ុន្តែផ្តល់អត្ថប្រយោជន៍ដល់ក្រុមនិងតម្លៃ/គោលដៅរួមរបស់យើង។ យូរៗទៅមិត្តរួមការងាររបស់ខ្ញុំនឹងទុកចិត្តខ្ញុំកាន់តែខ្លាំងឡើង ក្នុងនាមជាអ្នកដឹកនាំដែលមានទំនួលខុសត្រូវម្នាក់ដែលនឹងធ្វើឱ្យគ្រប់គ្នាមានការទទួលខុសត្រូវហើយជាពិសេសខ្ញុំនឹងត្រូវគោរពបទដ្ឋានដូចគ្នា។

### *តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

គុណតម្លៃស្នូលរបស់ខ្ញុំគឺសមភាព យុត្តិធម៌ និងសុចរិតភាព។

គោលការណ៍ដ៏សំខាន់បំផុតមួយដែលខ្ញុំឱ្យតម្លៃគឺសមភាពហើយរឿងនេះទាក់ទងទៅបទពិសោធន៍កុមារភាពរបស់ខ្ញុំដែលខ្ញុំទទួលបានភាពមិនស្មើគ្នាព្រោះខ្ញុំជាក្មេងស្រីនិងអ្នកក្រហើយខ្ញុំមិនបានស្គាល់បុគ្គលល្អៗ ឬបណ្តាញត្រឹមត្រូវទេ។ សង្គមបង្កើតឱ្យមានយេនឌ័រនិងវណ្ណៈ។ ខ្ញុំជឿលើសិទ្ធិនិងសមភាពសម្រាប់មនុស្សទាំងអស់ដោយមិនគិតពីជីវភាព សេដ្ឋកិច្ចសង្គម ពូជសាសន៍ សាសនា និងនយោបាយ។ ដូច្នេះ ខ្ញុំខិតខំដើម្បីលើកស្ទួយយុត្តិធម៌សម្រាប់មនុស្សគ្រប់គ្នានៅគ្រប់ទីកន្លែងដែលខ្ញុំទៅដល់។ បើស្តាប់មើលទៅវាមានលក្ខណៈឧត្តមគតិពេក ប៉ុន្តែវាស្របជាមួយការអនុវត្តជាក់ស្តែង។ ជាមួយនឹងការងារដែលខ្ញុំធ្វើនៅអង្គការអុកហ្វាម (Oxfam) យើងស្វះស្វែងដើម្បីបម្រើមនុស្សដែលពុំសូវទទួលបានសិទ្ធិនិងផលប្រយោជន៍ ដើម្បីជួយពួកគេឱ្យជួយខ្លួនឯងដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដែលមានអំណាចនិងធនធានច្រើនជាងខ្លួន។ នេះភ្ជាប់ទៅនឹងជំនឿស្នូលទីពីររបស់ខ្ញុំនិងគំនិតនៃយុត្តិធម៌ដែលបានធ្វើឱ្យខ្ញុំក្លាយជាមនុស្សដូចសព្វថ្ងៃនេះ។ តាំងពីខ្ញុំនៅតូច ខ្ញុំមានអារម្មណ៍ថាយើងត្រូវរកវិធីដើម្បីធ្វើឱ្យមានភាពស្មើគ្នាហើយថាកុមារគ្រប់រូបត្រូវទទួលបាននូវតម្រូវការជាមូលដ្ឋានស្មើៗគ្នា។

ហើយសំខាន់ជាងនេះទៅទៀត ខ្ញុំជឿជាក់ថាវាមានសារសំខាន់ណាស់ក្នុងការសម្របអាកប្បកិរិយានិងការរស់នៅរបស់ខ្ញុំជាមួយតម្លៃស្នូលទាំងនេះជារៀងរាល់ថ្ងៃ។ ដូចដែលគេបាននិយាយថា យើងត្រូវធ្វើនូវ អ្វីដែលយើងនិយាយ។ ខ្ញុំលើកទឹកចិត្តដល់មិត្តរួមការងារនិងដៃគូដែលមកពីគ្រប់មជ្ឈដ្ឋានអាយុ និងពូជសាសន៍ ឱ្យចូលរួមជាផ្នែកមួយនៃដំណោះស្រាយផ្ទាល់ខ្លួនរបស់ពួកគេ។ ខ្ញុំរំឭកខ្លួនខ្ញុំនិងមិត្តរួមការងារនិងមិត្តភក្តិរបស់ខ្ញុំអំពីអភ័យឯកសិទ្ធិនិងភាពលម្អៀងរបស់យើងហើយព្យាយាមស្វែងយល់ពីអ្នកដទៃគឺ

"ពួកអ្នកដែលមិនជឿ គិត ឬធ្វើដូចយើង"។ យើងព្យាយាមជារៀងរាល់ថ្ងៃរួមគ្នាជាក្រុមដើម្បីឱ្យកាន់តែបើកចំហ។

តម្លៃទីបីគឺភាពសុចរិត។ ខ្ញុំតែងតែនិយាយថាចាំបាច់មិនត្រូវអត់ឱនចំពោះការអនុវត្តណាដែលធ្វើឱ្យអន្តរាយដល់សុចរិតភាពបុគ្គលនិងអង្គការរបស់យើងឡើយ។ វាមានសារសំខាន់ដូចគ្នាដែរដែលខ្ញុំត្រូវអនុវត្តតាមអ្វីដែលខ្ញុំបង្រៀន។ ក្រុមរបស់ខ្ញុំជឿជាក់ថា ប្រសិនបើយើងមិនប្រកាន់យកស្តង់ដារសុចរិតភាពខ្ពស់បំផុតទេនោះយើងផ្ទាញ់ខ្លួនឯងក្នុងដំណើរការនេះជាពិសេសក្នុងបេសកកម្មរបស់យើងដើម្បីប្រយុទ្ធប្រឆាំងនឹងឧបសគ្គជាប្រព័ន្ធដើម្បីដោះស្រាយភាពក្រីក្រនិងភាពអយុត្តិធម៌។ យើងត្រូវស្មោះត្រង់ជាមួយខ្លួនយើង ហើយសារភាពថាយើងមិនទាន់ដល់ទីដែលយើងចង់បាន។ យើងមិនត្រូវលាក់ខ្លួនឬលាក់បាំងបញ្ហា ហើយសង្ឃឹមថាវានឹងរលាយបាត់ទៅវិញទេ។ យើងត្រូវតែត្រៀមខ្លួនដើម្បីដោះស្រាយបញ្ហាដ៏ឈឺចាប់នៅខាងក្នុងសិន បើយើងចង់ទទួលបានជោគជ័យខាងក្រៅ។ យើងប្រើព័ត៌មានខាងក្រៅដើម្បីរម្លឹកខ្លួនឯងពីគុណតម្លៃស្នូលរបស់យើង ហើយដឹងពីចំណុចខ្សោយនិងភាពខ្លាំងរបស់យើង។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

ខ្ញុំគិតថា ដោយសារភាពលម្អៀងផ្នែកវប្បធម៌និងបញ្ញានាំឱ្យមានការយល់ច្រឡំច្រើនអំពីអ្វីជាអ្នកដឹកនាំនិងអ្វីដែលធ្វើឱ្យអ្នកដឹកនាំល្អ។ ខ្ញុំបានឃើញភាពលម្អៀងខាងបញ្ញាដែលអះអាងថា មានតែអ្នកដែលមានការអប់រំខ្ពស់ប៉ុណ្ណោះដែលជាមេដឹកនាំដ៏អស្ចារ្យបានហើយដោយសារតែ "ពូជពង្ស" ពួកគេ ទើបគេមានចម្លើយទាំងអស់។ ខ្ញុំគិតថាវាជាការក្រអឺតក្រទមមែនទែន! ខ្ញុំស្គាល់អ្នកដឹកនាំដែលបំផុសគំនិតជាច្រើនដែលមិនបានបញ្ចប់ការសិក្សាពីបឋមសិក្សាឡើយហើយពួកគេមានបេះដូងចំពោះប្រជាជននិងសង្គមដោយមិនចាំបាច់មានការអប់រំខ្ពស់។

ម្យ៉ាងទៀត អ្វីដែលនាំឱ្យមានការភ័ន្តច្រឡំគឺថា មនុស្សមួយចំនួនគិតថាមេដឹកនាំគឺជា"ឪពុកម្តាយ" ហើយអ្នកគាំទ្រ ឬ "កូនៗ" មិនគួរសួរសំណួរអំពី"ថ្នាក់ដឹកនាំកំពូលៗ" ទាំងអស់នោះទេ។ នេះគឺជារឿងឆោតល្ងង់ និងអំនួតសុទ្ធសាធ។ ខ្ញុំជឿជាក់លើភាពជាអ្នកដឹកនាំដែលមានការចូលរួម ដែលបុគ្គលម្នាក់ៗផ្តល់នូវភាពជាអ្នកដឹកនាំរបស់ពួកគេហើយថាគ្មាននរណាម្នាក់នៅពីលើក្រមសីលធម៌របស់ប្រទេសឬអង្គការឡើយ។ អ្នកដឹកនាំមិនគួរធ្វើពុតជាមានចម្លើយទាំងអស់នោះទេហើយពួកគេគួរតែដឹងពីរបៀបដាក់បញ្ចូលមនុស្សដែលមានគំនិតល្អៗដើម្បីស្វែងរកការយល់ស្របនិងដំណោះស្រាយដែលមាននិរន្តរភាពជាងនេះ។

ប៉ុន្តែប្រសិនបើអ្នកទទូចឱ្យខ្ញុំជ្រើសយកនូវចរិតអវិជ្ជមានបំផុតសម្រាប់អ្នកដឹកនាំខ្ញុំគិតថាវាគួរតែជាអ្នកដឹកនាំដែលមិនអាចទទួលយកការរិះគន់ហើយដែលអនុញ្ញាតឱ្យពួកគេមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនឬយកផលប្រយោជន៍ផ្ទាល់ខ្លួនដាក់លើកាតព្វកិច្ចរបស់ពួកគេ។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

ខ្ញុំមិនប្រាកដថាខ្ញុំមានទេពកោសល្យខាងអ្វីមួយនៅឡើយទេ។ និយាយឱ្យស្មោះត្រង់ទៅ ខ្ញុំមិនចាត់ទុកខ្លួនថាជាអ្នកដឹកនាំទេ ប៉ុន្តែជាសារធាតុបង្កដែលនឹងគាំទ្រនិងជួយអ្នកដែលនៅជុំវិញខ្ញុំឱ្យសម្រេចបាននូវអ្វីដែលពួកគេអាចធ្វើបាន។ ខ្ញុំជឿជាក់យ៉ាងមុតមាំលើភាពជាអ្នកដឹកនាំដែលមានការចូលរួម។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា មនុស្សគ្រប់គ្នាអាចដឹកនាំបានហើយគួរតែដឹកនាំពីកន្លែងដែលពួកគេកំពុងឈរ ដោយមិនគិតថាពួកគេស្ថិតក្នុងឋានៈអ្វីនោះទេ។ ដូច្នេះខ្ញុំបន្តរៀនពីមនុស្សគ្រប់គ្នានៅជុំវិញខ្ញុំ ហើយជំរុញខ្លួនឯងឱ្យជួយអ្នកដែលនៅក្បែរខ្ញុំឱ្យបានច្រើនជាងមុន ទោះពួកគេជាអ្នកទទួលភ្ញៀវ ឬជាអ្នកបើកបរ ឬអ្នកគ្រប់គ្រងក៏ដោយ។ ខ្ញុំព្យាយាមបង្កើតកន្លែងស្មើភាពដើម្បីឱ្យអ្នកដឹកនាំអាចរីករាយនឹងបេសកកម្មរបស់ពួកគេនិងសម្រេចបាននូវសក្តានុពលដ៏ខ្ពស់បំផុតរបស់ពួកគេ។ ខ្ញុំជឿជាក់លើការគាំទ្ររបស់អ្នកគ្រប់គ្រងនិងអ្នកដឹកនាំដែលឱ្យពួកគាត់បង្កើតដំណោះស្រាយផ្ទាល់ខ្លួននិងស្គាល់នូវភាពរឹងមាំក៏ដូចជាចំណុចខ្សោយរបស់ពួកគាត់។វាធ្វើឱ្យខ្ញុំរីករាយនិងពេញចិត្តយ៉ាងខ្លាំងចំពោះខ្លួនឯង ពេលឃើញពួកគាត់បញ្ចេញសមត្ថភាពបានល្អបំផុត។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា?*

មានរឿងពីរខ្ញុំអាចរកនឹកឃើញ។ បន្ទាប់ពីរយៈពេល ១០ឆ្នាំក្នុងអាជីពជាមួយវិស័យបរិស្ថានខ្ញុំបានសម្រេចចិត្តត្រលប់ទៅរៀនវិញដោយមិនដឹងថានឹងមានអ្វីកើតឡើងបន្ទាប់ឬថាតើខ្ញុំអាចរកការងារធ្វើបានឬទេ ខណៈប្រាក់សន្សំរបស់ខ្ញុំមានកម្រិតហើយខ្ញុំត្រូវបន្តគាំទ្រគ្រួសាររបស់ខ្ញុំ។ នៅពេលដែលខ្ញុំបានបញ្ចប់សញ្ញាបត្រទីពីររបស់ខ្ញុំសំណាងល្អដែលខ្ញុំត្រូវបានផ្តល់ឱ្យនូវអាហារូបករណ៍ PDH និងការងារថ្មីនៅក្នុងវិស័យថ្មីមួយក្នុងពេលតែមួយ។ ខ្ញុំបានសម្រេចចិត្តយកការងារនោះជាបទពិសោធន៍ ហើយវាបានក្លាយជាការសម្រេចចិត្តដ៏ត្រឹមត្រូវ។ វាជារឿងដែលមិនទៀងមួយដែលខ្ញុំបានធ្វើ ប៉ុន្តែវាបានប្រែជាល្អវិញនៅទីបញ្ចប់។

រឿងមួយទៀតគឺនៅពេលខ្ញុំកំពុងតែរីករាយនិងដល់កម្រិតកំពូលក្នុងការងាររបស់ខ្ញុំនៅពេលនោះស្វាមីខ្ញុំត្រូវតែផ្លាស់ប្តូរទៅប្រទេសផ្សេង។ វាជាការចាំបាច់សម្រាប់គាត់។ បន្ទាប់ពីការពិចារណាយ៉ាងយូរ ខ្ញុំបានសម្រេចចិត្តជ្រើសយកគ្រួសារហើយចាកចេញពីការងាររបស់ខ្ញុំ។ វាគឺជាការដោះដូរមួយ ប៉ុន្តែវាគឺជាឱកាសមួយក្នុងជីវិតដែលខ្ញុំបានជ្រើសរើសអាទិភាពគ្រួសារ។ ដូចខ្ញុំបានប្រាប់អ្នកថា ខ្ញុំចាប់ផ្តើមធ្វើការតាំងពីក្មេងមកម្លេះហើយខ្ញុំតែងតែមមាញឹក ដូច្នេះការចាកចេញពីការងារខ្ពស់របស់ខ្ញុំនិងការស្វែងរកអ្វីផ្សេងទៀតដោយគ្មានភាពច្បាស់លាស់ណាមួយគឺមិនមែនជារឿងដែលខ្ញុំចូលចិត្តនោះទេ។






*អ្នកដឹកនាំតំណាងក្រុមកម្មករបាត់បង់ឱកាសពីប្រទេសកម្ពុជា វៀតណាម និងឡាវ ខេត្តសៀមរាប។* រូបថត: អុកហ្វាម

ប៉ុន្តែខ្ញុំសប្បាយចិត្តនឹងជម្រើសនោះ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

យើងត្រូវតែធ្វើឱ្យបានល្អប្រសើរជាងខ្លួនយើងផ្ទាល់ពីជំនាន់មួយទៅជំនាន់មួយនិងដើម្បីផ្តល់ជូននូវចំណុចល្អរបស់កម្ពុជាដល់ពិភពលោកឱ្យកាន់តែច្រើន។ តាមខ្ញុំដឹងប្រជាជនខ្មែរឱ្យតម្លៃដល់ប្រាជ្ញារបស់មនុស្សចាស់ដែលបានកើតមុនយើង ហើយផ្តល់រង្វាន់ដល់ការវៃឆ្លាតនិងការខិតខំរបស់ក្មេងជំនាន់បច្ចុប្បន្ន។ ប្រជាជនខ្មែរ តែងតែគិតអំពីថា តើអ្វីៗទាំងអស់ដែលយើងធ្វើសព្វថ្ងៃនេះគឺជាការរៀបចំល្អប្រសើរនិងផ្តល់ជោគជ័យបន្ថែមទៀតសម្រាប់មនុស្សជំនាន់ក្រោយឬយ៉ាងណា។ ខ្ញុំបានឃើញស្ត្រីដែលចិញ្ចឹមខ្ញុំ ហើយឥឡូវនេះខ្ញុំឃើញរឿងនេះក្នុងខ្លួនខ្ញុំដែលជាម្តាយម្នាក់។ ប្រជាជនខ្មែរយើងមិនខ្ជិលច្រអូសទេ ហើយចូលចិត្តការប្រកួតប្រជែង។ ក្នុងន័យនេះវប្បធម៌ខ្មែរដែលខ្ញុំស្គាល់ មានមោទនភាពចំពោះអត្តសញ្ញាណផ្ទាល់ខ្លួន ប៉ុន្តែឧស្សាហ៍ព្យាយាមនិងអាត្មានិយម។ ដូច្នេះខ្ញុំមានសង្ឃឹមជានិច្ច។ ខ្ញុំតែងតែជាមនុស្សមានសុទិដ្ឋិនិយមហើយខ្ញុំជឿជាក់លើយុវជនខ្មែរក្នុងគ្រប់វិស័យទាំងអស់មិនថាពួកគេជាសហគ្រិន មន្ត្រីរាជការ ឬបុគ្គលិកសង្គមទេ។ ពួកគេនឹងផ្លាស់ប្តូរប្រទេសកម្ពុជាហើយគ្មានអ្វីអាចបញ្ឈប់ពួកគេបានទេ។ ប៉ុន្តែដើម្បីឱ្យរឿងនេះកើតឡើង មនុស្សជំនាន់ខ្ញុំមិនអាចធ្វេសប្រហែសបានឡើយ។ មនុស្សជំនាន់នេះជំពាក់គុណអ្នកជំនាន់មុនដែលបានចូលមកមុនយើងហើយបានលះបង់ញើសឈាមដើម្បីឱ្យយើងបានដល់នៅសព្វថ្ងៃនេះ។ ដូច្នេះវាគឺជាកាតព្វកិច្ចរបស់យើងក្នុងការត្រួសត្រាយផ្លូវបន្ថែមទៀតនិងរៀបចំសម្រាប់មនុស្សជំនាន់ក្រោយដើម្បីបង្កើនភាពជាអ្នកដឹកនាំរបស់ពួកគេលើប្រទេសជាតិនិងរួមចំណែកក្នុងតំបន់និងពិភពលោករបស់យើង។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

អ្នកអាចរៀន និងដឹកនាំបានក្នុងពេលតែមួយ។ ប្រសិនបើនរណាម្នាក់ប្រាប់អ្នកថាពួកគេបានកើតមកដើម្បីដឹកនាំ ហើយថាដំណើរជាអ្នកដឹកនាំរបស់ពួកគេរលូន ហើយថាពួកគេមិនដែលធ្វើខុសនោះ ជឿខ្ញុំចុះ ពួកគេកុហកទេ។ ជឿលើខ្លួនអ្នកហើយបង្កើតដំណើរជាអ្នកដឹកនាំដោយខ្លួនឯង។ កុំមានអារម្មណ៍អន់ចិត្តពេកចំពោះកំហុសផ្ទាល់ខ្លួនឬកំហុសរបស់អ្នកដទៃ ហើយប្រសិនបើអ្នកគិតថាអ្នកមិនអាចទៅដល់កន្លែងដែលអ្នកចង់បានភ្លាមៗ គួរមានចិត្តមេត្តាដល់ខ្លួនឯង (នេះជាអ្វីដែលខ្ញុំបានចាប់ផ្តើមធ្វើចំពោះខ្លួនឯងដែរ)។ កែតម្រូវចំណុចសំខាន់ៗដែលអ្នក កសាងឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរបស់អ្នកឱ្យស្របតាមផ្លូវជីវិតនិងជីវិតដ៏ស្រស់ស្អាតរបស់អ្នកហើយព្យាយាមរីករាយជាមួយពួកគេតាមដែលអ្នកអាចធ្វើបាននិងផ្តល់ការលើកទឹកចិត្តឱ្យបន្តទៅមុខ។ ការធ្វើដំណើររបស់អ្នកនឹងមិនងាយស្រួលនោះទេ។ អ្នកនឹងសង្ស័យខ្លួនឯងហើយអ្នកប្រហែលជាអស់សង្ឃឹម ប៉ុន្តែអ្នកត្រូវតែក្រោកឈរឡើងលើឧបសគ្គទាំងនោះហើយទាញអ្នកដទៃឱ្យឡើងជាមួយអ្នក! នៅពេលដែលអ្នកធ្វើដំណើរតាមបណ្តោយដងទន្លេក្នុងដំណើរនៃការរីកចម្រើននិងការដឹកនាំរបស់អ្នក អ្នកអាចស្វែងយល់នូវអ្វីថ្មីៗនៅតាមផ្លូវនោះ ហើយវាអាចជួយអ្នកឱ្យដឹងពីគោលបំណងពិតប្រាកដរបស់អ្នកនៅក្នុងជីវិតនិងអត្ថន័យពិតប្រាកដសម្រាប់អ្នក។ ហើយសំខាន់ជាងនេះទៅទៀតកុំភ្លេចគោលដៅនោះឱ្យសោះ។

ខ្ញុំសង្ឃឹមថា គោលដៅរបស់អ្នកគឺជាការមួយដែលនឹងជួយលើកតម្កើងអ្នកនិងរួមចំណែកដល់ភាពប្រសើរឡើងនៃប្រជាជននៅជុំវិញអ្នក ជាពិសេសស្ត្រីនិងកុមារីដទៃទៀតដែលនឹងធំឡើងបន្ទាប់ពីអ្នក មិនថាទោះតិចតួចប៉ុនណានោះទេ។ ពីព្រោះនោះគឺជាវិធីតែមួយគត់ដែលខ្ញុំជឿថាសម្រាប់យើងទាំងអស់គ្នាជាស្ត្រីដើម្បីរួមចំណែកក្នុងការកសាងសង្គមស្មើភាពនិងសមស្របសម្រាប់មនុស្សគ្រប់រូបជាពិសេសអ្នកដែលមិនសូវមានសិទ្ធិ។ ការអាណិតអាសូរគឺជាគន្លឹះ។ រួមបញ្ចូលជាមួយការប្តេជ្ញាចិត្តដោយខ្លួនឯង អ្នកអាចធ្វើអ្វីបានទាំងអស់។ ខ្ញុំនិយាយមែន! WK

# លោកជំទាវ ជូ ប៊ុនអេង

## រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ



អ្នកដឹកនាំ
ស្ត្រីនៅកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត?*

ខ្ញុំកើតនៅខែឧសភា ឆ្នាំ១៩៥៦ នៅខេត្តបាត់ដំបង។ ម្តាយរបស់ខ្ញុំធ្លាប់ធ្វើជាគ្រូបង្រៀនតាំងពីគាត់នៅក្មេង ប៉ុន្តែក្រោយពីរៀបការមកគាត់នៅធ្វើជាស្ត្រីមេផ្ទះខណៈពេលដែលឪពុកខ្ញុំជាជាងទងនិងជាកសិករ។ ម្តាយរបស់ខ្ញុំមានកូន ១០នាក់ ហើយគ្រួសារខ្ញុំមានជីវភាពមិនធូរធារទេ។ បងប្រុសពីរនាក់របស់ខ្ញុំបានស្លាប់តាំងពីនៅវ័យក្មេង។ ខ្ញុំក្លាយជាកូនទី៣ក្នុងចំណោមកូន៨នាក់នៅក្នុងគ្រួសាររបស់ខ្ញុំ។ បងស្រី និងប្អូនប្រុសរបស់ខ្ញុំមិនបានទទួលការអប់រំខ្ពស់ទេ។ គាត់បានបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាតាមសំណើរបស់ឪពុកម្តាយ ខ្ញុំ ដោយសារតែម្តាយខ្ញុំមានសុខភាពកាន់តែយ៉ាប់ទៅៗហើយគ្មាននរណាមើលថែ គាត់នៅពេលដែលឪពុកខ្ញុំទៅធ្វើការនៅឆ្ងាយពីផ្ទះ។ បងប្រុសច្បងខ្ញុំក៏ត្រូវបោះបង់ចោលការសិក្សារបស់គាត់បន្ទាប់ពីគាត់បានបញ្ចប់ការសិក្សាថ្នាក់អនុវិទ្យាល័យដើម្បីចុះឈ្មោះជាទាហានហើយគាត់បានស្លាប់ក្នុងអំឡុងសង្គ្រាមស៊ីវិលឆ្នាំ ១៩៧៣ ដោយជំងឺ។ ខ្ញុំជាកូនតែម្នាក់គត់នៅក្នុងគ្រួសារដែលអាចបញ្ចប់ថ្នាក់វិទ្យាល័យក្នុងឆ្នាំ១៩៧៤ នៅឯស្រុកកំណើតរបស់ខ្ញុំក្នុងខេត្តបាត់ដំបង (វិទ្យាល័យបាត់ដំបងជាឈ្មោះទីពីរនៃវិទ្យាល័យព្រះមុន្នីវង្ស)ហើយខ្ញុំបានបន្តការសិក្សានៅសកលវិទ្យាល័យនៅភ្នំពេញខាងជំនាញគណិតវិទ្យា។

ជាអកុសលសង្គ្រាមនៅតែបន្តយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យខ្ញុំមិនអាចចូលរៀននៅសកលវិទ្យាល័យ។ ខ្ញុំក៏សម្រេចចិត្តរកការងារធ្វើនៅក្រុមហ៊ុនសេង ថៃ។ ខ្ញុំនឹកឃើញពីបទពិសោធន៍ការងាររបស់ខ្ញុំក្នុងអំឡុងពេលខ្ញុំមានអាយុ១៩ឆ្នាំ។ ខ្ញុំត្រូវបានគេប្រគល់តួនាទីអ្នកដឹកនាំជាន់ខ្ពស់ ជាប្រធានឃ្លាំងដែលបានគ្រប់គ្រងលើក្រុមហ៊ុនចំនួនបួនក្រោមឈ្មោះថា "Tissage MechanicSeng Thai" នៅក្នុងខណ្ឌឫស្សីកែវ។

ខ្ញុំចូលចិត្តសរសេររឿង។ ពេលខ្ញុំនៅរៀនវិទ្យាល័យ ខ្ញុំបានសរសេររឿងពីរហើយផ្ញើវាទៅមន្ទីរព័ត៌មាននៅភ្នំពេញ។ រឿងទាំងនោះត្រូវបានជ្រើសរើសដោយលោកម៉ៅប៊ុនថន ជានិពន្ធនាយកនៃវិទ្យុជាតិដែលត្រូវបានចាក់ផ្សាយប្រចាំសប្តាហ៍តាមស៊េរីដែលគេហៅថា "រឿងព្រេងនិទាន"។ ក្នុងពេលថ្មីៗសៀវភៅរឿងខ្ញុំមួយនេះបានទាក់ទាញចំណាប់អារម្មណ៍របស់ក្រុមហ៊ុនភាពយន្តមួយដែលចង់ទិញវាដើម្បីធ្វើវាជាខ្សែភាពយន្ត។

ពេលរីករាយរបស់ខ្ញុំត្រូវបានបញ្ចប់នៅថ្ងៃទី ១៧ ខែមេសាឆ្នាំ ១៩៧៥។ ក្នុងរបបប៉ុលពត ក្តីសង្ឃឹមរបស់ខ្ញុំក្នុងអំឡុងពេលវ័យជំទង់ត្រូវបានរលាយអស់។ ខ្ញុំត្រូវធ្វើការយ៉ាងលំបាកពីកន្លែងមួយទៅកន្លែងមួយមិនត្រឹមតែនៅក្នុងសហគមន៍ប៉ុណ្ណោះទេប៉ុន្តែថែមទាំងនៅពន្ធនាគារប៉ុលពតផងដែរស្ថិតនៅក្នុងភ្នំបាសិតដែលហៅថាតំបន់ពន្ធនាគារទី ៣២។ យ៉ាងណាខ្ញុំត្រូវបានគេចាត់តាំង ឱ្យធ្វើជាមេអ្នកទោសស្រី។ វាប្រហែលជាដោយសារតែគេឃើញខ្ញុំមានភាពស្មោះត្រង់និងមានសមត្ថភាពដឹកនាំ។ ទីបំផុតខ្ញុំត្រូវបានគេរៀបចំឱ្យរៀបការក្នុងឆ្នាំ ១៩៧៨ ក្នុងរបបប៉ុលពត។

នៅឆ្នាំ ១៩៨៣ ខ្ញុំបានព្យាយាមដាក់ពាក្យធ្វើគ្រូបង្រៀន ហើយចូលរៀននៅសកលវិទ្យាល័យភ្នំពេញរយៈពេលមួយឆ្នាំដើម្បីរម្លឹកឡើងវិញនូវគណិតវិទ្យា។ ខ្ញុំចាប់ផ្តើមអាជីពជាគ្រូបង្រៀនគណិតវិទ្យានៅវិទ្យាល័យដូនពេញ(ឈ្មោះទីពីរនៃវិទ្យាល័យព្រះស៊ីសុវត្ថិ) រហូតមកដល់ឆ្នាំ ១៩៩៤ តំណាលគ្នាជាមួយការសិក្សាបរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងឆ្នាំ ២០១០ ខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាហើយពេលនេះខ្ញុំជាបេក្ខបណ្ឌិតនៅរាជបណ្ឌិត្យសភាកម្ពុជា។



> ❝ **ស្ត្រីអាចធ្វើជាអ្នកដឹកនាំដ៏ពូកែបាន បើយើងចង់។ ដូច្នេះយើងត្រូវក្លាហាន និងឱ្យគេដឹងឮ និងឃើញពីសមិទ្ធផលរបស់យើង**

បន្ទាប់ពីការបោះឆ្នោតជាសកលជាលើកដំបូងក្នុងឆ្នាំ ១៩៩៣ លេខាធិការដ្ឋានកិច្ចការនារីត្រូវបានបង្កើតឡើង ហើយត្រូវការបុគ្គលិកបច្ចេកទេសដើម្បីដំណើរការនាយកដ្ឋាន។ ខ្ញុំត្រូវបានណែនាំនិងជ្រើសរើសជានាយករងនៃនាយកដ្ឋានព័ត៌មាន។ បន្ទាប់មកខ្ញុំបានផ្លាស់ប្តូរអាជីពពីគ្រូបង្រៀនទៅក្រសួងកិច្ចការនារីក្នុងឆ្នាំ ១៩៩៤។ នៅឆ្នាំ ១៩៩៨ ខ្ញុំត្រូវបានដំឡើងឋានៈជាអគ្គអធិការ។

នៅឆ្នាំ ១៩៩៩ ជាថ្មីម្តងទៀតខ្ញុំបានជាប់ឆ្នោតជាសមាជិកគណៈកម្មការដឹកនាំសមាគមនារីដែលហៅថាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិង

អភិវឌ្ឍន៍។ បន្ទាប់មកខ្ញុំត្រូវបានជ្រើសរើសឱ្យធ្វើជាអគ្គលេខាធិការ និងដើរតួជានាយកប្រតិបត្តិចាប់តាំងពីឆ្នាំ១៩៩៩ និងគ្រប់គ្រងសមាគមនេះរហូតដល់ឆ្នាំ ២០០៥។ បន្ទាប់មកខ្ញុំត្រូវបានគេហៅត្រលប់មកវិញឱ្យទៅធ្វើការនៅ MOWA ជាអគ្គនាយកទទួលខុសត្រូវលើនាយកដ្ឋានចំនួន៣ គឺនាយកដ្ឋានស្រ្តីនិងការអប់រំសុខភាពស្រ្តី និងជំនួយផ្នែកច្បាប់ដល់ស្រ្តី។ នៅអាណត្តិទី ៤នៃរាជរដ្ឋាភិបាលឆ្នាំ ២០០៨-២០១៣ ខ្ញុំត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលដើម្បីធ្វើជារដ្ឋលេខាធិការនៅក្រសួងមហាផ្ទៃហើយនៅតែស្ថិតនៅក្នុងតំណែងនេះរហូតមកដល់បច្ចុប្បន្នអាណត្តិទី ៦ ឆ្នាំ ២០១៨-២០២៣ ។

ក្នុងន័យនេះ ខ្ញុំនឹងចែករំលែកទស្សនៈរបស់ខ្ញុំថា “ការអប់រំ និងភាពជាអ្នកដឹកនាំជាមួយនឹងការអនុវត្ត” អាចជំរុញយើងឱ្យឈានទៅមុខ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំអាចផ្លាស់ពីគ្រូបង្រៀនសាមញ្ញម្នាក់ទៅធ្វើជាប្រធាននាយកដ្ឋាន បន្ទាប់មកខ្ញុំអាចដឹកនាំទាំងនៅក្នុងក្រសួងនិងសង្គមស៊ីវិលក្នុងពេលតែមួយ ហើយនៅទីបំផុតខ្ញុំអាចត្រូវបានដំឡើងឋានៈជារដ្ឋលេខាធិការនៅក្នុងការទទួលបន្ទុកការងារមួយចំនួនដូចជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (CWPD) អនុប្រធានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (NCCT) អនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្រ្តី (CNCW) ក៏ដូចជាអនុប្រធានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមគ្រួសារនិងគុណតម្លៃស្រ្តី។ វាទាមទារឱ្យមានការខិតខំប្រឹងប្រែងនិងពេលវេលាយ៉ាងច្រើន។




*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ ?*

- មេដឹកនាំនិងអ្នកក្រោមបង្គាប់មិនយល់គ្នាទេ។ ក្រុមរបស់យើងមិនយល់ដឹងច្បាស់អំពីអ្វីដែលយើងកំពុងធ្វើទេ
- ធ្វើការសម្រេចចិត្តយ៉ាងឆាប់រហ័ស និងត្រូវដើរតួនាទីជាគំរូល្អនិងកៀងគរអ្នកដទៃ

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ខ្ញុំមានគោលការណ៍ជីវិតរបស់ខ្ញុំ។ ខ្ញុំត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីយកឈ្នះឧបសគ្គនានា ចូលចិត្តប្រឈមនឹងបញ្ហា និងដោះស្រាយបញ្ហាទាំងនោះ។ ខ្ញុំទទួលយកគំនិតផ្សេងៗគ្នាហើយខ្ញុំរៀនសម្របខ្លួនតាមស្ថានភាពដែលខ្ញុំស្ថិតនៅ។ ដូច្នេះខ្ញុំអាចទទួលបានការគាំទ្រនិងការគោរពពីអ្នកដទៃជាពិសេសពីអ្នកដែលខ្ញុំបានដឹកនាំ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា “យើងត្រូវតែជឿជាក់លើខ្លួនឯងដោយធានាថាមនុស្សនៅជុំវិញយើងអាចធ្វើការងាររបស់យើងបាន”។ ខ្ញុំទទួលបានដំបូន្មានពីគ្រូរបស់ខ្ញុំថា មនុស្សគ្រប់រូបមានកាតព្វកិច្ចជាពលរដ្ឋល្អ។ ហើយពលរដ្ឋល្អគឺជាមូលដ្ឋានគ្រឹះដើម្បីកសាងសង្គមល្អ។ នៅពេលយើងមានសង្គមល្អ ប្រទេសរបស់យើងនឹងមានភាពរីកចម្រើន។ យើងអាចដឹកនាំសង្គមទៅមុខ ប្រសិនបើយើងកសាងសង្គមរួបរួមមួយ។ យើងអាចប្រកួតប្រជែងគ្នា ប៉ុន្តែដើម្បីទិសដៅនិងគោលដៅរួមច្បាស់លាស់មួយ។

*តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើលោកជំទាវធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច ?*

- ភាពស្មោះត្រង់ជាមួយការងារ និងអ្នកធ្វើការជាមួយ។
- ត្រូវមានភាពក្លាហានក្នុងការធ្វើអ្វីដែលយើងគិតថាជាការត្រឹមត្រូវដែលនឹងមិនធ្វើឱ្យខូចខាតដល់នរណាម្នាក់ឡើយ។
- មិនរួញរាលើកិច្ចការដែលបានកំណត់
- សិល្បៈនៃការចរចា និងជំនាញបញ្ចុះបញ្ចូល
- ទំនួលខុសត្រូវ និងគណនេយ្យភាព

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

- អាត្មានិយម
- បង្ខំឱ្យអ្នកដទៃគោរពខ្លួនឯង
- ខ្វះការទទួលខុសត្រូវ
- មិនមានភាពជាអ្នកដឹកនាំ
- មើលងាយអ្នកដទៃ
- អយុត្តិធម៌





*តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្រ្តីឬសមភាពយេនឌ័រ) ?*

- ស្គាល់ខ្លួនឯងជាអ្នកណា
- យល់និងទទួលយកការពិត
- ត្រូវមានភាពយុត្តិធម៌និងសមធម៌សម្រាប់ទាំងអស់គ្នា
- គ្រប់គ្រងបញ្ហាប្រឈមដោយដាក់បញ្ហារសើបខាងយេនឌ័រជាស្នូលនៃការងារ
- កសាងទំនុកចិត្ត និងការលើកទឹកចិត្ត
- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌
- បង្កើតវប្បធម៌នៃសាមគ្គីភាព និងការទទួលស្គាល់ទង្វើល្អសម្រាប់សង្គម។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

យើងតែងតែគិតថា សហគ្រិនភាពមិនមែនជាប្រវត្តិខ្មែររបស់យើងទេ។ រហូតមកដល់ពេលនេះប្រសិនបើយើងនិយាយពីជំនួញឬសហគ្រិនយើងតែងតែគិតពីជនជាតិចិន។ ប៉ុន្តែយើងជាជនជាតិខ្មែរយើងត្រូវតែកសាងភាពជាសហគ្រិន ដែលមាននៅក្នុងប្រទេសកម្ពុជារាប់សតវត្សឱ្យក្លាយជាទម្លាប់របស់យើង។ ភាពជាសហគ្រិនអាចជួយមនុស្សរបស់យើងឱ្យឆ្លាតវៃក្នុងការធ្វើអាជីវកម្ម ក៏ដូចជារួបរួមគ្នានិងជួយគ្នាទៅវិញទៅមកដើម្បីលុបបំបាត់ភាពក្រីក្រ។ ដូច្នេះយើងត្រូវការជំនាញដឹកនាំ ទម្លាប់ ហើយគ្រប់គ្នាអាចធ្វើបានដើម្បីលើកកម្ពស់ខ្លួនយើងឱ្យក្លាយជាផ្នែកមួយនៃពាណិជ្ជកម្មអន្តរជាតិហើយដើម្បីធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសយើងកាន់តែប្រសើរឡើង។

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ប្រទេសកម្ពុជាគឺជាសង្គមមាតាធិបតេយ្យ។ ប៉ុន្តែយើងឃើញថា ស្រ្តីតែងតែមិនមែនជាអ្នកកាន់តំណែងខ្ពស់ៗទេ។ មិនថាស្រ្តីឬបុរសជាអ្នកមានអំណាចដឹកនាំទេ វាសំខាន់ណាស់ដែលពួកគេត្រូវលើកកម្ពស់តម្លៃស្រ្តីនិងមនុស្ស។ ខ្ញុំតែងតែនិយាយថាអ្នកដឹកនាំត្រូវតែមានបេះដូងជាម្តាយ។ ស្រ្តីត្រូវត្រៀមខ្លួនឱ្យបានល្អនិងត្រៀមខ្លួនឱ្យរួចជាស្រេចក្នុងការដើរតួនាទីនិងតំណែងជាអ្នកដឹកនាំ។ ពួកគេត្រូវដឹងពីទិសដៅនិងចែករំលែកដល់អ្នកដើរតាមឬអ្នកក្រោមបង្គាប់។

យើងជាស្រ្តីគ្រប់គ្នាអាចជាមេដឹកនាំល្អនិងសហគ្រិនប្រសិនបើយើងចង់។ ចូរមានភាពក្លាហាននិងឱ្យអ្នកដទៃដឹងឮនិងបានឃើញការអនុវត្តនិងសមិទ្ធផលដ៏ល្អរបស់អ្នក! WK

# លោកស្រី ខៀវ មាលី
## ដៃគូអាជីវកម្ម | SokSiphana & Associates និងជាសមាជិកនៃ ZICO Law



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំបានកើតនៅក្នុងគ្រួសារដែលមានជីវភាពមធ្យមដែលផ្តល់តម្លៃខ្ពស់ដល់ការអប់រំ។ ខ្ញុំជាកូនទី៧ក្នុងគ្រួសារដែលមានកូន៩នាក់។ ឪពុកម្តាយរបស់ខ្ញុំដែលបានចែកឋានទៅតែង ជឿជាក់លើការអប់រំហើយពួកគាត់មានទស្សនៈថាកូនៗរបស់ពួកគាត់ទាំងកូនស្រីនិងកូនប្រុសត្រូវទទួលបានការអប់រំសមស្រប។ ម្តាយរបស់ខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីរឿងនេះជាពិសេសដោយសារគាត់មិនមានឱកាសទៅសាលារៀនដោយសារប្រពៃណីទំនៀមទម្លាប់នៃសង្គមអភិរក្ស។ ពេញមួយជីវិតរបស់គាត់ គាត់បានធ្វើការយ៉ាងលំបាកដើម្បីធ្វើឱ្យប្រាកដថា កូនៗរបស់គាត់ទាំងអស់បានទទួលការអប់រំ។ យើងទទួលបានទាំងការអប់រំផ្លូវការនិងការចិញ្ចឹមអប់រំតាមបែបប្រពៃណីយ៉ាងម៉ត់ចត់ដែលបង្រៀនយើងនូវជំនាញទន់។ យើងបានធំធាត់ឡើងដោយបង្រៀនឱ្យមានការគោរពចំពោះអ្នកដែលមានអត្តចរិតល្អ មិនមែនដោយសារតែទ្រព្យសម្បត្តិសម្ភារៈរបស់ពួកគាត់ឬតំណែងរបស់ពួកគាត់នៅក្នុងសង្គមរបស់យើងទេ។ ក្នុងនាមជាគ្រួសារគោរពពុទ្ធសាសនាដ៏ក្លៀវក្លា ឪពុកម្តាយរបស់ខ្ញុំបានបង្រៀនយើងផងដែរឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍ព្រះពុទ្ធសាសនាទាំងបួននៃសេចក្តីមេត្តាករុណា មុទិតា ឧបិក្ខា។ ឥរិយាបថយកចិត្តទុកដាក់របស់ពួកគាត់ចំពោះគ្រួសារ អ្នកជិតខាងនិងសហគមន៍បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំអាចនិយាយដូចគ្នានេះដែរអំពីបងប្អូនប្រុសស្រីរបស់ខ្ញុំ។ យើងធំធាត់នៅក្នុងបរិយាកាសដ៏សុខដុម សូម្បីតែក្នុងអំឡុងពេលដ៏ខ្មៅងងឹត ដែលប្រទេសនេះត្រូវបានលេបត្របាក់ដោយសង្គ្រាមប្រល័យពូជសាសន៍និងការអត់ឃ្លាន។

ក្រៅពីឪពុកម្តាយខ្ញុំ គំរូដ៏អស្ចារ្យមួយទៀតក្នុងជីវិតរបស់ខ្ញុំគឺប្តីរបស់ខ្ញុំលោកបណ្ឌិត សុក ស៊ីផាណា។ ខ្ញុំជាស្ត្រីមានសំណាងដែលបានរៀបការជាមួយគាត់ ជាពិសេសតាមរយៈអាពាហ៍ពិពាហ៍បែបផ្សំផ្គុំតាមប្រពៃណី។ គាត់ក៏ឱ្យតម្លៃខ្ពស់ចំពោះការអប់រំនិងការខិតខំប្រឹងប្រែងដែរ។ គាត់ទទួលបានបណ្ឌិតចៅក្រមមកពីសហរដ្ឋអាមេរិកនិងបណ្ឌិតផ្នែកច្បាប់មកពីប្រទេសអូស្ត្រាលី។ បច្ចុប្បន្នគាត់កំពុងបញ្ចប់និក្ខេបបទរបស់គាត់សម្រាប់បណ្ឌិតមួយផ្សេងទៀតនៅ Université de Paris Panthéon-Assas នៅប៉ារីសប្រទេសបារាំង។ ដោយសារខ្ញុំបានរៀបការនៅឆ្នាំ ១៩៩៣គាត់បានលើកទឹកចិត្តខ្ញុំឱ្យបន្តការសិក្សា។ តាមទស្សនៈរបស់គាត់ការរៀនគួរជាដំណើរពេញមួយជីវិត។ ខ្ញុំត្រូវបានបំផុសគំនិតនេះយ៉ាងខ្លាំងហើយខ្ញុំបានធ្វើតាមក្តីសុបិនរបស់ខ្ញុំក្នុងការរៀនទោះជាខ្ញុំស្ថិតនៅវ័យរាងជ្រេក៏ដោយ។ កាលពីឆ្នាំមុនខ្ញុំបានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់អន្តរជាតិពីសាកលវិទ្យាល័យ Libre Bruxelle និងមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំចំណាយពេល ២ ឆ្នាំរៀនថ្នាក់ពេលល្ងាចដើម្បីបញ្ចប់កម្មវិធី។ ខ្ញុំមានសំណាងណាស់ដោយមានកូនពីរនាក់ដែលកំពុងដើរតាមគន្លងនៃការអប់រំនិងគុណតម្លៃរបស់ពួកយើង។ កូនស្រីខ្ញុំ រូស្សេត បានបញ្ចប់ការសិក្សាផ្នែកទំនាក់ទំនងនៅសាកលវិទ្យាល័យ McGill កាលពីឆ្នាំទៅ ហើយកំពុងបន្តទៅបណ្ឌិតនីតិក្រមនៅសាកលវិទ្យាល័យស៊ីដនី។ កូនប្រុសរបស់ខ្ញុំឈ្មោះសមិទ្ធិនឹងបញ្ចប់ការសិក្សាពីវិទ្យាល័យនៅឆ្នាំនេះ។ គាត់ជាអ្នកនិពន្ធដ៏ឆ្នើមម្នាក់ ហើយនៅអាយុ ១២ឆ្នាំគាត់ចាប់ផ្តើមបោះពុម្ពផ្សាយរឿងប្រលោមលោកបែបវិទ្យាសាស្ត្រ។ គាត់ បានបោះពុម្ពនិងលក់សៀវភៅប្រលោមលោកចំនួនបួន។ អ្វីដែលជះឥទ្ធិពលលើខ្ញុំបំផុតនោះគឺថា គាត់បានបរិច្ចាគប្រាក់ខ្លះពីការលក់សៀវភៅរបស់គាត់ទៅមន្ទីរពេទ្យគន្ធបុប្ផា។ ក្នុងនាមជាម្តាយខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលឃើញកូនៗរបស់ពួកយើងធំឡើងដោយយកចិត្តទុកដាក់ចំពោះអ្នកដែលមានសំណាងតិចតួច។



ក្រៅពីការចិញ្ចឹមគ្រួសារ ខ្ញុំមានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការបើកក្រុមហ៊ុនច្បាប់ជាដៃគូ។ ជាការពិត ប្តីខ្ញុំនិងខ្ញុំបានចាប់ផ្តើមក្រុមហ៊ុន Sok Siphana & Associates កាលពីឆ្នាំ ២00៩ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនច្បាប់នេះបានរីកចម្រើនក្លាយជាក្រុមហ៊ុនច្បាប់ឈានមុខគេនៅក្នុងប្រទេស។ ក្រុមហ៊ុនច្បាប់របស់យើងដំណើរការអស់រយៈពេល ៧ ឆ្នាំមកហើយដែលជាផ្នែកមួយនៃ ZICO Law ដែលជាបណ្តាញក្រុមហ៊ុនច្បាប់នៅក្នុងប្រទេសអាស៊ានទាំង១០។ កាលពីឆ្នាំមុនយើងបានបើកសាខារបស់យើងនៅខេត្តសៀមរាបដើម្បីបំពេញតាមតម្រូវការរបស់អតិថិជននៅក្នុងផ្នែកបដិសណ្ឋារកិច្ច។ ភាគច្រើននៃបុគ្គលិករបស់យើងគឺស្ត្រីនិងវ័យក្មេង។ ខ្ញុំបានចំណាយពេលច្រើនគួរសមក្នុងការបង្វឹកនិងណែនាំពួកគាត់។ ខ្ញុំជឿជាក់លើការផ្តល់អំណាចដល់បុគ្គលិក ហើយខ្ញុំចូលចិត្តលើកទឹកចិត្តបុគ្គលិកនារីរបស់ខ្ញុំឱ្យជឿជាក់លើខ្លួនឯង។ ខ្ញុំបានថែរក្សាពួកគាត់ហើយបំផុសគំនិតឱ្យពួកគាត់ធ្វើការដោយប្រឹងប្រែងដើម្បីឱ្យពួកគាត់អាចក្លាយជាដៃគូ។ នៅក្នុងក្រុមហ៊ុនយើងមានក្រុមអនុវត្តន៍ផ្សេងៗដូចជាច្បាប់សាជីវកម្ម កម្មសិទ្ធិបញ្ញា ធនាគារជាដើមហើយខ្ញុំបានបង្វឹកបុគ្គលិកជាន់ខ្ពស់ជាច្រើននាក់ដើម្បីដឹកនាំក្រុមអនុវត្តន៍។

តាមទស្សនៈរបស់ខ្ញុំ យើងម្នាក់ៗគឺជាអ្នកដឹកនាំមិនថាយើងឈរនៅកន្លែងណាឬធ្វើអ្វីនោះទេ។ ខ្ញុំធំឡើងដោយជឿថាមេដឹកនាំម្នាក់គឺជាមនុស្សម្នាក់ដែលអាចធ្វើរឿងធំៗ បាន ប៉ុន្តែតាមពិតបន្ទាប់ពីឆ្លងកាត់ជីវិតជាច្រើនក្នុងនាមជាភរិយា ជាម្តាយ ជានិស្សិត និងដៃគូច្បាប់ ខ្ញុំដឹងថាអ្នកដឹកនាំគឺជាអ្នកដែលអាចមានឥទ្ធិពលលើមនុស្សម្នាក់ផ្សេងទៀត។ ក្នុងន័យនេះយើងគ្រប់គ្នាគឺជាមេដឹកនាំហើយរាល់រឿងតូចតាចដែលយើងអាចធ្វើបាន អាចមានឥទ្ធិពលយ៉ាងធំទៅលើជីវិតអ្នកដទៃ។ ក្នុងនាមជាមេដឹកនាំនៃគ្រួសារយើងអាចមានឥទ្ធិពលលើកូនៗរបស់យើងដើម្បីក្លាយជាកូនល្អនិងពលរដ្ឋល្អ។ យើងអាចបង្រៀនពួកគាត់នូវគុណតម្លៃល្អដើម្បីជួយដល់សហគមន៍និងជាតិរបស់យើង។ យើងត្រូវបង្រៀនពួកគាត់ពីតម្លៃនៃការផ្តល់ទៅសហគមន៍វិញ។

ទាក់ទងទៅនឹងសមិទ្ធផលផ្ទាល់ខ្លួនខ្ញុំមានមោទនភាពដែលត្រូវបានទទួលស្គាល់និងគោរពថាជាដៃគូរបស់ក្រុមហ៊ុនច្បាប់ក្នុងតំបន់។ ខ្ញុំក៏ត្រូវបានគេទទួលស្គាល់ថា ជាមេធាវីនាំមុខគេក្នុងផ្នែកកម្មសិទ្ធិបញ្ញាដោយ AsiaLaw ហើយខ្ញុំបានទទួលពានរង្វាន់ភាពជាអ្នកដឹកនាំដោយ CMO Asia កាលពីថ្មីៗនេះនៅទីក្រុង



បាងកក។ ទាក់ទងនឹងកាតព្វកិច្ចជាតិ ខ្ញុំមានកិត្តិយសខ្លាំងណាស់នៅពេលដែលខ្ញុំត្រូវបានស្នើឡើងដោយលោកជំទាវឃួន សូដារី អនុប្រធានទី ២ នៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឱ្យធ្វើជាទីប្រឹក្សារបស់លោកជំទាវ។ នៅក្នុងការិយាល័យច្បាប់របស់ខ្ញុំ បុគ្គលិករបស់ខ្ញុំតែងតែនិយាយមកខ្ញុំថាជា "មីង" ដែលជាសញ្ញានៃការគោរព។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី ?*

នៅពេលខ្ញុំចាប់ផ្តើមអាជីពជាមេធាវីខ្ញុំត្រូវប្រឈមនឹងបញ្ហាប្រឈមខាងក្នុងនិងខាងក្រៅ។ បញ្ហាប្រឈមខាងក្រៅមួយគឺជាការពិបាកក្នុងការទទួលបានឯកសារច្បាប់។ សម្រាប់ច្បាប់និងបទបញ្ជារបស់រដ្ឋាភិបាល (អនុក្រឹត្យ) គេមិនចាំបាច់បោះពុម្ពផ្សាយនៅក្នុងសារព័ត៌មានទេ ប៉ុន្តែសម្រាប់បទបញ្ញត្តិក្រសួង (ប្រកាស)។ វាពិតជាពិបាកនិងទាមទារឱ្យមានការតាមដានជាច្រើនជាមួយក្រសួងរដ្ឋាភិបាល។ មិនមានការបកប្រែជាភាសាអង់គ្លេសទេ ដូច្នេះយើងត្រូវបកប្រែវាឱ្យអតិថិជនរបស់យើង។ ក្រៅពីច្បាប់និងបទបញ្ជា ការវិនិច្ឆ័យរបស់តុលាការក៏មិនត្រូវបានគេបោះពុម្ពផ្សាយផងដែរ។ ជាលទ្ធផលយើងត្រូវធ្វើការស្រាវជ្រាវនិងត្រួតពិនិត្យទ្វេដងមុនពេលយើងចេញផ្សាយឬផ្តល់នូវយោបល់ផ្នែកច្បាប់ដល់អតិថិជនរបស់យើង។ បញ្ហាប្រឈមមួយទៀតគឺឧបសគ្គភាសា។ ភាសាអង់គ្លេសមិនមែនជាភាសាកំណើតរបស់ខ្ញុំទេ។

បញ្ហាប្រឈមផ្ទាល់ខ្លួនរបស់ខ្ញុំគឺខ្ញុំដែលមិនសូវមាត់កទេ។ ខ្ញុំមានការស្ទាក់ស្ទើរក្នុងការទាក់ទងជាមួយអ្នកដទៃ ជាពិសេសចំពោះមន្ត្រីរដ្ឋាភិបាល។ ខ្ញុំតែងតែមានអារម្មណ៍តានតឹងនៅពេលដែលខ្ញុំត្រូវបានគេស្នើសុំឱ្យកំណត់ការណាត់ជួបជាមួយពួកគាត់ទោះបីខ្ញុំស្គាល់ពួកគាត់ក៏ដោយ។ ខ្ញុំសារភាពថា នៅគ្រានោះខ្ញុំមិនសូវពូកែក្នុងការទាក់ទងជាមួយមនុស្សផ្សេងទៀតទេ ជាពិសេសនៅក្នុងការបង្កើតបណ្តាញ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

មេរៀនដ៏មានតម្លៃដែលខ្ញុំបានរៀនក្នុងនាមជាអ្នកដឹកនាំគឺត្រូវគិតគូរពីបរិស្ថានជុំវិញខ្ញុំហើយត្រូវមានផែនការក្នុងការដោះស្រាយបញ្ហា។ ការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់ជាមួយមនុស្សដែលខ្ញុំធ្វើការជាមួយជាពិសេសជាមួយអតិថិជនគឺសំខាន់ណាស់។ នៅក្នុងក្រុមហ៊ុនរបស់ខ្ញុំពេលប៉ុន្មានឆ្នាំកន្លងទៅខ្ញុំបានរៀនទទួលយកកំហុសពេលខ្ញុំធ្វើអ្វីខុស ក៏ដូចជាខ្ញុំបានរៀនផ្តល់គុណសម្បត្តិដល់សហសេវិកនិងបុគ្គលិករបស់ខ្ញុំ។ ខ្ញុំបានយល់ច្បាស់ថា ខ្ញុំមិនអាចធ្វើអ្វីមួយតែម្នាក់ឯងទេហើយខ្ញុំត្រូវការក្រុមមួយដើម្បីធ្វើការសម្រេចបាននូវគោលបំណងរបស់ក្រុមហ៊ុន។ ខ្ញុំត្រូវធ្វើឱ្យប្រាកដថាពួកគេទាំងអស់យល់ដូចគ្នាជាមួយខ្ញុំ ទាក់ទងនឹងចក្ខុវិស័យ និងបេសកកម្ម។ ខ្ញុំបានរៀនពិនិត្យយ៉ាងល្អិតល្អន់អំពីប្រតិបត្តិការផ្នែកច្បាប់ គ្រប់គ្រងថវិកាឱ្យល្អិតក៏ដូចជាតាមដាននិន្នាការទីផ្សារ។ ខ្ញុំបានដឹងថាការអប់រំបន្តសម្រាប់បុគ្គលិកគឺមានសារសំខាន់ណាស់ ជាពិសេសសម្រាប់ចំណេះដឹងតាមវិស័យជាក់លាក់។ ការលើកកម្ពស់ជំនាញទន់របស់បុគ្គលិកគឺជាកិច្ចការមួយទៀតដែលខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំង។ នៅពេលមានឱកាសកើតឡើងខ្ញុំមិនដែលភ្លេចបញ្ជូនបុគ្គលិកទៅបណ្តុះបណ្តាលនៅក្រៅប្រទេសឬជាអ្នកហាត់ការនៅទីស្នាក់ការកណ្តាលក្នុងតំបន់របស់យើង។

> “ខ្ញុំជឿថា គ្មាននរណាអាចឃាត់យើងមិនឱ្យរីកចម្រើនបាននោះទេ មានតែយើងខ្លួនឯងប៉ុណ្ណោះ !

នៅពេលធ្វើការជាមួយបុគ្គលិក ខ្ញុំមានការយល់ដឹងច្បាស់អំពីការរក្សាកិត្តិយស។ ខ្ញុំមិនបន្ទោសបុគ្គលិករបស់ខ្ញុំជាសាធារណៈទ តែខ្ញុំប្រាប់ពួកគេពីចំណុចដែលពួកគេអនុវត្តមិនបានល្អ។ ផ្ទុយទៅវិញ ខ្ញុំតែងតែសរសើរពួកគេជាសាធារណៈ។ ខ្ញុំផ្តល់អំណាចដល់ពួកគេដើម្បីធ្វើការសម្រេចចិត្តនិងជំរុញពួកគេឱ្យហ៊ានសាកល្បង។ មេរៀនមួយទៀតដែលខ្ញុំបានរៀនគឺរបៀបក្នុងការថែរក្សាបុគ្គលិកនិងមិត្តរួមការងារឱ្យបានត្រឹមត្រូវនិងត្រៀមលក្ខណៈដើម្បីផ្តល់ជំនួយនៅពេលត្រូវការ។ ក្នុងនាមជាមេដឹកនាំខ្ញុំត្រូវស្គាល់និងកំណត់បញ្ហានៅក្នុងក្រុមហ៊ុនដើម្បីស្វែងរកដំណោះស្រាយពេលខ្លះដោយខ្លួនឯងហើយពេលខ្ញុំមិនអាច ត្រូវទាក់ទងជាមួយអ្នកផ្សេង។ នៅកន្លែងធ្វើការយើងបានបង្កើតបរិយាកាសការងារបើកទូលាយនិងមិត្តភាព ហើយបុគ្គលិកត្រូវបានលើកទឹកចិត្តឱ្យគាំទ្រគ្នា។ ខ្ញុំជឿជាក់យ៉ាងខ្លាំងទៅលើការធ្វើសកម្មភាពកសាងក្រុម និងធ្វើការលំហែខួរក្បាលសម្រាប់បុគ្គលិក។ ដោយធ្វើការដោយផ្ទាល់ជាមួយពួកគេ ពួកគេបានស្គាល់ខ្ញុំថាជាមេដឹកនាំយុត្តិធម៌ដែលផ្តល់បានសុខភាពនិងសុខុមាលភាពដល់ពួកគេ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថាអ្នកដឹកនាំគឺជាមនុស្សម្នាក់ដែលមិនខ្លាចជួយបុគ្គលិកនិងមិត្តរួមការងារឱ្យធ្វើការល្អជាងខ្លួន។ ភាពជាអ្នកដឹកនាំមិនមែនអំពីការគ្រប់គ្រងបុគ្គលិកទេ។ វាគឺអំពីការណែនាំពួកគេ ផ្តល់អំណាចនិងផ្តល់ឱ្យពួកគេនូវកន្លែងនិងឱកាសដើម្បីធ្វើការងាររបស់ពួកគេឱ្យបានល្អប្រសើរ។

មេរៀនដ៏សំខាន់មួយទៀតគឺ ខ្ញុំមិនអាចផ្គាប់ចិត្តមនុស្សគ្រប់គ្នាបានទេ ហើយខ្ញុំដឹងថាខ្ញុំបានបរាជ័យច្រើនដងផងដែរ។ ខ្ញុំធ្លាប់ស្តីបន្ទោសខ្លួនឯងនៅពេលដែលខ្ញុំបរាជ័យលើរឿងអ្វីមួយប៉ុន្តែខ្ញុំបានរៀនសូត្រថាខ្ញុំជាមនុស្ស។ ខ្ញុំបានធ្វើលំហាត់ប្រាណនិងធ្វើសមាធិជាទៀងទាត់ ៣ ទៅ ៤ ដងក្នុងមួយសប្តាហ៍ហើយវាបានជួយខ្ញុំឱ្យដោះស្រាយបញ្ហាលំបាកទាំងនេះ។ ខ្ញុំបានរៀនទទួលយកកំហុសដែលខ្ញុំធ្វើហើយវិភាគអ្វីដែលខ្ញុំធ្វើបានល្អឬមូលហេតុដែលខ្ញុំធ្វើមិនបានល្អ។ ខ្ញុំបានដឹងថាភាពជោគជ័យមិនគួរជាទិសដៅនៃជីវិតទេ ហើយជីវិតមិនគួរមានតែការឈ្នះ ឬចាញ់នោះទេ។ អ្វីដែលសំខានគឺខ្ញុំត្រូវក្រោកឡើងក្រោយពេលខ្ញុំដួលហើយខ្ញុំដឹងថាក្នុងនាមជាមនុស្សខ្ញុំនឹងដួលម្តងហើយម្តងទៀតក្នុងជីវិត។ ខ្ញុំត្រូវរៀនពីកំហុសរបស់ខ្ញុំ។ ខ្ញុំបានរៀនយល់ពីអារម្មណ៍របស់អ្នកដទៃនិងការសង្កេត។ រហូតមកដល់ពេលនេះ ខ្ញុំអាចមានអារម្មណ៍ឬដឹងនៅពេលបុគ្គលិករបស់ខ្ញុំមិនសប្បាយចិត្ត។ មេដឹកនាំដែលទទួលបានជោគជ័យគឺមិនមែនជាការឆ្លាតវៃឬមានការអប់រំច្រើននោះទេ ប៉ុន្តែអំពីរបៀបដើម្បីព្យាបាលមនុស្សដោយការគោរពនិងដើម្បីជំរុញនិងផ្តល់ជំនួយដល់អ្នកដែលត្រូវការ។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

នៅក្នុងក្រុមហ៊ុនរបស់យើង យើងមានតម្លៃស្នូលដូចខាងក្រោម៖ ដឹកនាំ ទុកចិត្ត ទាក់ទង សុចរិតភាព ការច្នៃប្រតិដ្ឋ ត្រួសត្រាយ និងការថែទាំ។ នៅពេលយើងជ្រើសរើសមនុស្សយើងមិនផ្តោតតែលើបទពិសោធន៍វិជ្ជាជីវៈឬការអប់រំទេ ប៉ុន្តែថែមទាំងលើចរិតលក្ខណៈបុគ្គលឬអាកប្បកិរិយាផងដែរ។ យើងបានបែងចែកយ៉ាងច្បាស់រវាងកំហុសនិងជម្រើស។ ប្រសិនបើពួកគេមានកំហុស យើងអាចទទួលយកវាលើកទីមួយប៉ុន្តែប្រសិនបើពួកគេបន្តធ្វើកំហុសដដែលៗយើងនឹងមិនអត់ធ្មត់ចំពោះអាកប្បកិរិយាគ្មានវិជ្ជាជីវៈឬការ

ធ្វេសប្រហែសឡើយ។ ទីផ្សាររបស់យើងតូចពេកណាស់ក្នុងការធ្វើឱ្យខ្លួនឯងបាត់បង់កេរ្តិ៍ឈ្មោះ។ សុចរិតភាពគឺតម្លៃខ្ពស់បំផុតនៅក្នុងតម្លៃស្នូលរបស់យើង។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

កប្បកិរិយាដែលអាចមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំគឺភាពក្រអឺតក្រទម គំនិតចង្អៀតចង្អល់ បក្សពួកនិយម ការច្រណែន និងការប្រកាន់ចរិត "អ្វីក៏ដឹង"។

ក្នុងនាមជាមេដឹកនាំខ្ញុំជឿថាយើងគួរស្វែករកការគោរពពីមិត្តរួមការងារនិងបុគ្គលិកជាជាងការបង្ខំឱ្យគេគោរព។ ចរិកលក្ខណៈសំខាន់នៃអ្នកដឹកនាំល្អគឺជាអ្នកដែលមានចក្ខុវិស័យ ជាគំរូនិងមានភាពឱនលំទោន និងយុត្តិធម៌។ ភាពយុត្តិធម៌មានសារសំខាន់ក្នុងបរិយាកាសការងារដែលមានការប្រកួតប្រជែងនៅពេលមេដឹកនាំត្រូវតែរៀនផ្តល់ឱកាសស្មើៗគ្នាសម្រាប់ការអភិវឌ្ឍដល់អ្នកដទៃ។

ខ្ញុំរំឭកថាកាលខ្ញុំនៅក្មេងខ្ញុំបានដាក់ពាក្យសុំអាហារូបករណ៍ទៅសិក្សានៅបរទេសពីរឬបីឆ្នាំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ នៅពេលនោះយើងមិនមានឱកាសជ្រើសរើសកន្លែងដែលយើងចង់ទៅឬអ្វីដែលយើងចង់រៀនទេ។ នៅអាយុនោះខ្ញុំគិតថាការមានបក្សពួកនិយមគឺអាចទទួលយកបានហើយល្អទៀតផង។ ដូច្នេះខ្ញុំបានសុំឱ្យបងប្រុសរបស់ខ្ញុំជួយខ្ញុំឱ្យទៅប្រទេសដ៏ល្អមួយដូចជាអាល្លឺម៉ង់។ ផ្ទុយទៅវិញខ្ញុំត្រូវបានបញ្ជូនទៅសិក្សានៅប្រទេសរុស្ស៊ី។ ខ្ញុំបានសុំគាត់បន្ថែមទៀតឱ្យខ្ញុំបានចូលរៀនកម្មវិធីថ្នាក់បរិញ្ញាបត្រល្អហើយខ្ញុំបានបញ្ចប់ការសិក្សាដើម្បីក្លាយជាមេកានិចម៉ាស៊ីនកាត់ដេរ។



នៅពេលខ្ញុំត្រលប់មកវិញ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្មដែលមានមុខតំណែងទំនេរពីរ៖ មួយនៅការិយាល័យនាំចេញនិងនាំចូល និងមួយទៀតនៅការិយាល័យស្រាវជ្រាវតម្លៃទំនិញ។ ខ្ញុំមានការរំពឹងទុកខ្ពស់ដែលបងប្រុសរបស់ខ្ញុំអាចជួយខ្ញុំឱ្យទទួលបានតំណែងនៅក្រុមហ៊ុននាំចេញ/នាំចូលព្រោះខ្ញុំអាចទទួលបានប្រយោជន៍ច្រើនប៉ុន្តែជាអកុសលខ្ញុំត្រូវបានបញ្ជូនទៅការិយាល័យស្រាវជ្រាវតម្លៃទំនិញ។ ខ្ញុំខឹងបងប្រុសខ្ញុំដែលមិនចង់លើកម្រាមដៃរបស់គាត់ដើម្បីជួយខ្ញុំ។ ខ្ញុំឈឺចិត្តណាស់ ហើយវាពិតជាលំបាកណាស់ក្នុងការទទួលយករឿងនេះ។ ក្រោយមកនៅពេលសេដ្ឋកិច្ចប្រទេសបានចាប់ផ្តើមបើកចំហខ្ញុំបានសម្រេចចិត្តចូលរួមជាមួយវិស័យឯកជន។ នៅទីនោះខ្ញុំបានប្រកួតប្រជែងខ្លួនឯងហើយខ្ញុំនៅតែបន្តរៀន។ ជួនកាលខ្ញុំមើលទៅក្រោយហើយខ្ញុំត្រូវតែសារភាពថាខ្ញុំអរគុណដល់បងប្រុសរបស់ខ្ញុំដែលបានធ្វើដូច្នេះចំពោះខ្ញុំ។ មេរៀនពីបទពិសោធន៍របស់ខ្ញុំផ្ទាល់បានបង្រៀនខ្ញុំពីរបៀបរឹងមាំនិងឱ្យតម្លៃឱកាសស្មើភាព។ ក្រោយមកទៀតបងប្រុសរបស់ខ្ញុំនិយាយថា បើគាត់បានលើកម្រាមដៃរបស់គាត់ដើម្បីជួយខ្ញុំឱ្យទទួលនូវអ្វីដែលខ្ញុំចង់បាននោះទង្វើរបស់គាត់នឹងត្រូវបានគេមើលឃើញថាជាការយកបក្សពួកគ្រួសារហើយវានឹងប៉ះពាល់ដល់អារម្មណ៍របស់អ្នកដទៃ។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ដើម្បីធ្វើជាអ្នកដឹកនាំយើងមិនគួរឈប់រៀនទេ ដោយសារយើងរស់នៅក្នុងសង្គមដែលពឹងលើចំណេះដឹងហើយត្រូវការការគិតប្រកបដោយការច្នៃប្រតិដ្ឋជានិច្ច ដើម្បីដោះស្រាយបញ្ហាបច្ចេកវិទ្យាដែលកំពុងលេចឡើងនិងការផ្លាស់ប្តូរផ្សេងៗ។ ការផ្លាស់ប្តូរនៅទីនេះមានន័យថា ការផ្លាស់ប្តូរនៅក្នុងវិធីនៃការដឹកនាំ និងការធ្វើការ។ ខ្ញុំជឿថាគ្មាននរណាម្នាក់អាចបញ្ឈប់អ្នកមិនឱ្យរៀនឬលូតលាស់បានទេ មានតែអ្នកខ្លួនឯង។ ក្រៅពីនេះយើងត្រូវមានឆន្ទៈលើកកម្ពស់ជំនាញទន់របស់យើងមិនថាមានជំនាញទំនាក់ទំនងឬមានទំនាក់ទំនងគ្នារវាងបុគ្គល។ អ្នកដឹកនាំដែលទទួលបានជោគជ័យគឺជាអ្នកដែលបង្កើតទំនាក់ទំនងល្អជាមួយមនុស្សនៅជុំវិញគាត់។ ជាការពិតណាស់ខ្ញុំដឹងថាយើងត្រូវចាប់យកបច្ចេកវិទ្យា ប៉ុន្តែ បញ្ញាសិប្បនិម្មិត មិនអាចជំនួសសភាវគតិនិងអន្តរកម្មមនុស្សបានទេ។

ព័ត៌មានគន្លឹះរបស់ខ្ញុំសម្រាប់ស្ត្រីក្នុងអាជីវកម្មគឺត្រូវដឹងពីនិន្នាការទីផ្សារដែលប៉ះពាល់ដល់អាជីវកម្មរបស់ពួកគេហើយពួកគេគួរតែចូលរួមក្នុងបណ្តាញជំនួញនានាទាំងនៅក្នុងប្រទេសឬខាង ក្រៅប្រទេស។ ពួកគេគួរបើកភ្នែកនិងត្រចៀករបស់គេចំហសម្រាប់ឱកាសអាជីវកម្មថ្មី និងរៀនធ្វើអ្វីខុសប្លែកពីអ្នកដទៃ។ ពួកគេគួរតែសកម្មនិងត្រៀមលក្ខណៈដើម្បីចាប់យកឱកាសនៅពេលវាកើតឡើង។ លើសពីនេះទៅទៀត ពួកគេគួរហ៊ានដើរចេញពីកន្លែងដែលមានផាសុកភាពរបស់ពួកគេហើយបង្កើតទំនុកចិត្តលើខ្លួនឯង។ តាមបទពិសោធន៍របស់ខ្ញុំ ស្ត្រីកម្ពុជាភាគច្រើនខ្វះទំនុកចិត្តនិងមិនសូវហ៊ានដាក់បញ្ហា។ ពួកគេត្រូវផ្លាស់ប្តូរផ្នត់គំនិតនេះ។ ពួកគេត្រូវគិតពីខ្លួនឯងជាមុនសិននិងចេះស្រឡាញ់ខ្លួនឯង។ ពួកគេគួរតែយកឈ្នះលើការភ័យខ្លាចចំពោះការវិនិច្ឆ័យនិងការរិះគន់ពីសង្គមនិងហ៊ានសាកល្បងធ្វើ។ ដរាបណាពួកគេជឿថាសកម្មភាពរបស់ពួកគេនឹងមិនធ្វើឱ្យអ្នកដទៃមានគ្រោះថ្នាក់ នោះពួកគេគួរតែធ្វើវា។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ខ្ញុំបានប្រថុយដោយយល់ស្របជាមួយស្វាមីរបស់ខ្ញុំនៅពេលគាត់សម្រេចចិត្តត្រលប់មកប្រទេសកម្ពុជាវិញពីប្រទេសស្វីស។ នៅពេលនោះគាត់មានអាជីពល្អនិងការងារដែលទទួលបានប្រាក់ខែខ្ពស់ ដោយធ្វើការឱ្យអង្គការសហប្រជាជាតិនិងអង្គការពាណិជ្ជកម្មពិភពលោក។ នោះគឺជាហានិភ័យធំបំផុតរបស់ខ្ញុំ។ នៅពេលដែលខ្ញុំត្រលប់មកប្រទេសកម្ពុជាវិញខ្ញុំគ្មានការងារធ្វើទេហើយខ្ញុំភ័យខ្លាចព្រោះខ្ញុំជាស្ត្រីមេផ្ទះរយៈពេលជិតបួនឆ្នាំនៅទីក្រុងហ្សឺណែវ។ ខ្ញុំមានកូនពីរនាក់ទៅសាលារៀនឯកជនអន្តរជាតិ។ ប្តីរបស់ខ្ញុំមិនចង់ធ្វើការឱ្យនរណាម្នាក់ទេដូច្នេះហើយយើងបានសម្រេចចិត្តដំណើរការក្រុមហ៊ុនច្បាប់របស់យើងគឺ Sok Siphana &Associates ឡើងវិញ។ យើងបានចាប់ផ្តើមនៅក្នុងបន្ទប់នៃផ្ទះផ្ទាល់របស់យើងជាមួយយើងតែពីរនាក់ហើយឥឡូវនេះយើងមានមនុស្សប្រហែល ៣៨នាក់និងបានផ្លាស់ប្តូរចេញពីផ្ទះរបស់យើងទៅអគារដ៏ស្រស់ស្អាតនៅលើមហាវិថីធំមួយក្នុងទីក្រុង។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

តួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារគឺជាអ្វីដែលធ្វើឱ្យវប្បធម៌ខ្មែរមានលក្ខណៈប្លែកពីគេ។ ខ្ញុំអាចនិយាយបានថាជាទូទៅស្ត្រីកម្ពុជាដើរតួយ៉ាងសំខាន់ក្នុងនាមជាមេដឹកនាំពីធម្មជាតិដោយសារតែតួនាទីប្រពៃណីរបស់ពួកគេនៅក្នុងគ្រួសារ ប៉ុន្តែជាទូទៅដោយសារវប្បធម៌ ពួកគេមិនអាចនិងមិនចង់ទទួលយកទេ។ ជំនាញមួយដែលស្ត្រីមានគឺជំនាញស្តាប់។ ស្ត្រីកម្ពុជាក៏មានស្មារតីនៃភាពជាសហគ្រិនផងដែរ។ កំណើនដ៏ធំធេងដែលកម្ពុជាបានទទួលក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះគឺដោយសារតែភាពជាសហគ្រិនក្នុងតំបន់និងភាពបើកទូលាយនៃសេដ្ឋកិច្ច។ នៅដើមទសវត្សរ៍ឆ្នាំ ២០០០ នៅពេលដែលប្តីរបស់ខ្ញុំជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ហើយគាត់បានដឹកនាំការចរចាដើម្បីឱ្យកម្ពុជាចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកខ្ញុំបានឃើញនៅការពិភាក្សាជាច្រើនអំពីភាពបើកចំហនៃកម្ពុជាទាំងក្នុងគោលនយោបាយសេដ្ឋកិច្ចនិងវិស័យឯកជន។ ឥឡូវនេះយើងស្ថិតនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន សហគ្រិនកម្ពុជាអាចទទួលបាននូវបច្ចេកវិទ្យាទីផ្សារ ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងជំនាញបច្ចេកទេស។ លើសពីនេះទៅទៀត ប្រជាជនកម្ពុជាវ័យក្មេងដែលមានភាពរឹងមាំក៏អាចប្រកួតប្រជែងជាមួយនឹងអ្នកដទៃនៅក្នុងតំបន់ផងដែរ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ដំបូន្មានរបស់ខ្ញុំចំពោះសហគ្រិនស្ត្រីវ័យក្មេងគឺត្រូវដឹងពីតម្លៃរបស់ខ្លួនឯងរួមទាំងអ្វីដែលជាភាពខ្លាំងរបស់ពួកគេ និងអ្វីដែលជាចំណុចខ្សោយរបស់ពួកគេ។ ទន្ទឹមនឹងនេះ គេត្រូវធ្វើការវាយតម្លៃដោយខ្លួនឯងលើអ្វីដែលគេគួរពង្រឹង។ ដូចដែលខ្ញុំបានលើកឡើងពីមុន ពួកគេគួរតែមានឱកាសរកស៊ីថ្មីនិងល្អប្រសើរជាងមុន ហើយពួកគេមិនគួរភ័យខ្លាចក្នុងការចាប់ឱកាសនោះទេ។ ពួកគេគួរតែទាក់ទងអ្នកជំនាញដើម្បីទទួលបានដំបូន្មាននៅពេលពួកគេកំពុងប្រឈមនឹងបញ្ហា មិនថាពួកគេជាអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ឬហិរញ្ញវត្ថុក៏ដោយ។ ដំបូន្មានវិជ្ជាជីវៈជាទូទៅមិនមានតម្លៃថោកទេ ប៉ុន្តែសេវានេះគឺសមនិងតម្លៃ។ ពួកគេគួរតែចាប់យកបច្ចេកវិទ្យានិងស្វ័យប្រវត្តិកម្ម។ នោះគឺជាអនាគតដែលពួកគេមិនអាចចៀសវាងបាន។ ពួកគេគួរតែបង្កើតទម្លាប់ស្រឡាញ់ការអប់រំនិងបន្តរៀនសូត្រ។ ពួកគេគួរតែអានសៀវភៅអាជីវកម្មមួយក្បាលក្នុងមួយខែប្រសិនបើពួកគេអាចឬយ៉ាងហោចណាស់អានព័ត៌មានអាជីវកម្មប្រចាំថ្ងៃ។

ពួកគេមិនគួរភ័យខ្លាចក្នុងការនិយាយប្រសិនបើពួកគេជឿថាពួកគេត្រូវ។ ខ្ញុំចង់ឃើញស្ត្រីកម្ពុជាវ័យក្មេងទាំងអស់អាចនិយាយថា "ចាស! ខ្ញុំអាចធ្វើបាន" នៅថ្នាក់មូលដ្ឋាន តំបន់និងអន្តរជាតិ។ WK

អ្នកដឹកនាំ
ស្ត្រីនៅកម្ពុជា

# លោកស្រី ហ៊ុន បូរមី

## នាយិកាប្រចាំប្រទេស | អង្គការអាក់សិន អេតកម្ពុជា



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះ ហ៊ុន បូរមី ហើយបច្ចុប្បន្នខ្ញុំជានាយិកាប្រចាំប្រទេសរបស់អង្គការ ActionAid Cambodia។ ខ្ញុំកើតនៅខេត្តបាត់ដំបង។ ឪពុកម្តាយខ្ញុំបានផ្លាស់ទីលំនៅមករាជធានីភ្នំពេញនៅពេលខ្ញុំមានអាយុ ៣ ឆ្នាំដោយសង្ឃឹមថាខ្ញុំនិងបងប្អូនបង្កើតរបស់ខ្ញុំនឹងទទួលបានការអប់រំខ្លះ។ ខ្ញុំមានបងប្អូនស្រី២នាក់និងបងប្អូនប្រុស៤នាក់។ ខ្ញុំជាកូនទីពីរ ហើយបានរៀបការរួចនិងមានកូនប្រុសម្នាក់។ នៅពេលខ្ញុំគិតអំពីការអប់រំរបស់ខ្ញុំ ខ្ញុំតែងតែគិតពិចារណាពីពេលវេលារបស់ខ្ញុំកាលនៅសាលាបឋមសិក្សាទួលគោកដែលខ្ញុំសប្បាយរីករាយនឹងការចូលរៀនដំបូងមុនពេលខ្ញុំបន្តទៅសិក្សានៅវិទ្យាល័យឥន្ទ្រទេវីដើម្បីរៀនថ្នាក់អនុវិទ្យាល័យនិងវិទ្យាល័យ។ ខ្ញុំមានមោទនភាពក្នុងការបញ្ចប់ការសិក្សាពីវិទ្យាស្ថានភាសាបរទេសនៅឆ្នាំ២០០១។ នៅឆ្នាំ ២០០៥ ខ្ញុំបានបញ្ចប់សញ្ញាបត្រអនុបណ្ឌិតផ្នែកកិច្ចការអន្តរជាតិនៅសាកលវិទ្យាល័យ Ohio សហរដ្ឋអាមេរិក។ ក្នុងឆ្នាំ ២០១២ ខ្ញុំបានទទួលពានរង្វាន់ពីកម្មវិធី Endeavour របស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីធ្វើការជាមួយគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលីនៅទីក្រុងស៊ីដនីអស់រយៈពេល៣ ខែ។

នៅឆ្នាំ២០១៦ ខ្ញុំបានក្លាយជានាយិកាប្រចាំប្រទេសរបស់អង្គការ ActionAid Cambodia ដែលធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលដែរ។ ខ្ញុំមិនដែលគិតពីការទទួលបានតួនាទីដ៏ខ្ពស់និងលំបាកបែបនេះទេ។ វាពិតជាដំណើរផ្សងព្រេងមួយ។ មុខតំណែងជាន់ខ្ពស់មានការទទួលខុសត្រូវជាច្រើន ប៉ុន្តែខ្ញុំមានសំណាងដែលមានក្រុមការងារដ៏រឹងមាំនិងប្តេជ្ញាចិត្តយ៉ាងមុតមាំហើយមានបច្ចេកទេសគ្រប់គ្រាន់និងការស្រឡាញ់លើចក្ខុវិស័យបេសកកម្ម និងគោលដៅរបស់អង្គការ។ ទំនុកចិត្តនិងការគាំទ្ររបស់ពួកគាត់នៅលើខ្ញុំបានជួយខ្ញុំឱ្យបំពេញតួនាទីខ្ញុំបាន។ រឿងមួយដែលខ្ញុំមានមោទនភាពបំផុតគឺអាចចូលរួមចំណែកគាំទ្រការតស៊ូរបស់សមាជិកសហគមន៍ ជាពិសេសស្ត្រីនិងកុមារហើយឃើញពួកគាត់ព្យាយាមយកឈ្នះភាពអយុត្តិធម៌ដើម្បីនាំមកនូវការផ្លាស់ប្តូរវិជ្ជមាននៅក្នុងជីវិតរបស់ពួកគាត់និងសហគមន៍ទាំងមូល។ មនុស្សដែលខ្ញុំធ្វើការជាមួយតែងលើកទឹកចិត្តខ្ញុំជានិច្ច។ ខ្ញុំក៏ត្រូវថ្លែងអំណរគុណដល់ក្រុមគ្រួសាររបស់ខ្ញុំ ជាពិសេសម្តាយរបស់ខ្ញុំដែលបានបន្តបង្ហាត់បង្រៀន និងគាំទ្រខ្ញុំទាំងពេលសុខសប្បាយ និងក្នុងពេលមានទុក្ខទាំងអស់ដែលខ្ញុំបានជួបប្រទះពេញមួយជីវិត។




*ជនចំណាកស្រុកជាស្ត្រីងាយនឹងរងការរំលោភបំពានផ្លូវភេទនៅកម្ពុជា។ រូបថត: Supplied*

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

ខ្ញុំគិតថា ខ្ញុំត្រូវតែបង្ហាញថា ខ្ញុំជាអ្នកដឹកនាំដែលគិតគូរ មិនអាត្មានិយមនិងចេះអាណិតអាសូរ។ ខ្ញុំធ្វើការសម្រេចចិត្តជាច្រើនដងជារៀងរាល់ថ្ងៃ ហើយខ្ញុំត្រូវបន្តសួរខ្លួនឯងថាតើការសម្រេចចិត្តរបស់ខ្ញុំគឺជាអ្វីដែលត្រឹមត្រូវឬទេ? តើខ្ញុំធ្វើវាតាមវិធីត្រឹមត្រូវដែរឬទេ? តើវាសម្រាប់គោលបំណងត្រឹមត្រូវទេ? សំខាន់បំផុតតើខ្ញុំប្រើអំណាចរបស់ខ្ញុំដោយត្រឹមត្រូវឬទេ?

បញ្ហាប្រឈមផ្សេងទៀតរបស់ខ្ញុំគឺ តម្រូវឱ្យខ្ញុំខិតខំប្រឹងប្រែងជានិច្ចដើម្បីនិយាយនិងបញ្ជាក់ពីខ្លួនឯងហើយបង្ហាញថាខ្ញុំអាចធ្វើជាអ្នកដឹកនាំអង្គការក្រៅរដ្ឋាភិបាលមួយបានដោយមិនគិតពីភេទ អាយុ និងពូជសាសន៍ខ្ញុំ។ វាជាបញ្ហាប្រឈមមួយដែលត្រូវយកចិត្តទុកដាក់ជានិច្ច។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

“ស្រឡាញ់ខ្លួនឯង។ ការស្រឡាញ់ខ្លួនឯងគឺមិនមែនអាត្មានិយមទេ។ ប្រសិនបើអ្នកមិនអាចថែរក្សាខ្លួនអ្នកបាន អ្នកនឹងមិនអាចថែរក្សាអ្នកដទៃបានទេ។ ការស្រឡាញ់ខ្លួនឯងគឺជាសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។ នៅពេលអ្នកថែទាំខ្លួនអ្នក អ្នកក្លាយជាអ្នកដឹកនាំដែលមានសុខភាពល្អ។ មេដឹកនាំដែលមានសុខភាពល្អអាចបង្កើតក្រុមដែលមានសុខភាពល្អ។ ក្រុមដែលមានសុខភាពល្អបង្កើតអង្គការដែលមានសុខភាពល្អ។ អង្គការដែលមានសុខភាពល្អប្រាកដជានឹងទទួលជោគជ័យក្នុងការបំពេញបេសកកម្មរបស់ខ្លួន។” ការនិយាយស្រួលជាងការធ្វើ។ ខ្ញុំក៏កំពុងរៀនជារៀងរាល់ថ្ងៃដែរ។

“

## ឧបសគ្គកន្លងមកបានបង្កើតជាបទពិសោធន៍ និងទំនុកចិត្តដល់ខ្ញុំដែលនាំឱ្យខ្ញុំបានមកដល់ទីនេះ

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់អ្នកយ៉ាងដូចម្ដេច ?*

ដោយធ្វើការជាមួយ ActionAid ខ្ញុំគោរពចំពោះតម្លៃនិងគោលការណ៍របស់អង្គការយ៉ាងជ្រាលជ្រៅ។ តម្លៃនោះរួមមាន ការបន្ទាបខ្លួន ការគោរពគ្នាទៅវិញទៅមក សមភាពនិងយុត្តិធម៌ និងសេចក្ដីក្លាហាន។

ការចេះបន្ទាបខ្លួនគួរបង្ហាញពីអាកប្បកិរិយារបស់យើង ហើយដើម្បីទទួលស្គាល់ថាយើងជាផ្នែកមួយនៃសម្ព័ន្ធភាពធំមួយក្នុងការប្រឆាំងនឹងភាពក្រីក្រនិងភាពអយុត្តិធម៌សង្គម។ យើងមិនទាមទារគុណសម្បត្តិតែម្យ៉ាងទេ។ ការគោរពគ្នាទៅវិញទៅមកតម្រូវឱ្យយើងទទួលស្គាល់តម្លៃមនុស្សគ្រប់គ្នា។ ជាពិសេសយើងប្ដេជ្ញាបម្រើដល់មនុស្សដែលរស់នៅក្នុងភាពក្រីក្រ និងការបំបិទសិទ្ធិ ហើយយើងត្រូវតែផ្ដល់តម្លៃដល់ភាពខុសគ្នា។ សមធម៌ និងយុត្តិធម៌តម្រូវឱ្យយើងធ្វើការដើម្បីធានាឱ្យបាននូវឱកាសស្មើគ្នាសម្រាប់មនុស្សគ្រប់រូបដោយមិនគិតពីពូជសាសន៍ អាយុ ភេទ យេនឌ័រ ទំនោរផ្លូវភេទ ស្ថានភាពផ្ទុកមេរោគអេដស៍ ជនជាតិ ពិការភាព ទីតាំង និងសាសនា។ ភាពក្លាហានទាមទារឱ្យយើងប្រកាន់យកជំហរច្បាស់លាស់ ចេះច្នៃប្រតិដ្ឋនិងបង្កើតថ្មីដោយគ្មានការភ័យខ្លាចឬបរាជ័យក្នុងការស្វែងរកឥទ្ធិពលខ្លាំងបំផុត។

តម្លៃទាំងនេះត្រូវបានបង្កប់ក្នុងការរចនាកម្មវិធីប្រតិបត្តិការប្រចាំថ្ងៃនិងនីតិវិធី និងគោលនយោបាយរបស់យើង។ ជាមួយនឹងសមាជិកក្រុមការងារជាន់ខ្ពស់ផ្សេងទៀត យើងព្យាយាមដឹកនាំដោយធ្វើជាគំរូដើម្បីអនុវត្តនូវទ្រឹស្ដីរបស់យើង។ ការសម្រេចចិត្តដែលយើងធ្វើ ចាំបាច់ត្រូវឆ្លុះបញ្ចាំងពីតម្លៃទាំងនេះ មិនថាក្នុងជីវិតផ្ទាល់ខ្លួននិងក្នុងជីវិតការងាររបស់យើងទេ។



*ស្ត្រីចូលរួមក្នុងកម្មវិធីសម្ពោធតិកាសញ្ញាដើម្បីបញ្ឈប់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងប្រទេសកម្ពុជានៅថ្ងៃអាទិត្យនារាជធានីភ្នំពេញ. រូបថត: (Leng Len/The Cambodia Daily)*

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

ខ្ញុំទើបតែអានសៀវភៅដ៏ល្អមួយ។ អ្នកនិពន្ធបានរំឭកខ្ញុំថា អំនួតគឺជាសត្រូវនៃការដឹកនាំល្អ។ យើងទទួលបានអំណាចកាន់តែច្រើននៅពេលយើងឡើងតំណែងកាន់តែខ្ពស់នៅក្នុងអង្គការ។ ដូច្នេះប្រសិនបើយើងមិនបានដើរថយក្រោយមួយជំហាន ហើយពិចារណាទេ អំនួតរបស់យើងអាចយកឈ្នះយើងនៅពេលដែលយើងមិនបានរៀនពីកំហុសរបស់យើងដែលនាំយើងឱ្យធ្វើការសម្រេចចិត្តដែលមានគ្រោះថ្នាក់ចំពោះខ្លួនយើង ក្រុមការងារនិងអង្គការទាំងមូល។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្ដល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ខ្ញុំព្យាយាមថែរក្សាស្មារតីផ្លូវចិត្តខ្ញុំឱ្យបានល្អ។ ការថែទាំខ្លួនឯងគឺមានសារសំខាន់ខ្លាំងណាស់ហើយជាអ្វីដែលខ្ញុំត្រូវធ្វើឱ្យបានច្រើនទៀត។ ការថែទាំខ្លួនឯងគឺ ជាគុណសម្បត្តិចម្បងមួយដែលមេដឹកនាំត្រូវតែមាន។
ដើម្បីលើកកម្ពស់ការផ្ដល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សូចនាករជោគជ័យមិនគួរគ្រាន់តែនិយាយអំពីចំនួនប្រាក់ដែលស្ត្រីរកបានទេ។ វាមិនគ្រប់គ្រាន់ទេ។ វាក៏គួរតែបញ្ចូលគុណភាពនៃជីវិតដែលស្ត្រីមាន។ នៅក្នុងបទពិសោធន៍របស់យើងដែលធ្វើការជាមួយស្ត្រីមកពីក្រុមផ្សេងៗគ្នា យើងបានឃើញពួកគាត់ឈរនៅជួរមុខក្នុងការទាមទារសិទ្ធិរបស់ពួកគាត់ការពារដីធ្លី និងធនធានធម្មជាតិរបស់សហគមន៍ពួកគាត់ ប៉ុន្តែពួកគាត់ត្រូវការការស្រឡាញ់និងថែរក្សាខ្លួនឯងផងដែរ។ ខ្ញុំសង្ឃឹមថា ខ្ញុំអាចធ្វើការបានបន្ថែមទៀត ដើម្បីគាំទ្រដល់ស្ត្រីដែលយើងធ្វើការជាមួយដើម្បីគាត់ចាប់យកគុណភាពស្មារតីទាំងនេះ។ ប៉ុន្តែខ្ញុំត្រូវចាប់ផ្ដើមជាមួយខ្លួនឯងសិន!

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ហានិភ័យមួយគឺការជ្រើសរើសធ្វើការនៅក្នុងវិស័យអភិវឌ្ឍន៍បន្ទាប់ពីខ្ញុំបានបញ្ចប់ថ្នាក់អនុបណ្ឌិតរបស់ខ្ញុំ។ ជំនួសឱ្យការជ្រើសរើសវិស័យមួយផ្សេងទៀត ខ្ញុំបានជ្រើសរើសយកវិស័យនេះ ដោយធ្វើការជាមួយមនុស្សក្រីក្រ និងអ្នកដែលត្រូវបានគេបំបិទសិទ្ធិព្រោះខ្ញុំជឿលើវិធីសាស្ត្រដែលផ្អែកលើសិទ្ធិមនុស្ស។ វាបានបង្ហាញលទ្ធផលយ៉ាងល្អ ទោះបីជាការពិតដែលថាខ្ញុំមិនអាចផ្លាស់ប្ដូរពិភពលោកដូចដែលខ្ញុំបានគិតនៅពេលខ្ញុំជានិស្សិតទើបបញ្ចប់ការសិក្សា។ ខ្ញុំគិតថាខ្ញុំបានទទួលចំណេះដឹង ការស្គាល់ខ្លួនឯងច្រើនតាមរយៈការងារនេះ។ ទោះបីខ្ញុំត្រូវរៀនសូត្រច្រើនទៀតក៏ដោយ ខ្ញុំមានអំណរគុណចំពោះអ្វីដែលខ្ញុំទទួលបានតាមរយៈជម្រើសដែលខ្ញុំបានធ្វើនៅពេលនោះ។

ហានិភ័យមួយទៀតដែលខ្ញុំបានធ្វើគឺ កាលពីឆ្នាំ ២០១១ នៅពេលខ្ញុំសម្រេចចិត្តផ្លាស់ប្ដូរការងាររបស់ខ្ញុំ ពីអ្នកគ្រប់គ្រង ការស្វែងរកប្រាក់មូលនិធិមកជាអ្នកគ្រប់គ្រង និងដឹកនាំផ្នែកកម្មវិធី។ ខ្ញុំមិនដឹងច្បាស់អំពីការផ្លាស់ប្ដូរនោះទេ។ ខ្ញុំមិនមានទំនុកចិត្តលើខ្លួនឯងទេហើយខ្ញុំមានការប្រុងប្រយ័ត្នខ្លាំងណាស់អំពីរបៀបដែលអ្នកដទៃមើលមកខ្ញុំ។ ទោះបីជាខ្ញុំខ្វះបទពិសោធន៍ហើយបាត់បង់ទំនុកចិត្តលើខ្លួនឯងក៏ដោយ ខ្ញុំបានទទួលយកតួនាទីនោះហើយវាបានក្លាយជារឿងល្អ។ នៅពេលខ្ញុំត្រលប់មើលក្រោយ ខ្ញុំគិតថាខ្ញុំបានធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ។ បញ្ហាប្រឈមទាំងនេះបានបង្កើតបទពិសោធន៍ និងទំនុកចិត្តរបស់ខ្ញុំដែលបាននាំខ្ញុំទៅកន្លែងដែលខ្ញុំឈរសព្វថ្ងៃនេះ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្ដេច ?*

សហគ្រិនកម្ពុជាពិតជាខិតខំផ្សព្វផ្សាយផលិតផល និងអត្តសញ្ញាណជាតិរបស់ពួកគាត់ណាស់។ ខ្ញុំគិតថាការខិតខំប្រឹងប្រែងយ៉ាងខ្លាំងនេះគឺជាកត្តាមួយដែលធ្វើឱ្យសហគ្រិនភាពលូតលាស់ខ្លាំងក្នុងប្រទេសនេះ។ ពួកគាត់មិនត្រឹមតែសម្លឹងរកប្រាក់ចំណេញប៉ុណ្ណោះទេប៉ុន្តែថែមទាំងបង្កើតអ្វីដែលអាចធ្វើឱ្យជាតិមានមោទនភាពនិងដោះស្រាយបញ្ហាសង្គមក្នុងពេលតែមួយ។ អ្នកខ្លះថែមទាំងគិតពីវិធីដែលពួកគាត់អាចចូលរួមក្នុងការដោះស្រាយបញ្ហាយេនឌ័រនិងរក្សាការផ្ដល់សិទ្ធិអំណាចដល់ស្ត្រីក្នុងបេះដូងនៃមុខជំនួញរបស់ពួកគាត់ទៀតផង។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

“ភាពជោគជ័យនៃអាជីវកម្មរបស់អ្នកមិនគួរត្រឹមតែគិតពីប្រាក់ចំណេញរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែគិតថាផលចំណេញដែលអ្នករកបាននោះ ធំ ឬតូចក្ដី បានរួមចំណែកដល់សង្គមមួយដែលយុត្តិធម៌និងស្មើភាពសម្រាប់មនុស្សគ្រប់រូប ជាពិសេសសម្រាប់ស្ត្រីនិងកុមារ។” WK

# លោកជំទាវ គឹមរ៉េត កំរង

## រដ្ឋលេខាធិការ | ក្រសួងពាណិជ្ជកម្ម



អ្នកដឹកនាំ ស្រ្តីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត?*

ខ្ញុំរៀបការហើយមានកូន ៣ នាក់។ ពួកគេមានអាយុ ១៤ឆ្នាំ ១១ឆ្នាំនិង ៨ ឆ្នាំ។ ប្តីរបស់ខ្ញុំគឺជាគ្រូពេទ្យនិងជាមន្ត្រីរដ្ឋបាលផ្នែកសុខភាពដែលកំពុងធ្វើការនៅក្នុងវិស័យឯកជនមួយ។ ទាក់ទងនឹងការអប់រំខ្ញុំបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៩៦។ ដោយមានការគាំទ្រពីកម្មវិធីអាហារូបករណ៍ Fulbright របស់សហរដ្ឋអាម៉េរិក ខ្ញុំបានទៅបន្តការសិក្សារបស់ខ្ញុំ ផ្នែកសុខភាពសាធារណៈនៅសាកលវិទ្យាល័យ Oklahoma (University of Oklahoma School of Public Health) នៅសហរដ្ឋអាម៉េរិក និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសុខភាពសាធារណៈនៅឆ្នាំ២០០៤។ មុននោះដែរ ខ្ញុំក៏បានបញ្ចប់កម្មវិធីបណ្តុះបណ្តាលរយៈពេលមួយឆ្នាំនៅប្រទេសអូស្ត្រាលីក្នុងឆ្នាំ២០០០ ដោយទទួលសញ្ញាបត្រផ្នែកគ្រប់គ្រងធនធានមនុស្ស។ លើសពីនេះទៀត ខ្ញុំបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវគ្គខ្លីៗជាច្រើនស្តីអំពីភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងវគ្គបណ្តុះបណ្តាលជាច្រើនផ្សេងទៀត។ វគ្គបណ្តុះបណ្តាលថ្មីបំផុតរបស់ខ្ញុំគឺផ្នែករដ្ឋបាលសាធារណៈនៅសាលាភូមិន្ទរដ្ឋបាលឆ្នាំ២០១៦។

សរុបមក ខ្ញុំអាចនិយាយបានថា កម្មវិធីអប់រំ និងកម្មវិធីហ្វឹកហ្វឺនបណ្តុះបណ្តាលទាំងអស់របស់ខ្ញុំមានតម្លៃណាស់សម្រាប់ខ្ញុំ ក្នុងការឆ្ពោះទៅមុខ ក្នុងអាជីព និងជីវិតរបស់ខ្ញុំ។ ខ្ញុំមានមោទនភាពខ្លាំងណាស់ដែលក្នុងនាមជាស្ត្រីម្នាក់ ខ្ញុំត្រូវបានផ្តល់ឱកាសដើម្បីរៀនសូត្រនិងអនុវត្តចំណេះដឹងនិងជំនាញរបស់ខ្ញុំដើម្បីបម្រើប្រទេសនិងរួមចំណែកឱ្យអស់ពីសមត្ថភាពដើម្បីអភិវឌ្ឍប្រទេសជាតិរបស់ខ្ញុំ។

*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ?*




បញ្ហាប្រឈមទីមួយនិងសំខាន់បំផុតសម្រាប់ខ្ញុំគឺ ការបង្វែរចំណេះដឹងរបស់ខ្ញុំទៅជាការអនុវត្តការងារជាក់ស្តែង។ វិធីសាស្ត្រ និងរបៀបដើម្បីសម្របខ្លួនរបស់ខ្ញុំពីបរិយាកាសក្នុងសាលាទៅនឹងភាពស្មុគស្មាញនៃបរិយាកាសការងារប្រចាំថ្ងៃគឺជាការសាកល្បងដ៏ធំមួយសម្រាប់ខ្ញុំ។ ពេលខ្លះខ្ញុំមានអារម្មណ៍ថាសូម្បីតែការស្វែងរកដំណោះស្រាយដ៏សាមញ្ញមួយចំពោះបញ្ហាធម្មតាមួយក៏ពិបាកដែរក្នុងបរិបទនៃភាពមិនច្បាស់លាស់។ នៅក្នុងដំណើរជីវិត ខ្ញុំគិតថាជំហានដំបូងមានភាពលំបាកជាងជំហានបន្ទាប់។ ការព្យាយាមស្វែងយល់ពីតម្រូវការនិងបំពេញការរំពឹងទុករបស់មនុស្សគឺតែងតែជាការលំបាក ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វាក៏បានផ្តល់មេរៀនល្អៗនិងធ្វើឱ្យខ្ញុំកាន់តែមានភាពចាស់ទុំក្នុងការទាក់ទងជាមួយមនុស្សនៅមជ្ឈដ្ឋានខុសៗគ្នា។ វាក៏ជួយឱ្យខ្ញុំធ្វើការកាន់តែមានប្រសិទ្ធភាព។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

ខ្ញុំគិតថាក្នុងនាមជាអ្នកដឹកនាំយើងត្រូវមានឆន្ទៈនិងចិត្តរឹងមាំក្នុងការដឹកនាំមនុស្សដើម្បីលើកទឹកចិត្តឱ្យក្រុមរបស់អ្នកអនុវត្តគោលនយោបាយឬភារកិច្ចណាមួយឱ្យសម្រេចបាននូវគោលដៅរួម។

មេរៀនទី ២ សម្រាប់ខ្ញុំគឺភាពត្រឹមត្រូវមិនលម្អៀង។ គុណភាពនៃអ្នកដឹកនាំនឹងនាំមកនូវសាមគ្គីភាព និងបង្កើតភាពសុខដុមនៅកន្លែងធ្វើការ។ មនុស្សនឹងស្វែងរកអ្នក ហើយធ្វើតាមអ្នកនៅពេលអ្នកបាន ធ្វើឱ្យគេទុកចិត្តលើការវិនិច្ឆ័យដោយយុត្តិធម៌របស់អ្នក។

ចំណុចទីបី អ្នកដឹកនាំត្រូវការមានបេះដូងដ៏ធំមួយៈ មានការគោរព យកចិត្តទុកដាក់និងចេះគិតគូរ។ អ្នកដឹកនាំត្រូវ ប្រព្រឹត្តចំពោះមនុស្សដោយសេចក្តីថ្លៃថ្នូរដោយមិនគិតពីភាពខុសគ្នាទេ។ ការមានមេត្តាធម៌ និងការយល់ដឹងពីតម្រូវការរបស់មនុស្ស គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់មេដឹកនាំដើម្បីទទួលបានការពេញចិត្តពីអ្នកដទៃ។ ការធ្វើការជាមួយមនុស្សនិងការចំណាយពេលវេលាក៏ដូចជាការខិតខំប្រឹងប្រែងដើម្បីជួយពួកគេដោយការយល់ចិត្តគឺជាមូលដ្ឋាននៃការជឿទុកចិត្តនិងទំនាក់ទំនងយូរអង្វែង និងការគោរពគ្នាទៅវិញទៅមក។

*តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើលោកជំទាវធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច?*

ខ្ញុំអាចនិយាយបានថា តម្លៃស្នូលរបស់ខ្ញុំមានដូចជាភាពស្មោះស្ម័គ្រ ស្មោះត្រង់និងមានការអត់ធ្មត់។ ខ្ញុំជឿថាការស្មោះស្ម័គ្រនឹងបុព្វហេតុណាមួយ ការប្តេជ្ញាចិត្តណាមួយ និងកាតព្វកិច្ចណាមួយជាគុណសម្បត្តិដ៏អស្ចារ្យមួយ។ ភាពស្មោះត្រង់ចំពោះខ្ញុំមានន័យថាស្គាល់ខ្លួនឯង និយាយហើយធ្វើ ធ្វើសកម្មភាព ឬប្រតិកម្មដោយពិតប្រាកដចំពោះរាល់អ្វីដែលកើតឡើងនៅជុំវិញខ្លួន។ អ្វីដែលសំខាន់ជាងនេះទៀតគឺ ដើម្បីសម្រេចបាននូវអ្វីមួយក្នុងជីវិត យើងត្រូវតែខិតខំមិនរួញរានូវអ្វីដែលយើងធ្វើទាំងរឿងបុគ្គលឬវិជ្ជាជីវៈ។ បើគ្មានការប្តេជ្ញាចិត្ត គ្មានវិន័យនិងការខិតខំ ខ្ញុំគិតថាយើងមិនអាចទទួលជោគជ័យក្នុងជីវិតបានទេ។

ការធ្វើឱ្យមនុស្សសម្របតាមតម្លៃរបស់យើង មិនមែនជាកិច្ចការងាយស្រួលនោះទេ ដោយសារតែមនុស្សមានប្រវត្តិ ទស្សនៈនិងការរំពឹងទុកខុសគ្នា។ ទោះជាយ៉ាងណាក៏ដោយតាមរយៈការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់ គេអាចរៀនអ្វីមួយពីអ្នកនៅពេលពួកគេឃើញថាអ្នកជាគំរូនិងមើលឃើញថាអ្នក ពោរពេញទៅដោយផលិតភាព។ នោះហើយជាហេតុផលសម្រាប់ពួកយើងដែលជាអ្នកដឹកនាំក្នុងការដឹកនាំឧទាហរណ៍ បើនិយាយគឺត្រូវតែធ្វើ។ ការធ្វើបែបនេះតែមួយគត់ដែលអ្នកអាចរកបានការគោរពជឿទុកចិត្តពីអ្នកដទៃនិងទទួលបានការគាំទ្រ ពីតម្លៃរបស់អ្នក។

“

# ស្ត្រីត្រូវចេះរៀនចំណេះនិងជំនាញ ចេះដាក់គោលដៅ និងឆ្ពោះទៅមុខដោយក្លាហាន



*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

ខ្ញុំជឿជាក់ថាភាពអាត្មានិយម ការខ្វះភាពជឿជាក់លើខ្លួនឯងនិងការខ្វះភាពក្លាហានប្រហែលជាមិនមានប្រយោជន៍ចំពោះមេដឹកនាំណាម្នាក់ទេ។ ខ្ញុំមានអារម្មណ៍ថាមនុស្សមិនចង់ដើរតាមអ្នកដឹកនាំដែលតែងតែគិតអំពីខ្លួនគាត់ផ្ទាល់ដោយមិនខ្វល់ពីអ្នកដទៃហើយមិនច្បាស់អំពីចក្ខុវិស័យឬទិសដៅរបស់គាត់ ក៏ដូចជាអ្នកដែលមិនមានភាពក្លាហានដើម្បីប្រឈមមុខនឹងការពិតនិងទទួលយកទំនួលខុសត្រូវ។

*តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

ភាពជាអ្នកដឹកនាំសម្រាប់ខ្ញុំគឺដូចជាសិល្បៈ ជាជំនាញដែលអាចរៀនអនុវត្ត ពង្រឹងនិងស្ទាត់ជំនាញក្នុងរយៈពេលណាមួយ។ វាជាដំណើរនៃការរៀនដែលមិនចេះចប់។ ប្រសិនបើយើងនៅស្ងៀម យើងប្រាកដជាបាត់បង់អ្វីដែលយើងបានទទួលហើយយើងនឹងក្លាយទៅជាហួសសម័យហើយលែងមានប្រយោជន៍នៅក្នុងពិភពលោកដែលកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ! ដូច្នេះការរៀនសូត្រនិងការរីកចម្រើនឥតឈប់ឈរគឺមានសារសំខាន់ដើម្បីឱ្យមានផលិតភាពកាន់តែមានប្រសិទ្ធភាពក្នុងគ្រប់ការងារ។ ខ្ញុំចាត់ទុកកាលៈទេសៈទាំងអស់ជាឱកាសក្នុងការរៀនសូត្រសម្រាប់ខ្ញុំដើម្បីជំរុញឱ្យខ្ញុំកាន់តែពូកែទាំងផ្នែកបុគ្គលនិងវិជ្ជាជីវៈ។

អរគុណដល់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ស្ត្រីត្រូវបានផ្តល់ឱកាសឱ្យចូលរួមគ្រប់កម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងវិស័យសាធារណៈនិងឯកជន។ ស្ត្រីជាច្រើនបានកាន់តំណែងជាមេដឹកនាំនៅក្នុងជួររដ្ឋាភិបាល។ ខ្ញុំចាត់ទុកតួនាទី និងការទទួលខុសត្រូវរបស់ខ្ញុំមានសារសំខាន់ណាស់ ហើយប្រើឱ្យអស់សមត្ថភាពរបស់ខ្ញុំដើម្បីបម្រើប្រទេសនិងប្រជាជនរបស់ខ្ញុំ។

ឧទាហរណ៍ វិស័យពាណិជ្ជកម្ម ខ្ញុំគិតថាការលើកកម្ពស់ពាណិជ្ជកម្ម និងការធ្វើពិពិធកម្មទីផ្សារនិងមូលដ្ឋានផលិតកម្មសម្រាប់ការនាំចេញ គឺជាធាតុផ្សំដ៏សំខាន់បំផុតក្នុងការរក្សាកំណើនសេដ្ឋកិច្ចពីព្រោះប្រទេសកម្ពុជាជាប្រទេសដែលរីកចម្រើនដោយការនាំចេញ។ យើងត្រូវធ្វើការរួមគ្នាដើម្បីធ្វើឱ្យវាកើតឡើង។ លើសពីនេះទៀត ដោយសារស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចយើងត្រូវបន្តលើកទឹកចិត្តដល់ស្ត្រីដទៃទៀតឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍជាតិកសាងភាពជាសហគ្រិន និងពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រីតាមរយៈការបញ្ជ្រាបសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការបង្កើតគោលនយោបាយជាតិ និងការអនុវត្ត។ ដើម្បីគាំទ្រដល់ស្ត្រីយើងត្រូវយល់ដឹងអំពីឧបសគ្គចំពោះកំណើនសេដ្ឋកិច្ចរបស់ស្ត្រី ដោយស្តាប់នូវអ្វីដែលពួកគេត្រូវការតាមរយៈការភ្ជាប់បណ្តាញជាមួយក្រុមស្ត្រីជាសហគ្រិន និងការខិតខំប្រឹងប្រែងរបស់ខ្ញុំក្នុងនាមជាស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំដើម្បីនាំឱ្យមានការផ្លាស់ប្តូរបន្ថែមទៀតនៅក្នុងជីវិតរបស់ស្ត្រី។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា?*

ខ្ញុំគិតថាការផ្លាស់ប្តូរពីការងារមួយទៅការងារមួយជារឿងប្រថុយប្រថាន។ ខ្ញុំតែងតែមានអារម្មណ៍ច្របូកច្របល់ហើយត្រូវការភាពក្លាហានជាច្រើន។ វាក៏បានកើតឡើងផងដែរនៅពេលដែលខ្ញុំដកខ្លួនចេញពីការងាររបស់ខ្ញុំនិងបន្តការសិក្សាថ្នាក់ឧត្តមរបស់ខ្ញុំនៅបរទេស។ ខ្ញុំអាចនិយាយបានថាវាជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ខ្ញុំ។ ខ្ញុំអាចបាត់បង់តំណែងឬប្រឈមមុខនឹងភាពមិនច្បាស់លាស់ពេលត្រលប់មកវិញ។ ជាសំណាងល្អវាបានក្លាយជាលទ្ធផលយ៉ាងល្អសម្រាប់ខ្ញុំ។ ខ្ញុំបានដឹងថាការប្រថុយប្រថានធ្វើឱ្យខ្ញុំកាន់តែឈ្លាសវៃខ្លាំងហើយជួយខ្ញុំធ្វើការកាន់តែមានប្រសិទ្ធភាព។

ឥឡូវនេះខ្ញុំកាន់តែមានទំនុកចិត្តលើអ្វីដែលខ្ញុំកំពុងធ្វើនៅក្នុងការងាររបស់ខ្ញុំហើយខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាណិជ្ជកម្មដែលបានបង្ហាញការជឿទុកចិត្តលើខ្ញុំនិងបានផ្តល់ការងារថ្មីដល់ខ្ញុំនិងឱកាសដើម្បីប្រើប្រាស់នូវសក្តានុពលពេញលេញរបស់ខ្ញុំ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

ខ្ញុំគិតថាវប្បធម៌កម្ពុជាមានការស្វាគមន៍ បើកចំហ រាក់ទាក់ទទួលយកនិងគាំទ្រការច្នៃប្រតិដ្ឋ ការអភិវឌ្ឍ និងការរីកចម្រើន។ លើសពីនេះទៅទៀតប្រទេសកម្ពុជាបានក្លាយទៅជាកោះនៃសន្តិភាព និងជាគោលដៅទេសចរណ៍ដ៏ល្បីល្បាញមួយ។ ក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី កម្ពុជាបានរក្សាកំណើនសេដ្ឋកិច្ចបាន ៧%ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ។ លើសពីនេះរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនថាជាម៉ាស៊ីននៃកំណើន ហើយបានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនដើម្បីគាំទ្រដល់វិស័យឯកជនផងដែរ។

លក្ខខណ្ឌអំណោយផលទាំងនោះអាចធ្វើឱ្យសហគ្រិនភាពមានភាពរីកចម្រើន។ ខណៈពេលដែលគំនិតថ្មីឬការច្នៃប្រតិដ្ឋថ្មីអាចត្រូវបានសាកល្បង ផលិតផលថ្មីត្រូវបានបង្កើតនិងប្រព័ន្ធចែកចាយថ្មីត្រូវបានបង្កើតឡើងហើយនៅទីបំផុតនៅពេលដែលគំរូទាំងនោះត្រូវបានគេបង្ហាញថាដំណើរការបាននៅទីផ្សារនោះ ការពង្រីកនិងការរីកចម្រើននឹងកើតមានឡើង។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យអ្វីៗទាំងអស់នេះកើតមាន ចាំបាច់ណាស់វិស័យសាធារណៈ និងវិស័យឯកជនគួរតែធ្វើការជាមួយគ្នាជាធ្លុងមួយ។ ហើយអាជីវកម្មចាំបាច់ត្រូវយល់ពីតម្រូវការរបស់ទីផ្សារក្នុង និងក្រៅប្រទេស ហើយត្រូវមានសមត្ថភាពបង្វិលធនធានដើម្បីឆ្លើយតបទៅនឹងទីផ្សារឱ្យបានត្រឹមត្រូវ។ យ៉ាងណាមិញ សហគ្រិន និងអ្នកដឹកនាំអាជីវកម្មគួរតែមានទស្សនៈ ទិសដៅនិងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីដឹកនាំសកម្មភាពប្រចាំថ្ងៃរបស់ពួកគេឆ្ពោះទៅរកភាពជោគជ័យ។

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

តាមគំនិតរបស់ខ្ញុំ ស្ត្រីកម្ពុជាមានសំណាងដែលបានកើតក្នុងវប្បធម៌មួយដែលផ្តល់តម្លៃដល់ស្ត្រី។ មិនដូចនៅជំនាន់ចាស់ទេ នៅពេលស្ត្រីមិនត្រូវបានលើកទឹកចិត្តឱ្យសិក្សា និងធ្វើការនៅឆ្ងាយពីផ្ទះរបស់ពួកគេ ស្ត្រីឥឡូវនេះមានសេរីភាពកាន់តែច្រើននិងទទួលបានការអប់រំល្អ ការងារជំនាញនិងពិភពដែលយើងបង្កើតខ្លួនឯង។ មានឱកាសជាច្រើនសម្រាប់ស្ត្រីក្នុងជំនាន់ក្មេងៗ ក្នុងការរៀន ដុះខាត់ និងរីកចម្រើនជាងពេលមុនៗ។ ខ្ញុំគិតថាអ្វីដែលយុវនារីឬសហគ្រិនវ័យក្មេងត្រូវធ្វើគឺ ការបំពាក់ខ្លួនពួកគេជាមួយចំណេះដឹងនិងជំនាញកំណត់គោលដៅរបស់ពួកគេហើយឈានទៅមុខ ហើយធ្វើដោយភាពក្លាហាន! យើងត្រូវបំបែកបទដ្ឋានអវិជ្ជមានពីមុនដែលរារាំងយើងមិនឱ្យធ្វើសកម្មភាពនិងច្នៃប្រតិដ្ឋក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ យើងត្រូវពង្រឹងខ្លួនយើងឱ្យក្លាយជាអ្នកដឹកនាំ! យើងចេះបង្កើត យើងមានការច្នៃប្រតិដ្ឋ ហើយយើងមានភាពរឹងមាំនិងមានសមត្ថភាពធ្វើនិងតាមរកក្តីសុបិនរបស់យើងផ្ទាល់។ សូមយើងធ្វើវា ហើយបន្តធ្វើរហូតដល់យើងទទួលជោគជ័យ! WK

# ឧកញ៉ា កែវ មុំ

## ស្ថាបនិក និងប្រធាន | ក្រុមហ៊ុនផលិតនំស្រួយ លីលី



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំកើតនៅឆ្នាំ ១៩៧៥ និងបានបញ្ចប់ថ្នាក់វិទ្យាល័យហើយចាប់ផ្តើមជួយឪពុកម្តាយរបស់ខ្ញុំពេលខ្ញុំមានអាយុ ១៥ ឆ្នាំ។ ពេលនោះម្តាយរបស់ខ្ញុំឈឺ បន្ទាប់មកខ្ញុំត្រូវមើលថែអាជីវកម្មគ្រួសារ។ ខ្ញុំជាកូនទី ៣ ក្នុងចំណោមបងប្អូន ៧នាក់។ នៅពេលនោះបងស្រីរបស់ខ្ញុំបានរៀបការ ហើយបានផ្លាស់ទីលំនៅទៅប្រទេសកាណាដាហើយបងប្រុសរបស់ខ្ញុំបានទៅប្រទេសថៃ។ ដូច្នេះខ្ញុំគឺជាអ្នកដែលបានកាន់កាប់មុខជំនួញ។

ខ្ញុំបានរៀបការនៅឆ្នាំ១៩៩៣ ហើយបានសម្រាលកូនប្រុសរបស់ខ្ញុំនៅឆ្នាំ១៩៩៤ ហើយនៅឆ្នាំ ១៩៩៦ កូនស្រីរបស់ខ្ញុំបានចាប់កំណើត។ នៅឆ្នាំ ១៩៩៧ ខ្ញុំក៏កើតបានកូនប្រុសម្នាក់ទៀត។ បន្ទាប់ពីកំណើតកូនប្រុសដំបូងរបស់ខ្ញុំ ខ្ញុំបានទៅធ្វើការឱ្យម្ចាស់អាជីវកម្មជនជាតិសិង្ហបុរី(នាំចូលនំ បារី ភេសជ្ជៈនិងគ្រឿងទេសផ្សេងទៀត)។ ខ្ញុំបានធ្វើជាគណនេយ្យករ បន្ទាប់មកជាអ្នកកាន់កាប់ស្តុកហើយក្រោយមកជាអ្នកលក់ ព្រោះខ្ញុំពូកែលក់ដូរ។

នៅពេលនោះខ្ញុំមានគំនិតចង់ចាប់ផ្តើមអាជីវកម្មដោយខ្លួនឯងដែលខ្ញុំអាចផលិតនំស្រួយនិងជួយសន្សំថ្លៃសេវាដឹកជញ្ជូន ផ្តល់ការងារដល់ប្រជាជនរបស់ខ្ញុំនិងផ្តល់ឱ្យកុមារនូវអាហារមានសុវត្ថិភាព។ ដូច្នេះខ្ញុំបានសម្រេចចិត្តផលិតនំស្រួយខ្លួនឯង ហើយបានចាប់ផ្តើមស្វែងរកអ្នកវិនិយោគប៉ុន្តែខ្ញុំមិនបានជោគជ័យក្នុងការស្វែងរកអ្នកវិនិយោគម្នាក់សោះ។ ខ្ញុំក៏បានស្វែងរកម៉ាស៊ីនផលិតជាច្រើនឆ្នាំផងដែរ។

មុនពេលចាប់ផ្តើមក្រុមហ៊ុនអាហារលីលីខ្ញុំបាននាំចូលផលិតផលជាច្រើនពីប្រទេសជិតខាងប៉ុន្តែអាជីវកម្មមិនល្អសោះ។ ខ្ញុំបានបើកអាជីវកម្មមួយផ្សេងទៀត




> **ត្រូវហ៊ានប្រថុយពេលយើងបានគិតសព្វជ្រុងជ្រោយ ហើយហ៊ានទទួលខុសត្រូវលើអ្វីដែលកើតឡើង**

ដោយលក់ក្រណាត់ជជុះប៉ុន្តែវាក៏បរាជ័យដែរ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងឆ្នាំ ២០០២ ខ្ញុំបានចាប់ផ្តើមអាជីវកម្មរបស់ខ្ញុំគឺ លីលី ដោយមិនមានចំណេះដឹងខាងអាជីវកម្មច្រើនសោះ។ ខ្ញុំបានលក់ផ្ទះរបស់ខ្ញុំក្នុងតម្លៃ ៧0.000 ដុល្លារអាម៉េរិកដើម្បីទិញម៉ាស៊ីនហើយខ្ញុំបានប្រឈមនឹងបញ្ហាជាច្រើនដូចជាធនធានមនុស្សនិងសង្វាក់ផលិតកម្មរួមទាំងការភ្លក់រសជាតិអាហារ។ អាជីវកម្មរបស់ខ្ញុំបានចាប់ផ្តើមរីកចម្រើននៅពេលខ្ញុំបង្កើតការទុកចិត្តក្នុងចំណោមប្រជាជនតាមរយៈការលើកទឹកចិត្តឱ្យអ្នកលក់រាយលក់ផលិតផលក្នុងស្រុកដូចជារបស់ខ្ញុំ។

នៅឆ្នាំ២០០៥ ខ្ញុំបានទទួលការគាំទ្រជាច្រើនពីក្រសួងឧស្សាហកម្ម និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនដូចជា JICA, APO, UNIDO, JODC។ ទីបំផុតខ្ញុំអាចធ្វើពាណិជ្ជកម្មបានដោយសារតែខ្ញុំមានទំនុកចិត្តនិងភាពអត់ធ្មត់។ នៅពេលនោះ ខ្ញុំអន្ទះអន្ទែងចង់រៀននិងស្រូបយកចំណេះដឹងថ្មីៗពីអ្នកដទៃ។

ខ្ញុំមានមោទនភាពណាស់ដោយសារតែក្រុមហ៊ុនរបស់ខ្ញុំត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលនិងទីផ្សារនៅបរទេស។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

- ចំណេះដឹងអំពីការធ្វើអាជីវកម្ម
- ហិរញ្ញវត្ថុ
- បទពិសោធន៍នៃភាពជាអ្នកដឹកនាំ
- សង្វាក់ផលិតកម្ម
- មានទីផ្សារ
- ទំនុកចិត្តពីអតិថិជនអំពីផលិតផលក្នុងស្រុក

ខ្ញុំបានដោះស្រាយបញ្ហាដោយធ្វើការជិតស្និទ្ធជាមួយក្រុមរបស់ខ្ញុំ។ ខ្ញុំតែងតែគិតនិងប្រើខួរក្បាលរបស់ខ្ញុំគ្រប់ពេលវេលា។ ចំណុចសំខាន់គឺត្រូវមានគំនិតច្រើន ហើយគិតទៅមុខជានិច្ច។ ខ្ញុំចាប់ផ្តើមជឿថា មិនមានអ្វីនៅលើផែនដីដែលខ្ញុំមិនអាចធ្វើបានទេ។ ទីបំផុតខ្ញុំបានដឹងថាខ្ញុំអាចទទួលបានជោគជ័យដូចអ្នកដទៃដែរ។ ពេលខ្លះខ្ញុំគិតថាឥឡូវនេះមានអ្វីដែលខ្ញុំមិនអាចធ្វើបាននៅថ្ងៃនេះប៉ុន្តែថ្ងៃណាមួយខ្ញុំអាចធ្វើបាន!

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

- យល់អំពីមនុស្សនៅពេលខ្ញុំដឹកនាំពួកគេ
- បានរៀនសូត្រពីបញ្ហាដែលយើងជួបប្រទះនៅពេលអាជីវកម្មរីកចម្រើន ហើយនៅពេលមានបញ្ហាកើតឡើងផងដែរ។ នៅពេលខ្ញុំជួបប្រទះឧបសគ្គខ្ញុំ អាចដោះស្រាយបញ្ហាទាំងនោះតាមរយៈការស្តាប់និងរកឫសគល់បញ្ហា។

- ខ្ញុំបានប្រើចំណេះដឹងរបស់ខ្ញុំដែលខ្ញុំទទួលបានពីការសិក្សាពីប្រទេសដទៃ។
- យល់ពីផ្នត់គំនិតរបស់មនុស្សនិងសម្រេចចិត្តដោយស្មារតីស្ងប់ស្ងាត់ដោយផ្អែកលើប្រភពនៃបញ្ហា។
- ខ្ញុំមានតុល្យភាពក្នុងជីវិតគ្រួសារខ្ញុំនិងអាជីវកម្មព្រោះឪពុកម្ដាយខ្ញុំនិងឪពុកម្ដាយក្មេកខ្ញុំជួយមើលថែកូនរបស់ខ្ញុំ។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់អ្នកយ៉ាងដូចម្ដេច ?*

- ធ្វើជាមនុស្សដែលមានហេតុផលនិងមានទំនុកចិត្តលើខ្លួនឯង
- ការគិត ចក្ខុវិស័យរយៈពេលវែងអំពីគុណសម្បត្តិនិងគុណវិបត្តិនៃទិសដៅដែលយើងបានកំណត់
- ខ្ញុំជាបុគ្គលដែលចូលចិត្តចាប់យកហានិភ័យ និងទទួលខុសត្រូវចំពោះអ្វីដែលកើតឡើង។ ខ្ញុំហ៊ានលក់ផ្ទះរបស់ខ្ញុំដើម្បីបើកអាជីវកម្មរបស់ខ្ញុំ ខណៈដែលអ្នកដទៃគិតថាវាមិនមែនជារឿងត្រឹមត្រូវទេ ព្រោះខ្ញុំមិនមានចំណេះដឹងនិងបទពិសោធន៍ក្នុងអាជីវកម្មនេះសោះ។
- ខ្ញុំគ្មានវិប្បដិសារៈចំពោះអ្វីដែលខ្ញុំសម្រេចចិត្តធ្វើទេ។ គ្មាននរណាម្នាក់អាចផ្លាស់ប្ដូរការសម្រេចចិត្តរបស់ខ្ញុំបានទេ ព្រោះខ្ញុំត្រូវទទួលខុសត្រូវចំពោះអ្វីដែលកើតឡើងចំពោះខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំកំពុងធ្វើអ្វីដែលត្រឹមត្រូវ។ ខ្ញុំមិនប្រើលុយរបស់ខ្ញុំដើម្បីលេងល្បែងស៊ីសងទេ។ ខ្ញុំប្រើលុយដើម្បីបង្កើតលុយបន្ថែម។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

- ភាពមិនប្រាកដប្រជានៃទិសដៅ
- មិនគោរពការសន្យាជាមួយនឹងអ្នកដើរតាម
- មានមោទនភាពនិងអួតអាងជ្រុលលើសមិទ្ធផលរបស់ពួកគេ
- មិនគោរពមតិរបស់អ្នកដទៃ
- មើលងាយអ្នកដទៃពេលពួកគេក្លាយជាអ្នកដឹកនាំ
- មើលងាយលើការងារនិងអត្ថប្រយោជន៍នៃការងារ
- ក្នុងនាមជាអ្នកដឹកនាំដ៏ល្អម្នាក់យើងត្រូវតែធ្វើឱ្យមនុស្សគោរពយើងកុំធ្វើឱ្យពួកគេខ្លាចយើង

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្ដល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

- ធ្វើឱ្យមនុស្សគោរព

# ខ្ញុំហ៊ានលក់ផ្ទះខ្ញុំដើម្បីចាប់ផ្ដើមជំនួញរបស់ខ្ញុំ




- អត់ធ្មត់
- ផ្ដល់តម្លៃខ្លួនរបស់អ្នកបន្ទាប់មកអ្នកដទៃនឹងផ្ដល់តម្លៃដល់អ្នក
- មានទំនុកចិត្តនិងជំនឿលើខ្លួនអ្នក
- ដឹងថាអ្វីដែលអ្នកធ្វើនឹងមិនជះផលវិបាកដល់អ្នកដទៃទេ
- ជួយខ្លួនឯងសិន បន្ទាប់មកអ្នកដទៃនឹងជួយអ្នក
- កុំខ្វល់ខ្វាយច្រើនអំពីការរិះគន់ពីព្រោះគ្មាននរណាម្នាក់ស្គាល់អ្នកច្រើនជាងអ្នកទេ។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

- ចាប់យកហានិភ័យដោយលក់ផ្ទះរបស់ខ្ញុំ
- ចេះលក់ផលិតផលនៅពេលដែលជំពាក់បំណុលហើយមិនយល់ដឹងច្រើនលើជំនាញលក់។
- អគ្គិភ័យមួយចំនួនបានកើតឡើងនៅក្នុងរោងចក្ររបស់ខ្ញុំកាលពីឆ្នាំ២០០៨ប៉ុន្តែខ្ញុំបានគ្រប់គ្រងស្ថានភាពដោយសុំឱ្យគេជួយ។ ក្នុងនាមជាស្ត្រីម្នាក់ ខ្ញុំមានស្មារតីរឹងមាំហើយដែលអាចគ្រប់គ្រងភាពភ័យស្លន់ស្លោនិងគ្រប់គ្រងឧប្បត្តិហេតុហើយជាសំណាងល្អ គ្មាននរណាម្នាក់រងរបួស។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្ដេច ?*

- វប្បធម៌នៃការចែករំលែកបទពិសោធន៍អាជីវកម្ម។ វាអាចជួយម្ចាស់អាជីវកម្មថ្មីដើម្បីដោះស្រាយបញ្ហាប្រឈមនឹងអាជីវកម្ម។ វារួមចំណែកដល់កំណើនសេដ្ឋកិច្ច។
- ការគាំទ្រពីរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាដែលប្រឈមដោយសហគ្រាសខ្នាតតូចនិងមធ្យមដូចជាការលើកទឹកចិត្តពន្ធវេទិការវាងវិស័យឯកជន និង រដ្ឋាភិបាលដែលជាកន្លែងដែលសហគ្រាសធុនតូចនិងមធ្យមអាចលើកពីបញ្ហាហើយស្នើសុំជំនួយពីរដ្ឋាភិបាល។ កិច្ចប្រជុំត្រូវបានធ្វើឡើងពីរដងក្នុងមួយឆ្នាំ។
- យើងកើតមកពីដែនដីមហាស្ចារ្យរបស់បុព្វបុរសរបស់យើងដែលបានសាងសង់ប្រាសាទអង្គរវត្ត។ យើងត្រូវមានមោទនភាពហើយធ្វើដូចបុព្វបុរសរបស់យើងដែរ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

- រឹងមាំនិងជឿជាក់លើខ្លួនឯង
- ផ្ដល់តម្លៃដល់ខ្លួនឯង
- កុំយកចិត្តទុកដាក់ច្រើនពេកចំពោះអ្វីដែលអ្នកដទៃយល់ឃើញ ប្រសិនបើអ្នកគិតថាវាល្អ ធ្វើវាទៅ
- ផ្ដួចផ្ដើមគំនិតក្នុងការដោះស្រាយបញ្ហា។ ប្រសិនបើអ្នកមិនអាចធ្វើបានថ្ងៃនេះ ព្យាយាមធ្វើវានៅថ្ងៃស្អែកហើយកុំបោះបង់ចោល។ កុំមានភាពតានតឹងលើខ្លួនឯងហើយទទួលយកការពិតហើយបំភ្លេចវាប្រសិនបើអ្នកមិនអាចធ្វើវាបានក្នុងពេលឥឡូវនេះអ្នកត្រូវតែបន្តដំណើររបស់អ្នក។

គំរូស្ត្រីរបស់ខ្ញុំនៅកម្ពុជា៖
- លោកស្រីលីម ឈីវហួរ
- លោកជំទាវឈុនលាង (ធនាគារវឌ្ឍនៈ)

ដោយសារតែពួកគេមានទ្រព្យសម្បត្តិច្រើននិងពូកែក្នុងអាជីវកម្ម ខ្ញុំរៀនតាមរយៈការមើលវីដេអូអំពីរបៀបធ្វើអាជីវកម្មនិងដឹកនាំមនុស្សដូចជាខ្សែភាពយន្ត007។ ពីសាច់រឿង ខ្ញុំបានរៀនថា ក្នុងស្ថានភាពពិបាកយើងត្រូវធ្វើការសម្រេចចិត្តថាត្រូវធ្វើយ៉ាងណាសូមកុំរង់ចាំអ្នកដទៃបញ្ជាឱ្យយើងធ្វើ ដោយសារស្ថានភាពប្រែប្រួល។ WK

# លោកស្រី ស៊ុយ ចាន់ណៃ

## នាយិកាគ្រប់គ្រង | InSTEDD iLab Southeast Asia



អ្នកដឹកនាំ
ស្រ្តីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត ?*

ខ្ញុំកើតនៅខេត្តកំពង់ចាមហើយធំឡើងនិងរស់នៅក្នុងរាជធានីភ្នំពេញ។ នៅឆ្នាំ ២០០៣ ខ្ញុំបានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលឥណ្ឌាដើម្បីបញ្ចប់សញ្ញាបត្រអនុបណ្ឌិតផ្នែកកម្មវិធីកុំព្យូទ័រនៅ Bangalore ។ ឥឡូវនេះខ្ញុំបានរៀបការហើយមានកូនប្រុសម្នាក់អាយុ ៣ ឆ្នាំ។

ក្នុងរយៈពេល១០ ឆ្នាំចុងក្រោយនេះ ខ្ញុំបានចូលរួមជាមួយ InSTEDD ហើយតួនាទីបច្ចុប្បន្នរបស់ខ្ញុំគឺនាយកគ្រប់គ្រង iLab នៅអាស៊ីអាគ្នេយ៍។ ខ្ញុំចាំថា ខ្ញុំជាស្ត្រីតែម្នាក់គត់នៅក្នុងក្រុមកម្ពុជាពេលខ្ញុំបានចូលរួមជាលើកដំបូង។ ឥឡូវនេះយើងមានស្ត្រី ៧នាក់នៅក្នុងក្រុម។ ខ្ញុំមានអារម្មណ៍ពិសេសណាស់ដែលបានធ្វើការជាមួយក្រុមចម្រុះមួយនៅអង្គការ InSTEDD នៅទូទាំងពិភពលោក។ ពួកយើងជាអង្គការបច្ចេកវិទ្យាទំនើបដែលមិនរកប្រាក់ចំណេញ និងមានលំដាប់ឋានានុក្រមរាបស្មើជាមួយនឹងវប្បធម៌ បើកទូលាយចំពោះគំនិតច្នៃប្រតិដ្ឋថ្មីៗពីសមាជិកក្រុមគ្រប់គ្នា។ ខ្ញុំសូមសារភាពថា ខ្ញុំបានរៀនសូត្រ និងរីកចម្រើនជាច្រើនប៉ុន្មានឆ្នាំមកនេះនៅអង្គការ InSTEDD ។

ខ្ញុំមានអំណរគុណដែលមានឱកាសធ្វើការជាមួយក្រុមដ៏អស្ចារ្យមួយនេះក៏ដូចជាមនុស្សដែលមានចក្ខុវិស័យ និងអ្នកបង្កើតភាពផ្លាស់ប្តូរពីខាងភ្នាក់ងារអន្តរជាតិ រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកជួរមុខ។ ខ្ញុំមានមោទនភាពយ៉ាងខ្លាំងចំពោះសមិទ្ធផលរបស់យើងក្នុងការជួយពង្រឹងប្រព័ន្ធសុខាភិបាលសាធារណៈដែលជាដំណោះស្រាយពីក្រោមឡើងលើ ដោយបុគ្គលិកជួរមុខក៏ដូចជាគម្រោងថ្មីរបស់យើងដើម្បីជួយពង្រឹងប្រព័ន្ធអប់រំសាធារណៈតាមរយៈថ្នាក់សរសេរកូដ និងការកសាងសមត្ថភាពបច្ចេកវិទ្យា។




*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី ?*

បញ្ហាប្រឈមដ៏ធំបំផុតសម្រាប់ខ្ញុំគឺនៅពេលខ្ញុំត្រលប់មកពីការសិក្សានៅបរទេស។ អស់រយៈពេលមួយឆ្នាំខ្ញុំបានធ្វើការឱ្យក្រុមហ៊ុនបច្ចេកវិទ្យាមួយប៉ុន្តែខ្ញុំមិនពេញចិត្តទេ ព្រោះដូចជាមានអ្វីមួយដែលបាត់ ហើយនោះគឺជាតម្លៃនៃទំនាក់ទំនង។ ខ្ញុំបានចំណាយពេលមួយឆ្នាំដើម្បីស្វែងយល់ពីខ្លួនឯងឱ្យច្បាស់អំពីប្រភេទការងារដែលខ្ញុំចង់ធ្វើ ការងារដែលមានគុណតម្លៃដែលខ្ញុំចង់បាន។ និយាយទៅ ខ្ញុំបានរកឃើញថា ការស្វែងយល់ពីខ្លួនឯងគឺជាការលំបាកបំផុតនៅពេលខ្ញុំចាប់ផ្តើមអាជីពរបស់ខ្ញុំ។

> “
> **បើអ្នកសួរប្រជាជនកម្ពុជាថាពួកគេចង់ធ្វើអ្វីក្នុងជីវិតនោះ ចម្លើយជាទូទៅគឺគាត់ចង់មានអាជីវកម្មមួយ**

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ប៉ុន្មានឆ្នាំមកនេះខ្ញុំបានដឹងថាប្រសិនបើមេដឹកនាំល្អបង្កើតក្រុមការងារនិងវប្បធម៌ដ៏អស្ចារ្យបាន ភាពជោគជ័យនឹងមកតាមក្រោយ។ វាគឺការផ្តល់អំណាចដល់ក្រុមការងារ ផ្តល់ឱកាសឱ្យពួកគេរីកចម្រើន និងទទួលខុសត្រូវ ហើយក្នុងពេលតែមួយយើងត្រូវតែឈរលើតម្លៃរបស់យើងនិងធ្វើសេចក្តីសម្រេចចិត្តលំបាកៗជាច្រើន។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់អ្នកយ៉ាងដូចម្តេច ?*

ការជឿទុកចិត្តគឺជាតម្លៃស្នូលនៃជីវិតរបស់ខ្ញុំក្នុងការងារក៏ដូចជានៅក្នុងទំនាក់ទំនង។ នៅកន្លែងធ្វើការខ្ញុំបានទាក់ទងទៅក្រុមរបស់ខ្ញុំដើម្បីប្រាប់ពួកគេថា ខ្ញុំជឿជាក់លើពួកគេហើយប្រសិនបើមានការសង្ស័យណាមួយខ្ញុំទាញពួកគេចេញហើយនិយាយជាមួយពួកគេអំពីការសង្ស័យឬការព្រួយបារម្ភរបស់ខ្ញុំ។ យើងមិនអាចធ្វើការជាមួយគ្នាបានទេ ប្រសិនបើគ្មានការទុកចិត្ត។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

ប្រហែលជាឥរិយាបថ “នគរបាលនិងចោរ” នៅក្នុងអង្គការណាមួយហើយដែលជាឥរិយាបថអវិជ្ជមានចំពោះភាពជាអ្នកដឹកនាំ។ ប្រសិនបើអ្នកដឹកនាំមិនមានទំនុកចិត្តនៅក្នុងក្រុម ហើយផ្តោតលើការបង្កើតច្បាប់និងការស្វែងរកកំហុសក្រុមការងារនឹងមិនប្រឹងឱ្យអស់លទ្ធភាពរបស់ពួកគេឬប្រើប្រាស់សក្តានុពលពេញលេញរបស់ពួកគេសម្រាប់អង្គការទេ។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ភាពជាអ្នកដឹកនាំមិនមែនជាវិញ្ញាបនបត្រទេ វាត្រូវបានបង្ហាញតាមរយៈគុណភាពនៃក្រុមដែលអ្នកដឹកនាំ និងជោគជ័យដែលទទួលបាន។ ជារៀងរាល់ថ្ងៃខ្ញុំរៀនធ្វើឱ្យប្រសើរឡើងក្នុងការឱ្យក្រុមរបស់ខ្ញុំធ្វើការអស់ពីចិត្តហើយខ្ញុំសង្ឃឹមថា ខ្ញុំអាចរួមចំណែកដោយជួយគ្នាក្នុងការក្លាយជាអ្នកដឹកនាំនាពេលអនាគត។

នាពេលបច្ចុប្បន្ននេះយើងមានស្ត្រីនៅក្នុងក្រុមច្រើនជាងបុរសដែលវាក្លាយជាកង្វល់ផ្សេងមួយទៀត ក្នុងពិភពលោកដ៏មិនស្មើភាពរបស់យើង។ ទៅមុខទៀត យើងចង់ធ្វើឱ្យមានតុល្យភាពនៃចំនួន (ការជ្រើសរើសបុគ្គលិកនាពេលអនាគតប្រហែលជាផ្តល់អាទិភាពកាន់តែច្រើនដល់បុរស) ដូច្នេះយើងអាចមានតុល្យភាពយេនឌ័រក្នុងការងាររបស់យើងដើម្បីមានឥទ្ធិពលស្មើគ្នាលើសង្គម។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ពីរបីឆ្នាំមុនខ្ញុំបានលើកឡើងនូវគំនិតថ្មីមួយឱ្យការិយាល័យកណ្តាលរបស់ខ្ញុំដើម្បីបង្កើតជា startup incubator ដើម្បីស្វែងរកសក្តានុពលថ្មីៗ និងបង្កើតនូវដំណោះស្រាយផលប៉ះពាល់សង្គមជាមួយអ្នកអនុវត្តជួរមុខ។ ខ្ញុំមិនអាចទទួលបានការយល់ស្របពីការិយាល័យរបស់ខ្ញុំទេ ប៉ុន្តែសំណាងល្អពួកគេក៏មិនបានហាមខ្ញុំមិនឱ្យរកមូលនិធិដើម្បីសាកល្បងវាដែរ។ នៅទីបំផុត អ្នកផ្តល់ប្រាក់ឧបត្ថម្ភដែលមានស្រាប់របស់យើងបានយល់ព្រមគាំទ្រវាដូចដែលពួកគេជឿលើការងារពីមុនរបស់យើង។ ខ្ញុំសប្បាយចិត្តណាស់ដែលយើងទទួលបានប្រាក់ឧបត្ថម្ភដើម្បីធ្វើការលើគំនិតនោះ ប៉ុន្តែខ្ញុំមានការភ័យខ្លាចផងដែរ។ ចុះប្រសិនបើ លទ្ធផលមិនបានល្អ? ការជឿទុកចិត្តរបស់ការិយាល័យរបស់ខ្ញុំ និងពីអ្នកផ្តល់ប្រាក់ឧបត្ថម្ភច្បាស់ជានឹងត្រូវកាត់បន្ថយ។ យ៉ាងណាមិញលទ្ធផលបានចេញមកយ៉ាងល្អ ហើយអ្នកឧបត្ថមក៏បានយល់ព្រមផ្តល់ថវិកាដល់កម្មវិធីមួយទៀតហើយនៅទីបំផុតការិយាល័យកណ្តាលរបស់ខ្ញុំរីករាយនិងគាំទ្រកម្មវិធីរបស់យើង។



*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ប្រជាជនកម្ពុជាមានភាពឧស្សាហ៍ព្យាយាម។ ជាមួយប្រវត្តិសាស្ត្រងងឹតនិងសេវាសាធារណៈមានកម្រិត ប្រជាជនយើងហាក់ដូចជាមានការរំពឹងទុកតិចតួចសម្រាប់ការគាំទ្រពីខាងក្រៅហើយត្រូវការពឹងផ្អែកលើខ្លួនឯង។ ប្រសិនបើអ្នកសួរប្រជាជនខ្មែរថា តើពួកគេចង់បានអ្វីនៅក្នុងជីវិត ចម្លើយទូទៅមួយគឺ ចង់ធ្វើជាម្ចាស់អាជីវកម្ម។ ប្រជាជនខ្មែរមានស្មារតីសហគ្រិន។ ពួកគាត់ចង់បានឱកាសដើម្បីចាប់ផ្តើមអាជីវកម្មថ្មីនិងធ្វើជាចៅហ្វាយខ្លួនឯង។ ខ្ញុំមានសុទិដ្ឋិនិយមខ្លាំងណាស់ដែលប្រជាជនខ្មែរមានចរិតលក្ខណៈសហគ្រិនល្អនឹងរីកចម្រើននៅសម័យនេះ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

សម្រាប់សហគ្រិនស្ត្រីក្មេងៗជាពិសេសអ្នកដែលទើបតែបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ខ្ញុំសូមណែនាំពួកគេឱ្យចំណាយពេលយ៉ាងហោចណាស់មួយឆ្នាំដើម្បីធ្វើការឱ្យអាជីវកម្មណាមួយដែលពួកគេកោតសរសើរ។ អ្នកអាចមានគំនិតដ៏អស្ចារ្យ ប៉ុន្តែអ្នកត្រូវការបទពិសោធន៍ដើម្បីយល់អំពីសក្តានុពលនៃដំណើរការអាជីវកម្ម។ ប្រតិបត្តិការអាជីវកម្មគឺមិនមែនពឹងតែលើគំនិតដ៏អស្ចារ្យនោះទេ។ WK



អ្នកដឹកនាំ ស្ត្រីនៅកម្ពុជា

# លោកជំទាវ គឹម សេដ្ឋានី

## រដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត?*

ខ្ញុំចង់ចែករំលែកដោយសង្ខេបអំពីជីវិតរបស់ខ្ញុំដោយបែងចែងជាបួនផ្នែកៈ គ្រួសារ ការអប់រំ អាពាហ៍ពិពាហ៍ និងអាជីពការងារ។ ដំបូងគឺជីវិតគ្រួសារខ្ញុំ។ ឪពុកម្តាយរបស់ខ្ញុំមានកូនស្រីពីរនាក់ហើយខ្ញុំជាកូនស្រីច្បង។ ខ្ញុំកើតនៅថ្ងៃទី ១២ ខែមករាឆ្នាំ ១៩៧៩ នៅខេត្តក្រចេះដែលឪពុករបស់ខ្ញុំជាអតីតនាយកនៃនាយកដ្ឋានព័ត៌មាន ហើយម្តាយរបស់ខ្ញុំគឺជាអតីតប្រធានខុទ្ទកាល័យសាលាខេត្ត។ ម្តាយរបស់ខ្ញុំបច្ចុប្បន្នកំពុងបម្រើការជាសមាជិកតំណាងរាស្ត្ររដ្ឋសភានៃមណ្ឌលបោះឆ្នោតខេត្តក្រចេះ។

ទីពីរគឺជីវិតអប់រំរបស់ខ្ញុំ។ ខ្ញុំបានបញ្ចប់ការសិក្សានិងទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅខេត្តក្រចេះក្នុងឆ្នាំ១៩៩៥ដោយទទួលបានចំណាត់ថ្នាក់លេខ១ ប្រចាំខេត្ត ។ នៅឆ្នាំ ២០០០ ខ្ញុំបានទទួលបរិញ្ញាបត្រច្បាប់ជំនាញនីតិសាធារណៈពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅរាជធានីភ្នំពេញ។ ក្រោយមកខ្ញុំបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាលនៅឆ្នាំ២០០២។ នៅឆ្នាំ ២០១០ ខ្ញុំទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈនិងគោលនយោបាយពីសាកលវិទ្យាល័យវេស្ទើន។ នៅឆ្នាំ ២០១៤ ខ្ញុំទទួលបានវិញ្ញាបនបត្រជំនាញ មគ្គុទេសភាព អភិបាលកិច្ចនិងគោលនយោបាយសាធារណៈសម្រាប់ឧត្តមមន្ត្រីពីសាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង នៅសិង្ហបុរី។ ខ្ញុំបានចូលរួមវគ្គខ្លីស្តីពីសារគមនាគមន៍កំណែទម្រង់នៅ វិទ្យាស្ថាន World Bank-Annenberg នៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ាភាគខាងត្បូងក្នុងឆ្នាំ២០១៥។ នៅឆ្នាំ ២០១៦ ខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ១០០ ម៉ោងស្តីពី «ស្ត្រីក្នុងភាពជាអ្នកដឹកនាំ»នៅសាលាភូមិន្ទរដ្ឋបាល និងវគ្គបណ្តុះបណ្តាលស្តីពីអភិបាលកិច្ច នៅសាលា Harvard's Kennedy ក្នុងឆ្នាំ២០១៦ ។

ទីបីគឺជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំ។ ខ្ញុំបានរៀបការនៅឆ្នាំ ២០០៣ ជាមួយលោក នុត ពុធដារ៉ា ដែលសព្វថ្ងៃជាអភិបាលខណ្ឌដង្កោ រាជធានីភ្នំពេញ។ យើងមានកូនស្រីបីនាក់ដែលបានកើតក្នុងឆ្នាំ ២០០៤ ២០០៧ និង២០០៩។ សម្រាប់អាជីពរបស់ខ្ញុំ ខ្ញុំបានធំធាត់នៅក្នុងគ្រួសារមន្ត្រីរាជការ។ ខ្ញុំតែងតែសុបិនចង់ក្លាយជាមន្ត្រីរាជការល្អម្នាក់តាំងតែពីខ្ញុំរៀននៅវិទ្យាល័យម្លេះ។



ក្តីសុបិនរបស់ខ្ញុំមួយនេះ គឺជាកម្លាំងជំរុញឱ្យខ្ញុំទៅរៀននៅមហាវិទ្យាល័យបន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។ ដោយមានការគាំទ្រ ពីគ្រួសារនិងការប្តេជ្ញាចិត្តរបស់ខ្ញុំ ខ្ញុំបានប្រលងជាប់ចូលរៀននៅមហាវិទ្យាល័យចំនួនបីគឺមហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច មហាវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងជំនាញអក្សរសិល្ប៍ខ្មែរនៅឆ្នាំ ១៩៩៥។

ដោយសារក្តីសុបិនរបស់ខ្ញុំចង់ក្លាយជាមន្ត្រីរាជការខ្ញុំក៏បានសម្រេចចិត្តសិក្សាតែជំនាញច្បាប់សាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចពីព្រោះច្បាប់សាធារណៈជាមូលដ្ឋានគ្រឹះនៃការក្លាយជាមន្ត្រីសាធារណៈដ៏ល្អម្នាក់ហើយមុខវិជ្ជានេះដែរក៏បានផ្តល់ឱកាសច្រើនដល់និស្សិតណាដែលមានបំណងចង់សិក្សាបន្តនៅសាលាភូមិន្ទរដ្ឋបាល។ តាមរយៈ

> **“ គោលការណ៍នៃភាពជោគជ័យគឺមិនអាចដើរំលងបាន ទេទោះបីជាយើងមានភេទអ្វីក៏ដោយ**

ការកំណត់គោលដៅអាជីពច្បាស់លាស់និងការតាំងចិត្តក្នុងការរៀនសូត្រនៅពេលនោះ ខ្ញុំបានរងការរិះគន់ពីអ្នកជិតខាង ដែលយុវនារីមិនគួររស់នៅម្នាក់ឯងនៅភ្នំពេញឆ្ងាយពីគ្រួសារនោះទេ។ ពួកគេយល់ថាមនុស្សស្រីមិនចាំបាច់ត្រូវការការអប់រំខ្ពស់នោះទេ ព្រោះពេលទីបំផុតពួកគេនឹងក្លាយជាម្តាយហើយត្រូវនៅផ្ទះដើម្បីថែរក្សាកូននិងគ្រួសារ។

នៅឆ្នាំ ២០០០ បន្ទាប់ពីខ្ញុំបានទទួល បរិញ្ញាបត្រច្បាប់ ហើយខ្ញុំបានប្រលងជាប់ជានិស្សិតឧត្តមមន្ត្រីនៅសាលាភូមិន្ទរដ្ឋបាល ដែលជាមោទនភាពដ៏ធំធេងចំពោះខ្ញុំនិងគ្រួសាររបស់ខ្ញុំ។ ខ្ញុំក៏បានប្រលងជាប់នៅសាកលវិទ្យាល័យធំៗ



ចំនួនបីផ្សេងទៀតផងដែរ។ មានបេក្ខជនរាប់ពាន់នាក់ដែលមានសញ្ញាបត្រជាន់ខ្ពស់និងបទពិសោធន៍ជាច្រើន ប៉ុន្តែមានតែ ៣០នាក់ទេដែលត្រូវបានជ្រើសរើស ហើយមានតែពីរនាក់ប៉ុណ្ណោះជាស្ត្រី។ ពេលនោះហើយដែលខ្ញុំបានសម្រេចបំណងប្រាថ្នាពាក់កណ្តាលផ្លូវរបស់ខ្ញុំដើម្បីក្លាយជាមន្ត្រីរាជការជាន់ខ្ពស់ដ៏ពិតប្រាកដម្នាក់។

បន្ទាប់ពីបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាលនៅចុងឆ្នាំ ២០០២ ខ្ញុំបានចាប់ផ្តើមធ្វើការនៅសាលារាជធានីភ្នំពេញ ដែលពេលនោះមានតំណែងជាមន្ត្រីសាធារណៈជាន់ខ្ពស់ ប៉ុន្តែខ្ញុំមិនទាន់មានឱកាសកាន់តំណែងជាអភិបាលនៅឡើយទេ។

នៅថ្ងៃធ្វើការដំបូងនៅឯសាលាក្រុង ខ្ញុំបានសួរបុគ្គលិកនៅទីនោះថា «តើមួយណាជាបន្ទប់របស់លោកជំទាវអភិបាលរងសាលារាជធានីភ្នំពេញ?»។ មុនពេលត្រលប់មកផ្ទះវិញខ្ញុំបានសម្លឹងមើលបន្ទប់របស់គាត់ ដោយមានទំនុកចិត្តហើយសន្យានឹងខ្លួនឯងថា ពេលណាមួយនៅថ្ងៃអនាគត ខ្ញុំនឹងមានឱកាសអង្គុយនៅទីនោះហើយក្លាយទៅជាស្ត្រីម្នាក់ដែលមានតួនាទីធំជាងគេនៅក្នុងសាលារាជធានីភ្នំពេញ។

តាមរយៈការប្តេជ្ញាចិត្តក្នុងការសម្រេចក្តីសុបិននេះខ្ញុំបានធ្វើការអស់រយៈពេល ១១ ឆ្នាំនៅក្នុងសាលារាជធានីភ្នំពេញ។ ខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារ។ ខ្ញុំមានថ្ងៃឈប់សម្រាកតិចតួចឬសឹងតែគ្មានផង ហើយត្រូវប្រឈមនឹងការលំបាកជាច្រើនដើម្បីទទួល បានលទ្ធផលល្អបំផុតពីការងាររបស់ខ្ញុំ។ ខ្ញុំបានធ្វើការក្នុងវិស័យវិមជ្ឈការ និងវិសហមជ្ឈការ

## “ បើចង់ជោគជ័យ អ្នកត្រូវហ៊ានបរាជ័យ

ហើយត្រូវបានដំឡើងឋានៈជាអនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋានអស់រយៈពេល ៧ឆ្នាំ និងជានាយកអង្គភាពកិច្ចការច្បាប់និងសិទ្ធិមនុស្សអស់រយៈពេល៣ ឆ្នាំ ដែលពេលនោះខ្ញុំជានាយិកាស្រីតែម្នាក់និងក្មេងជាងគេនៅសាលារាជធានីភ្នំពេញ។

ភាពលំបាកបំផុតនៃជីវិតការងាររបស់ខ្ញុំរួមមានការសម្រេចឱ្យបាននូវការទទួលខុសត្រូវខ្ពស់ (របស់ការងារ) ក៏ដូចជាការបំពេញភារកិច្ចជាស្ត្រីមេផ្ទះ ជាម្តាយរបស់កូនស្រីទាំង៣ នាក់ ហើយខ្ញុំក៏ត្រូវចំណាយពេលវេលាដើម្បីសិក្សាថ្នាក់អនុបណ្ឌិតផងដែរ។ ខ្ញុំត្រូវបំពេញការងារទាំងអស់ខណៈពេលដែលមានផ្ទៃពោះនិងសម្រាលកូនម្តងហើយម្តងទៀត។

ទាំងអស់នេះបណ្តាលឱ្យខ្ញុំមានបញ្ហាមួយចំនួនជាមួយស្វាមីរបស់ខ្ញុំ។ យើងបានឈ្លោះប្រកែកគ្នាព្រោះខ្ញុំតែងតែមាញឹកមិនសូវបាននៅផ្ទះនិងដោយសារតែយើងមានគំនិតខុសគ្នាលើជីវិតការងាររបស់ខ្ញុំ។

នៅពេលនោះដោយសារតែសម្ពាធពីការងារការសិក្សានិងគ្រួសារ ខ្ញុំស្ទើរតែសម្រេចចិត្តបោះបង់ការងាររបស់ខ្ញុំ។ ប៉ុន្តែទីបំផុតតាមរយៈការប្រឹងប្រែងរបស់ខ្ញុំក្នុងការវិភាគពន្យល់បកស្រាយ និងថ្លឹងថ្លែងទិដ្ឋភាពទាំងពីរនេះ (គ្រួសារនិងការងារ) ប្តីរបស់ខ្ញុំបានយល់កាន់តែច្រើន ហើយបានគាំទ្រខ្ញុំនៅពេលខ្ញុំឆ្លងកាត់ឧបសគ្គទាំងនេះ។ ក្នុងឆ្នាំ២០១២លោកជំទាវអភិបាលរង សាលារាជធានីភ្នំពេញបានចូលនិវត្តន៍។ តាមរយៈការវាយតម្លៃការងាររបស់ខ្ញុំ ខ្ញុំត្រូវបានគេស្នើសុំធ្វើជាបេក្ខជនជំនួសតំណែងនេះ ដែលជាក្តីសុបិនរបស់ខ្ញុំ។ ជាអកុសលយោងទៅតាមច្បាប់ស្តីពីការរៀបចំសាលារាជធានីនិងខេត្ត សមាជិកនៃក្រុមប្រឹក្សាអភិបាលត្រូវមានអាយុយ៉ាងហោចណាស់ ៣៥ ឆ្នាំ។ នៅពេលនោះខ្ញុំមានអាយុខ្វះ ៧ ខែទៀតទើបគ្រប់សម្រាប់ការជ្រើសតាំងជាអភិបាលរង។ នេះបណ្តាលឱ្យខ្ញុំបាត់បង់ឱកាសដ៏អស្ចារ្យនេះ។ ទោះជាយ៉ាងនេះក្តី ក៏ចំណង់ចំណូលចិត្តរបស់ខ្ញុំនៅដដែល ហើយឆន្ទៈរបស់ខ្ញុំនឹងមិនរសាយឡើយ។ ផ្ទុយទៅវិញ នេះបានក្លាយជាការលើកទឹកចិត្តដែលបានជំរុញឱ្យខ្ញុំធ្វើការកាន់តែខ្លាំងជាងមុន និងទទួលយកការទទួលខុសត្រូវកាន់តែច្រើនជាងមុន។ ហេតុដូច្នេះហើយទើបឱកាសមួយទៀតបានមកដល់ ហើយឱកាសលើកនេះគឺធំជាងមុនទៅទៀត។ ក្នុងឆ្នាំ២០១៣ ខ្ញុំត្រូវបានគេតែងតាំងជាផ្លូវការក្នុងឋានៈរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ដែលជាឋានៈខ្ពស់និងគួរឱ្យចង់បានបំផុតនៅក្នុងនយោបាយជាតិ ហើយជាតំណែងដែលខ្ញុំមិនដែលនឹកស្រមៃសម្រាប់ខ្លួនឯងទេ។

### *នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ ?*

ខ្ញុំបានធ្វើការជារដ្ឋលេខាធិការនៃក្រសួងអប់រំក្នុងឆ្នាំ២០១៣ នៅក្នុងអាណត្តិទី ៥របស់រដ្ឋាភិបាល។ នៅឆ្នាំ ២០១៨ ខ្ញុំក៏ត្រូវបានតែងតាំងជារដ្ឋលេខាធិការនៃក្រសួងអប់រំយុវជននិងកីឡាសម្រាប់អាណត្តិទី៦របស់រដ្ឋាភិបាល ។ មានបញ្ហាប្រឈមធំៗជាច្រើននៅក្នុងអាជីពការងាររបស់ខ្ញុំ។ បញ្ហាប្រឈមទីមួយរបស់ខ្ញុំ គឺការផ្លាស់ប្តូរពីរដ្ឋបាលថ្នាក់ក្រោមជាតិទៅជាអ្នកនយោបាយនៅក្នុងវិស័យដែលពាក់ព័ន្ធនឹងការអប់រំថ្នាក់ជាតិ ដែលខ្ញុំមិនដែលស្រមៃថានឹងមានឱកាសកាន់ឋានៈនិងតួនាទីនេះទេ។ បញ្ហាប្រឈមទីពីរគឺ គំនិតមន្ទិលសង្ស័យរបស់អ្នកដទៃអំពីសមត្ថភាពរបស់ខ្ញុំក្នុងការធ្វើការ ក្នុងនាមជាអ្នកដឹកនាំវ័យក្មេងមួយរូបក្នុងវិស័យអប់រំ។ លើសពីនេះទៀតនៅក្នុងអាណត្តិទី៥របស់រដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់និងអនុវត្តកំណែទម្រង់ស៊ីជម្រៅនៃប្រព័ន្ធអប់រំដែលទាមទារឱ្យមានកម្រិតនៃភាពជាអ្នកដឹកនាំខ្ពស់ក្នុងការគ្រប់គ្រងកំណែទម្រង់នេះដើម្បីទទួលជោគជ័យនិងប្រសិទ្ធភាព។ ការងារទាំងអស់នេះគឺពិតជាថ្មីសម្រាប់ខ្ញុំហើយវាទាមទារឱ្យខ្ញុំមានការខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត និងការរៀនចំណេះដឹងថ្មីៗ។ ដូច្នេះ ខ្ញុំគេងបានត្រឹមតែបីទៅបួនម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ជាពិសេសក្នុងអំឡុងពេលឆ្នាំដំបូង។ ខ្ញុំត្រូវបង្ខំខ្លួនខ្ញុំឱ្យអានឯកសាររាប់សិបទំព័រជារៀងរាល់ថ្ងៃ ទោះបីជាវាមិនមែនជាចំណង់ចំណូលចិត្តរបស់ខ្ញុំក៏ដោយ។ ខ្ញុំបានអានរយៈពេល ពី ៥ ទៅ ១០ ម៉ោងដើម្បីអាចដឹកនាំកិច្ចប្រជុំបច្ចេកទេសមួយប្រកបដោយប្រសិទ្ធភាពដែលមានរយៈពេលតែមួយម៉ោងឬពីរម៉ោងប៉ុណ្ណោះ។

### *ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

នៅក្នុងរដ្ឋាភិបាលរបស់យើងសព្វថ្ងៃនេះយើងត្រូវការភាពជាអ្នកដឹកនាំជាងពេលណាៗទាំងអស់។ ហើយជាពិសេសយើងត្រូវការភាពជាអ្នកដឹកនាំដើម្បីនាំយើងទៅអនាគត។ យើងត្រូវការមនុស្សដែលមានចក្ខុវិស័យនិងភាពក្លាហាន មនុស្សដែលមានសមត្ថភាពរិះរកគំនិតថ្មីនិងបង្កើតស្នាដៃថ្មីៗ។ យើងត្រូវការអ្នកដឹកនាំពីរប្រភេទនេះ។

ប្រភេទទីមួយគឺសំខាន់បំផុតឬជាមូលដ្ឋានគ្រឹះ៖ អ្នកដឹកនាំដែលមានទំនាក់ទំនងល្អ ដែលជាមនុស្សម្នាក់ដែលសម្រេចការងារបានជាមួយនិងតាមរយៈអ្នកដទៃ។

អ្នកដឹកនាំប្រភេទទី ២ ដែលយើងត្រូវការគឺអ្នកដឹកនាំបែបបំផ្លាស់ប្រែ ជាមនុស្សដែលជាអ្នកបង្កើតផ្លូវ។ អ្នកដឹកនាំប្រភេទនេះគឺជាទស្សនវិទូដែលលើកទឹកចិត្ត លើកស្ទួយ បំផុសទឹកចិត្ត និងផ្តល់សិទ្ធិអំណាចដល់មនុស្ស ដើម្បីឱ្យពួកគេសម្រេចបានកិច្ចការដែលហួសពីអ្វីដែលពួកគេធ្លាប់ធ្វើពីមុនមក។

អ្វីដែលខ្ញុំបានចងចាំគឺ ថាអ្នកដឹកនាំត្រូវបានកសាងបង្កើតឡើង មិនមែនកកើតឡើងដោយឯកឯងនោះទេ។ គ្មាននរណាម្នាក់ក្នុងពិភពលោក នេះដែលកើតមកជាមួយនិងភាពជាអ្នកដឹកនាំពីធម្មជាតិនោះទេ។ ភាពជាអ្នកដឹកនាំគឺជាសមត្ថភាពក្នុងការទទួលបានអ្នកដើរតាម (មិនមែនសំដៅដល់អ្នកតាមក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមទេ)។ សព្វថ្ងៃនេះភាពជាអ្នកដឹកនាំដែលបានមកពីតំណែង ឬពីប្រាក់ ឬអំណាច មានអាយុកាលខ្លី។ ភាពជាអ្នកដឹកនាំតែមួយគត់ដែលមានភាពយូរអង្វែង គឺនៅពេលដែលមនុស្សសម្រេចចិត្តថាពួកគេនឹងដើរតាមទិសដៅ ការណែនាំនិងទស្សនវិស័យរបស់នរណាម្នាក់ផ្សេងទៀត។ អាចនិយាយបានម្យ៉ាងទៀតថាវាជាការដើរតាមដោយស្ម័គ្រចិត្ត ដែលធ្វើឱ្យយើងជាអ្នកដឹកនាំដែលល្អនាពេលសព្វថ្ងៃនេះ។

ប្រសិនបើអ្នកចង់ក្លាយជាអ្នកដឹកនាំម្នាក់ឬក៏ល្អជាងនេះអ្នកត្រូវចងចាំថាអ្វីៗ អាស្រ័យលើអ្នក។ វាស្ថិតនៅក្នុងដៃរបស់អ្នកឬក៏សំខាន់ជាងនេះទៀត នៅក្នុងគំនិតរបស់អ្នក។ អ្នកគឺជាអ្វីដែលអ្នកគិត។ រូបភាពផ្ទាល់ខ្លួនរបស់អ្នក កំណត់ការប្រព្រឹត្តិរបស់អ្នក។ អ្នកអាចក្លាយជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាពជាងនេះតាមរយៈការផ្លាស់ប្តូរគំនិតខ្លួនឯងពីអ្វីដែលអ្នកគិតអំពីខ្លួនអ្នកជាអ្នកដឹកនាំ។

ក្នុងនាមជាអ្នកដឹកនាំ ហេតុផលដ៏សំខាន់បំផុតដែលអ្នកអាចមានសម្រាប់ខ្លួនអ្នកគឺធ្វើខ្លួនឱ្យល្អបំផុត ហើយហេតុផលដូចគ្នាត្រូវតែអនុវត្តចំពោះអាជីវកម្មឬអង្គភាពរបស់អ្នក។ បើអ្នកធ្វើការងាររបស់អ្នកឱ្យល្អបំផុតនោះអ្វីដែលទទួលបានមកវិញសម្រាប់ខ្លួនអ្នក ឬស្ថាប័នរបស់អ្នក នឹងមិនតិចតួចឡើយ។

### *តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច ?*

អ្នកដឹកនាំល្អម្នាក់ត្រូវការចក្ខុវិស័យច្បាស់លាស់និងការកំណត់នូវតម្លៃនៃបេសកកម្មរបស់ខ្លួនរបស់ស្ថាប័នប៉ុន្តែក៏ជាតម្លៃរបស់មនុស្សគ្រប់គ្នាផងដែរ។ ឧទាហរណ៍ទស្សនវិស័យនិងគោលដៅរបស់ក្រសួងអប់រំយុវជននិងកីឡារួមមាន៖ ១) គាំទ្រដល់បុព្វហេតុនៃកំណែទម្រង់ដែលបានចាប់ផ្តើមដើម្បីលើកកម្ពស់ធនធានមនុស្ស ២) គាំទ្រការអភិវឌ្ឍសង្គម - សេដ្ឋកិច្ចសម្រាប់មនុស្សជំនាន់ក្រោយនិងភាពរុងរឿងនៃប្រទេស។ បុគ្គលិកអប់រំទាំងអស់មានមោទនភាពចំពោះការរួមចំណែក របស់ពួកគេក្នុងការសម្រេចគោលដៅនៃកំណែទម្រង់ប្រព័ន្ធអប់រំដោយមានការគាំទ្រយ៉ាងខ្លាំងពីសិស្ស ឪពុកម្តាយនិងសាធារណជន។

យោងទៅតាមបទពិសោធន៍ការងាររបស់ខ្ញុំមានវិធីមួយចំនួនដែលមនុស្សអាចដឹងពីសារសំខាន់នៃការរួមចំណែករបស់ពួកគេ នៅកន្លែងធ្វើការរបស់ពួកគេដូចជា៖

- លើកទឹកចិត្តនិងគាំទ្រដល់បុគ្គលិកទាំងអស់នៅក្នុងស្ថាប័នសម្រាប់ការខិតខំនិងគុណភាពនៃការងាររបស់ពួកគេដើម្បីសម្រេចបាននូវគោលដៅស្ថាប័ន។
- អនុញ្ញាតឱ្យពួកគេចែករំលែកគំនិតនិងចូលរួមចំណែកក្នុងការអនុវត្ត។
- បន្តផ្តល់ការលើកទឹកចិត្តតាមរយៈការផ្តល់រង្វាន់ជាតួនាទីដល់បុគ្គលិកទាំងអស់នៅក្នុងស្ថាប័នដើម្បីធ្វើឱ្យពួកគេកាន់តែមានការប្តេជ្ញាចិត្តនិងយល់ថាពួកគេមានតម្លៃខ្លាំងចំពោះអង្គភាព។
- យកចិត្តទុកដាក់លើគំនិតយោបល់របស់មនុស្សគ្រប់ៗគ្នាក្នុងកន្លែងការងារគឺជាចំណុចសំខាន់បំផុតនៃការធ្វើជាអ្នកដឹកនាំល្អ។ មនុស្សនឹងបោះបង់ចោលការសម្រេចចិត្តរបស់ពួកគេដើម្បីធ្វើការឆ្ពោះទៅគោលដៅរបស់ស្ថាប័នប្រសិនបើពួកគេមិនយល់ច្បាស់ពីវា។ ពួកគេមិនមានអារម្មណ៍ថាខ្លួនឯងជាមនុស្សសំខាន់ម្នាក់នៅក្នុងស្ថាប័នទេប្រសិនបើពួកគេទទួលបានតែការបញ្ជាឱ្យធ្វើ ដោយគ្មានឱកាសដើម្បីផ្តល់នូវមតិយោបល់និងមតិត្រលប់សម្រាប់ការងាររបស់ពួកគេ។
- វាក៏សំខាន់ផងដែរក្នុងការកសាងមិត្តភាពជាមួយមិត្តរួមការងាររបស់អ្នក។ ខ្ញុំផ្ទាល់បានរកឃើញថា ការធ្វើបែបនេះបង្កឱ្យមានភាពងាយស្រួលពេលធ្វើការជាមួយពួកគេ។ ខ្ញុំបានបង្កើតទំនាក់ទំនងល្អជាមួយពួកគេដែលខ្ញុំគិតថាទំនាក់ទំនងនេះ អាចមានរយៈពេលមួយជីវិត។ យើងបានយល់ និងដាក់ការជឿទុកចិត្តឱ្យគ្នាទៅវិញទៅមក។ ក្នុងនាមជាអ្នកដឹកនាំម្នាក់ ខ្ញុំដឹងថាអ្វីដែលសមស្របសម្រាប់ពួកគេ ហើយក្នុងនាមជាអ្នកក្រោមបង្គាប់ខ្ញុំ ពួកគេដឹងពីអ្វីដែលខ្ញុំចង់បាន។ តាមរយៈការធ្វើដូច្នេះយើងបានបង្កើតនូវស្មារតីធ្វើការជាក្រុម។

### *តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

អ្នកដឹកនាំត្រូវមានគំនិតផ្តួចផ្តើម សហគ្រិនភាព ជំនាញដោះស្រាយបញ្ហានិងការដាក់កិច្ចការជាក់ស្តែង។ គំនិតផ្តួចផ្តើមឬការច្នៃប្រតិដ្ឋមានន័យថាការបង្កើតនូវអ្វីដែលថ្មីដោយមិនចាំបាច់រង់ចាំអ្វីទាំងនេះកើតឡើងដោយឯកឯង។

អ្នកដឹកនាំបច្ចុប្បន្នកំពុងគិតអំពីអនាគតគិតអំពីអ្វីដែលថ្មី ធ្វើការអនុវត្តវានិងកែលម្អជានិច្ចនូវអ្វីដែលមានកំហុសឆ្គង។ ការមិនធ្វើការសម្រេចចិត្តច្បាស់លាស់ ការឆ្លើយតបភ្លាមៗនិងការវិភាគដែលចំណាយពេលយូរមិនមែនជាគន្លឹះដើម្បីជោគជ័យនោះទេ។ ដូច្នេះវាចាំបាច់ត្រូវចាប់ផ្តើមអនុវត្តជំហានទាំងនេះដោយបោះជំហានឆ្ពោះទៅរកគោលដៅដែលបានកំណត់។ «កុំស្ទាក់ស្ទើរនិងចំណាយពេលរាប់ខែនិងឆ្នាំលើការវិភាគ ការធ្វើអ្វីមួយ ឆ្ពោះទៅមុខ»។ មនុស្សភាគច្រើនបរាជ័យដោយសារតែពួកគេមិនធ្វើសកម្មភាពដើម្បីសម្រេចគោលដៅរបស់ពួកគេ។ នេះគឺជាកំហុសមួយក្នុងចំណោមកំហុសដ៏ធំបំផុតនៃភាពជាអ្នកដឹកនាំ។



### *តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

សម្រាប់ភាពជាអ្នកដឹកនាំខាងផ្នែកជំនួញនិងការលើកកម្ពស់ស្ត្រីខ្ញុំនឹងខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍខ្លួនឯងដើម្បីបំពេញ នូវតម្រូវការនៃមុខតំណែងនេះ។ លើសពីនេះទៀតខ្ញុំរៀនមេរៀនដ៏អស្ចារ្យពីមនុស្សដែលទទួលបានជោគជ័យដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំរបស់ខ្ញុំ។ ក្នុងនាមជាអ្នកដឹកនាំស្ត្រី ខ្ញុំនឹងផ្តល់ឱកាសដើម្បីគាំទ្រនិងលើកទឹកចិត្តដល់ស្ត្រីដទៃទៀត ក្នុងការពង្រឹងភាពជាអ្នកដឹកនាំរបស់ពួកគេក្នុងការអភិវឌ្ឍសមត្ថភាពនិងតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការគ្រប់គ្រងអប់រំនៅគ្រប់កម្រិតទាំងអស់ ពីសាលារៀន ការិយាល័យអប់រំយុវជននិងកីឡា នាយកដ្ឋានអប់រំយុវជននិងកីឡា និងរចនាសម្ព័ន្ធជាតិ។ លើសពីនេះទៀតខ្ញុំនឹងលើកកម្ពស់ការអនុវត្តគោលនយោបាយស្តីពីសមភាពយេនឌ័រក្នុងវិស័យអប់រំដែលជាកត្តាសំខាន់ក្នុងការផ្តល់ឱកាសឱ្យស្ត្រីរៀនសូត្រជំនាញអភិវឌ្ឍន៍របស់ពួកគេដើម្បីឱ្យពួកគេមានភាពក្លាហានក្នុងការទទួលយកសិទ្ធិអំណាចសេដ្ឋកិច្ចសង្គមនិងនយោបាយ។ ខ្ញុំនឹងចូលរួមច្រើនថែមទៀតនៅក្នុងវេទិកាផ្សេងៗ ដែលទាក់ទងនិងស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងភាពជាសហគ្រិនដើម្បីចែករំលែកមេរៀនដែលទទួលបានពីស្ត្រីដែល ជោគជ័យក្នុងអាជីវកម្មនិងក្នុងនយោបាយសម្រាប់កុមារីនិងស្ត្រីទាំងអស់នៅក្នុងប្រទេសកម្ពុជា។

### *តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា ?*

បញ្ហាទី១៖ ការស្វែងរកតុល្យភាពរវាងគ្រួសារនិងការងារ

ដំណោះស្រាយរបស់ខ្ញុំចំពោះបញ្ហាប្រឈមនេះមានដូចខាងក្រោម៖

- កំណត់អាទិភាពរវាងការទទួលខុសត្រូវទាំងពីរដែលអាចត្រូវបានផ្លាស់ប្តូរទៅតាមកាលៈទេសៈ។ សូមចងចាំថាក្រុមគ្រួសារគឺជាអាទិភាពមុនគេ។ កុំខ្លាចក្នុងការប្រើពេលវេលាធ្វើការរបស់អ្នកខ្លះ ដើម្បីថែរក្សាមនុស្សជាទីស្រឡាញ់ ចំណាយពេលជាមួយពួកគេសម្រាលទុក្ខពួកគេដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ថាទទួលបានក្តីស្រឡាញ់និងបំពេញនូវតម្រូវការជាមូលដ្ឋានរបស់ពួកគេ។
- ប្រើពេលខ្លះក្នុងការងាររបស់អ្នកដើម្បីតភ្ជាប់ជាមួយពេលវេលាគ្រួសារ។ សូមព្យាយាមរកវិធីដើម្បីឱ្យគ្រួសាររបស់អ្នកចូលរួមជាមួយអ្វីដែលអ្នកធ្វើ។ នាំពួកគេទៅចូលរួមព្រឹត្តិការណ៍នៃការងារអ្នក ដើម្បីឱ្យពួកគេយល់កាន់តែច្បាស់និងគាំទ្រអ្នក។ វាអាចជាបទពិសោធន៍សិក្សាដ៏ល្អមួយសម្រាប់ពួកគេផងដែរ។ សម្រាប់ខ្ញុំ ខ្ញុំចូលចិត្តយកកូនៗខ្ញុំទៅចូលរួមព្រឹត្តិការណ៍កីឡានិងពិព័រណ៍អប់រំ។ ខណៈពេលដែលពួកគេមានភាពសប្បាយរីករាយនិង មានបទពិសោធន៍ថ្មីៗយើងក៏អាចចំណាយពេលជាមួយគ្នាបានដែរ។
- មិនថាវាលំបាក វាអស់កម្លាំងខ្លាំង អ្នករវល់ ឬពេលឧបសគ្គកើតឡើងចំពោះអ្នកយ៉ាងណាក៏ដោយអ្នកត្រូវប្រឈមមុខនឹងបញ្ហាទាំងនេះ វាមិនមានផ្លូវកាត់ណាមួយដើម្បីសម្រេចសមតុល្យនេះទេ។ អ្នកត្រូវដោះស្រាយបញ្ហាទាំងនោះជាជំហានៗ ដោយនៅតែស្មោះត្រង់នឹងអ្វីដែលសំខាន់ ហើយអ្នកនឹងអាចធ្វើវាបានបន្តិចម្តងៗ។ ទោះបីជាក្រុមគ្រួសារនិងការងារមិនមានតុល្យភាពពេលខ្លះ ពីព្រោះរឿងទាំងនេះមិនអាចចៀសរួច សូមកុំធ្លាក់ទឹកចិត្ត ហើយត្រូវតែធ្វើវាឱ្យល្អបំផុត។

បញ្ហាប្រឈមទី២៖ កង្វះពេលវេលានិងធនធាននៅកន្លែងធ្វើការ កង្វះខាតនៃស្មារតីក្រុមនិងផលប្រយោជន៍រួម។

ដំណោះស្រាយរបស់ខ្ញុំចំពោះបញ្ហាប្រឈមនេះមានដូចខាងក្រោម៖

- ទាញយកប្រយោជន៍ពេញលេញពីធនធានដែលមាន។ ត្រូវប្រាកដថាអ្នកដឹងពីអ្វីដែលអ្នកមានហើយប្រើវាឱ្យអស់ពីសមត្ថភាពរបស់អ្នក។ ស្វែងរកវិធីដែលមានប្រសិទ្ធភាពនិងមានប្រសិទ្ធផលបំផុតដើម្បីប្រើធនធានរបស់អ្នក។
- ព្យាយាមគ្រប់គ្រងពេលវេលាដោយកំណត់សកម្មភាពផែនការប្រចាំខែ ប្រចាំសប្តាហ៍ និងប្រចាំថ្ងៃ ដើម្បីសម្រេចគោលដៅដែលបានកំណត់។ ធ្វើអ្វីដែលអ្នកអាចធ្វើបាននាពេលបច្ចុប្បន្នដោយមិនចាំបាច់រង់ចាំថ្ងៃស្អែក។ សមតុល្យរវាងពេលវេលានិងធនធាន (រាប់បញ្ចូលទាំងមនុស្សនិងលុយ)ដែលទាំងពីរនេះមានឥទ្ធិពលយ៉ាងខ្លាំងលើគោលដៅរបស់យើង។
- កំណត់ទិសដៅឱ្យល្អហើយចងចាំពីវិធីច្បាស់លាស់ក្នុងការបង្រួបបង្រួមមនុស្សគ្រប់គ្នាក្នុងបុព្វហេតុដូចគ្នាដោះស្រាយជម្លោះផលប្រយោជន៍រវាងបុគ្គលនៅក្នុងស្ថាប័នដែលប៉ះពាល់ដល់គោលដៅរបស់ស្ថាប័ន។ បន្តបណ្តុះបណ្តាលស្មារតីសាមគ្គីភាពនិងផលប្រយោជន៍របស់ស្ថាប័នធំៗដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ជាពិសេសដើម្បីធ្វើជាគំរូក្នុងការលះបង់ភាពជាអ្នកដឹកនាំដោយខ្លួនឯងដោយមិនគិតពីការលំបាកនិងផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។

### *តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ដោយសារតែការនាំចេញសម្លៀកបំពាក់និងវិស័យទេសចរណ៍ កម្ពុជាបានរក្សាអត្រាកំណើនសេដ្ឋកិច្ចជាមធ្យម៧,៧% ក្នុងចន្លោះឆ្នាំ ១៩៩៥-២០១៧ កម្ពុជាបានក្លាយជាសេដ្ឋកិច្ចលូតលាស់លឿនបំផុតទី៦ លើពិភពលោក។ ខណៈពេលដែលតម្រូវការសកលកើនឡើងនៅឆ្នាំក្នុង ២០១៨ កំណើនសេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៧%បើប្រៀបធៀបទៅនឹងកំណើន ៦,៩% នៅឆ្នាំ ២០១៧ ។ ផលប៉ះពាល់នៃកំណើននៃការចូលរួម

របស់សហគ្រិនស្ត្រីគឺមានសារសំខាន់ហើយអាចរក្សាបាននូវសក្តានុពលក្នុងការបន្តក្លាយជាកត្តាជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ លើសពីនេះទៅទៀតខ្ញុំមានមោទនភាពណាស់ក្នុងការនិយាយថា ប្រទេសកម្ពុជា មានសហគ្រិនជាស្ត្រីដែលមានចំណាប់អារម្មណ៍ខ្លាំង។
ស្ត្រីកម្ពុជាមានចំនួន៥១ភាគរយនៃប្រជាជនសរុបរបស់ប្រទេស ហើយជាប្រភពនៃកំណើនដ៏មានសក្តានុពល។ ដោយផ្អែកលើបញ្ហានេះរដ្ឋាភិបាលបានប្រឹងប្រែងធ្វើការដើម្បីគាំទ្រពួកគេ។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំអាជីវកម្មផ្តល់លទ្ធភាពទទួលបានឥណទានរបស់សហគ្រិនជាស្ត្រីបង្កើតឱ្យមានឱកាសក្នុងការផ្សារភ្ជាប់ទំនាក់ទំនងសម្រាប់សហគ្រិនស្ត្រីនិងភ្ជាប់ទំនាក់ទំនងរបស់សហគ្រិនស្ត្រីកម្ពុជាទៅកាន់ក្រុមហ៊ុនក្នុងស្រុកនិងអន្តរជាតិនិងបណ្តាញអ្នកជំនាញផ្សេងៗ វាអាចផ្តល់សិទ្ធិអំណាចដល់ពួកគេនិងលើកទឹកចិត្តឱ្យពួកគេឈានទៅមុខ។ ការផ្សារភ្ជាប់ទំនាក់ទំនងទាំងនេះអាចជួយដល់អ្នកជំនួញស្ត្រីកម្ពុជាក្នុងការបំបែកឧបសគ្គនាំទៅរកឱកាសការបណ្តុះបណ្តាលកម្រិតអន្តរជាតិនិងចែករំលែកការអនុវត្តល្អៗ។ តាមរយៈការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ កម្ពុជាអាចប្រកាសថាខ្លួនមានជាប្រទេសល្អបំផុតសម្រាប់សហគ្រិនស្ត្រីនៅអាស៊ី។

### *លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ដើម្បីក្លាយជាស្ត្រីដែលទទួលបានជោគជ័យខ្ញុំសូមណែនាំសហគ្រិនកម្ពុជាវ័យក្មេងដូចជា៖

#### ១. ជឿជាក់លើខ្លួនឯង

គន្លឹះសំខាន់ដើម្បីទទួលបានភាពជោគជ័យក្នុងមុខជំនួញគឺការជឿជាក់លើខ្លួនឯងហើយជាក្រឹត្យក្រមធម្មជាតិដែលស្ត្រីត្រូវស្គាល់សមត្ថភាពរបស់ពួកគេ។ ដើម្បីទទួលបានជោគជ័យក្នុងមុខជំនួញ អ្នកត្រូវតែជឿលើខ្លួនឯង។ នេះមានសារសំខាន់ខ្លាំងណាស់ ពីព្រោះគ្មាននរណាម្នាក់ជឿជាក់លើអ្នកនិងផលិតផលឬសេវាកម្មរបស់អ្នកនោះទេ ប្រសិនបើអ្នកមិនជឿលើខ្លួនឯងជាមុន។ គ្មានវិនិយោគិនណានឹងវិនិយោគជាមួយអ្នកទេ ប្រសិនបើអ្នកខ្វះទំនុកចិត្តលើខ្លួនឯង ហើយបុគ្គលិករបស់អ្នកនឹងមិនមានសមត្ថភាពខ្ពស់ដោយសារតែអ្នកខ្វះស្មារតីដើម្បីជំរុញពួកគេ។

ជាការពិតបើអ្នកគ្មានជំនឿលើខ្លួនឯងនោះទេ ទោះក្នុងកម្រិតណា ការខិតខំប្រឹងប្រែងលើអាជីវកម្មរបស់អ្នក នឹងមិនធានាបាននូវលទ្ធផលវិជ្ជមានឡើយ។ ដូច្នេះបង្កើនជំនឿរបស់អ្នកនៅថ្ងៃនេះ អភិវឌ្ឍជំនឿថាអ្នកមានអ្វីដែលមានតម្លៃនៅក្នុងខ្លួនអ្នក ដែលពិភពលោកចង់បាន។

#### ២. មានបេសកកម្មរឹងមាំ

ហេតុអ្វីបានជាអ្នកចង់ចាប់ផ្តើមអាជីវកម្ម?សំណួរនេះអាចស្តាប់ទៅដូចជាធម្មតា ប៉ុន្តែវាគឺជាកត្តាចាំបាច់ដែលកំណត់ថាតើអ្នកនឹងទទួលបានភាពជោគជ័យឬបរាជ័យក្នុងនាមជាសហគ្រិន។ សូមក្រឡេកមើលសហគ្រិនស្ត្រីជោគជ័យបំផុតរបស់ពិភពលោកហើយអ្នកនឹងឃើញថាពួកគេទាំងអស់សុទ្ធតែមានហេតុផលដ៏រឹងមាំក្នុងការធ្វើអាជីវកម្មហើយមូលហេតុនោះបានក្លាយជាបេសកកម្មពាណិជ្ជកម្មរបស់ពួកគេ។

#### ៣. ត្រៀមផ្នត់គំនិតរបស់អ្នក

ភាពជោគជ័យក្នុងអាជីវកម្មគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើផ្នត់គំនិតដែលអាជីវកម្មត្រូវបានបង្កើត។ ដើម្បីក្លាយជាសហគ្រិនដែលមានជោគជ័យជាទូទៅអ្នកត្រូវតែដាក់ចិត្តរបស់អ្នកនៅចំកន្លែង។ សម្រាប់សហគ្រិនស្ត្រីទាំងឡាយអ្នកមិនត្រូវមើលខ្លួនឯងថាជាភេទដែលទន់ខ្សោយ នោះទេ។ អ្នកត្រូវតែមានផ្នត់គំនិតដើម្បីដោះស្រាយនូវរាល់ភាពលំបាកដែលអាចកើតមានឡើងចំពោះអ្នក។ ភាពជោគជ័យនឹងមិនត្រូវបានផ្តល់ឱ្យអ្នកដោយសារតែអ្នកជាស្ត្រីនោះទេ ហើយវាក៏មិនអាចយកចេញពីអ្នកព្រោះអ្នកគឺជាស្ត្រីដែរ។ អ្នកត្រូវតែអាចដាក់ចិត្តរបស់អ្នកលើវា សូម្បីតែវាមានន័យថាការដាក់ខ្លួនអ្នកលើភាពលំបាកក៏ដោយ។

#### ៤. មានឆន្ទៈក្នុងការបរាជ័យ

គោលការណ៍នៃភាពជោគជ័យមិនអាចត្រូវបានលើកឡើងតែមួយចំហៀង ទោះអ្នកមានភេទណាក៏ដោយ។ នេះមានន័យថាដើម្បីក្លាយជាអ្នកទទួលបានជោគជ័យ អ្នកត្រូវតែមានឆន្ទៈទទួលយកការបរាជ័យ។ អាជីវកម្មគឺជាហានិភ័យ ប៉ុន្តែរង្វាន់របស់វាគឺសមនឹងហានិភ័យ។ ខ្ញុំបានសង្កេតឃើញថាសហគ្រិនស្ត្រីដែលទទួលបានជោគជ័យបំផុតគឺស្ត្រីដែលធ្វើសកម្មភាពដោយមិនខ្វល់ខ្វាយពីភាពបរាជ័យ។ ដូច្នេះប្រសិនបើអ្នកចង់ក្លាយជាស្ត្រីដែរទទួលបានជោគជ័យក្នុងអាជីវកម្ម អ្នកត្រូវតែមានឆន្ទៈក្នុងការទទួលយកភាពបរាជ័យដែលនេះជាផ្នែកមួយក្នុងការទទួលបានភាពជោគជ័យ។

បរាជ័យក៏មិនមែនជារឿងអាក្រក់ដែរហើយក៏មិនមែនជា ចំណុចអវិជ្ជមានដែរ។ ផ្ទុយទៅវិញចូរព្យាយាមកត់ចំណាំនូវអ្វីដែលនាំទៅដល់បរាជ័យហើយចងចាំរឿងទាំងនេះក្នុងគំនិតថាជាអ្វីដែលអ្នកត្រូវចៀសវាងក្នុងពេលកំពុងកសាងផ្លូវរបស់អ្នកទៅរកភាពជោគជ័យ។ វាមិនដែលយឺតពេកទេក្នុងការព្យាយាមម្តងទៀត។ កាលដែលអ្នកកាន់តែរៀនពីវា វានឹងកាន់តែងាយស្រួលក្នុងការដែលស្រោចស្រង់ខ្លួនអ្នក ហើយដំណើររបស់អ្នកកាន់តែលឿន មុនពេលអ្នកឈានដល់ភាពជោគជ័យ។

#### ៥. បង្កើនជំនាញអាជីវកម្មរបស់អ្នក

សហគ្រិនមួយចំនួនបានកើតមកជំនាញស្រាប់។ អ្នកផ្សេងទៀតបានធ្វើឱ្យខ្លួនឯងល្អ តាមរយៈការខិតខំប្រឹងប្រែង។ ប្រសិនបើការធ្វើ ពាណិជ្ជកម្មមិនត្រូវបានប្រគល់ឱ្យអ្នកដោយគ្រួសាររបស់អ្នកទេ ដូច្នេះអ្នកត្រូវតែបង្កើតវាដោយខ្លួនអ្នក និងសម្រេចវាឱ្យបាន នោះអ្នកនឹងត្រូវអភិវឌ្ឍជំនាញសហគ្រិនដែលត្រូវការហើយដើម្បីសម្រេចវាឱ្យបាននោះ អ្នកនឹងត្រូវការអភិវឌ្ឍជំនាញសហគ្រិនភាពដែលតម្រូវឱ្យមាន។ តើអ្នកធ្វើអ្វីនៅពេលទំនេររបស់អ្នក? ចម្លើយទៅនឹងសំណួរនេះនឹងកំណត់ថាតើអ្នកនឹងទទួលបានជោគជ័យឬអត់។ ជំនួសឱ្យការមើលភាពយន្តឬការទិញទំនិញពេលទំនេរ ហេតុអ្វីអ្នកមិនចូលរួមសិក្ខាសាលា






ឬអានសៀវភៅទាក់ទងនិងអាជីវកម្មផ្សេងៗ។ អ្នកនឹងមិនដឹងពីស្ថានភាពដែលអ្នកនឹងអាចជួបប្រទះនៅថ្ងៃស្អែកទេហើយចំណេះដឹងដែលអ្នកបានទទួលក្នុងពេលទំនេររបស់អ្នកអាចក្លាយទៅជាការសង្គ្រោះអ្នកក៏ថាបាន។

#### ៦. យល់ពីអាជីវកម្មរបស់អ្នកឱ្យល្អិតល្អន់

តើអ្នកយល់អំពីអាជីវកម្មរបស់អ្នកយ៉ាងម៉េចដែរ? តើអ្នកកំពុងធ្វើអាជីវកម្មដែលអ្នកស្រឡាញ់ឬ? ឬអ្នកលោតចូលក្នុងឧស្សាហកម្មមួយសម្រាប់តែប្រាក់? ដោយមិនគិតពីប្រភេទនៃអាជីវកម្មដែលអ្នកកំពុងប្រឡូក ធ្វើឱ្យប្រាកដថាអ្នកយល់ពីវាយ៉ាងល្អិតល្អន់ដូចបាតដៃ។ មែនហើយ អ្នកអាចទទួលយកចំណេះដឹងជាច្រើនពីការអនុវត្តអាជីវកម្មផ្ទាល់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មុនពេលចាប់យកអាជីវកម្មណាមួយ យ៉ាងហោចណាស់អ្នកត្រូវអប់រំខ្លួនអ្នកអំពីមូលដ្ឋានគ្រឹះនៃអ្វីដែលអ្នកចង់ធ្វើជាមុនសិន។ ប្រសិនបើអ្នកយល់ពីមូលដ្ឋានគ្រឹះរួចហើយសួរខ្លួនឯងម្តងទៀតថា តើអ្នកយល់ថាអាជីវកម្មរបស់អ្នកដល់ចំណុចកណ្តាលហើយឬនៅ?ប្រសិនបើអ្នកមិនយល់ពីមូលដ្ឋានគ្រឹះទេ ត្រូវចងចាំជានិច្ចថា វាគ្មានដែនកំណត់ចំពោះចំណេះដឹងទេហើយវាតែងតែមានចំណុចដែលត្រូវកែលម្អ។ ពិតណាស់គ្មាននរណាម្នាក់អាចដឹងគ្រប់លម្អិតបានទេ ប៉ុន្តែព្យាយាមរៀននូវអ្វីដែលអ្នកអាចធ្វើបាន។ នៅពេលដែលអ្នកបានបណ្តុះ ខួរក្បាលរបស់អ្នក ដំណោះស្រាយបញ្ហានឹងកើតឡើងកាន់តែងាយស្រួល ដូចអ្នកប្រើដើម្បីរកមើលអ្វីដែលកំពុងព្យាយាមយល់ពីអាជីវកម្មរបស់អ្នក។

#### ៧. គ្រប់គ្រងពេលវេលារបស់អ្នកឱ្យមានប្រសិទ្ធភាព

ឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗមួយចំនួនដែលអ្នកជំនួញស្ត្រីជួបប្រទះគឺបញ្ហាពេលវេលា។ អ្នកជំនួញស្ត្រីតែងតែជាប់ផុងក្នុងពេលវេលាពីព្រោះមានការទទួលខុសត្រូវច្រើន។ សហគ្រិនស្ត្រីត្រូវតែបំពេញតម្រូវការអាជីវកម្មរបស់ពួកគេខណៈដែលត្រូវថែទាំគ្រួសារនិងតម្រូវការផ្ទាល់ខ្លួន។ ពិតប្រាកដណាស់ វាមានភាពលំបាកជាងការគិតរបស់មនុស្សម្នាក់ៗ។ ប្រសិនបើអ្នកអាចយកឈ្នះលើបញ្ហានេះហើយក្លាយជាអ្នកជំនួញស្ត្រីដែលជោគជ័យម្នាក់នោះអ្នកត្រូវតែពូកែជំនាញធ្វើប្រតិភូកម្ម។ រៀនពីវិធីប្រគល់ការងារដល់អ្នកដទៃការងារដែលមិនចាំបាច់ការសម្រេចចិត្តច្រើនដើម្បីឱ្យអ្នកមានពេលវេលាដើម្បីផ្តោតអារម្មណ៍លើអ្វីដែលត្រូវការអ្នកសម្រេចចិត្ត។

#### ៨. រក្សាអតិថិជនរបស់អ្នក

ខ្ញុំជឿជាក់ថាស្ត្រីរក្សាអតិថិជនរបស់ពួកគេបានល្អជាងបុរស។ ចងចាំថាអតិថិជនរបស់អ្នកគឺជាហេតុផលដែលអ្នកកំពុងធ្វើអាជីវកម្មនេះ។ គ្មាននរណាម្នាក់ដែលទទួលជោគជ័យក្នុងមុខជំនួញដោយមិនទទួលបានភាពស្មោះត្រង់របស់អតិថិជនឡើយ។ ដូច្នេះមិនត្រូវបន្ទាបតម្លៃរបស់អ្នកពាក់ព័ន្ធសំខាន់ៗទាំងនេះឡើយពីព្រោះពួកគេជាអ្នកកំណត់ទិសដៅរបស់អាជីវកម្មរបស់អ្នក។

#### ៩. ដើរតាមដំណើរការ

ស្ថិតិបង្ហាញថា៩0% នៃអាជីវកម្មទាំងអស់បានចាប់ផ្តើមបរាជ័យក្នុងរយៈពេល១០ឆ្នាំដំបូង។ មូលហេតុគឺដោយសារមិនមែនគ្រប់អ្នកដែលចាប់ផ្តើមអាជីវកម្មទាំងអស់មានសេចក្តីក្លាហានក្នុងការដើរតាមដំណើរការដែលបានកំណត់នោះទេ។ ដំណើរការសហគ្រិនភាពនៃការកសាងអាជីវកម្មដែលទទួលបានជោគជ័យមួយគឺពិតជាមានភាពលំបាក។ អ្នកនឹងត្រូវតែចេះងើបពីបញ្ហាមួយទៅមួយទៀតដោយមិនបាត់បង់ភាពរំភើបរបស់អ្នក។ ប្រសិនបើអ្នកអាចធ្វើដូច្នេះបានអ្នកនឹងក្លាយជាអាជីវកម្មស្ត្រីដែលទទួលបានជោគជ័យ។

ចុងបញ្ចប់ខ្ញុំសូមជូនពាក្យផ្តាំផ្ញើមួយថា ការកសាងជំនួញមួយដែលជោគជ័យឬក្លាយជាស្ត្រីដែលធ្វើជំនួញជោគជ័យមិនមែនជាការផ្សងព្រេងមួយយប់ទេ។ វាជាដំណើរការដែលឡើងចុះដែលតម្រូវឱ្យមានការលះបង់រាប់មិនអស់។ ប្រសិនបើអ្នកអាចស៊ូទ្រាំនិងដោះស្រាយបញ្ហាអាជីវកម្មបាននៅពេលដែលវាកើតឡើង នោះអ្នកនឹងមកដល់គោលដៅដែលអ្នកចង់បាន យឺតៗប៉ុន្តែពិតប្រាកដ។ WK

# លោកស្រី ឆាយ ស៊ីវលីន

## ប្រធាន | សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា




*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះឆាយ ស៊ីវលីន ហើយខ្ញុំកើតនៅខែវិច្ឆិកា ឆ្នាំ ១៩៧២ នៅខេត្តសៀមរាប។ ខ្ញុំជាកូនពៅក្នុងចំណោមកូនប្រាំនាក់ដែលមានម្តាយជាជនជាតិខ្មែរ និងឪពុកជាជនជាតិចិន។ ខ្ញុំមានបរិញ្ញាបត្រជំនាញគ្រប់គ្រង ហើយបច្ចុប្បន្នខ្ញុំបានរៀបការនិងមានកូនចំនួនបីនាក់។ បទពិសោធន៍របស់ខ្ញុំក្នុងនាមជាប្រធានសមាគមភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)និងជាអនុប្រធានសហព័ន្ធនៃសមាគមទេសចរណ៍អាស៊ាន (FATA) ពិតជាដំណើរដ៏គួរឱ្យពេញចិត្តមួយពេលទទួលបានឱកាសជួបជុំមិត្តភក្តិជាច្រើនមកពីជុំវិញពិភពលោកនិងចែករំលែកគំនិតនិងបទពិសោធនិផ្សេងៗជុំវិញការអភិវឌ្ឍវិស័យទេសចរណ៍។

សមិទ្ធផលដែលខ្ញុំមានមោទនភាពបំផុតគឺការធ្វើជាគំរូស្ត្រីដ៏មានឥទ្ធិពលម្នាក់ក្នុងភាពជាអ្នកដឹកនាំនិងការផ្លាស់ប្តូរដល់ការអភិវឌ្ឍឧស្សាហកម្ម

> ### ខ្ញុំចាត់រាល់កាលៈទេសៈទាំងអស់ជា ឱកាសរៀនសូត្រ ដើម្បី ឱ្យខ្ញុំរីកចម្រើនក្នុង នាមបុគ្គលនិងក្នុងអាជីព

ទេសចរណ៍របស់ប្រទេសយើង។ នេះមិននិយាយពីការមានកិត្តិយសក្នុងការបង្ហាញពីកំណប់ទ្រព្យរបស់កម្ពុជាដល់ភ្ញៀវអន្តរជាតិនៅគ្រប់កម្រិតទេ គឺហួសពីអ្វីដែលខ្ញុំអាចនឹកស្មានដល់កាលពីនៅក្មេង។ សំខាន់ដូចគ្នាផងដែរគឺប្រទេសកម្ពុជាមានសំឡេងនៅក្នុងកិច្ចប្រជុំថ្នាក់អាស៊ានហើយខ្ញុំមានមោទនភាពលើសពីការថ្លែងដែលមានឱកាសធ្វើជាវាគ្មិនតំណាងឱ្យប្រទេសកម្ពុជាក្នុងចំណោមសមាជិករបស់ FATA ។

*នៅពេលដែលអ្នកចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

នៅពេលចាប់ផ្តើមអាជីពរបស់ខ្ញុំនៅក្នុងឧស្សាហកម្មទេសចរណ៍ខ្ញុំបានប្រឈមមុខនឹងបុរេវិនិច្ឆ័យមួយចំនួនលើស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ។ បើទោះបីជាខ្ញុំធ្លាប់មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងរបរក្រុមហ៊ុនទេសចរណ៍ក៏ដោយ ក៏សមត្ថភាពរបស់ខ្ញុំក្នុងការដឹកនាំ CATA បានរងការវាយតម្លៃទាប។ ខ្ញុំត្រូវរកកេរ្តិ៍ឈ្មោះដោយពិបាក តាមរយៈការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីបង្ហាញពីភាពសាកសមរបស់ខ្ញុំក្នុងការរក្សាតួនាទីជាអ្នកដឹកនាំ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

មមេរៀនដ៏មានតម្លៃដែលខ្ញុំបានរៀនក្នុងនាមជាអ្នកដឹកនាំរួមមាន៖

- ការសម្រេចចិត្តគឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើជាអ្នកដឹកនាំពីព្រោះអង្គភាពរបស់ខ្ញុំនឹងរងគ្រោះបើខ្ញុំមិនអាចធ្វើការសម្រេចចិត្តបានលឿនទេនោះ។
- ក្នុងនាមជាអ្នកដឹកនាំ ការបំផុសគំនិតគឺមានសារសំខាន់ខ្លាំងណាស់ព្រោះការសម្រេចបានការងារអ្វីមួយមិនមែនត្រូវការតែមនុស្សម្នាក់ទេ វាត្រូវការខ្ញុំនិងក្រុមរបស់ខ្ញុំទាំងមូល។ ហេតុដូច្នេះហើយ ការបំផុសគំនិតឱ្យក្រុមរបស់ខ្ញុំមានគោលដៅដូចគ្នាគឺសំខាន់។
- ការមានការយល់ចិត្តគ្នាគឺមានសារសំខាន់ចំពោះអ្នកដឹកនាំពីព្រោះយើងតែងតែជួបជាមួយមនុស្ស ការគ្រប់គ្រង និងទំនាក់ទំនង។ នៅពេលយើងអាចយល់ឃើញនូវអ្វីដែលអ្នកដទៃគិតយើងមានទំនោរនឹងអាចរកដំណោះស្រាយដែលមនុស្សម្នាក់ទៀតក៏កំពុងពិចារណា។
- ការចេះគ្រប់គ្រងអារម្មណ៍របស់ខ្ញុំមានឥទ្ធិពលយ៉ាងធំធេងចំពោះការវិនិច្ឆ័យរបស់ខ្ញុំ។ ក្នុងនាមជាអ្នកដឹកនាំវាក៏ជាការទទួលខុសត្រូវរបស់ខ្ញុំក្នុងការគ្រប់គ្រងអារម្មណ៍ បើមិនដូច្នោះការសម្រេចចិត្តរបស់ខ្ញុំអាចមានភាពលម្អៀងនិងអយុត្តិធម៌។
- ខ្ញុំបានឃើញថា មិនថាមនុស្សទទួលបានជោគជ័យឬបទពិសោធន៍ច្រើនក៏ដោយក៏មនុស្សយើងមិនគួរឈប់រៀននិងស្វែងរកដំបូន្មាននោះទេ។ ពិភពលោកវិវត្តរាល់ថ្ងៃ ដូច្នេះមានរឿងថ្មីៗជាច្រើនដែលត្រូវរៀន

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច?*

គុណតម្លៃចម្បងរបស់ខ្ញុំគឺដាក់ក្រមសីលធម៌សេចក្តីមេត្តាករុណា និងភាពសុចរិតនៅក្នុងការសម្រេចចិត្តនានារបស់ខ្ញុំ។ ខ្ញុំជឿយ៉ាងមុតមាំថា ជាអ្នកដឹកនាំមួយរូប ប្រសិនបើខ្ញុំចង់ឱ្យក្រុមការងារឬអ្នកគាំទ្ររបស់ខ្ញុំទទួលយក និងអនុវត្តគោលការណ៍ស្នូលដូចខ្ញុំនោះ អ្នកដឹកនាំត្រូវតែធ្វើវាមុនគេ ហើយធ្វើជាគំរូសម្រាប់អ្នកដទៃ។

### *តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

យោងលើបទពិសោធន៍របស់ខ្ញុំ អ្នកដឹកនាំដែលបង្ហាញអំណាចនិងភាពក្រអឺតក្រទមជាទូទៅមានអ្នកដើរតាមដែលមានលក្ខណៈសម្បត្តិដូចគ្នា។ ម្យ៉ាងទៀត អ្នកដឹកនាំដែលមិនបើកចិត្តទូលាយទទួលយកការផ្លាស់ប្តូរនិងគំនិតថ្មីៗទេ ហាក់ដូចមិនទទួលយកទស្សនៈរបស់នរណាម្នាក់ផ្សេងទៀតក្រៅពីរបស់ខ្លួន ហើយនេះអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អង្គភាព/ស្ថាប័នទាំងមូល។

### *តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ខ្ញុំរីករាយក្នុងការចែករំលែកគន្លឹះនៃភាពជាអ្នកដឹកនាំរបស់ខ្ញុំរួមមាន៖

- រក្សាភាពថ្លៃថ្នូរនិងសុចរិតភាពដោយក្លាយជាអ្នកជំនួញបុរស/ ស្ត្រីម្នាក់ដែលស្មោះត្រង់និងមានក្រមសីលធម៌
- រៀនទទួលយកនិងជម្នះឧបសគ្គនិងគំនិតថ្មីៗនៅក្នុងសង្គម
- ចាត់ទុកនិយោជិតរបស់ខ្ញុំដោយស្មើៗគ្នានិងដោយការគោរព ក៏ដូចជាជំរុញឱ្យពួកគេចែករំលែកទស្សនៈនៅក្នុងកិច្ចប្រជុំព្រោះវាមានសារសំខាន់សម្រាប់អាជីវកម្មនៅពេលសមាជិកក្រុមទាំងអស់ចូលរួមយ៉ាងសកម្ម

ការលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីតាមរយៈ៖

- ចូលរួមសិក្ខាសាលានិងកិច្ចប្រជុំដែលលើកកម្ពស់អំណាចរបស់ស្ត្រី
- រៀបចំសិក្ខាសាលាជជែកពីប្រធានបទសមភាពយេនឌ័រដល់អ្នកចូលរួម
- ក្លាហាននៅពេលមានឱកាសនិយាយនៅពេលអ្នកមានគំនិត
- បន្តផ្តល់សិទ្ធិអំណាចដល់ស្ត្រីដោយលើកទឹកចិត្តឱ្យពួកគេបំភ្លេចពីការសង្ស័យលើខ្លួនពួកគេនិងបន្តចាប់យកមហិច្ឆតារបស់ពួកគេ

### *តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

នៅពេលខ្ញុំចាប់ផ្តើមអាជីពរបស់ខ្ញុំនៅក្នុងវិស័យទេសចរណ៍ខ្ញុំគឺជាអ្នករកគោលដៅទេសចរណ៍ថ្មីៗនៅបរទេសដើម្បីនាំយកផលិតផលថ្មីៗមកឱ្យអតិថិជនរបស់ខ្ញុំហើយធ្វើជាស្ត្រីម្នាក់ដែលធ្វើដំណើរទៅប្រទេសផ្សេងគ្នាដែលមិនសូវមានគេទៅដល់ តែម្នាក់ឯងគឺជាបទពិសោធន៍ប្រថុយប្រថានមួយ។ ជាសំណាងល្អ រាល់ដំណើរទេសចរណ៍មួយលើកៗ គឺជាការចងចាំមួយដែលស្រស់ស្អាត និងជួបជាមួយមនុស្សល្អៗ។ លើសពីនេះទៀត ការធ្វើដំណើរបែបអាជីវកម្មរបស់ខ្ញុំមិនតែងតែជារឿងជោគជ័យទេព្រោះអាជីវកម្មតូចៗមួយចំនួនរបស់ខ្ញុំមិនដំណើរការល្អឡើយហើយខ្ញុំត្រូវចាប់ផ្តើមពីចំណុចសូន្យម្តងទៀត។ យ៉ាងណាមិញ វាមិនមែនជារឿងអាក្រក់នោះទេ ព្រោះការបរាជ័យទាំងនោះបានបង្រៀនខ្ញុំនូវមេរៀនដ៏មានតម្លៃព្រមទាំងបានត្រៀមខ្លួនសម្រាប់ឧបសគ្គធំៗទៅមុខទៀត។

### *តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

វប្បធម៌កម្ពុជាគឺមានលក្ខណៈពិសេសដាច់ដោយឡែកពីគេដោយសារប្រវត្តិសាស្ត្រដ៏មោទនភាពរបស់យើងតាំងពីសម័យអាណាចក្រអង្គរដ៏ខ្លាំងក្លា។ របាំអប្សរា សិល្បៈប្រពៃណីបុរាណ និងសិប្បកម្មសិប្បនិម្មិតគឺជាចំណែកមួយដែលធ្វើឱ្យវប្បធម៌ខ្មែរមានលក្ខណៈប្លែកហើយពួកគេញែកយើងចេញពីវប្បធម៌របស់ប្រទេសជិតខាង។ ប្រជាជនកម្ពុជាមានភាពអត់ធ្មត់ មានមេត្តាករុណា និងពូកែធ្វើការ។ ដូច្នេះ យើងនឹងបន្តរីកចម្រើននៅក្នុងភាពជាសហគ្រិន និងភាពជាអ្នកដឹកនាំប្រកបដោយថាមភាព។ ជាពិសេសយុវជនជំនាន់ក្រោយដែលកំពុងទទួលបានការអប់រំកាន់តែច្រើន ពួកគេពិតជាបុគ្គលដែលខ្នះខ្នែងខិតខំបង្កើតស្នាដៃផ្ទាល់ខ្លួននៅក្នុងសង្គម។

### *លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ដំបូន្មានរបស់ខ្ញុំសម្រាប់សហគ្រិននារីជំនាន់ក្រោយ៖

- មិនត្រូវមើលស្រាលសមត្ថភាពរបស់អ្នកផ្ទាល់ក្នុងការបង្កើតការផ្លាស់ប្តូរ
- បោះជំហានចេញពីភាពងាយស្រួលរបស់អ្នកនិងចាប់យកអាជីពដែលអ្នកបាននឹងកំពុងស្រមៃ។
- កុំយកចិត្តទុកដាក់ចំពោះការរើសអើងនិងបុរេវិនិច្ឆ័យចំពោះស្ត្រីយើងក៏ជាសមាជិកនៃសង្គមនេះដែរ ហើយយើងសមនឹងទទួលបានការគោរពគ្នាទៅវិញទៅមកដូចគ្នានឹងបុរសកំពុងតែទទួលបានដែរ។
- អបអរសាទរភាពជោគជ័យរបស់អ្នកប៉ុន្តែកុំភ្លេចក្តីមេត្តារបស់អ្នកជាមនុស្សឱ្យសោះ។
- ត្រូវមានឆន្ទៈល្អប៉ុន្តែមិនត្រូវរឹងរូសឡើយ។ ចូរសុភាពទន់ភ្លន់តែកុំទន់ខ្សោយ។ ត្រូវមានវិន័យប៉ុន្តែមិនត្រូវដាច់អង្គការពេកទេ។
- មានទំនុកចិត្តរឹងមាំ ហើយសំខាន់បំផុតត្រូវរីករាយ! WK



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

# លោកស្រី នួន ភិមាន

## ស្ថាបនិក និងនាយិកាប្រតិបត្តិ | អង្គការលើកស្ទួយប្រជាពលរដ្ឋ



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត ?*

ខ្ញុំមានអាយុ ៤ឆ្នាំនៅពេលដែលខ្មែរក្រហមបានកាន់អំណាចនៅកម្ពុជា។ ក្នុងរយៈពេល៤ឆ្នាំ យើងរស់នៅក្នុងភាពងងឹតដោយមានម្ហូបអាហារតិចតួចហើយគ្មានលទ្ធភាពចូលសាលារៀន។ គ្រួសារខ្ញុំនិងខ្ញុំបានធ្វើការយ៉ាងលំបាកវេទនានៅក្នុងជំរំហើយវាជារឿងដ៏មិនគួរឱ្យជឿដែរដែលយើងទាំងអស់គ្នាបានរួចជីវិតពីរបបនេះ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមខ្ញុំក៏អាចចាប់ផ្តើមចូលរៀនបាន។ ម្តាយរបស់ខ្ញុំប្រាប់ខ្ញុំថាការអប់រំគឺជាគន្លឹះនៃអនាគតរបស់ខ្ញុំ ហើយខ្ញុំបានខិតខំប្រឹងប្រែងដើម្បីទទួលបានពិន្ទុល្អហើយតែងតែចង់ឡើងឱ្យបានកាន់តែខ្ពស់។

នៅពេលខ្ញុំមានអាយុ ១៥ឆ្នាំ ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺមហារីក។ បងស្រីរបស់ខ្ញុំបានទុកកូនស្រីអាយុ២ឆ្នាំរបស់គាត់នៅជាមួយម្តាយខ្ញុំ ហើយកូននោះក៏បានក្លាយជាបន្ទុករបស់ខ្ញុំ។ ជារៀងរាល់ថ្ងៃខ្ញុំត្រូវធ្វើការយ៉ាងខ្លាំងដើម្បីថែរក្សាក្មួយស្រីរបស់ខ្ញុំក៏ដូចជាឱ្យខ្លួនខ្ញុំបានចូលរៀនផងដែរ។ ជាច្រើនឆ្នាំក្រោយមក ខ្ញុំត្រូវបានគេជ្រើសរើសឱ្យចូលរួមក្នុងអង្គការសហប្រជាជាតិ ហើយជីវិតរបស់ខ្ញុំត្រូវបានផ្លាស់ប្តូរ។ ការខិតខំរបស់ខ្ញុំបានទទួលលទ្ធផលល្អហើយ។ ខ្ញុំបានក្លាយជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុម្នាក់។ យ៉ាងណាក៏ដោយខ្ញុំចង់បន្តការសិក្សារបស់ខ្ញុំ។ ក្រោយមកខ្ញុំទទួលបានអាហារូបករណ៍ដើម្បីទៅរៀននៅសកលវិទ្យាល័យនៅសហរដ្ឋអាមេរិក។ ឥឡូវនេះខ្ញុំមានគ្រួសារដែលមានប្តីរបស់ខ្ញុំ Steve និងកូនពីរនាក់របស់ខ្ញុំ Angie និង Alex ។

បទពិសោធន៍របស់ខ្ញុំក្នុងនាមជាអ្នកដឹកនាំម្នាក់គឺវាជាការប្រឈមផងនិងជារឿងគួរឱ្យរីករាយផង។ សមិទ្ធផលដ៏ធំបំផុតរបស់ខ្ញុំគឺខ្ញុំបានបើកសាលារៀន "អង្គការលើកស្ទួយប្រជាពលរដ្ឋ" របស់ខ្ញុំដើម្បីជួយកុមារជាង ១៥០០នាក់ នៅក្នុងប្រទេសកម្ពុជាឱ្យមានអនាគតល្អប្រសើរ។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី ?*

បញ្ហាប្រឈមសំខាន់បំផុតរបស់ខ្ញុំគឺហិរញ្ញវត្ថុ។ នៅពេលខ្ញុំចាប់ផ្តើមអង្គការរបស់ខ្ញុំ ខ្ញុំបានចាកចេញពីការងារជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុនៅអង្គការសហប្រជាជាតិហើយបានដាក់ប្រាក់របស់ខ្ញុំចូលទៅក្នុងសាលារៀនសម្រាប់កុមារក្រីក្រ។ នៅពេលនោះខ្ញុំគឺជាអ្នករកស៊ីចិញ្ចឹមគ្រួសាររបស់ខ្ញុំ ហើយនៅពេលខ្ញុំសម្រេចចិត្តបន្តក្តីសុបិនរបស់ខ្ញុំក្នុងការបើកសាលារៀន វាធ្វើឱ្យប៉ះពាល់ដល់ហិរញ្ញវត្ថុរបស់គ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែបន្តធ្វើការឆ្ពោះទៅរកអ្វីដែលខ្ញុំជឿជាក់ ហើយខ្ញុំបានសម្រេចវាដោយជោគជ័យ។




*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ខ្ញុំបានដឹងថាការតស៊ូនិងចំណង់ចំណូលចិត្តគឺជាគន្លឹះក្នុងការទទួលបានជោគជ័យ។ ខ្ញុំគិតថាពេលធ្វើការជាមួយក្រុមរបស់ខ្ញុំ ការអនុញ្ញាតឱ្យសមាជិកក្រុមរបស់ខ្ញុំនិយាយចេញពីគំនិតរបស់ពួកគេនិងមានសេរីភាពក្នុងការច្នៃប្រតិដ្ឋ ជាហេតុធ្វើឱ្យយើងមានក្រុមមួយដ៏សកម្ម។ វាជាការចាំបាច់ផងដែរដែលត្រូវយល់ថា ជាអ្នកដឹកនាំវាមិនអីទេបើយើងមានកំហុសខ្លះ ហើយត្រូវបន្តទៅមុខដរាបណាខ្ញុំទុកចិត្តលើជំនឿរបស់ខ្ញុំថាខ្ញុំបានធ្វើការសម្រេចចិត្តដ៏ល្អបំផុត។ ជំនឿរបស់ខ្ញុំគឺថានៅពេលកំណត់គោលដៅហើយ ខ្ញុំត្រូវតែធ្វើវាហើយបញ្ចប់វាឱ្យបាន ហើយនៅទីបញ្ចប់ទង្វើរបស់ខ្ញុំបង្ហាញយ៉ាងច្បាស់ជាងពាក្យសម្តីរបស់ខ្ញុំទៅទៀត។

> **“ខ្ញុំបានរៀនទទួលស្គាល់ថា ភាពអំណត់និងការស្រលាញ់ គឺជាគន្លឹះនៃភាពជោគជ័យ**

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

តម្លៃស្នូលរបស់ខ្ញុំគឺភាពស្មោះត្រង់ សុចរិតភាព ការគោរព (ចំពោះខ្លួនឯងនិងអ្នកដទៃ) ត្រូវមានយុត្តិធម៌ជានិច្ច ត្រូវតែរៀននិងកែលម្អនិងខិតខំធ្វើការ។ ដើម្បីធានាថាក្រុមរបស់ខ្ញុំយល់ស្របជាមួយតម្លៃស្នូលរបស់ខ្ញុំ ខ្ញុំបង្ហាញវាតាមរយៈសកម្មភាពដែលខ្ញុំធ្វើ។ ខ្ញុំជឿជាក់ថាដើម្បីឱ្យក្រុមរបស់ខ្ញុំធ្វើតាមតម្លៃស្នូលរបស់ខ្ញុំ ពួកគេត្រូវការឱ្យអ្នកដឹកនាំក្រុមដើម្បីបង្ហាញពួកគេពីវិធីធ្វើ។ ទង្វើបែបនេះហើយដែលខ្ញុំអាចបណ្តុះតម្លៃទាំងនេះសម្រាប់អង្គការរបស់ខ្ញុំទាំងមូល។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

ការមានគំនិតចង្អៀតចង្អល់នឹងមិនត្រឹមតែប៉ះពាល់ដល់ក្រុមរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់ខ្លួនអ្នកដែរ ហើយវាមិនឱ្យអ្នកលូតលាស់បានទេ។ នៅគ្រប់តំណែងដឹកនាំវាជាការល្អក្នុងការរក្សាចិត្តបើកចំហដល់គំនិតនិងដំណោះស្រាយផ្សេងៗ។ អាកប្បកិរិយាផ្សេងទៀតដែលអ្នកដឹកនាំគួរតែចៀសវាងគឺការគ្រប់គ្រងបែបរឹតត្បិត។ ការដាក់បញ្ជារាល់គ្រប់សកម្មភាពដែលបុគ្គលិករបស់អ្នកត្រូវធ្វើតាម នឹងដាក់ភាពតានតឹងលើអ្នកនិងបុគ្គលិក។ ផ្ទុយទៅវិញអ្នកចាំបាច់ត្រូវច្បាស់អំពីអ្វីដែលជាគោលដៅនិងធ្វើឱ្យប្រាកដ

ថាដើម្បីទទួលបានព័ត៌មានទាន់ហេតុការណ៍អំពីបរិបទសំខាន់ៗ។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

ដោយសារសេចក្តីស្រឡាញ់ក្នុងការរៀនសូត្រគឺជាចំណុចខ្លាំងនៃអត្តចរិតរបស់ខ្ញុំ ខ្ញុំតែងតែស្វែងរកមធ្យោបាយដើម្បីទទួលបានចំណេះដឹងនិងបន្តធ្វើជាអ្នកដឹកនាំ។ ទំនាក់ទំនងវិជ្ជមានគឺជាផ្នែកសំខាន់មួយនៃរឿងនេះ។ ខ្ញុំមានបណ្តាញអន្តរជាតិធំទូលាយហើយមានមនុស្សគួរឱ្យទុកចិត្តជាច្រើននៅជុំវិញពិភពលោកដែលខ្ញុំអាចសុំយោបល់។ ខ្ញុំតែងតែធ្វើអ្វីគ្រប់យ៉ាងដែលខ្ញុំអាចធ្វើបានដើម្បីជួយមនុស្សដោយមិនរំពឹងអ្វីត្រលប់មកវិញហើយខ្ញុំគិតថាមនុស្សអាចដឹងពីរឿងនេះ ហើយនិងមានឆន្ទៈក្នុងការគាំទ្រខ្ញុំព្រោះពួកគេដឹងថាខ្ញុំជាមនុស្សស្មោះត្រង់និងត្រឹមត្រូវ។

ប្រសិនបើខ្ញុំផ្តល់ដំបូន្មានដល់យុវនារីដែលចង់ធ្វើជាអ្នកដឹកនាំល្អ ខ្ញុំនឹងនិយាយថាពួកគេគួរតែរៀនពីអ្នកដទៃដែលមានបទពិសោធន៍ច្រើនជាងប៉ុន្តែត្រូវដឹងថាមនុស្សនឹងផ្តល់យោបល់ដោយផ្អែកលើគុណតម្លៃផ្ទាល់ខ្លួនរបស់ពួកគេ។ ខ្ញុំចង់លើកទឹកចិត្តយុវនារីឱ្យស្មោះត្រង់ចំពោះខ្លួននិងដើរតាមផ្លូវរបស់ខ្លួនឯង។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា?*

ការចាកចេញពីការងារដែលមានប្រាក់ខែច្រើនដើម្បីចេញទៅសាងសង់សាលារៀននៅលើទីលានចាក់សំរាម គឺជាការងារដ៏ប្រថុយប្រថានមួយ។ ខ្ញុំបានឃើញថាកុមាររងទុក្ខវេទនាហើយការណ៍ដែលពួកគេមិនបានចូលសាលារៀន វាបានរំឭកខ្ញុំឱ្យនឹកឃើញកុមារភាពរបស់ខ្ញុំនៅពេលខ្មែរក្រហមបិទសាលាទាំងអស់។ នៅថ្ងៃដំបូងមានកុមារ២៥នាក់បានមក។ សព្វថ្ងៃនេះយើងបម្រើក្មេងៗចំនួន ១៣០០នាក់ហើយខ្ញុំទទួលបានការទទួលស្គាល់ជាអន្តរជាតិសម្រាប់ការងាររបស់ខ្ញុំ។ នេះគឺជាហានិភ័យមួយដែលខ្ញុំមិនដែលស្ទាក់ស្ទើរក្នុងការទទួលយកទេ ព្រោះខ្ញុំដឹងនៅក្នុងចិត្តថាវាគឺជារឿងត្រឹមត្រូវដែលត្រូវតែធ្វើ។ ដោយសារខ្ញុំបានធ្វើអ្វីៗ ដើម្បីការពារអ្វីដែលខ្ញុំពិតជាឱ្យតម្លៃ ក្មេងៗទាំងអស់នោះនឹងមានអនាគតល្អនៅថ្ងៃមុខ។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

ប្រទេសកម្ពុជាគឺជាប្រទេសកំពុងរីកចម្រើនដែលមានប្រជាជនវ័យក្មេង។ យើងត្រូវការបន្ទូវដំណោះស្រាយនិងផលិតផលថ្មីប្រកបដោយភាពច្នៃប្រតិដ្ឋ។ ជាមួយនឹងការណែនាំអំពីបច្ចេកវិទ្យារបស់បណ្តាប្រទេសដទៃទៀត ខ្ញុំជឿជាក់ថាក្មេងៗជាច្រើននឹងត្រូវបានបំផុសគំនិតឱ្យក្លាយទៅជាសហគ្រិន។ យើងគឺជាប្រទេសដែលពោរពេញទៅដោយទេពកោសល្យ ហើយនឹងតាមទាន់ពិភពលោកជាមួយនឹងការច្នៃប្រតិដ្ឋនិងសហគ្រិនភាព។

វប្បធម៌កម្ពុជាក៏ជាវប្បធម៌មួយ ដែលប្រជាជនផ្តោតលើការដឹងគុណ និងវិធីដែលយើងអាចទទួលប្រយោជន៍ច្រើនបំផុតពីអ្វីដែលត្រូវបានផ្តល់ដល់យើង។ មិត្តភក្តិស៊ុយអែតរបស់ខ្ញុំកំពុងសិក្សាពី ឥទ្ធិពលដែលកតញ្ញូមានលើភាពជាសហគ្រិន ហើយគាត់បានរកឃើញប្រទេសកម្ពុជាជាគំរូដ៏ល្អមួយនៃប្រទេសដែលប្រជាជនវ័យក្មេងប្រើអំណាចនៃការដឹងគុណដើម្បីក្លាយជាសហគ្រិន។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

ដំបូន្មានរបស់ខ្ញុំគឺត្រូវមានក្តីសុបិន មិនថាមានអ្វីទេ ចូរបន្តធ្វើការឆ្ពោះទៅរកក្តីសុបិននោះ។ ប្រសិនបើអ្នកបរាជ័យ សូមបន្តងើបឈរហើយព្យាយាម។ ក្តីសុបិនមិនអាចត្រូវបានសម្រេចក្នុងពេលមួយថ្ងៃទេហើយអ្នកអាចរៀនពីភាពបរាជ័យរបស់អ្នក។ WK



អ្នកដឹកនាំស្ត្រីនៃកម្ពុជា

# លោកជំទាវ ជា ស៊ុនដាណែត

## អនុរដ្ឋលេខាធិការ | ក្រសួងព័ត៌មាន





*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត ?*

ខ្ញុំកើតនៅឆ្នាំ ១៩៥៨។ ឪពុកម្តាយរបស់ខ្ញុំគឺជាម្ចាស់អាជីវកម្ម ហើយខ្ញុំបានរៀបការជាមួយបុរសម្នាក់ដែលជាបុគ្គលិករដ្ឋ ហើយគាត់បានស្លាប់ក្នុងរបបប៉ុលពត។ ចាប់ពីឆ្នាំ ១៩៧០-១៩៧៥ ខ្ញុំបានបញ្ចប់ថ្នាក់សិក្សាទុតិយភូមិនៅវិទ្យាល័យឥន្ទ្រទេវី។ នៅចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៨១ ខ្ញុំបានធ្វើជាមន្ត្រីពិធីការនៅកាសែតកម្ពុជា។ មួយឆ្នាំក្រោយមក ខ្ញុំត្រូវបានគេតែងតាំងជាអ្នកនិពន្ធនិងអ្នកយកព័ត៌មានសម្រាប់កាសែតរដ្ឋ។ ខ្ញុំបានផ្សព្វផ្សាយយ៉ាងសកម្មអំពីការងារប្រព័ន្ធផ្សព្វផ្សាយនៅក្នុងអង្គភាពរបស់ខ្ញុំ។ ជាលទ្ធផល ខ្ញុំត្រូវបានដំឡើងឋានៈជាប្រធានការិយាល័យព័ត៌មាននៅកាសែតកម្ពុជាឆ្នាំ ១៩៩២។ ខ្ញុំត្រូវបានគេផ្តល់តួនាទីយ៉ាងសំខាន់ក្នុងការដំណើរការកម្មវិធីស្ត្រីរបស់អ៊ុនតាក់។ ក្នុងនាមជាបុគ្គលិករដ្ឋាភិបាលដែលមានទេពកោសល្យ នៅពេលនោះខ្ញុំបានទទួលការបណ្តុះបណ្តាលពីអ្នកឯកទេសប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិជាច្រើនខណៈពេលដែលមិនមានការអប់រំវិជ្ជាជីវៈសារព័ត៌មានជាផ្លូវការនៅឡើយទេក្នុងប្រទេសកម្ពុជា។ ជាមួយនិងនារីចំនួន៤នាក់ផ្សេងទៀតដែលបានប្តេជ្ញាចិត្តក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ យើងបានបង្កើតវិទ្យុស្ត្រីនៅមជ្ឈមណ្ឌលព័ត៌មានស្ត្រី(WMC) នៅឆ្នាំ ១៩៩៥។ វាត្រូវបានគេចាត់ទុកថាជាស្ថានីយវិទ្យុអព្យាក្រឹតដំបូងគេនៅក្នុងប្រទេសបន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ វិទ្យុនេះទទួលបានអាជ្ញាប័ណ្ណផ្សព្វផ្សាយពីក្រសួងព័ត៌មានក្នុងឆ្នាំ ១៩៩៩។

> **“ពេលស្ត្រីទទួលបានការបណ្តុះបណ្តាលផ្នែកដឹកនាំ ពួកគេអាចលូតលាស់ក្នុងអាជីវកម្មរបស់ពួកគេ**

WMC របស់យើងបានទទួលការគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញអង់គ្លេសលោក Roy Head និងអ្នកពិគ្រោះយោបល់អាម៉េរិកពីររូបផ្សេងទៀត។ បន្ទាប់មកក្រុមការងារជាតិត្រូវបានពង្រីកពីវិទ្យុដោយឱ្យមានជំនាញបន្ថែមទៀតលើទូរទស្សន៍ការភ្ជាប់បណ្តាញ និងការធ្វើយុទ្ធនាការផ្សព្វផ្សាយផ្សេងៗទៀត។ ក្នុងឆ្នាំ ២០០៩ ខ្ញុំទទួលខុសត្រូវចំពោះនាយកផ្នែកផលិតកម្មវិទ្យុទូរទស្សន៍។ ចាប់ពីឆ្នាំ ២០១១ រហូតដល់ឆ្នាំ២០១៨ ខ្ញុំត្រូវបានដំឡើងឋានៈជានាយកប្រតិបត្តិរបស់ WMC ។ ខ្ញុំឈប់ធ្វើការនៅ WMC នៅចុងឆ្នាំ២០១៨ ហើយឥឡូវនេះខ្ញុំបានប្តូរវិទ្យុស្ត្រី១០២ ទៅជាសហគ្រាសសង្គមដែលខ្ញុំជានាយកគ្រប់គ្រងផ្ទាល់។ ខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងការជំរុញសិទ្ធិប្រជាធិបតេយ្យនិងសិទ្ធិស្ត្រីនៅកម្ពុជា។ ថ្មីៗនេះខ្ញុំត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងព័ត៌មាន។ ក្នុងនាមជាមន្ត្រីជាន់ខ្ពស់ខ្ញុំត្រូវទទួលបន្ទុកជាអនុគណៈកម្មការឃ្លាំមើលវិទ្យុ FM ។ ខ្ញុំក៏ចូលរួមផងដែរនៅក្នុងគណៈកម្មាធិការសិទ្ធិកុមារនៅក្នុងក្រសួង។ បន្ថែមលើតួនាទីនេះខ្ញុំត្រូវបានតែងតាំងជាអនុប្រធានសមាគមនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍។ ខ្ញុំមានមោទនភាពខ្លាំងណាស់ដែលបានធ្វើជាស្ត្រីបម្រើដល់ស្ត្រីខ្មែរជាច្រើន។ ការលើកកម្ពស់សិទ្ធិស្ត្រីគឺជាកត្តាសំខាន់នៃការងាររបស់ខ្ញុំ។

*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ ?*

- គ្រួសាររបស់ស្ត្រី ជាពិសេសបុរស មិនឱ្យតម្លៃការងារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព្រោះពួកគេគិតថាការងារនេះមានការប្រឈមខ្ពស់ក៏ដូចជាមានគ្រោះថ្នាក់ហើយមិនបានប្រាក់ចំណូលខ្ពស់ផងដែរ។
- នារីធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយមិនមានពេលច្រើនដើម្បីចំណាយជាមួយគ្រួសារនិងមើលថែរក្សាផ្ទះទេ។ ខ្ញុំប្រឈមមុខនឹងការលំបាកក្នុងការជ្រើសរើសស្ត្រីសម្រាប់សហគ្រាសរបស់ខ្ញុំក៏ដូចជានៅក្រសួងព័ត៌មាន។ ខ្ញុំត្រូវផ្តល់ឱ្យពួកគេនូវការហ្វឹកហាត់ការងារដោយខ្លួនឯង។ ក្រុមរបស់ខ្ញុំខ្លះអាចត្រូវបានបញ្ជូនឱ្យមានការបណ្តុះបណ្តាលនៅបរទេស។
- បញ្ហាប្រឈមមួយទៀតគឺការបង្កើនមូលនិធិនិងការសរសេរសំណើ។ ដើម្បីដឹកនាំអង្គភាព ខ្ញុំត្រូវប្រមូលថវិកានិងការវិនិយោគដើម្បីទ្រទ្រង់ប្រតិបត្តិការនិងកំណើននាពេលអនាគត។ លើសពីនេះទៅទៀត ខ្ញុំមិនមានជំនាញគ្រប់គ្រាន់ក្នុងភាពជាអ្នកដឹកនាំដើម្បីគ្រប់គ្រងបុគ្គលិកទាំងបរទេសនិងខ្មែរទេនៅពេលខ្ញុំចាប់ផ្តើមអាជីពរបស់ខ្ញុំដំបូង។
- បន្ទាប់ពីលាលែងពីអង្គការក្រៅរដ្ឋាភិបាលដើម្បីបង្កើតសហគ្រាសសង្គមនៅឆ្នាំ២០១៨ ខ្ញុំប្រឈមនឹងបញ្ហាជាច្រើនក្នុងការរកប្រាក់ចំណូលនិងការដឹកនាំ។ ទន្ទឹមនឹងនេះខ្ញុំត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងព័ត៌មាន។ ខ្ញុំត្រូវសិក្សានិងដោះស្រាយភារកិច្ចប្រកបដោយវិជ្ជាជីវៈ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

- ការប្រជែងខ្លួនឯង និងអ្នកដទៃដោយការរៀនសូត្រ (វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ គ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងការផ្លាស់ប្តូរនិងច្រើនទៀត)៖ អស់រយៈពេលជាច្រើនទសវត្សរ៍មកនេះ ខ្ញុំនៅតែកំពុងបន្តការរៀនធ្វើជាអ្នកដឹកនាំ ដែលមានប្រសិទ្ធភាពដែលអាចដឹកនាំភារកិច្ចស្មុគស្មាញ ក្នុងប្រព័ន្ធផ្សព្វផ្សាយរួមទាំងវិទ្យុ ទូរទស្សន៍ និងអ៊ីនធឺណិត។ ស្ត្រីកម្ពុជាដែលស្ថិតនៅក្រោមសម្ពាធ បានដើរតួយ៉ាងសំខាន់ ក្នុងនាមជា ម្តាយ និងភរិយាល្អ និងថែរក្សាគ្រួសាររបស់ពួកគឱ្យបានត្រឹមត្រូវ។ ខ្ញុំបន្តធ្វើការដើម្បីផ្លាស់ប្តូរគំនិតបែបប្រពៃណីដោយបង្ហាញពួកគេនូវគំរូ របស់ខ្ញុំ។
- ការកសាងនូវក្រុមធនធានស្ត្រីឱ្យបានល្អ៖ ខ្ញុំកំពុងព្យាយាមជ្រើសរើសស្ត្រីដែលមានទេពកោសល្យបន្ថែមទៀត និងកសាងសមត្ថភាពរបស់ពួកគេក្នុងការជំរុញសមភាពយេនឌ័រ និងសិទ្ធិស្ត្រីនៅក្នុងសង្គម។ វាបង្ហាញឱ្យបុរសបានឃើញថា ស្ត្រីអាចធ្វើបានច្រើនជាងអ្វីដែលគេរំពឹងទុក។

### *តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវ ហើយតើលោកជំទាវធានាថាក្នុងក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច ?*

- តម្លៃស្នូលរបស់ខ្ញុំគឺត្រូវធ្វើការដើម្បីស្ត្រី៖ អ្វីដែលខ្ញុំធ្វើដោយឯកជនឬសម្រាប់ក្រសួងព័ត៌មាន សិទ្ធិស្ត្រីនិងយេនឌ័រ គឺជាការផ្តោតសំខាន់របស់ខ្ញុំ។ យើងផ្សព្វផ្សាយយ៉ាងទូលាយ និងសកម្មអំពីចំណេះដឹងនិងបទពិសោធន៍ នៃសិទ្ធិរបស់ស្ត្រី ហើយធានាថាក្រុមការងាររបស់យើងបានយល់ដឹងច្បាស់អំពីតម្លៃស្នូលរបស់យើង។
- ទំនួលខុសត្រូវដោយខ្លួនឯងនិងគណនេយ្យភាពសង្គម៖ មនុស្សគ្រប់គ្នាទទួលខុសត្រូវចំពោះការអនុវត្តរបស់ពួកគេដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនក្រសួង និងសង្គម។ យើងចាត់វិធានការនិងផលិតកម្មវិធីវិទ្យុដើម្បីជួយដល់សង្គមនិងរដ្ឋាភិបាលដោយមានដៃគូខ្លាំងក្លាជាមួយវិស័យឯកជន។

### *តើអ្វីខ្លះជាអាកប្បកិរិយា ឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

- ងាយនិងសាមញ្ញពេក៖ អ្នកដឹកនាំល្អត្រូវមានភាពបត់បែននៅក្នុងការដឹកនាំមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនគួរមានភាពងាយស្រួលនិងសាមញ្ញពេកទេដែលធ្វើឱ្យអ្នកដើរតាមនិងអ្នកក្រោមបង្គាប់អាចធ្វើអ្វីគ្រប់យ៉ាងនៅក្នុងក្រុមហ៊ុន ឬអង្គការ។ វិធាននិងគោលការណ៍ណែនាំ / បញ្ញត្តិមួយចំនួនត្រូវតែមាន និងត្រូវអនុវត្តឱ្យល្អ។
- មានមោទនភាពពេកចំពោះអ្វីដែលពួកគេកំពុងធ្វើ៖វាជាការលើកទឹកចិត្តឱ្យមានមោទនភាពចំពោះសមិទ្ធផលយើង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមេដឹកនាំមានមោទនភាពនិងបង្អាញអ្នកដទៃច្រើនពេកពួកគេប្រហែលជាមើលរំលងនូវរឿងសំខាន់ៗដែលក្រុមរបស់ពួកគេឬអ្នកដទៃលើកមក។
- ការខ្សោយជំនាញទំនាក់ទំនង៖ ជំនាញទំនាក់ទំនងល្អគឺជាចំណុចសំខាន់បំផុតមួយ សម្រាប់អ្នកដឹកនាំដែលគួរតែមាន។ វាមិនសំខាន់ទេថាតើផែនការដែលអ្នកដឹកនាំ អាចអភិវឌ្ឍបានមានផលធំប៉ុនណា ប្រសិនបើពួកគេមិនអាចធ្វើការទំនាក់ទំនងផែនការនោះ ទៅបុគ្គលិកឬអ្នកដើរតាមរបស់ពួកគេ ដោយងាយស្រួលយល់នោះលទ្ធផលនឹងបានមកតិចជាងការគិតចង់បាន។

### *តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ ( គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញ និងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ ) ?*

- យល់ពីអាជីវកម្មដែលយើងកំពុងគ្រប់គ្រង
- សមត្ថភាពអ្នកដឹកនាំ។ អ្នកដឹកនាំត្រូវតែមានសមត្ថភាពដឹកនាំមនុស្សហើយជំរុញពួកគេឱ្យបំពេញភារកិច្ចដែលពួកគេបានកំណត់។

### *តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា ?*

- ហានិភ័យចម្បងដែលខ្ញុំបានជួបប្រទះមកទល់ពេលនេះគឺការបរាជ័យក្នុងការជ្រើសរើសបុគ្គលិកដែលមានទេពកោសល្យ និងមានការប្តេជ្ញាចិត្ត ជាពិសេសផ្នែកទីផ្សារនិងលក់។
- បញ្ហាប្រឈមទី ២គឺ ការស្វែងរកអ្នកឧបត្ថម្ភ។ ខ្ញុំត្រូវធ្វើវាដោយខ្លួនឯងហើយអតិថិជន និងអង្គការជាច្រើនទាមទារឱ្យខ្ញុំធ្វើការដោយផ្ទាល់ជាមួយពួកគេ។

### *តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាព និងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ប្រជាជនកម្ពុជាមានភាពរួសរាយរាក់ទាក់ និងមានការច្នៃប្រតិដ្ឋថ្មីដើម្បីប្រឈមមុខនឹងការប្រកួតប្រជែង ដូចដែលបានឃើញសមិទ្ធផលដ៏ធំធេងរបស់បុព្វការីខ្មែររបស់យើងក្នុងសម័យអង្គរ។ យើងសម្បូរទៅដោយវប្បធម៌ និងតំបន់ភូមិសាស្ត្រដែលមានបឹងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍និងមានសមុទ្រដ៏ធំធេង។ វាមានគុណសម្បត្តិប្រៀបធៀបសម្រាប់អាជីវកម្មនៅក្នុងតំបន់។ រដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់អាជីវកម្មក្នុងស្រុក និងការវិនិយោគដែលអាចរក្សាអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅឆ្នាំ២០១៨បាន ៧%។ ឧទាហរណ៍ នៅពេលដែលរដ្ឋាភិបាលផ្តល់ការគាំទ្រដល់សហ



គ្រិន (ឧទាហរណ៍ការលើកទឹកចិត្តពន្ធ) ពួកគេបានកសាងសមត្ថភាពរបស់មន្ត្រីសាធារណៈ ដែលផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងសម្រាប់ប្រជាជនទូទៅ។ដូចគ្នានេះដែរម្ចាស់អាជីវកម្មក្នុងស្រុកអាចពង្រីកអាជីវកម្មរបស់ខ្លួនទៅក្រៅប្រទេស និងបណ្តាក់ទុនរួមគ្នាជាមួយអ្នកវិនិយោគ។ ជាការពិតណាស់សហគ្រិនត្រូវតែសិក្សាអំពីភាពជាអ្នកដឹកនាំនិងភាពជាសហគ្រិន។ ក្រុមហ៊ុននឹងរឹងមាំនៅពេលដែលពួកគេផ្តល់ជូននូវផលិតផលដែលមានគុណភាពខ្ពស់និងសេវាកម្មស្តង់ដារដល់អតិថិជន និងសាធារណជន។ ប្រសិនបើយើងមានប្រជាជនកម្ពុជាកាន់តែច្រើនដែលទិញនិងប្រើប្រាស់ផលិតផលក្នុងស្រុក វានាំទៅរកកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។

### *លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

សហគ្រិនស្ត្រីត្រូវមានភាពក្លាហានគ្រប់គ្រាន់ដើម្បីបង្ហាញពីខ្លួនឯង និងសមិទ្ធផលរបស់ពួកគេ និងមានមោទនភាពក្នុងការក្លាយជាស្ត្រីរឹងមាំ។ សំខាន់ដូចគ្នានេះដែរ ពួកគេត្រូវរួមចំណែកដល់សង្គមដោយផ្តល់ជំនាញនិងបទពិសោធន៍របស់ពួកគេដល់មនុស្សជំនាន់ក្រោយ។ ទន្ទឹមនឹងនេះដែរស្ត្រីត្រូវតែស្វែងរកការគាំទ្រនិងចូលរួមកម្មវិធីកសាងសមត្ថភាព ដើម្បីប្រើប្រាស់ជំនាញភាពជាអ្នកដឹកនាំរបស់ពួកគេ។ ខ្ញុំសង្កេតឃើញថា នៅពេលស្ត្រីទទួលបានការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងវគ្គសិក្សាអាជីវកម្មផ្សេងទៀត ពួកគេអាចធ្វើឱ្យរីកចម្រើនអាជីវកម្មរបស់ពួកគេហើយមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងរបៀបដែលពួកគេកំពុងធ្វើអាជីវកម្ម។ WK

# លោកស្រី សេង តក្កនារី

## ស្ថាបនិក និងនាយិកាគ្រប់គ្រង | សន្តុសាសៀល



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំបានរៀបការនិងមានកូនបីនាក់។ ស្វាមីខ្ញុំគឺជាអ្នកដែលបំផុសគំនិតខ្ញុំឱ្យបើកអាជីវកម្មផ្ទាល់ខ្លួន។ កូនច្បងរបស់ខ្ញុំគឺជានារីវ័យក្មេងម្នាក់ដែលបញ្ចប់ការសិក្សាផ្នែករចនាម៉ូដដែលកំពុងផ្តោតទៅលើម៉ូដផ្ទាល់ខ្លួនរបស់ពួកគាត់។ ខ្ញុំក៏មានកូនពីរនាក់ ដែលបច្ចុប្បន្នម្នាក់កំពុងធ្វើការជាអ្នកគ្រប់គ្រង ហើយកូនពៅរបស់ខ្ញុំគឺជានិស្សិតសាកលវិទ្យាល័យ។ ម្តាយរបស់ខ្ញុំរស់នៅជាមួយយើងហើយជួយចិញ្ចឹមកូនៗរបស់ខ្ញុំពេលដែលស្វាមីខ្ញុំនិងខ្ញុំកំពុងធ្វើការលើអាជីវកម្មរបស់យើង។ សរុបមកខ្ញុំជាមនុស្សដែលមានសុភមង្គលក្នុងការរៀបការនិងមានសុភមង្គលក្នុងគ្រួសារ ខ្ញុំកំពុងព្យាយាមក្លាយជាមនុស្សល្អដើម្បីជួយអ្នកដទៃ។

ខ្ញុំជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ចហើយការងារដំបូងរបស់ខ្ញុំគឺធ្វើការជាមួយក្រុមហ៊ុនជប៉ុន។ បទពិសោធន៍នេះបានផ្តល់ឱ្យខ្ញុំនូវវិន័យនិងការលើកទឹកចិត្តជាច្រើន ប៉ុន្តែខ្ញុំតែងតែមានស្មារតីសហគ្រិន ដូច្នេះនៅពេលខ្ញុំឃើញសូត្រដ៏ស្រស់ស្អាតនៅហាងទំនិញមួយនៅព្រលានយន្តហោះក្នុងអំឡុងពេលធ្វើដំណើរ វាបានផ្តល់គំនិតឱ្យខ្ញុំ។ ខ្ញុំបាននិយាយទៅកាន់ខ្លួនឯងថាប្រទេសរបស់យើងរឹងមាំនៅក្នុងការផលិតសូត្រ ដូច្នេះហេតុអ្វីខ្ញុំមិនជួយស្តារឧស្សាហកម្មសូត្រ?

ខ្ញុំចាប់ផ្តើមធ្វើតាមចំណង់ចំណូលចិត្តនិងការស្រឡាញ់វប្បធម៌របស់យើងដោយបង្កើត សន្តុសាសៀលនៅឆ្នាំ ២០០៤។ យើងបានចាប់ផ្តើមប្រតិបត្តិការនៅលើផ្ទះល្វែងតូចមួយដែលស្ថិតនៅតាមដងផ្លូវដ៏មមាញឹកមួយនៅតាមបណ្តោយមាត់ទន្លេ។ តាំងពីដំបូងមកខ្ញុំប្តេជ្ញាផ្តល់ឱកាសដល់ជនពិការក្នុងតំបន់និងជួយលើកកម្ពស់សុខុមាលភាពរបស់ពួកគេដោយផ្តល់ឱ្យពួកគេនូវការងារ។ សន្តុសាសៀល បានចាប់ផ្តើមជាមួយបុគ្គលិកពិការចំនួន ២នាក់មក




ពីអង្គការជាតិជនពិការកម្ពុជា(NCDP)។ ចាប់តាំងពីពេលនោះមកអ្នកទាំងពីរបានក្លាយជាគ្រូបង្ហាត់/គ្រូបង្រៀននៅសន្តុសាសៀល ហើយមានមុខជំនួញ

និងសេវាកម្មកាត់ដេរផ្ទាល់ខ្លួន។ យើងក៏បានក្លាយជាក្រុមទីមួយដែលត្រូវបានជួយគាំទ្រដោយ IFC/ធនាគារពិភពលោកក្រោមគម្រោងរបស់ពួកគេ

ដែលហៅថា"CraftNetwork`` ដែលផ្តល់ឱ្យយើងនូវលទ្ធភាពទទួលបានទីផ្សារអន្តរជាតិ។ នៅពេលដែលក្រុមហ៊ុនបានរីកចម្រើនជនពិការកាន់តែច្រើនត្រូវបានគេផ្តល់ឱកាសឱ្យមានការងារសមរម្យ។ លើសពីនេះទៅទៀតនិស្សិតវ័យក្មេងពីគ្រួសារក្រីក្រដែលមានបំណងចង់រៀនសូត្រ ត្រូវបានផ្តល់ឱកាសដើម្បីទទួលបានការបណ្តុះបណ្តាលតាមរយៈសន្តុសាសៀល ហើយប្រជាជនវ័យក្មេងកាន់តែច្រើនអាចមានបទពិសោធន៍ជំនាញផ្នែកគ្រប់គ្រង។ លើសពីនេះទៀត សិប្បករនិងអ្នកតម្បាញនៅតាមបណ្តាខេត្តផ្សេងៗត្រូវបានបង្កើតជាសហគ្រិនដោយផ្តល់ប្រាក់ចំណូលប្រកបដោយនិរន្តរភាពដល់សហគមន៍របស់ពួកគេ។

យើងមានបំណងធ្វើឱ្យវិស័យនេះមានឥទ្ធិពលដល់សង្គមកម្ពុជាតាមរយៈការលើកកម្ពស់សូត្រនិងវប្បធម៌កម្ពុជាក៏ដូចជាផ្តល់ដល់ស្ត្រីនិងប្រជាជនដែលមានជីវភាពមិនសូវធូរធារ ដោយធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេនិងនាំឱ្យគ្រួសាររាប់ពាន់គ្រួសារចៀសផុតពីភាពក្រីក្រ។ ផលិតផលសូត្រដែលមានគុណភាពខ្ពស់និងសេវាកម្មឯកសណ្ឋានគឺជាវិស័យមួយសម្រាប់បំពេញក្តីសុបិនរបស់យើង។ ខ្ញុំពិតជាមោះមុតក្នុង ការអភិវឌ្ឍជំនាញរបស់ប្រជាជនកម្ពុជានិងធ្វើការលើវិថីប្រកបដោយចីរភាពដើម្បីពង្រីកនិងផ្តល់ការងារដល់ពួកគេ។

ដោយសារតែភាពខ្ជាប់ខ្ជួននិងចំណង់ចំណូលចិត្តដើម្បីលើកកម្ពស់ផលិតផលឆើតឆាយរបស់ប្រទេសយើង យើងទទួលបានពានរង្វាន់ជាច្រើនក្នុងស្រុកតំបន់ និងអន្តរជាតិ។ ខ្ញុំមានមោទនភាពខ្លាំងណាស់ដែលយើងគឺជាក្រុមហ៊ុនដំបូងគេដែលបានចុះឈ្មោះផលិតផល Ikat របស់យើងនៅក្នុងក្រសួងសិប្បកម្មសម្រាប«កម្មសិទ្ធិបញ្ញា»។ សន្តុសាសៀល គឺជាអាជីវកម្មគ្រប់គ្រងដោយស្ត្រីដំបូងគេនៅក្នុងប្រទេសកម្ពុជាដែលបានក្លាយជាសមាជិកនៃសហភាពសូត្រអន្តរជាតិ(ISU) ។

គ្រាមួយដែលខ្ញុំមិនអាចបំភ្លេចបានគឺនៅពេលដែលខ្ញុំត្រូវបានជ្រើសរើស

ឱ្យធ្វើជាតំណាងឱ្យប្រទេសរបស់ខ្ញុំនៅក្នុងវេទិកាសាធារណៈរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុងហ្សឺណែវ។ ដូចគ្នានេះដែរ ខ្ញុំបានតំណាងឱ្យកម្ពុជានិងសហគ្រិនស្ត្រីកម្ពុជា ក្នុងកិច្ចពិភាក្សាអាស៊ានផ្សេងៗ។ ខ្ញុំជាសហស្ថាបនិកម្នាក់ក្នុងចំណោមសហគ្រិន១៤នាក់ទៀតនៃសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA)និងជាប្រធានសមាគមនារី និងសមាគមសិប្បករកម្ពុជា (AAC) ។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី ?*

បញ្ហាប្រឈមទី១ របស់ខ្ញុំគឺនៅពេលដែលយើងទទួលបានការបញ្ជាទិញដុំពី World of Goods ។ នៅឆ្នាំ ២០០៥ យើងមិនបានទទួលការបញ្ជាទិញច្រើនទេហើយយើងមិនមានចំណេះដឹងផ្នែកបច្ចេកទេសនៅឡើយ។ ដូច្នេះនៅពេលយើងទទួលបានការទទួល ទិញជាច្រើនដុំ វាហាក់ដូចជាបញ្ហាប្រឈមដែលមិនអាចទៅរួចនោះទេតែដោយសារតែមានការគាំទ្រពីធនាគារពិភពលោក យើងបានក្លាយជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុន៩ ដំបូងដែលត្រូវបានគេរាប់បញ្ចូល នៅក្នុងការសាកល្បងនៃ«ការនាំចេញទំនិញទៅសហរដ្ឋអាម៉េរិក» ហៅថា CraftNetwork ។ កម្មវិធីនេះគឺជាច្រកផ្លូវទៅកាន់ទីផ្សារថ្មីៗហើយជួយឱ្យយើងកែលម្អគុណភាពនៃក្រណាត់របស់យើង។

ដោយសារតែវាជាលើកដំបូងរបស់ខ្ញុំក្នុងការបើកអាជីវកម្មខ្ញុំក៏មានការលំបាកក្នុងការបណ្តុះបណ្តាលបុគ្គលិកពីព្រោះខ្ញុំមិនមានពេលទំនេរ។ ខ្ញុំតែងតែជាប់រវល់ជាមួយនឹងការសាកសួរផ្សេងៗ បញ្ហាផលិតកម្ម ហើយមិនដឹងថាត្រូវចាប់ផ្តើមពីកន្លែងណាដើម្បីកសាងចំណេះដឹងបច្ចេកទេសរបស់បុគ្គលិក។ នៅពេលនោះយើងមិនមានមនុស្សដែលមានជំនាញគ្រប់គ្រងត្រឹមត្រូវដែលអាចជួយខ្ញុំក្នុងការរៀបចំរចនាសម្ព័ន្ធរបស់យើងទេហើយយើងក៏ត្រូវដោះស្រាយជាមួយនឹងការខ្វះវិន័យរបស់បុគ្គលិកផងដែរ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ខ្ញុំជឿថា"គ្មានការឈឺចាប់ គ្មានការចំណេញទេ"។ អ្នកត្រូវប្រើគំនិតត្រិះរិះមុននឹងធ្វើការសម្រេចចិត្ត។ ការដឹកនាំមានន័យថាជាការផ្តល់ឱ្យ មិនមែនជាការក្រសោបយកទេ។ មេរៀនសំខាន់បំផុតអំពីភាពជាអ្នកដឹកនាំគឺត្រូវមានចិត្តរាបទាបនិងទទួលបាននូវមតិផ្សេងៗដើម្បីឱ្យអ្នកអាចធ្វើបានល្អជាងមុន។ ជាមួយនឹងភាពរាបសា អ្នកអាចជួយអ្នកដទៃដោយពិតប្រាកដនិងស្មោះត្រង់ជាមួយពួកគេ។ វាក៏សំខាន់ផងដែរក្នុងការធ្វើឱ្យមនុស្សរបស់អ្នកក្លាយជាផ្នែកមួយនៃដំណើរការសម្រេចចិត្ត។ អតិថិជនរបស់ខ្ញុំ មិត្តភក្តិនិងបុគ្គលិកគឺជាដៃគូអាជីវកម្មរបស់ខ្ញុំទាំងអស់។ យើងគួរតែសាងសង់តុវែងមួយដែលមនុស្សគ្រប់គ្នាអាចអង្គុយនិងហូបបាយបាន មិនមែនធ្វើរបងខ្ពស់ដែលរារាំងមនុស្សមិនឱ្យចូលនោះទេ។ ការកសាងរបងរវាងខ្លួនអ្នកនិងអ្នកដែលត្រូវការអ្នកនឹងបំបែកអ្នកចេញពីតថភាព ហើយអ្នកនឹងនៅតែម្នាក់ឯង



## “ មេរៀនដំបូងបំផុតក្នុងការដឹកនាំគឺការចេះបន្ទាបខ្លួននិងចេះទទួលយកការរិះគន់

នៅលើហ៊ឹងខ្ពស់ដែលបានបង្កើតដោយការភ័ន្តច្រឡំរបស់អ្នក។ តម្លាភាពនិងទំនាក់ទំនងនឹងធ្វើឱ្យអ្នកមានសេរីភាព។ ត្រូវស្វែងរកគំនិតរបស់អ្នកដទៃហើយកុំចង់បានគុណសម្បត្តិ ប្រសិនបើអ្នកមិនមែនជាអ្នកបង្កើតវា។ ត្រូវតែទទួលស្គាល់អ្នកដែលបានជួយអ្នកឱ្យទទួលបានជោគជ័យ។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

សម្រាប់ពួកយើងគុណភាពគឺជាការចាំបាច់វាមិនត្រឹមតែទាក់ទាញអតិថិជនថ្មីប៉ុណ្ណោះទេ ប៉ុន្តែវាក៏ដើម្បីជួយរក្សាកេរ្តិ៍ឈ្មោះល្អរបស់យើងនៅក្នុងទីផ្សារផងដែរ។ យើងជឿជាក់ថាអាជីវកម្មដែលទទួលបានជោគជ័យត្រូវបានកសាងឡើងតាមរយៈការបណ្តុះទំនាក់ទំនងយូរអង្វែងដែលមានមូលដ្ឋានលើជំនឿទុកចិត្តគ្នាទៅវិញទៅមក វិជ្ជាជីវៈ និងការយោគយល់។ យើងក៏ជឿជាក់លើការបង្កើតឱកាសការងារសម្រាប់ស្ត្រីដែលគ្មានលទ្ធភាពបង្រៀនពួកគេពីរបៀបត្បាញឬកាត់ដេរសម្លៀកបំពាក់ស្របពេលផ្តល់នូវបរិយាកាសការងារល្អមួយ។
តម្លៃស្នូលរបស់យើងគឺៈ

១ ភាពសុចរិត
២ ការលូតលាស់និងការច្នៃប្រតិដ្ឋ
៣ ការអាណិតអាសូរ និងការងារក្រុម
៤ ការគោរពដល់មនុស្ស វប្បធម៌ និងបរិស្ថាន
៥ ការប្រកាន់ខ្ជាប់នូវគោលការណ៍ទាំង១០ស្តីពីការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌

### *តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ?*

ខ្ញុំគិតថាមេដឹកនាំគួរតែមានទស្សនវិស័យវែងឆ្ងាយ។ ត្រូវចេះមើលទិដ្ឋភាពទូទៅនៃទីដែលអ្នកចង់ទៅដល់។ ការទុកចិត្តមនុស្សនិងការបែងចែកការងារគឺជាការចាំបាច់។ ប្រសិនបើអ្នកធ្វើឱ្យខ្លួនរវល់ពេកអ្នកនឹងបាត់បង់ចក្ខុវិស័យខ្លួនឯង។ វាក៏ជាគំនិតមិនល្អដែរ នៅពេលដែលអ្នកប្រៀបធៀបរបៀបដឹកនាំរបស់ខ្លួនជាមួយអ្នកដទៃ។ មនុស្សគ្រប់រូបគឺខុសៗគ្នា ហើយមនុស្សគ្រប់គ្នាកំពុងព្យាយាមរៀនសូត្រឱ្យកាន់តែប្រសើរឡើង។ មេដឹកនាំគួរតែរក្សាឥរិយាបថមានវិជ្ជាជីវៈ ដោយផ្តោតលើគោលដៅអាជីវកម្មនិងចៀសវាងការនិយាយដើមគ្នា។

កុំឈប់រៀន។ រាល់ថ្ងៃគឺជាថ្ងៃថ្មីហើយអ្នកនឹងមានមេរៀនមួយដើម្បីរៀនជានិច្ច។ កុំមានមោទនភាពពេកចំពោះខ្លួនអ្នក។ ដាក់ជើងរបស់អ្នកឱ្យដល់ដីហើយរៀនចេះបន្ទាបខ្លួន។ អ្នកគួរដឹងពីរបៀបស្តាប់ និងកុំនិយាយច្រើនពេក។ យើងត្រូវតែមានសមត្ថភាពក្នុងការមើលឃើញទស្សនៈរបស់អ្នកដទៃ។

កុំធ្វើកំហុសដដែលៗពីរដង។ អ្នកដឹកនាំល្អរៀនពីកំហុសនិងបទពិសោធន៍ជាច្រើន។ អ្នកដឹកនាំគួរតែបង្កើនជំនាញដោយការដោះស្រាយបញ្ហាប្រតិបត្តិការប្រចាំថ្ងៃនិងធ្វើការសម្រេចចិត្តផ្សេងៗ។ ការមិនហ៊ានសម្រេចចិត្តនឹងពន្យារពេលការងារហើយនឹងធ្វើឱ្យអ្នកបាត់បង់ឱកាស។

### *តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ)?*

ខ្ញុំធ្លាប់គ្រប់គ្រងសមាគមសហគ្រិនស្ត្រីកម្ពុជា(CWEA) ហើយជាប្រធានដំបូងនៃសមាគមនេះ។ ខ្ញុំបានតស៊ូដើម្បីឱ្យសមាគមនៅរឹងមាំទោះបីមានភាពច្របូកច្របល់ រឿងខុសឆ្គង និងការកុហកក៏ដោយ។ មានទឹកភ្នែកនិងការលំបាកជាច្រើន ប៉ុន្តែខ្ញុំមិនដែលគិតចង់បោះបង់នោះទេ ដោយសារខ្ញុំមានចក្ខុវិស័យសម្រាប់សមាគមនេះថាជាស្ថាប័នល្អមួយក្នុងការអភិវឌ្ឍអ្នកដឹកនាំស្ត្រីដ៏ល្អនៅក្នុងគ្រួសារ។ ឥឡូវនេះចក្ខុវិស័យរបស់ខ្ញុំគឺត្រូវបន្តរហូតដល់អាណត្តិរបស់ខ្ញុំចប់ ដោយគ្មានការបោះបង់ចោលកន្លែង សម្រាប់អ្នកដឹកនាំថ្មីទទួលបានការបណ្តុះបណ្តាលការអភិវឌ្ឍនិងត្រូវបានផ្តល់ឱកាសក្នុងការអនុវត្តភាពជាអ្នកដឹកនាំរបស់ពួកគេក៏ដូចជាទទួលបានបទពិសោធន៍ជាមួយនឹងការណែនាំនិងឥរិយាបថផ្លូវចិត្តនិងអាកប្បកិរិយាត្រឹមត្រូវ។ ខ្ញុំជឿជាក់ថាសមាគមសហគ្រិនស្ត្រីកម្ពុជា(CWEA) តាមរយៈការបន្តថ្នាក់ដឹកនាំថ្មីនិងអ្នកដឹកនាំគណៈកម្មាធិការដ៏សកម្មនឹងក្លាយជាសមាគមសហគ្រិនស្ត្រីធំជាងគេនិងសកម្មបំផុតនៅក្នុងប្រទេស និងមានការទទួលស្គាល់យ៉ាងខ្លាំងពីក្រសួងផ្សេងៗ។

ភាពជាអ្នកដឹកនាំមិនចេះចប់ទេហើយក៏គ្មានអាណត្តិដែរ។ មនុស្សយើងត្រូវតែដើរទៅមុខនិងបន្តយកភាពជាអ្នកដឹកនាំទៅលើវិស័យផ្សេងៗទៀតហើយមិនត្រូវបញ្ឈប់ការដឹកនាំទេត្រូវតែដឹងជានិច្ច។ ឥឡូវនេះខ្ញុំជាអ្នកណែនាំដល់ក្មេងជំនាន់ក្រោយជាពិសេសយុវជន។ ខ្ញុំគាំទ្រដល់ស្ត្រីទាំងនោះដែលធ្វើការពេលកំពុងសិក្សា និងស្វែងរកឱកាសដើម្បីរកការងារធ្វើដើម្បីបង់ថ្លៃសាលាពួកគេ។ ខ្ញុំផ្តល់ឱកាសដល់យុវវ័យហើយដាក់ពួកគេឱ្យចូលហ្វឹកហាត់ដើម្បីទទួលបាននូវបទពិសោធន៍ត្រឹមត្រូវ។ យើងត្រូវបន្តគាំទ្រនិងអប់រំស្ត្រីនៅគ្រប់កម្រិត ដែលចាប់អារម្មណ៍ក្នុងភាពជាសហគ្រិនដើម្បីបង្កើតឱកាសការងារនិងចំណូលបន្ថែមសម្រាប់ស្ត្រី។

ម៉្យាងទៀត ក្នុងនាមជាអ្នកដឹកនាំអាជីវកម្មយើងកំពុងពង្រីកប្រតិបត្តិការសូត្ររបស់យើងឱ្យទៅជាមជ្ឈមណ្ឌលវប្បធម៌និងតម្បាញបន្ថែមលើការធ្វើការងារជាមួយអ្នកតម្បាញដែលមានស្រាប់នៅក្នុងភូមិផ្សេងៗគ្នា។ យើងកំពុងថែរក្សាកន្លែងធ្វើការនៅតាមសហគមន៍របស់យើង។ ដូចគ្នានេះដែរខ្ញុំនឹងបន្តជួយដល់បុគ្គលិករបស់ខ្ញុំដើម្បីបំពេញក្តីសុបិនរបស់ពួកគេនៅពេលពួកគេនៅជាមួយខ្ញុំហើយបង្កើតឱកាសជាច្រើនទៀតសម្រាប់ពួកគេដើម្បីរៀននិងទទួលបានបទពិសោធន៍ដែលពួកគេត្រូវការ។ ខ្ញុំនឹងបន្តធ្វើការវាយតម្លៃព័ត៌មានដោយការវិនិច្ឆ័យយ៉ាងលម្អិត។ ខ្ញុំនឹងព្យាយាមទទួលយកការពិតដើម្បីដឹកនាំនិងទទួលបានការទុកចិត្តពីគ្រួសារ មិត្តភក្តិនិងមិត្តរួមការងាររបស់ខ្ញុំ។ ហើយសំខាន់បំផុត ខ្ញុំនឹងរកពេលវេលាដើម្បីអានសៀវភៅនិងចូលរួមសិក្ខាសាលាដើម្បីលើកកម្ពស់ខ្លួនឯងហើយត្រូវបានកែតម្រូវផ្នែកវិជ្ជាជីវៈផ្ទាល់ខ្លួន និងខាងស្មារតី។

### *តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា?*

មានពេលមួយដែលខ្ញុំបានវិនិយោគលើហាងលក់សម្លៀកបំពាក់នាំចូលហើយបានរកស៊ីខុស។ ខ្ញុំធ្លាប់មានហាងដែលលក់សម្លៀកបំពាក់និងស្បែកជើងនាំចូល ប៉ុន្តែចុងក្រោយខ្ញុំបានសល់អីវ៉ាន់និងស្តុកដែលលក់មិនចេញ។ ហាងនេះត្រូវបានសាងសង់ឡើងដោយមានការជួសជុលអាគារទំនើប និងបន្ទប់តាំងបង្ហាញបែបអស្ចារ្យ ប៉ុន្តែវាមិនគ្រប់គ្រាន់ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាជនឡើយ។ ឥឡូវអាជីវកម្មនេះត្រូវបានបិទ ហើយវាជាមេរៀនដ៏ធំមួយសម្រាប់ខ្ញុំ។ វាជាការគណនាតម្លៃខុសមួយចំនួនដែលធ្វើឱ្យខ្ញុំលក់ផលិតផលក្នុងតម្លៃទាបជ្រុល ដូច្នេះឥឡូវនេះយើងបានបង្កើតការគណនាចំណាយត្រឹមត្រូវមួយជាជាងការប្រើការស្មាន។ កាលពីមុនមានបុគ្គលិកចាកចេញជាច្រើន ប៉ុន្តែនៅទីបំផុតពួកគេបានត្រលប់មកសន្ទុសាសៀលវិញ។ ដូច្នេះខ្ញុំបានផ្តោតលើសូត្រនិងពង្រីកអាជីវកម្មរបស់ខ្ញុំលើសង្វាក់តម្លៃដើម្បីទ្រទ្រង់ការផ្គត់ផ្គង់វត្ថុធាតុដើមនិងផ្តល់តម្លៃសមរម្យដល់អតិថិជនរបស់ខ្ញុំ។

### *តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច?*

យើងមានបទដ្ឋានវប្បធម៌និងប្រវត្តិសាស្ត្រដែលប្លែកពីគេ។ ស្ត្រីត្រូវបានគេចាត់ទុកថាល្វតល្វន់និងស្រស់ស្អាត និងរូបរាងល្អប្រណីត។ ហើយនោះគឺដោយសារតែរហូតមកដល់ពេលនេះ យើងនៅតែប្រើប្រាស់សម្លៀកបំពាក់ប្រពៃណីរបស់យើងដែលជាសូត្រត្បាញដោយដៃដែលជាក្រណាត់ល្អបំផុតនៅក្នុងពិភពលោក។ ដោយសារមានរឿងរ៉ាវល្អៗជាច្រើននៅពីក្រោយក្រណាត់របស់យើងហើយវាកំពុងទទួលបានប្រជាប្រិយភាពខ្លាំងពេលនេះចិនកំពុងមើលឃើញពីសក្តានុពលនិងកំពុងធ្វើការអភិវឌ្ឍលើការចិញ្ចឹមដង្កូវពួកគាត់ របស់ប្រទេសកម្ពុជាដើម្បីផ្គត់ផ្គង់បន្តដោយហេតុថាប្រទេសនេះជាប្រទេសកសិកម្ម។

ប្រទេសកម្ពុជាមានទីតាំងយុទ្ធសាស្ត្រនៅក្បែរប្រទេសថៃនិងវៀតណាមហើយពាក់កណ្តាលរវាងប្រទេសចិននិងឥណ្ឌាហើយបាន ទទួលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចពីប្រទេសជិតខាងរបស់ខ្លួន។ ប្រទេសកម្ពុជាមានធនធានធម្មជាតិជាច្រើន និងតំបន់ទេសចរណ៍ល្បីល្បាញនិងមានប្រជាប្រិយភាពកំណប់រ៉ែប្រេងកាតនិងឧស្ម័នបម្រុងក្នុងសមុទ្រ និងដីមានជីជាតិច្រើនសម្រាប់វិស័យកសិកម្មដែលមិនទាន់ត្រូវបានយកមកប្រើនៅឡើយ។ ចំនួនប្រជាជន៖ ប្រហែល ១៥ លាននាក់ (២,២ លាននាក់នៅរាជធានីភ្នំពេញ)។ យើងមានកំណើនផលិតផលក្នុងស្រុកសរុប៦% ក្នុងមួយឆ្នាំក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ដែលឧស្សាហកម្មសំខាន់ៗមាននៅក្នុងវិស័យទេសចរណ៍វាយនភ័ណ្ឌ ឧស្ម័នធម្មជាតិ កសិកម្ម សំណង់ និងឈើដែលផ្តល់ភាពងាយស្រួលក្នុងការទទួលបានការធ្វើពាណិជ្ជកម្មតាមសមុទ្រ។

យើងមានកម្លាំងពលកម្មវ័យក្មេងដែលមានតម្លៃថោកមានឆន្ទៈនិងអាចបណ្តុះបណ្តាលបាន និងមានកត្តាផលិតភាពកើនឡើងជាប្រចាំ។ នយោបាយយើងមានស្ថិរភាពតំណភ្ជាប់ប្រព័ន្ធដឹកជញ្ជូនកាន់តែប្រសើរឡើង និងផ្លូវដែកត្រូវបានស្តារឡើងវិញ យើងមានអ៊ីនធឺណិតដែលមានតម្លៃថោក។ ប្រជាសាស្ត្ររបស់យើងធានាថាតម្រូវការក្នុងស្រុកនឹងកាន់តែកើនឡើង (៦១%នៃប្រជាជនកម្ពុជាមានអាយុក្រោម ២៥ ឆ្នាំ អាយុជាមធ្យម៖២១)។

### *លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា?*

"«តាមបទពិសោធន៍ផ្ទាល់របស់ខ្ញុំ ខ្ញុំជឿជាក់ថា ភាពជាអ្នកដឹកនាំចាប់ផ្តើមជាមួយក្រុមតូចមួយហើយនោះគឺជាគ្រួសាររបស់អ្នក។ អ្នកមិនអាចដឹកនាំក្រុមធំជាងនេះបានទេប្រសិនបើអ្នកបរាជ័យក្នុងការដឹកនាំក្រុមតូចដែលនៅជិតអ្នក»"

អ្នកត្រូវប្រជែងជាមួយខ្លួនឯង ហ៊ានប្រថុយផ្តោតអារម្មណ៍និងធ្វើឱ្យក្តីសុបិនរបស់អ្នកក្លាយជាការពិត អ្នកត្រូវជឿជាក់លើខ្លួនឯងធ្វើកិច្ចការដែលអ្នកយកចិត្តទុកដាក់ឬងប់ងល់ និងជ្រើសរើសមុខជំនួញដែលសមនឹងជំនាញនិងចំណង់របស់អ្នក។ អ្នកក៏ត្រូវមានចក្ខុវិស័យ អភិវឌ្ឍស្មារតីសហគ្រិន រកមនុស្សល្អ អភិវឌ្ឍមនុស្សល្អ និងចូលរួមសមាគមអាជីវកម្មដែលអាចជួយអ្នកក្នុងការរីកចម្រើននិងជាកន្លែងដែលអ្នកអាចស្វែងរកអ្នកណែនាំដ៏ល្អដែលនឹងដើរជាមួយអ្នកតាមផ្លូវរហូតត្រូវហ៊ានប្រឈមមុខនឹងការភ័យខ្លាចរបស់អ្នក។ ចូរក្លាហាន ទទួលយកហានិភ័យហើយកុំខ្លាចក្នុងការសាកពិសោធន៍ហើយអ្វីដែលសំខាន់បំផុតនោះគឺ អ្នកតែងតែអាចរៀនធ្វើឱ្យល្អជាងមុនបើកចំហទទួលយកការផ្លាស់ប្តូរនិងស្វែងយល់ពីរបៀបធ្វើឱ្យមានតុល្យភាពល្អរវាងជីវិតនិងស្មារតីអ្នក។ WK

អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

# លោកស្រី ដាំ ចន្ទី

## នាយិកាប្រតិបត្តិ | អង្គការសមាគមខ្មែរលើ



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី( គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត ?*

ខ្ញុំឈ្មោះ ដាំ ចន្ទីកើតនៅខែកញ្ញា ឆ្នាំ១៩៥៥ ជនជាតិទំពូន ក្នុងឃុំតាឡៅ ស្រុកអណ្ដូងមាស ខេត្តរតនគិរី។ ខ្ញុំបានរៀបការជាមួយលោក ឡូង សុធា ហើយយើងមានកូន៦នាក់ជាមួយគ្នា។ ខ្ញុំធំឡើងក្នុងគ្រួសារក្រីក្រមួយដែលពឹងផ្អែកលើការដាំស្រូវនិងបន្លែព្រៃ។ ពេលខ្ញុំនៅតូច ខ្ញុំត្រូវបានគេលក់ឱ្យធ្វើជាអ្នកបម្រើក្នុងគ្រួសារអ្នកមានទ្រព្យសម្បត្តិមួយហើយក្នុងសម័យបុលពត ខ្ញុំត្រូវគេចាត់ឱ្យធ្វើជាពេទ្យនៅតំបន់១០១។

ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៩៥ ខ្ញុំជាសមាជិកក្នុងសមាគមស្ត្រីមួយ។ នៅខែមីនា ឆ្នាំ ១៩៩៦ខ្ញុំត្រូវបានគេជ្រើសរើសធ្វើជាអ្នកបកប្រែសម្រាប់អង្គការ NTFP(Non-Timber Forest Products) និងក្រោយមកទៀតសម្រាប់គម្រោងផ្សេងៗ អំពីយេនឌ័រនិងសុខភាព។ នៅឆ្នាំ ២០០០ ខ្ញុំបានបង្កើតសមាគមជនជាតិដើម (Highlander Association, HA)។ ខ្ញុំបានបន្តការធ្វើដំណើរជាអ្នកដឹកនាំរហូតមក ព្រោះវាជាសុបិនរបស់ខ្ញុំតាំងពីខ្ញុំនៅក្មេង។ ខ្ញុំចូលរួមយ៉ាងសកម្មក្នុងការនាំសហគមន៍ឱ្យទាមទារសិទ្ធិរបស់ពួកគេហើយខ្ញុំបានទទួលការគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍ជនជាតិដើម មិត្តរួមការងារជាទីស្រឡាញ់ និងសហគមន៍អន្តរជាតិផងដែរ។ ក្នុងចន្លោះឆ្នាំ ២០០៣-២០០៥ខ្ញុំបានបង្កើតយុទ្ធនាការអប់រំដល់អ្នកភូមិជនជាតិភាគតិចចំនួន ១៨ឃុំ កុំឱ្យលក់ដីឱ្យអ្នកក្រៅ។ នោះជាពេលដែលបញ្ហារំលោភដីធ្លីកំពុងកើតឡើងយ៉ាងខ្លាំង។ ដោយសារតែយុទ្ធនាការរបស់យើងនិងការគាំទ្រពីសម្តេចនរោត្តមសីហនុនិងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន យើងបានទទួលមកវិញ តាមរយៈឯកឧត្តម នួន ភា (សហគមន៍វៀតខ្លូ និង ឈ្យូង) ។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី ?*

ខ្ញុំមានបញ្ហាប្រឈមជាច្រើនក្នុងតួនាទីជាអ្នកដឹកនាំ។ ខ្ញុំជួបការលំបាកក្នុងការចល័តធនធាននិងការប្រាស្រ័យទាក់ទងជាភាសាអង់គ្លេសដើម្បីគាំទ្រដល់បេសកកម្មរបស់អង្គការ។ ខ្ញុំមិនស្គាល់ដៃគូអភិវឌ្ឍន៍និងម្ចាស់ជំនួយច្រើន



ទេ។ សំខាន់ជាងនេះទៅទៀត ខ្ញុំមិនអាចសរសេរសំណើនិង របាយការណ៍សម្រាប់ការប្រមូលមូលនិធិបានទេ។ ក្រៅពីនេះ ខ្ញុំបានទទួលការគំរាមកំហែងសម្លាប់ពីជនមិនស្គាល់អត្តសញ្ញាណដោយសារតែយុទ្ធនាការដីធ្លីរបស់ខ្ញុំជាមួយសហគមន៍ជនជាតិដើមភាគតិច។ ឧទាហរណ៍ ខ្ញុំត្រូវបានទទួលការគំរាមសម្លាប់ដោយផ្ទាល់នៅឆ្នាំ២០១៦។ សមាគមជនជាតិភាគតិចរបស់យើងត្រូវបានគំរាមកំហែងថានឹងត្រូវបិទទ្វារដោយសារការធ្វើយុទ្ធនាការជាមួយសហគមន៍នាពេលថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅកំពុងខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់និងការពារសិទ្ធិដីធ្លីនិងធនធានធម្មជាតិរបស់ជនជាតិភាគតិច។ សំខាន់ខ្ញុំបានធ្វើការជាមួយស្ត្រីជនជាតិដើមភាគតិចក្នុងកម្មវិធីពង្រឹងអំណាចសេដ្ឋកិច្ចរបស់ពួកគេ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

> “
> **ស្ត្រីម្ចាស់អាជីវកម្មគួរចែករំលែកបទពិសោធន៍និងជំនាញពួកគាត់ជាមួយស្ត្រីនៅតំបន់ជនបទ**

ខ្ញុំមានបទពិសោធន៍ជីវិតដ៏ល្អមួយជាមេដឹកនាំជនជាតិដើម។ មេរៀនសំខាន់ៗទាំងនោះគឺ៖

- ការទុកចិត្តពីសំណាក់ ក្រុមម្ចាស់ជំនួយ និងសហគមន៍ជនជាតិដើមរបស់ខ្ញុំដែលបានចូលរួមក្នុងការលើកកម្ពស់សិទ្ធិកាន់កាប់ដី។
- តម្លៃនៃតម្លាភាពនៅក្នុងការដឹកនាំអង្គការ។ ខ្ញុំមានមោទនភាពជាខ្លាំងចំពោះអង្គការរបស់ខ្ញុំដោយសារយើងអាចសម្របខ្លួននិងធ្វើតាមតម្រូវការរបស់ម្ចាស់ជំនួយក្នុងស្រុកនិងដៃគូអភិវឌ្ឍន៍អន្តរជាតិទោះបីយើងជាអង្គការដែលដឹកនាំដោយជនជាតិដើមក៏ដោយ ។
- ការគាំទ្រដ៏រឹងមាំពីក្រុមប្រឹក្សាភិបាលនិងក្រុមការងារគឺជាកត្តាជំរុញចម្បងសម្រាប់ខ្ញុំក្នុងការដឹកនាំការទាមទារសិទ្ធិកាន់កាប់ដីជូនជនជាតិដើមទៅថ្ងៃអនាគត។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

ខ្ញុំមានគុណតម្លៃស្នូលមួយចំនួនក្នុងការដឹកនាំ។ ខ្ញុំជឿលើសកម្មភាពដែលមានតម្លាភាពនិងគណនេយ្យភាព ដើម្បីធានាការគោរពផលប្រយោជន៍និងសិទ្ធិដល់សហគមន៍ជនជាតិដើមភាគតិច។ ដើម្បីសម្រេចបាននូវរឿងទាំងនោះ ខ្ញុំនិងសហការីរបស់ខ្ញុំតែងតែទាមទារឱ្យមាន៖

- ការគោរព៖ ក្នុងនាមជាមនុស្ស យើងកើតមកមានសេចក្តីថ្លៃថ្នូរ។ យើងត្រូវគោរពគ្នាទៅវិញទៅមកដោយមិនគិតពី អត្តសញ្ញាណ វប្បធម៌ និងភេទទេ។
- ចំណង់ក្នុងការលើកកម្ពស់យេនឌ័រ៖ យើងត្រូវធានាឱ្យមានការចូលរួមផ្នែកយេនឌ័រក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍និងលើកកម្ពស់យេនឌ័រតាមរយៈការផ្តល់ឱកាសការងារ។
- ការប្តេជ្ញាចិត្តក្នុងការកសាងសហគមន៍ជនជាតិដើមដែលរឹងមាំ៖ ខ្ញុំមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជួយដល់យុវវ័យនិងស្ត្រីជនជាតិដើមភាគតិច

ទាមទារសិទ្ធិដីធ្លីរបស់ពួកគេ។

- ការតស៊ូ៖ ខ្ញុំមិនដែលបោះបង់សុបិនចង់ធ្វើជាអ្នកដឹកនាំសហគមន៍ខ្ញុំទេ។ ថ្វីបើខ្ញុំទទួលបានការគំរាមកំហែងលើជីវិតខ្ញុំជាច្រើនដងក៏ដោយ ខ្ញុំនៅតែធ្វើការដើម្បីអត្ថប្រយោជន៍នៃសហគមន៍ជនជាតិដើមរបស់ខ្ញុំដែរ។

### *តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

លក្ខណៈអវិជ្ជមាននៃអ្នកដឹកនាំគឺ៖

- អ្នកដឹកនាំដែលមិនយល់អំពីមនុស្សនិងបេសកកម្មរបស់អង្គការឬក្រុមរបស់ពួកគេ
- អ្នកដឹកនាំដែលមិនមានស្មារតីជាក្រុម។ អ្នកដឹកនាំដែលបំពានអំណាចរបស់ពួកគេទៅលើអ្នកក្រោមបង្គាប់និងក្រុមរបស់ពួកគេដោយមិនពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាភិបាលនិងអ្នកផ្សេងទៀត។
- មេដឹកនាំមិនមានគោលដៅនិងទិសដៅសម្រាប់ក្រុម។ ពួកគេខ្សោយទំនាក់ទំនងក្នុងក្រុម។
- ខ្វះតម្លាភាព៖ អ្នកដឹកនាំត្រូវមានភាពយុត្តិធម៌និងតម្លាភាពជាមួយក្រុមការងាររបស់ពួកគេ។ កង្វះតម្លាភាពអាចនាំឱ្យមានការខ្វះទំនុកចិត្តបាន។
- អំនួត៖ អ្នកដឹកនាំល្អត្រូវចេះស្តាប់ដោយប្រុងប្រយ័ត្ននិងទទួលយកទាំងអ្វីដែលត្រូវនិងអ្វីដែលខុស។ ដើម្បីក្លាយជាមេដឹកនាំដែលមានចក្ខុវិស័យដ៏ពិតប្រាកដ យើងត្រូវបោះបង់ចោលភាពអត្តានិយមរបស់យើងហើយផ្តោតលើប្រជាជនរបស់យើងពីព្រោះគ្មានពួកគេយើងនឹងមិនអាចដើរទៅមុខនោះទេ។

### *តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ដើម្បីជំរុញភាពជាអ្នកដឹកនាំ ខ្ញុំត្រូវពង្រឹងខ្លួនឯងនិងក្រុមទាំងមូលឱ្យធ្វើការដោយតម្លាភាពនិងភាពស្មោះត្រង់ចំពោះអង្គការ ម្ចាស់ជំនួយ និងសហគមន៍ជនជាតិដើមភាគតិច។ ខ្ញុំនឹងផ្តល់ឱកាសនិងលើកទឹកចិត្តស្ត្រីជនជាតិដើមភាគតិចនិងយុវវ័យឱ្យធ្វើការសម្រេចចិត្ត។ ពួកគេនឹងទទួលបានការកសាងសមត្ថភាពលើការដឹកនាំនិងការអភិវឌ្ឍសហគមន៍។ ខ្ញុំនឹងផ្តល់អំណាចដល់ក្រុមខាងក្នុងរបស់ខ្ញុំ នឹងប្រគល់ភារកិច្ចសំខាន់ៗក្នុងការស្រាវជ្រាវអំពីសិទ្ធិដីធ្លីនិងការបង្កើតការពិភាក្សាគោលនយោបាយជាមួយអ្នកពាក់ព័ន្ធផ្សេងៗទាំងក្នុងស្រុកនិងក្រៅប្រទេស។ ខ្ញុំកំពុងប្រាប់ខ្លួនឯងគ្រប់ពេលវេលាថា ខ្ញុំត្រូវទៅបម្រើឱ្យសហគមន៍របស់ខ្ញុំ ហើយបន្តរៀនពីអ្នកដទៃដើម្បីអភិវឌ្ឍជំនាញរបស់ខ្ញុំនិងប្រជាជនខ្ញុំ។ ខ្ញុំនឹងបន្តប្រើការគិតត្រិះរិះនិងធ្វើខ្លួនឱ្យស្ងប់ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលអាចមានគ្រោះថ្នាក់ដល់ជីវិតខ្ញុំ។



### *តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ហានិភ័យដែលខ្ញុំបានឆ្លងកាត់មាន៖

- ការចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធរឿងនយោបាយជាមួយគណបក្សប្រឆាំង
- ច្បាប់និងបទបញ្ញាថ្មីៗ ឧទាហរណ៍ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលដែលជះឥទ្ធិពលដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គការខ្ញុំ
- ការបំភិតបំភ័យនិងគំរាមកំហែងដល់ជីវិតខ្ញុំ ដោយសារការចូលរួមរបស់ខ្ញុំជាមួយសហគមន៍ជនជាតិដើមភាគតិចក្នុងរឿងសម្បទានដីធំៗ និងសម្បទានដីសេដ្ឋកិច្ចដទៃទៀត។
- ការគំរាមកំហែងបិទអង្គការខ្ញុំ

ខ្ញុំនិងក្រុមរបស់ខ្ញុំមានដំណោះស្រាយជាក់លាក់មួយចំនួនដើម្បីកាត់បន្ថយហានិភ័យខាងលើ៖

- ខ្ញុំបានកសាងបណ្តាញដ៏ល្អ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយវេទិកាអង្គការមិនមែនរដ្ឋាភិបាលនិង UNHCR ។ នៅពេលមានការគំរាមកំហែងដល់ជីវិតខ្ញុំ ខ្ញុំអាចធ្វើចំណាកស្រុកមួយរយៈពេលខ្លី
- ខ្ញុំបានពន្យល់និងបានជួបថ្នាក់ដឹកនាំកំពូលនៃសមាជិកសភា និងក្រសួងពាក់ព័ន្ធក៏ដូចជាថ្នាក់ខេត្តអំពីបេសកកម្មរបស់សមាគមជនជាតិដើមដើម្បីកាត់បន្ថយភាពតានតឹងនិងការយល់ច្រឡំ។
- ខ្ញុំបានចូលរួមចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់ខ្ញុំក្នុងការធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច ជាមួយរដ្ឋាភិបាលមូលដ្ឋាននិងថ្នាក់ជាតិ
- ខ្ញុំគោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់និងបទបញ្ញារបស់រដ្ឋាភិបាលហើយតែងតែពិគ្រោះជាមួយក្រុមប្រឹក្សាភិបាលនិងដៃគូអភិវឌ្ឍន៍មុនពេលធ្វើការជាមួយរដ្ឋាភិបាល។ យើងប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិ ទិវាជនជាតិដើមភាគតិចនិងព្រឹត្តិការណ៍ថ្នាក់ជាតិផ្សេងទៀតជាមួយរដ្ឋាភិបាល។

### *តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

រដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់វប្បធម៌ចម្រុះផ្សេងគ្នាហើយមាននូវគោលនយោបាយជាតិដែលជំរុញឱ្យមានស្ត្រីជាអ្នកដឹកនាំទាំងក្នុងវិស័យឯកជននិងសាធារណៈ។ រដ្ឋាភិបាលមានកូតាជាក់លាក់សម្រាប់ស្ត្រីមេដឹកនាំនយោបាយមកពីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដូចជាមេភូមិស្ត្រី ចៅហ្វាយខេត្តស្ត្រី និងរដ្ឋមន្ត្រីស្ត្រីជាដើម។ រដ្ឋាភិបាលបានបង្កើតក្រសួងកិច្ចការនារី ដែលមានតួនាទីសំខាន់ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំដល់ស្ត្រីនៅក្នុងសហគមន៍ ក្រុមហ៊ុននិងវិស័យរដ្ឋាភិបាល ក៏ដូចជាបង្កើតគោលនយោបាយនិងថវិកាទាក់ទងនឹងយេនឌ័រ។ សម្រាប់អង្គការក្រៅរដ្ឋាភិបាល យើងបានបង្កើតគំនិតផ្តួចផ្តើមជាច្រើនដើម្បីលើកកម្ពស់ស្ត្រីក្នុងតំណែងជាអ្នកដឹកនាំនិងគាំទ្រដល់ការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ។ ជារៀងរាល់ឆ្នាំយើងទាំងអស់គ្នាអបអរសាទរសមិទ្ធផលរបស់យើងដោយការរៀបចំទិវាសិទ្ធិនារីអន្តរជាតិ៨ មីនា។

### *លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ខ្ញុំមានអនុសាសន៍មួយចំនួនសម្រាប់សហគ្រិនស្ត្រី។ ពួកគេគួរគ្រប់គ្រងអាជីវកម្មរបស់ពួកគេដោយការដាក់ស្ត្រីឱ្យកាន់តែច្រើនក្នុងមុខតំណែងដឹកនាំដោយគ្មានការរើសអើង ជាពិសេសលើស្ត្រីមកពីតំបន់ជនបទ។ ពួកគេគួរតែផ្តល់ឱកាសបន្ថែមនិងអត់ធ្មត់ដល់ស្ត្រីនិងយុវវ័យជនជាតិភាគតិច។ ខ្ញុំស្នើឱ្យម្ចាស់អាជីវកម្មដែលជាស្ត្រីជួយចែករំលែកបទពិសោធន៍និងជំនាញបន្ថែមដល់ស្ត្រីជនបទនិងក្រីក្រ។ ខ្ញុំក៏ចង់បានការអន្តរាគមន៍ដ៏សកម្មពីរដ្ឋាភិបាលដើម្បីបិទ KTV និងការជួញដូរមនុស្សឆ្លងកាត់ព្រំដែន។ ចុងបញ្ចប់ខ្ញុំចង់ឃើញស្ត្រីកាន់តែច្រើននៅក្នុងរដ្ឋាភិបាលនិងសង្គមស៊ីវិល ជួយស្ត្រីដទៃទៀតនៅតំបន់ជនបទដូចជាតំបន់ខ្ញុំជាដើម។ WK

អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា

# លោកជំទាវ ជា សេរី
# ជំនួយការទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស | ធនាគារជាតិនៃកម្ពុជា



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកជំទាវ (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកជំទាវជាអ្នកដឹកនាំ និងតើអ្វីដែលលោកជំទាវមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះ ជា សេរី។ ខ្ញុំបានរៀបការហើយមានកូន៤នាក់ដែល២នាក់ក្នុងចំណោមអ្នកទាំង៤គឺជាកូនចិញ្ចឹម។ ខ្ញុំបានជួបកូនប្រុសពៅរបស់ខ្ញុំនៅពេលធ្វើដំណើរទៅខេត្តតាកែវជាមួយនឹងមូលនិធិរក្សាកុមារដែលជាមូលនិធិមួយ ខ្ញុំបានចូលរួមបង្កើតឡើងដោយផ្តោតលើសុខុមាលភាពរបស់កុមារកម្ពុជាដែលគ្មានលទ្ធភាពនិង លើកកម្ពស់ការយល់ដឹងអំពីពិការភាពខាងផ្លូវចិត្តនិងផ្លូវកាយ។ ខ្ញុំក៏ចូលរួមយ៉ាងសកម្មក្នុងការងារសប្បុរសធម៌ជាច្រើនទៀត រួមទាំងធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការស្នាមញញឹមកម្ពុជា(Smile Cambodia) ដែលផ្តល់ការវះកាត់ដោយឥតគិតថ្លៃដល់កុមារឆែបមាត់និងរលាកភ្លើងនិង មូលនិធិចក្ខុខ្មែរ ដែលផ្តល់ការវះកាត់ភ្នែកឡើងបាយសម្រាប់អ្នកដែលគ្មានលទ្ធភាព។



ខ្ញុំមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធនាគារពី SOAS University of London (ចក្រភពអង់គ្លេស)ហើយបច្ចុប្បន្នខ្ញុំកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យអាដឺឡេស (អូស្ត្រាលី) ដោយផ្តោតលើការធ្វើសមាហរណកម្ម និងស្ថិរភាពហិរញ្ញវត្ថុ។

ក្នុងនាមជាជំនួយការទេសាភិបាលនៃធនាគារជាតិកម្ពុជាខ្ញុំទទួលបន្ទុកនាយកដ្ឋានចំនួនប្រាំ និងមានតំណែងក្នុងគណៈកម្មាធិការគោលនយោបាយជាច្រើននៅក្នុងធនាគារនិងថ្នាក់ជាតិ។ ខ្ញុំក៏ជាប្រធានការិយាល័យឥណទានកម្ពុជាចាប់តាំងពីបង្កើតឡើងដំបូង។ ខ្ញុំក៏ជាសមាជិកនៅក្នុង South East Asia Advisory Board of WomenWorld Banking។ ហើយមុននោះខ្ញុំគឺជាសមាជិកនៃគណៈកម្មាធិការ Gender and Women Financial Inclusion នៃ Alliance for Financial Inclusion ។ មុនពេលខ្ញុំត្រូវបានតែងតាំងឱ្យកាន់តំណែងនេះ ខ្ញុំបានធ្វើការឡើងពីមន្ត្រីខុទ្ទកាល័យទៅជាអគ្គនាយករងនៃនាយកដ្ឋានត្រួតពិនិត្យធនាគារ។ ខ្ញុំបានចេញធ្វើការនៅពេលកំពុងមានការផ្លាស់ប្តូររចនាសម្ព័ន្ធប្រព័ន្ធធនាគារឡើងវិញខណៈធនាគារកណ្តាលចង់ពង្រឹងមុខងារត្រួតពិនិត្យធនាគារ។ ដូច្នេះខ្ញុំមានមោទនភាពក្នុងការចូលរួមការកសាងទំនុកចិត្តនៅក្នុងវិស័យធនាគារនៅក្នុងប្រទេសកម្ពុជាក៏ដូចជាការអភិវឌ្ឍជាវិជ្ជមានសំខាន់ដទៃទៀតក្នុងវិស័យនេះ។

ខ្ញុំមានកិត្តិយសផងដែរដែលបានរួមចំណែកក្នុងការកាត់បន្ថយគម្លាតនៃសមាហរណកម្មហិរញ្ញវត្ថុថ្នាក់ជាតិនិងអន្តរជាតិហើយត្រូវបានគេទទួលស្គាល់ដោយសារកិច្ចខិតខំប្រឹងប្រែងនេះ គេបានប្រគល់ពានរង្វាន់តស៊ូមតិផ្នែកយេនឌ័រដល់ខ្ញុំក្នុងឆ្នាំ២០១៨។ ខ្ញុំក៏ទទួលបានពានរង្វាន់ Asia 21 Young Leaders ឆ្នាំ ២០១៧ និង Young Societal Leaders ឆ្នាំ២០១៨ ក៏ដូចជា ZICO ASEAN 40 under 40 ជាការទទួលស្គាល់ភាពជាអ្នកដឹកនាំរបស់ខ្ញុំនៅក្នុងវិស័យធនាគារនៅកម្ពុជា។

*នៅពេលដែលលោកជំទាវចាប់ផ្តើមអាជីពដំបូងរបស់លោកជំទាវតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកជំទាវ?*

បញ្ហាប្រឈមចម្បងពេលដែលខ្ញុំចាប់ផ្តើមធ្វើការគឺការកសាងទំនុកចិត្តក្នុងវិស័យធនាគារជាពិសេសនៅពេលធនាគារចំនួន ១៧ ត្រូវបានរំលាយនៅពេលនោះ ហើយធនាគារ ៥ ទៀតមិនអាចសងប្រាក់បញ្ញើ សន្សំរបស់ខ្លួនបាន។ ដូច្នេះតើយើងធ្វើដូចម្តេចទើបអាចបញ្ចុះបញ្ចូលប្រជាជនឱ្យសន្សំប្រាក់នៅក្នុងធនាគារនិងអនុញ្ញាតឱ្យមានការអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ច? ខ្ញុំរៀនបានច្រើនពីបទពិសោធន៍នេះ។ ចំណែករឿងផ្ទាល់ខ្លួនវិញ ខ្ញុំទើបប្រសូត្របានកូនដំបូងរបស់ខ្ញុំ ហើយពួកគាត់ត្រូវបំបៅដោះតែមួយមុខ។ ពេលនោះមិនទាន់មានស្នប់ទឹកដោះទេ ដូច្នេះខ្ញុំត្រូវរត់ពីការិយាល័យមកផ្ទះដើម្បីបំបៅកូនរបស់ខ្ញុំ។ លើសពីនេះទៅទៀត នៅពេលនោះខ្ញុំគឺជាបុគ្គលិកក្នុងចំណោមបុគ្គលិកមួយចំនួនតូចដែលមានសញ្ញាបត្រអន្តរជាតិ ដូច្នេះមានការរំពឹងទុកខ្ពស់ណាស់មកលើខ្ញុំ។ វាគឺជាសម្ពាធបន្ថែមមកលើខ្ញុំ ប៉ុន្តែក៏ជាឱកាសដ៏ល្អមួយសម្រាប់ខ្ញុំក្នុងការធ្វើនិងរៀនបន្ថែមទៀត។

> “ត្រូវមានគោលបំណងច្បាស់លាស់និងប្តូរផ្តាច់ជាមួយវា។ គ្មានអ្វីអាចជំនួសញើសឈាមបានទេ

*ប៉ុន្មានឆ្នាំកន្លងមកតើលោកជំទាវបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

គណៈគ្រប់គ្រងនៅធនាគារជាតិនៃកម្ពុជាមានទស្សនៈមួយគឺថាតំណែងអាចត្រូវបានផ្តល់ឱ្យនិងដកចេញបាន ប៉ុន្តែទំនាក់ទំនងដែលយើងកសាងជាមួយនឹងក្រុមរបស់យើងនឹងនៅជាមួយយើងពេញមួយជីវិត។ ខ្ញុំបានរៀនដឹងថា ការដឹកនាំមិនមែនគ្រាន់តែជាការគ្រប់គ្រងក្រុមការងាររបស់យើងទេ ប៉ុន្តែវាក៏ជាការបំផុសគំនិតឱ្យពួកគេជឿនិងយល់ស្របតាមចក្ខុវិស័យរបស់យើង។ យើងទទួលបានលទ្ធផលល្អបំផុតពីក្រុមការងាររបស់យើងនៅពេលយើងជឿជាក់និងធ្វើការដើម្បីសម្រេចបាននូវគោលដៅរួម។ ការដឹកនាំពឹងផ្អែកលើការកសាងនិងរក្សាទំនាក់ទំនងប្រកបដោយការគោរពជាមួយក្រុម ព្រោះវានឹងក្លាយជាទ្រព្យសម្បត្តិដ៏ធំបំផុតរបស់អ្នក។

*តើអ្វីជាតម្លៃស្នូលរបស់លោកជំទាវហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកជំទាវស្របតាមតម្លៃរបស់លោកជំទាវយ៉ាងដូចម្តេច?*

ខ្ញុំរស់នៅតាមសម្តីមួយដ៏សាមញ្ញដែលខ្ញុំបានអាន “ធ្វើការដើម្បីបុព្វហេតុមិនមែនឱ្យគេទះដៃអបអរទេ។ រស់ដើម្បីបង្ហាញ មិនមែនបង្អួត។ កុំព្យាយាម

## “ បរាជ័យជាផ្នែកមួយនៃភាពជោគជ័យ។ ដូច្នេះត្រូវចេះរៀនពីវា។

ធ្វើឱ្យគេឃើញវត្តមានយើង តែឱ្យគេដឹងពេលយើងអវត្តមាន”។ ខ្ញុំគិតថាការរស់នៅដើម្បីផ្គាប់ចិត្តគេគឺច្បាស់ជាធ្វើឱ្យយើងហត់នឿយណាស់។ យើងមិនគួរតែការចង់បានការទទួលស្គាល់ពីអ្នកដទៃ នាំយើងឱ្យធ្វើអ្វីដែលប្រឆាំងនឹងមនសិការរបស់យើងទេ។ យើងត្រូវរីករាយជាមួយខ្លួនយើង ព្រោះចុងបញ្ចប់ទៅយើងគេងតែម្នាក់ឯងទេ។

ខ្ញុំមិនដែលបង្ខំក្រុមរបស់ខ្ញុំឱ្យមានទស្សនៈដូចខ្ញុំទេ។ ប៉ុន្តែខ្ញុំព្យាយាមដឹកនាំពួកគេដោយឧទាហរណ៍។ ខ្ញុំជឿថាអ្វីគ្រប់យ៉ាងអាចត្រូវបានធ្វើបានល្អប្រសើរជាងមុន ប្រសិនអ្នកធ្វើគាត់ជឿជាក់លើវា។ ខ្ញុំជឿជាក់ថាក្នុងនាមជាអ្នកដឹកនាំ អ្នកត្រូវបង្កើតបរិយាកាសការងារដែលអនុញ្ញាតឱ្យក្រុមរបស់អ្នកប្រើគំនិតច្នៃប្រឌិតរបស់ពួកគេដើម្បីសម្រេចលទ្ធផលល្អប្រសើរ។ ដូច្នេះជាជាងសរសេរបញ្ជីការងារឱ្យពួកគេ អ្នកត្រូវផ្តល់ឱ្យពួកគេនូវគោលបំណងច្បាស់លាស់និងផ្តល់អំណាចដល់ពួកគេដើម្បីរកវិធីដើម្បីសម្រេចគោលបំណងនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកក៏ត្រូវដឹងអំពីចំណុចខ្លាំងនិងភាពទន់ខ្សោយនៃសមាជិកក្រុមរបស់អ្នកដើម្បីអាចដាក់ការងារឱ្យពួកគេឱ្យមានប្រសិទ្ធភាព។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកជំទាវគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

ឆាប់ខឹងគ្មានចេះអាណិតអាសូរ មោទនភាពនិងអំនួត។

*តើលោកជំទាវធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ខ្ញុំជឿថាព័ត៌មានគឺជាអំណាច។ អ្នកដឹកនាំល្អគឺជាអ្នកពូកែអាននិងស្តាប់។ ចំពោះម្ចាស់អាជីវកម្មស្ត្រី ការប្តេជ្ញាចិត្តនិងការយកចិត្តទុកដាក់ដ៏មុឺងម៉ាត់គឺមានសារសំខាន់ណាស់ដើម្បីឈានទៅរកភាពជោគជ័យ។ កុំខ្លាចការបរាជ័យ ព្រោះវាជាផ្លូវទៅរកភាពជោគជ័យ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺត្រូវតែជឿជាក់លើខ្លួនឯងហើយមានគោលបំណងច្បាស់លាស់។




ការខិតខំប្រឹងប្រែងដោយគ្មានគោលបំណងច្បាស់លាស់គឺគ្មានប្រយោជន៍ទេ។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកជំទាវបានជួបប្រទះនៅក្នុងអាជីពរបស់លោកជំទាវ ? តើលោកជំទាវដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ចំពោះការសម្រេចចិត្តវាពាក់ពន្ធ័ទៅនឹងហានិភ័យមួយចំនួនដែលអាចនឹងប្រែទៅជាអាក្រក់ឬល្អ។ ហើយអ្នកត្រូវទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់អ្នក។ ប្រសិនបើវាល្អ យើងសប្បាយនឹងវា។ ប្រសិនបើវាប្រែទៅជាអាក្រក់សូមយកវាជាមេរៀន។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកជំទាវគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ប្រជាជនកម្ពុជាបានឆ្លងកាត់ដំណាក់កាលជាច្រើននៃប្រវត្តិសាស្ត្រដ៏ជូរចត់មួយ។ ប៉ុន្តែយើងមិនដែលឈប់តស៊ូឡើយ។ យើងជាមនុស្សរឹងមាំណាស់។ យើងអាចផ្លាស់ប្តូរប្រទេសមួយដែលហែកហួរដោយសង្គ្រាមទៅជាប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតមួយក្នុងពិភពលោកនិងសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ នេះគឺជាសក្ខីភាពនៃភាពអំណត់អត់ទ្រាំទាំងនេះ។ បើទោះបីជាធ្លាប់ឆ្លងកាត់បទពិសោធន៏ដ៏រន្ធត់យ៉ាងណាយើងក៏ជាប់ចូលក្នុងបញ្ជីប្រជាជនដែលមានភាពរួសរាយរាក់ទាក់បំផុតទាំង១០នៅលើពិភពលោកដែរ នេះបង្ហាញពីអាកប្បកិរិយាវិជ្ជមានរបស់យើងចំពោះជីវិត។

និយាយជាទូទៅក្នុងនាមជាប្រទេសដែលលូតលាស់ក្រោយគេកម្ពុជាអាចលោតរំលងដំណាក់កាលជាច្រើននៃការអភិវឌ្ឍ។ ដោយមានប្រជាជនវ័យក្មេងមានចំណង់ខ្លាំងនិងរីកចម្រើន ចេះនិយាយភាសាអង់គ្លេស សូចនាករម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព និងមានសក្តានុពលកំណើនសេដ្ឋកិច្ចវិជ្ជមាន ប្រទេសកម្ពុជាគឺជាបេក្ខជនដ៏ល្អម្នាក់ដែលជាគោលដៅវិនិយោគ។

*លោកជំទាវមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ហ៊ានប្រថុយ៖ បរាជ័យគឺជាផ្នែកមួយនៃភាពជោគជ័យ។ គ្រប់ថ្នាំទាំងអស់បានបរាជ័យក្នុងការសាកល្បងមុនពេលវាជោគជ័យហើយអាចសង្គ្រោះជីវិតបាន។ កុំខ្លាចបរាជ័យ។ រៀនពីការបរាជ័យរបស់អ្នក។

មានគោលដៅច្បាស់លាស់និងត្រូវប្តេជ្ញាចិត្តជាមួយវា៖
គ្មានអ្វីអាចជំនួសញើសឈាមបានឡើយ។
ភាពជាអ្នកដឹកនាំគឺជាជំនាញមិនមែនជាអំណោយធម្មជាតិទេ៖ យើងអាចកើតមកមានទេពកោសល្យ ប៉ុន្តែភាពជាអ្នកដឹកនាំអាចរៀនបាន។ WK

អ្នកដឹកនាំ
ស្ត្រីនៅកម្ពុជា

# លោកស្រី តាំង ហ្គេចលៀង

## ប្រធានក្រុមប្រឹក្សាភិបាល | អេច អេន អិល



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះតាំង ហ្គេចលាង អាយុ ៣៧ ឆ្នាំជាក្រុមប្រឹក្សានាយកនៃក្រុមហ៊ុន H & LGroup Co., Ltd.។ ខ្ញុំមានសំណាងណាស់ដែលបានកើតមកនៅក្នុងគ្រួសារមានទ្រព្យសម្បត្តិស្តុកស្តម្ភដែលឪពុកម្តាយគឺជាអ្នកជំនួញ ហើយខ្ញុំមានឱកាសគ្រប់គ្រងក្រុមហ៊ុនតាំងពីអាយុ១៧ឆ្នាំមកម្លេះ។ ដើម្បីបន្តអាជីវកម្មរបស់ឪពុកម្តាយខ្ញុំ ខ្ញុំសម្រេចចិត្តឈប់រៀននៅថ្នាក់ទី ៧ ហើយចាប់ផ្តើមគ្រប់គ្រងអាជីវកម្មរបស់ពួកគាត់។

*នៅពេលដែលលោកស្រីចាប់ផ្តើមអាជីពដំបូងរបស់លោកស្រីតើអ្វីជាបញ្ហាប្រឈមសំខាន់បំផុតរបស់លោកស្រី?*

ខ្ញុំជាក្មេងស្រីដែលក្លាហាននិងរួសរាយម្នាក់ ជាមនុស្សម្នាក់ដែលចូលចិត្តកែលម្អខ្លួនឯងនិងអ្វីៗដែលនៅជុំវិញខ្ញុំ មនុស្សម្នាក់ដែលហ៊ានចាប់យកហានិភ័យ និងមានគំនិតច្នៃប្រតិដ្ឋខ្ពស់។ ដូច្នេះខ្ញុំអាចប្រើទេពកោសល្យទាំងនេះដើម្បីធ្វើឱ្យអាជីវកម្មរបស់គ្រួសារខ្ញុំគឺក្រុមហ៊ុន តាំង ផេងប៉ោ កាន់តែរីកចម្រើនទាំងកេរ្តិ៍ឈ្មោះ និងមុខមាត់ផលិតផល ខណៈពេលដែលពង្រីកសាខាជាច្រើនកន្លែងនៅទូទាំងទីក្រុងនិងខេត្តនានាក្នុងអំឡុងឆ្នាំ ២000-២00៥ ។

បន្ទាប់ពីខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំដែលជំនួញសំណព្វរបស់គាត់គឺជាអាជីវកម្មអចលនទ្រព្យយើងបានចាប់ផ្តើមវិនិយោគលើអចលន ទ្រព្យ។ យើងអាចនិយាយបានថាយើងបានទទួលជោគជ័យយ៉ាងខ្លាំងនៅក្នុងអាជីវកម្មនេះចាប់តាំងពីឆ្នាំ ២00៦ មកដូចដែលយើងត្រូវបានទទួលស្គាល់ដោយមិត្តភក្តិនិងអ្នកដទៃចំពោះសមិទ្ធផលរបស់យើង។ នៅក្នុងឆ្នាំ ២00៨ មានវិបត្តិសេដ្ឋកិច្ចពិភពលោកដូចដែលយើងទាំងអស់គ្នាដឹង។ ជាសំណាងល្អយើងបានដឹងការ

> **“យើងរៀនបណ្តើរធ្វើបណ្តើរ ជួនយើងមានកំហុស តែយើងចេះកែប្រែកំហុសទាំងនោះ**

ធ្លាក់ចុះនេះមុន រួចក៏បានលក់ដីនិងអចលនទ្រព្យភាគច្រើនរបស់យើងនៅតំបន់ឆ្ងាយនិងនៅតាមបណ្តាខេត្តហើយបានប្រើប្រាក់ទាំងនោះដើម្បីទិញដីនិងទ្រព្យសម្បត្តិនៅក្នុងទីក្រុងវិញ។ ការណ៍នេះបានការពារយើងពីវិបត្តិមួយចំនួនធំ។ ទោះជាយ៉ាងណាក៏ដោយ យើងបានជួបឧបសគ្គមួយចំនួន។ ប៉ុន្តែយើងទាំងពីរនាក់ព្យាយាមក្រោកឈរឡើងដើម្បីដោះស្រាយបញ្ហា។ ជាសំណាងល្អនៅទីបំផុត មេឃប្រែជាពណ៌ខៀវបន្ទាប់ពីព្យុះនេះ។ យើងអាចជម្នះនូវឧបសគ្គពេលនោះ ហើយយើងបានរួមគ្នាបន្តអាជីវកម្មរបស់យើងដោយក្តីញញឹម។

សំខាន់ជាងនេះទៅទៀត យើងមិនបានចាយវាយខ្ជះខ្ជាយក្នុងពេលវេលាដ៏លំបាកទាំងនោះទេ។ ផ្ទុយទៅវិញយើងបានចំណាយលើការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសដើម្បីទទួលបាននូវចំណេះដឹងនិងបទពិសោធន៍ច្រើនជាងមុនហើយបានបង្កើតក្រុមហ៊ុនជាច្រើនទៀតដើម្បីទទួលបានចំណូលបន្ថែម។ យើងបានរៀននិងអនុវត្តក្នុងពេលតែមួយ។ យើងបានធ្វើកំហុស ប៉ុន្តែយើងបានកែតម្រូវវាយ៉ាងឆាប់រហ័ស។ យើងបានជួបឧបសគ្គ ប៉ុន្តែយើងបានដោះស្រាយវា។ យើងតែងតែគាំទ្រគ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក ស្វែងយល់ពីគ្នា រៀនសូត្រពីគ្នាទៅវិញទៅមក ហើយតែងតែរកឱកាសដើម្បីសាកល្បងនិងរីកចម្រើន។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ?*

យើងបានរៀនសូត្រច្រើនពីបទពិសោធន៍របស់យើងនិងពីមនុស្សនៅជុំវិញយើង។ ដោយសារយើងជាអ្នកដឹកនាំ យើងប្តេជ្ញាធ្វើជាអ្នកដើរតួជាជនគំរូផងដែរ។

នៅក្នុងគ្រួសារទាំងមូល ស្វាមីរបស់ខ្ញុំនិងខ្ញុំប្តេជ្ញាចិត្តធ្វើជាគំរូស្វាមីភរិយា។ នៅក្នុងសង្គម ខ្ញុំប្តេជ្ញាចិត្តធ្វើជាគំរូម្តាយល្អ ជាមិត្តល្អ និងជាស្ត្រីល្អម្នាក់។ ទាំងនេះរួមបញ្ចូលទាំងរបៀបដែលខ្ញុំស្លៀកពាក់ អាកប្បកិរិយារបស់ខ្ញុំ ពាក្យពេចន៍របស់ខ្ញុំក្នុងការប្រាស្រ័យទាក់ទងក៏ដូចជាការគោរពរបស់ខ្ញុំចំពោះអ្នកដទៃ។ ខ្ញុំតែងតែរៀនអ្វីដែលល្អពីអ្នកដទៃហើយព្យាយាមធ្វើឱ្យបានល្អ។ ក្នុងនាមជាមនុស្សគំរូម្នាក់វាជំរុញទឹកចិត្តឱ្យខ្ញុំស្រឡាញ់មនុស្សដោយ



ស្មោះត្រង់និងដោយគ្មានលក្ខខណ្ឌណាមួយ មិនមែនសម្រាប់តែមនុស្សនៅជុំវិញខ្ញុំនោះទេប៉ុន្តែក៏សម្រាប់មនុស្សទាំងអស់ជាទូទៅ។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើអ្នកធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

ភាពឱនលំទោន ទន់ភ្លន់ រួសរាយរាក់ទាក់ គោរពនិងផ្តល់តម្លៃដល់អ្នកដទៃ ការចែករំលែក ... សុទ្ធតែជាមូលធនក្នុងការធ្វើឱ្យមនុស្សស្គាល់ខ្ញុំស្រឡាញ់ខ្ញុំ ហើយគោរពខ្ញុំអស់ពីដួងចិត្តរបស់ពួកគេ។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

នេះគឺជាបុគ្គលិកលក្ខណៈអវិជ្ជមានដែលត្រូវចៀសវាង៖

- ទាមទារជ្រុល
- ក្រអឺតក្រទមជ្រុល
- បន្ទោសអ្នកដទៃចំពោះលទ្ធផលដែលមិនបានរំពឹងទុក
- គ្មានការណែនាំច្បាស់លាស់
- មិនផ្តល់តម្លៃគ្រប់គ្រាន់
- មិនផ្តល់ឱកាស
- គ្មានការបំផុសគំនិតទេ
- គ្មានការកោតសរសើរ
- មិនទទួលយកគំនិតឬការងារថ្មី ...... ទាំងនេះមិនត្រឹមតែមិនធ្វើឱ្យអ្នកក្លាយជាអ្នកដឹកនាំល្អនោះទេ វាក៏ជះឥទ្ធិពលដល់ភាពជាអ្នកដឹកនាំរបស់អ្នក។ អ្នកមិនអាចរីកចម្រើនខ្លួនអ្នក ហើយក៏មិនអាចជួយមនុស្សនៅជុំវិញអ្នករីកចម្រើនដែរ!!

អ្វីដែលយើងគួរធ្វើ៖

- កុំកែអ្នកដទៃ កែខ្លួនដោយខ្លួនឯង បញ្ឈប់ការទាមទារហួសហេតុ
- កុំរកមើលកំហុសរបស់អ្នកដទៃ
- មានភាពអត់ធ្មត់ ចេះលើកលែងទោសនិងផ្តល់ឱកាសដល់អ្នកដទៃគឺជាទម្លាប់ល្អរបស់អ្នកដឹកនាំ។
- លើសពីនេះទៀត មានប្រយោគមួយដែលខ្ញុំតែងតែប្រាប់និងរំឭកខ្លួនឯងថា "វាសនារបស់ពួកគេគឺនៅក្នុងដៃរបស់ខ្ញុំ ដូច្នេះតើខ្ញុំអាចធ្វើអ្វីសម្រាប់ពួកគេបាន?" សំណួរនេះពិតជាជំរុញខ្ញុំឱ្យធ្វើច្រើនជាងនេះ!

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*



ភាពជាអ្នកដឹកនាំមិនត្រឹមតែសម្រាប់បុរសប៉ុណ្ណោះទេ តែស្ត្រីត្រូវការជំនួយគ្រប់ទីកន្លែង។

- នៅក្នុងគ្រួសារ ពួកគាត់គឺជាម្តាយដែលយកចិត្តទុកដាក់ថែរក្សាកូនៗ ធ្វើជាគំរូល្អ បង្រៀនពួកគេ ផ្តល់ដំបូន្មានដល់ពួកគេនិងមានការងារជាច្រើនទៀតដែលម្តាយទាំងអស់មិនអាចចៀសវាងបាន។
- នៅក្នុងក្រុមហ៊ុន ពួកគាត់ដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលភារកិច្ចពីគ្រប់ទីកន្លែងហើយពួកគាត់ក៏ជាកម្លាំងចលករដ៏វិជ្ជមានមួយសម្រាប់វឌ្ឍនភាពផងដែរ។ ប្រហែលជាស្ត្រីមានការអត់ធ្មត់ជាងបុរស។
- នៅក្នុងសង្គម មានតែស្ត្រីទេដែលអាចយល់អំពីស្ត្រី ជំរុញទឹកចិត្តគ្នាទៅវិញទៅមក មើលថែគ្នាទៅវិញទៅមក ចែករំលែកជាមួយគ្នា និងការរៀនសូត្រពីគ្នាទៅវិញទៅមក ... គឺជាអ្វីដែលយើងតែងតែធ្វើ។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

ការទុកចិត្តលើមនុស្សខ្លាំងពេកបានបង្កឱ្យមានការបាត់បង់ដីធំធេងក្នុងអំឡុងឆ្នាំ២០០៧-២០១០។ នៅពេលនោះ ស្វាមីខ្ញុំនិងខ្ញុំបានជួយគ្នាទៅវិញទៅមកដើម្បីដោះស្រាយបញ្ហាម្តងមួយៗ ដោះស្រាយវាដោយការយល់ដោយបង្កើតដំណោះស្រាយឈ្នះ-ឈ្នះ។ យើងមិនចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃទេ។ យើងសុខចិត្តបាត់បង់ហើយចាត់ទុកវាជាមេរៀនជីវិត។ យើងដើរតាមគោលការណ៍"ចាញ់ដើម្បីឈ្នះ`` ។ យើងមិនបានជជែករកខុសត្រូវ ឬប្រឆាំងតបតវិញទេ។

ដោយគោលការណ៍ផ្ទាល់ខ្លួនរបស់យើងដើម្បីរក្សាចំណងដ៏ល្អរវាងមិត្តភក្តិនិងសាច់ញាតិ សព្វថ្ងៃយើងមាននិងបង្កើតមិត្តភក្តិជាច្រើនហើយខ្ញុំសប្បាយរីករាយដែលអាចនិយាយថាយើងរក្សាទំនាក់ទំនងល្អនៅក្នុងចំណោមពួកគេ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

- ស្ត្រីគឺជាកម្លាំងចលករដ៏សំខាន់ដែលគ្រួសារនិងសង្គមមិនអាចអត់បាន
- មនុស្សគ្រប់រូបមានភាពជាអ្នកដឹកនាំពីខាងក្នុងខ្លួន ប៉ុន្តែអ្នកខ្លះមិនចាប់អារម្មណ៍ក្នុងការអភិវឌ្ឍវាទេហើយចាំតែពឹងផ្អែកលើអ្នកដទៃ។ នោះហើយជាមូលហេតុដែលមនុស្សមួយចំនួនមិនមានឱកាសប្រើកម្លាំងរបស់ខ្លួននិងអភិវឌ្ឍវា។
- ជាមនុស្សដែលពឹងលើខ្លួនឯង
- ហ៊ានធ្វើអ្វីដែលអ្នកដទៃអាចធ្វើបាន។
- រៀនគ្រប់គ្រងមនុស្ស។ អ្នកកាន់តែគ្រប់គ្រងមនុស្សបានច្រើន អ្នកកាន់តែចេះទទួលខុសត្រូវកាន់តែច្រើនហើយអ្នកកាន់តែមានការប្រុងប្រយ័ត្នច្រើន។ បន្ទាប់មកភាពជាអ្នកដឹកនាំរបស់អ្នកនឹងប្រសើរឡើងផងដែរ។
- កុំខ្លាចមានកំហុស។ ហ៊ានធ្វើការសម្រេចចិត្ត។ ប៉ុន្តែមុនពេលដែលអ្នកធ្វើការសម្រេចចិត្ត អ្នកត្រូវវិភាគពីគ្រប់ជ្រុងទាំងអស់។
- មុននឹងអ្នកបន្ទោសអ្នកដទៃ សូមរៀនពីរបៀបដែលត្រូវសួរជាមុនសិន។ ដឹកនាំខ្លួនអ្នកសិន មុននឹងអ្នកដឹកនាំអ្នកដទៃ។ WK

# លោកស្រី ប៉ុង លីមសាន

## ស្ថាបនិក និងនាយិកាប្រតិបត្តិ | ក្រុមហ៊ុន ហ្វឺស វិម៉ិនថេក អេស៊ា



អ្នកដឹកនាំ
ស្ត្រីនៃកម្ពុជា



*សូមផ្តល់ការណែនាំខ្លីៗអំពីជីវិតរបស់លោកស្រី (គ្រួសារ ការអប់រំ និងស្ថានភាពគ្រួសារ) និងបទពិសោធន៍របស់លោកស្រីជាអ្នកដឹកនាំ និងតើអ្វីដែលលោកស្រីមានមោទនភាពបំផុត?*

ខ្ញុំឈ្មោះប៉ុង លីមសាន អ្នកជំនាញMIS និងSoftware Solution ហើយក៏ជាម្តាយរបស់កូនពីរនាក់។ ខ្ញុំកើតនៅឆ្នាំ១៩៨០នៅភូមិដាច់ស្រយាលមួយនៃខេត្តកណ្តាល ប្រទេសកម្ពុជា។ ខ្ញុំបានរៀបការជាមួយលោកបិន សុជាតិក្នុងឆ្នាំ២០០៦ ហើយមានកូនស្រីម្នាក់និងប្រុសម្នាក់។ ក្រោយពីបានចូលរួមយ៉ាងសកម្មអស់រយៈពេលជាង ១០ឆ្នាំក្នុងការផ្តល់សេវាប្រឹក្សាយោបល់ផ្នែកព័ត៌មានវិទ្យាដល់ស្ថាប័នរដ្ឋាភិបាល ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ខ្ញុំបានដឹងថាប្រទេសកម្ពុជានិងក្នុងតំបន់កំពុងត្រូវការ យុវនារីបន្ថែមទៀតដើម្បីចូលរួមក្នុងវិស័យSoftwareនិងបច្ចេកវិទ្យាដើម្បីបំពេញតម្រូវការរបស់សហគមន៍និងដើម្បីបង្កើនឥទ្ធិពលឱ្យកាន់តែខ្លាំង។

បន្ទាប់មកខ្ញុំបានចាប់ផ្តើមពិភាក្សាពីតម្រូវការជាមួយប្តីនិងកូនរបស់ខ្ញុំអំពីក្តីសុបិនរបស់ខ្ញុំដែលចង់ជំរុញបេសកកម្មនេះសម្រាប់ប្រទេសកម្ពុជានិងសហគមន៍ក្នុងតំបន់។ ចុងក្រោយពួកគាត់យល់ស្របនិងគាំទ្រក្តីសុបិនរបស់ខ្ញុំ។ ខ្ញុំបានបង្កើតក្រុមហ៊ុនFirst Womentech Asia Co., LTD ដែលត្រូវបានគេស្គាល់ថា FWTA ជាក្រុមហ៊ុនផ្តោតលើបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលមានស្ត្រីភាគច្រើនធ្វើការនៅក្នុងខែឧសភាឆ្នាំ២០១៣។ វាជាក្រុមការងារឯករាជ្យដែលមានសមាជិកក្រុម៥នាក់រួមទាំងខ្ញុំ។ ចាប់តាំងពីការបង្កើតឡើងមក FWTA បានរីកចម្រើនបន្តិចម្តងៗហើយត្រូវបានចុះបញ្ជីដោយស្របច្បាប់ជាមួយក្រសួងពាណិជ្ជកម្មរបស់រដ្ឋាភិបាល។ ក្តីសុបិនរបស់ខ្ញុំក្នុងការបង្កើត FWTA គឺចង់ចូលរួមនាំប្រជាជនកម្ពុជាវ័យក្មេងក៏ដូចជាវិស្វករបច្ចេកវិទ្យាស្ត្រីមកក្នុងក្រុមហ៊ុនដើម្បីឱ្យយើងអាចផ្តល់ជូននូវដំណោះស្រាយនិងបច្ចេកវិទ្យាថ្មៃប្រតិដ្ឋដ៏ល្អបំផុតដល់អតិថិជនរបស់យើងទាំងអស់ជាពិសេសចំពោះស្ត្រី និងសហគ្រិនវ័យក្មេងនៅក្នុងវិស័យសុខាភិបាលនិងវេជ្ជសាស្ត្រដើម្បីជួយឱ្យពួកគេរីកចម្រើននិងទទួលបានជោគជ័យនៅក្នុងអាជីវកម្មរបស់ពួកគេ។

> “
> ## បង្កើតវប្បធម៌ការងារដោយខ្លួនឯង អ្នកនឹងសម្រេចគោលដៅចុងក្រោយរបស់អ្នក

ក្នុងនាមជាស្ថាបនិកនិងជានាយិកាប្រតិបត្តិនៃFWTA ខ្ញុំដើរតួនាទីចម្បងដោយត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ក្រុមហ៊ុនដែលរួមមានៈ ការភ្ជាប់បណ្តាញសម្រាប់អាជីវកម្មដើម្បីគាំទ្រដល់ការរចនាផលិតផលក៏ដូចជាការអភិវឌ្ឍបច្ចេកទេសផលិតផលរបស់ក្រុមហ៊ុនដើម្បីបំពេញតាមស្តង់ដារអន្តរជាតិដែលមានគុណភាពនិងសុវត្ថិភាពខ្ពស់។ ទន្ទឹមនឹងនេះ ខ្ញុំបានផ្តល់សេវាកម្មពិគ្រោះយោបល់ សម្រាប់គម្រោងមួយចំនួនរបស់រដ្ឋាភិបាលដែលទទួលបានមូលនិធិពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ភ្នាក់ងារម្ចាស់ជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការចែករំលែកជំនាញរួមគ្នាជាមួយក្រុមហ៊ុនពិគ្រោះយោបល់ក្នុងស្រុកនិងអន្តរជាតិចាប់តាំងពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ននេះ។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ខ្ញុំគឺជាអ្នកឯកទេសផ្នែកព័ត៌មានវិទ្យានិងជាប្រធានផ្នែកព័ត៌មានវិទ្យារបស់ក្រុមហ៊ុនAgrifood Consulting International, Inc. (ACI) និងក្រុមហ៊ុនដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី AgriculturalDevelopment International (ADI)។ ជាមួយក្រុមហ៊ុនទាំងពីរនេះខ្ញុំត្រូវបំពេញតួនាទីនិងភារកិច្ចស្នូលក្នុងការរចនាMISការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងការគ្រប់គ្រងដំណោះស្រាយព័ត៌មានវិទ្យា។

ដោយសារខ្ញុំជាអ្នកធ្វើការងារហើយមានការប្តេជ្ញាចិត្ត ស្ថាបនិកនិងនាយកចាត់ការទូទៅនៃក្រុមហ៊ុនពិតជាទុកចិត្តលើខ្ញុំទាំងស្រុងហើយជឿជាក់លើសមត្ថភាពរបស់ខ្ញុំ។ ក្រុមហ៊ុននីមួយៗផ្តល់ឱ្យខ្ញុំនូវឱកាសដ៏ល្អក្នុងការកសាងជំនាញទន់បន្ថែមទៀតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុលំហូរសាច់ប្រាក់គ្រប់គ្រងធនធានមនុស្សនិងការគ្រប់គ្រងរដ្ឋបាលក្នុងការិយាល័យ។ ជាការឆ្លើយតបនឹងការជឿទុកចិត្តរបស់គេលើខ្ញុំ ខ្ញុំបានប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីបំពេញភារកិច្ចដែលខ្ញុំបានទទួលដោយហេតុនេះខ្ញុំអាចចូលរួមជាមួយក្រុមហ៊ុនធ្វើការរួមគ្នាជាធ្លុងមួយដើម្បីជោគជ័យនិងបញ្ចប់គម្រោងទាំងអស់ដល់រដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលអាស៊ានដទៃទៀតក៏ដូចជាគម្រោងដែលផ្តល់មូលនិធិដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ដូចជាសហគមន៍ម្ចាស់ជំនួយអន្តរជាតិ/ភ្នាក់ងារនិងអង្គការក្រៅរដ្ឋាភិបាល។

ខ្ញុំបានចាប់ផ្តើមអាជីពរបស់ខ្ញុំដោយធ្វើការជាប្រធានគ្រប់គ្រងទិន្នន័យនិងជាលេខាគណនេយ្យឱ្យគម្រោងមួយដែលឧបត្ថម្ភដោយដាណឺម៉ាកសម្រាប់រដ្ឋបាលព្រៃឈើកម្ពុជាបន្ទាប់ពីខ្ញុំបានទទួលបរិញ្ញាបត្រ។ តួនាទីចម្បងរបស់ខ្ញុំគឺការរចនា អភិវឌ្ឍនិងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់គម្រោង។

ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រនិងវិស្វកម្មក្នុងឆ្នាំ២០០៣ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ហើយបានទទួលបរិញ្ញាបត្រជាន់ខ្ពស់របស់ខ្ញុំពីសកលវិទ្យាល័យនេះនៅឆ្នាំ២០០៦។ ខ្ញុំក៏បានបញ្ចប់វគ្គមួយឆ្នាំផ្នែករដ្ឋបាលពាណិជ្ជកម្មពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច(RULE)។

ក្នុងនាមជាមេដឹកនាំស្ត្រីនៃក្រុមហ៊ុនបច្ចេកវិទ្យាFWTA នៅក្នុងប្រទេសមួយដែលមិនសូវទទួលស្គាល់ស្ត្រីដែលមានការងារធ្វើគឺជារឿងដ៏លំបាកមួយ។ ទោះជាយ៉ាងណា ខ្ញុំបានយកឈ្នះលើបញ្ហា និងបរិយាកាសនេះហើយឈានទៅរកសុបិនរបស់ខ្ញុំ។ ខ្ញុំចាប់ផ្តើមដោយប្រមូលមនុស្សនៅជុំវិញខ្ញុំ មិត្តរួមការងារ ដៃគូអាជីវកម្មឱ្យជឿលើ ចក្ខុវិស័យសមត្ថភាពនិង

ចំណេះដឹងរបស់ខ្ញុំ។ ខ្ញុំគិតថាយើងទាំងអស់គ្នារួមទាំងខ្ញុំផងដែរ ដូចជាមិត្តរួមការងារ មិត្តភក្តិ និងអ្នកគាំទ្រ ជាជាង អ្នកដឹកនាំនិងអ្នកក្រោមឱវាទ។ ខ្ញុំដឹងថាភាពជោគជ័យរបស់យើងមិនអាចត្រឹមតែជាការនិយាយមាត់ឡើយ ប៉ុន្តែតាមរយៈសកម្មភាពពិតប្រាកដដែលអាចធានាថា ខ្ញុំអាចទទួលបានជោគជ័យ។ ហើយយើងជាស្ត្រីអាចទទួលបានជោគជ័យក្នុងការដឹកនាំការងារបច្ចេកវិទ្យាដែលគេច្រើនវាយតម្លៃតួនាទីដឹកនាំថាជា ការងាររបស់បុរស។

ខ្ញុំត្រូវរក្សាតុល្យភាពនិងគ្រប់គ្រងពេលវេលារបស់ខ្ញុំសម្រាប់ការងារនិងគ្រួសារ ប៉ុន្តែសំណាងល្អវប្បធម៌របស់គ្រួសារខ្ញុំ ខុសពីគ្រួសារខ្មែរមួយចំនួនធំ។ យើងទៅធ្វើការនៅពេលព្រឹកហើយក្មេងៗទៅសាលារៀនហើយស្នាក់នៅរហូតដល់រសៀល។ យើងទទួលទានអាហារថ្ងៃត្រង់នៅខាងក្រៅហើយត្រលប់មកផ្ទះវិញនៅពេលល្ងាច។ ប្តីរបស់ខ្ញុំយល់ពីសមភាពយេនឌ័រហើយចង់លើកកម្ពស់ស្ត្រី ដូច្នេះវាមិនមានឧបសគ្គ សម្រាប់ខ្ញុំក្នុងការបំពេញការងារនិងអាជីវកម្មដើម្បីបំពេញក្តីស្រមៃរបស់ខ្ញុំ។

នៅក្នុងអាជីពរបស់ខ្ញុំ ខ្ញុំមានមោទនភាពដែលបានធ្វើជាគំរូសម្រាប់ស្ត្រីក្នុងវិស័យអភិវឌ្ឍន៍បច្ចេកវិទ្យានិងសម្រាប់នារីខ្មែរក្មេងៗដែលមានបំណងចាប់ផ្តើមអាជីវកម្មជាពិសេសអាជីវកម្មបច្ចេកវិទ្យា។ ជាមួយគ្នានេះដែរ ផ្នែកមួយនៃអាជីវកម្មរបស់ខ្ញុំគឺគាំទ្រនិងដោះស្រាយបញ្ហានិងជួយដល់ការលូតលាស់នៃអាជីវកម្មជាពិសេសសម្រាប់ស្ត្រីនិងសហគ្រិនវ័យក្មេងដែលកំពុងធ្វើអាជីវកម្មក្នុងវិស័យសុខាភិបាលនៅកម្ពុជា។ នេះជាក្តីសុបិនរបស់ខ្ញុំ។

ខ្ញុំបានចាប់ផ្តើមអាជីព ជាមន្ត្រីទិន្នន័យនិងធ្វើការងាររដ្ឋបាលផ្សេងទៀត នៅក្នុងខែកក្កដាឆ្នាំ២០០៣ ជាមួយគម្រោងរបស់រដ្ឋាភិបាលដែលទទួលបានមូលនិធិពីរដ្ឋាភិបាលដាណឺម៉ាកដែលមានមូលដ្ឋាននៅខេត្តព្រះសីហនុនៃប្រទេសកម្ពុជា។ ខ្ញុំត្រូវផ្លាស់លំនៅទៅធ្វើការហើយរស់នៅឆ្ងាយពីគ្រួសារ។ នេះគឺជាឧបសគ្គទីមួយរបស់ខ្ញុំក្នុងការបញ្ចុះបញ្ចូលគ្រួសារជាពិសេសម្តាយរបស់ខ្ញុំថាខ្ញុំអាចធ្វើបាន។ ម្តាយរបស់ខ្ញុំមិនចង់ឱ្យខ្ញុំទៅធ្វើការនៅទីនោះទេ នៅពេលគាត់ព្រួយបារម្ភខ្ញុំ ប៉ុន្តែខ្ញុំបានទៅធ្វើការជាមួយគម្រោងនេះអស់រយៈពេលជិត៣ឆ្នាំមុនពេលខ្ញុំអាចត្រលប់ទៅរាជធានីភ្នំពេញវិញ។ ពេលដែលនៅទីនោះខ្ញុំរៀនសូត្របានច្រើន ជាបទពិសោធន៏ដំបូងរបស់ខ្ញុំនៅក្នុងពិភពការងារអាជីព។ ខ្ញុំប្រឹងធ្វើការជាខ្លាំង ហើយបានធ្វើដំណើរច្រើន ពីខេត្តនេះមករាជធានីភ្នំពេញដោយសារខ្ញុំរៀនអនុបណ្ឌិតនៅចុងសប្តាហ៍ ហើយចាំបាច់ត្រូវមកធ្វើការនៅរាជធានីភ្នំពេញជាញឹកញាប់។ នៅទីបញ្ចប់ ខ្ញុំបានយកឈ្នះឧបសគ្គនេះដោយជោគជ័យហើយបានបញ្ចប់បេសកកម្មរបស់ខ្ញុំជាមួយគម្រោងនេះ ក៏ដូចជាទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រនិងវិស្វកម្ម។

បន្ទាប់ពីពិសោធន៏ដំបូងដ៏ធំមួយនេះខ្ញុំបានអភិវឌ្ឍខ្លួនខ្ញុំឱ្យកាន់តែខ្ពស់ជាមួយអ្នកជំនាញផ្នែក IT។ នៅពេលខ្ញុំត្រលប់មករាជធានីភ្នំពេញ ខ្ញុំបានចូលរួមជាមួយក្រុមហ៊ុនពិគ្រោះយោបល់ឯកជនអស់រយៈពេលជិត៤ ឆ្នាំ



ជាអ្នកពិគ្រោះយោបល់ដល់គម្រោងរដ្ឋាភិបាលដែលទទួលបានមូលនិធិពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ មុនពេលបង្កើត FWTAនៅឆ្នាំ ២០១៣ ហើយបន្ទាប់ពីនោះ ខ្ញុំគឺជាអ្នកប្រឹក្សាយោបល់ផ្នែកMISសម្រាប់ភ្នាក់ងាររដ្ឋាភិបាលនានា តាមរយៈការសហការរួមគ្នានិងការធ្វើការជាមួយក្រុមហ៊ុនពិគ្រោះយោបល់ក្នុងស្រុកនិងអន្តរជាតិ។
នៅក្នុងអាជីពរបស់ខ្ញុំក្នុងនាមជាអ្នកដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យានិងជាអ្នកជំនាញការផ្នែកMISខ្ញុំប្រឈមនឹងបញ្ហាប្រឈមមួយចំនួនដូចជាៈ
- ខ្ញុំត្រូវធ្វើឱ្យគេជឿថាក្នុងនាមជាស្ត្រី ខ្ញុំក៏អាចទទួលបានជោគជ័យក្នុងការងារដែលគេចាត់ទុកថាជាការងាររបស់បុរសដែរ។
- ខ្ញុំត្រៀមបញ្ចុះបញ្ចូលសមាជិកក្រុមឱ្យជឿលើចក្ខុវិស័យនិងគំនិតនៃការអភិវឌ្ឍរបស់ក្រុមហ៊ុនក៏ដូចជាការចូលរួមចំណែកដើម្បីធ្វើឱ្យផលមានឥទ្ធិពលកាន់តែច្រើនសម្រាប់សហគមន៍និងជីវិតការងារប្រចាំថ្ងៃរបស់ពួកគេ។
- បង្កើនការទុកចិត្តនៃដៃគូអាជីវកម្មទាំងអស់ ថាស្ត្រីក៏អាចដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យានិងបង្កើតផលិតផលបច្ចេកវិទ្យាប្រកបដោយគុណភាពដើម្បីដោះស្រាយបញ្ហាអាជីវកម្មរបស់ពួកគេ។
- បញ្ហាប្រឈមផ្សេងទៀតរួមមានការបែងចែករវាងគ្រួសារនិងការងារ។ ក្នុងនាមជាស្ត្រី យើងមានការងារផ្ទះច្រើនជាងបុរស ទោះបីជាយើងអាចមានស្វាមីដែលដឹងពីតួនាទីយេនឌ័រនិងវិសមភាពយេនឌ័រ ហើយជាអ្នកដែលគាំទ្រនិងចង់ឃើញស្ត្រីច្រើនទៀតមាន តួនាទីនៅក្នុងសង្គមក៏ដោយ។
- ការគ្រប់គ្រងលំហូរសាច់ប្រាក់ផ្តល់ឱ្យខ្ញុំនូវបទពិសោធន៏នៃការរៀនសូត្រមួយដ៏ល្អស្តីពីរបៀបគ្រប់គ្រងនិងធានាឱ្យ FWTAអាចរស់បាន នៅពេលយើងបានចាប់ផ្តើម បង្កើតក្រុមហ៊ុនដោយមានទឹកប្រាក់ត្រឹមតែ៥០០០ ដុល្លារអាមេរិកនិងប្រាក់កម្ចីបន្តិចបន្តួចពីបងស្រីរបស់ខ្ញុំ។ យើងមិនមានមូលនិធិបម្រុងច្រើនដើម្បីចំណាយលើការខាតបង់ទេ។ ខ្ញុំមានផែនការមេសម្រាប់ផលិតផលជំនួញ និងអាចផ្តល់មតិក្នុងការរចនាផលិតផលនិងការអភិវឌ្ឍហើយខ្ញុំបានពិនិត្យរាល់ការបង្កើតផលិតផលទាំងអស់។ ទន្ទឹមនឹងនេះខ្ញុំត្រូវចេញទៅធ្វើការងារលក់មួយចំនួននិងធ្វើការងារពិគ្រោះយោបល់ដើម្បីទទួលបានលុយសម្រាប់ការអភិវឌ្ឍក្រុមហ៊ុន។
- ការទទួលបាននូវប្រភពមូលនិធិដើម្បីឱ្យក្រុមហ៊ុនអាចរស់បាននៅដំណាក់កាលដំបូង ក៏ដូចជាគាំទ្រដល់ការរីកចម្រើនរបស់ក្រុមហ៊ុននៅក្នុងដំណាក់កាលរីកលូតលាស់ដំបូងគឺជាបញ្ហាប្រឈមមួយសម្រាប់អាជីវកម្មជាច្រើននៅក្នុងប្រទេសកម្ពុជា រួមទាំងក្រុមហ៊ុនរបស់ខ្ញុំផងដែរ។

*ប៉ុន្មានឆ្នាំកន្លងមកតើលោកស្រីបានរៀនមេរៀនដ៏មានតម្លៃអ្វីក្នុងនាមជាអ្នកដឹកនាំ ?*

ក្នុងតួនាទីជានាយិកាប្រតិបត្តិនៃ FWTA ខ្ញុំបានរៀនមេរៀនល្អៗជាច្រើនពីការងារប្រចាំថ្ងៃរបស់ខ្ញុំ។ ក្នុងនាមជាអ្នកដឹកនាំ យើងត្រូវមានទស្សនវិស័យច្បាស់លាស់អំពីគោលដៅនិងបេសកកម្មនៃអាជីវកម្មដែលជាយុទ្ធសាស្ត្រស្នូលដើម្បីដឹកនាំក្រុមឆ្ពោះទៅមុខជាមួយគ្នា។

នៅដំណាក់កាលដំបូងនៃការបង្កើតក្រុមហ៊ុន យើងត្រូវមានវិស្វករនិងស្ថាបត្យករដើម្បីរចនានិងបង្កើតវប្បធម៌ ការងារនិងប្រព័ន្ធការងារ ជាជាងផ្តល់ការងារឱ្យនរណាម្នាក់ផ្សេងទៀតធ្វើជំនួស។ ក្រោយមក យើងអាចឱ្យភារកិច្ចទាំងនេះទៅឱ្យមនុស្សទទួលខុសត្រូវនៅពេលក្រោយ បន្ទាប់ពីវប្បធម៌ធ្វើការត្រូវបានបណ្តុះនិងចាក់ឫសបានយ៉ាងល្អហើយ ដែលធ្វើឱ្យប្រព័ន្ធការងារត្រូវបានពង្រឹងនិងដំណើរការដោយរលូន ដោយមិនចាំបាច់យើងពិនិត្យទៀតឡើយ។

ការបង្កើតក្រុមអ្នកដឹកនាំប្រកបដោយគំនិតជោគជ័យ ដែលមានជំនឿលើបេសកកម្មនិងចក្ខុវិស័យរបស់ក្រុមហ៊ុនគឺជាយុទ្ធសាស្ត្រស្នូលក្នុងការធ្វើអោយក្រុមហ៊ុនមាន ការលូតលាស់។ ការទទួលខុសត្រូវនិងសុចរិតភាពនៃអ្នកដឹកនាំគឺជាចំណុចដែលមានសារសំខាន់ខ្លាំងណាស់ ដែលខ្ញុំត្រូវយកចិត្តទុកដាក់ព្រោះវាជាតម្លៃស្នូលសម្រាប់ជោគជ័យនៃ FWTA ។
ក្រុមដឹកនាំដែលមានបទពិសោធន៍ ដែលមានជំនាញទន់និងរឹងគឺមានសារសំខាន់ខ្លាំងណាស់ដើម្បីក្រុមហ៊ុនមួយរីកចម្រើន។ ក្រុមហ៊ុនណាមួយដែលគ្មានក្រុមការងារដែលមានភាពជាអ្នកដឹកនាំល្អ នឹងមានការលំបាកក្នុងការបំពេញតាមចក្ខុវិស័យនិងបេសកកម្មរបស់ក្រុមហ៊ុនព្រោះថាសមាជិកនៃអ្នកដឹកនាំគឺជាការបំផុសគំនិតរបស់បុគ្គលិកទាំងអស់ដើម្បីសម្រេចបានគោលដៅចុងក្រោយបំផុតរបស់ក្រុមហ៊ុន។

អ្នកដឹកនាំត្រូវតែកសាងបណ្តាញមួយដែលជាបណ្តាញដើម្បីឈានទៅដល់បេសកកម្ម ចក្ខុវិស័យនិងវិធីដើម្បីផ្តល់ផលិតផលឬសេវាកម្មដល់អតិថិជននិងអ្នកប្រើប្រាស់។

*តើអ្វីជាតម្លៃស្នូលរបស់លោកស្រីហើយតើលោកស្រីធានាថាក្រុម / បុគ្គលិក / គ្រួសារ / អតិថិជន របស់លោកស្រីស្របតាមតម្លៃរបស់លោកស្រីយ៉ាងដូចម្តេច ?*

តម្លៃស្នូលនៃ FWTA គឺមានវិជ្ជាជីវៈ គុណភាព និងការលូតលាស់ជាមួយគ្នា។ ក្នុងនាមជាអ្នកដឹកនាំក្រុមហ៊ុនខ្ញុំតែងតែពិភាក្សាអំពីបេសកកម្មចក្ខុវិស័យនិងគុណតម្លៃស្នូលរបស់យើងជាមួយបុគ្គលិក ដើម្បីរម្លឹកពួកគេពីអ្វីដែលត្រូវប្រកាន់ខ្ជាប់ ជាគោលការណ៍ក្នុងការងារប្រចាំថ្ងៃរបស់ពួកគេជាអ្នកផ្តល់សេវាកម្មដល់អតិថិជននិងជីវិតឯកជនរបស់ពួកគេផងដែរ។ សម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាការងារយើងគឺតឹងរឹងនិងតឹងតែងខ្លាំងណាស់បើនិយាយពីសុវត្ថិភាពទិន្នន័យនិងភាពជាឯកជនរបស់អតិថិជននិងអតិថិជនរបស់អតិថិជនរបស់យើង។ ប្រសិនបើពួកគេមិនមានវិជ្ជាជីវៈល្អក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ ពួកគេនឹងមិនខ្វល់អំពីគុណភាពផលិតផលឬសេវាកម្មដែលពួកគេផ្តល់រាល់ថ្ងៃទេ។ ការមិនមានវិជ្ជាជីវៈនឹងនាំឱ្យមានផលប៉ះពាល់អវិជ្ជមាននិងបំផ្លាញកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុននិងអតិថិជន។

ដើម្បីធានាថាក្រុមការងាររបស់យើងយល់ស្របតាមតម្លៃរបស់យើង យើងត្រូវដើរតួជាគំរូដំបូងហើយបន្ទាប់មកត្រូវប្រាកដថាក្រុមការងាររបស់យើងដឹងច្បាស់អំពីតម្លៃស្នូលរបស់យើងនឹងទទួលយកតម្លៃទាំងនេះដោយមានមោទនភាពទាំងនៅកន្លែងធ្វើការនិងក្នុងជីវិតឯកជន។

*តើអ្វីខ្លះជាអាកប្បកិរិយាឬលក្ខណៈដែលលោកស្រីគិតថាមានឥទ្ធិពលអវិជ្ជមានដល់ភាពជាអ្នកដឹកនាំ ?*

វាងាយស្រួលណាស់ក្នុងការនិយាយថាយើងជាមេដឹកនាំដ៏ល្អ ប៉ុន្តែ

## “ ភាពអង់អាចគឺក្លាហាន បើទោះមានការតំរាម កំហែងក៏ដោយ ដើម្បីបំរើប្រជាជន។

“ភាពជា” មេដឹកនាំល្អក្នុងពិភពការងារគឺមិនងាយដូចនិយាយទេ។ តាមរយៈបទពិសោធន៍របស់ខ្ញុំ ខ្ញុំមិនអាចដឹកនាំ FWTA ឱ្យលូតលាស់បានទេបើខ្ញុំមិនមានក្រុមការងារល្អមួយដែលនៅពីក្រោយខ្ញុំនិងគាំទ្រការដឹកនាំរបស់ខ្ញុំ។ បញ្ហាប្រឈមដ៏ធំបំផុតរបស់ខ្ញុំក្នុងនាមជាអ្នកដឹកនាំគឺធ្វើការជាមួយមនុស្សដែលមិនមានការទទួលខុសត្រូវចំពោះការងារដែលត្រូវបានចាត់តាំងឱ្យនិងអ្នកដែលមិនមានការប្តេជ្ញាចិត្ត និងភាពស្មោះត្រង់នៅកន្លែងធ្វើការ។ ខ្ញុំបាន ធ្វើការជាមួយមនុស្សជាច្រើនក្នុងជីវិតវិជ្ជាជីវៈរបស់ខ្ញុំហើយខ្ញុំមានបទពិសោធន៍ធ្វើការជាមួយមនុស្សខុសគ្នាៗ។ ខ្ញុំធ្លាប់មានបទពិសោធន៍ធ្វើការជាមួយមនុស្សដែលមិនទទួលខុសត្រូវហើយនេះធ្វើឱ្យភាពជាអ្នកដឹកនាំរបស់ខ្ញុំចុះខ្សោយ ហើយធ្វើឱ្យខ្ញុំហត់នឿយខ្លាំងដោយសារកិច្ចការដែលបានដាក់ឱ្យ មិនអាចត្រូវបានបញ្ចប់តាមពេលវេលានោះទេ។ គុណភាពនៃការងារគឺមិនល្អទេ ហើយបញ្ហាជាច្រើនមិនអាចត្រូវបានដោះស្រាយទាន់ពេលវេលា។

តាមរយៈបទពិសោធន៍នេះ ខ្ញុំតែងតែដឹកនាំអង្គការដោយបែងចែកការងារគ្នា។ ជាមួយនឹងការបែងចែកការដឹកនាំ ខ្ញុំត្រូវធ្វើឱ្យសមាសភាពក្រុមមេដឹកនាំដែលមានគំនិតចង់ឈ្នះ ឱ្យពួកគេទទួលខុសត្រូវចំពោះមុខតំណែងដែលបានដាក់ឱ្យ ហើយរក្សាសច្ចភាពចំពោះបេសកកម្ម ចក្ខុវិស័យនិងតម្លៃស្នូលនៃ FWTA ។ មុនពេលខ្ញុំអាចបែងចែកការងារដោយជោគជ័យ ខ្ញុំត្រូវរៀនចំណាយពេលវេលាបង្កើតនិងរៀបចំឱ្យមានក្រុមដឹកនាំដ៏ជោគជ័យមួយ។

បរិស្ថានក៏អាចបង្កើតផលប៉ះពាល់អវិជ្ជមានលើការដឹកនាំរបស់យើងផងដែរ។ ខ្ញុំបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីឡើងចេញឱ្យផុតពីបរិយាកាសសង្គមដែលស្ត្រីមិនត្រូវបានគេជឿថាមានសមត្ថភាពដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យាទំនើប។ មនុស្សជាច្រើនជឿ ថាក្រុមហ៊ុនបច្ចេកវិទ្យានិងតួនាទីជាអ្នកដឹកនាំកម្មវិធីគឺសម្រាប់តែបុរសប៉ុណ្ណោះ។

នៅក្នុងការដឹកនាំរបស់ខ្ញុំលំហូរនៃព័ត៌មានមានសារសំខាន់ខ្លាំងណាស់។ លំហូរព័ត៌មានល្អអាចជួយដល់ការដំណើរការរលូនរបស់ក្រុមហ៊ុន។

វប្បធម៌ការងារនិងបរិស្ថានជារឿយៗជះឥទ្ធិពលលើការដឹកនាំរបស់ខ្ញុំផងដែរ។ ប្រសិនបើបរិយាកាសការងារមិនមាននីតិវិធីនិងការដឹកនាំច្បាស់លាស់ទេ វានឹងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ការងាររបស់យើង ដូច្នេះខ្ញុំពិតជាហ្មត់ចត់មែនទែនអំពីវប្បធម៌ និងប្រព័ន្ធសម្រាប់គាំទ្រដល់ដំណើរការការងារ។ ទាំងនេះតម្រូវឱ្យមានគោលនយោបាយនិងគោលការណ៍ណែនាំជាក់លាក់ដើម្បីនាំទៅរកការដឹកនាំនិងការគ្រប់គ្រងល្អរបស់អង្គការ។ រឿងទាំងនេះត្រូវបានអនុវត្តជាទូទៅនៅ FWTA ក្រោមការដឹកនាំរបស់ខ្ញុំ។

*តើលោកស្រីធ្វើអ្វីដើម្បីបន្តធ្វើជាអ្នកដឹកនាំ (គន្លឹះនៃភាពជាអ្នកដឹកនាំក្នុងការធ្វើជំនួញនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រីឬសមភាពយេនឌ័រ) ?*

ក្នុងនាមជាមេដឹកនាំក្រុមហ៊ុនខ្ញុំមិនអាចធ្វើពាណិជ្ជកម្មដើម្បីតែប្រាក់ទេ ព្រោះយើងជាផ្នែកមួយនៃសង្គម។ អាជីវកម្មត្រូវការប្រាក់ចំណេញប៉ុន្តែការអនុវត្តអាជីវកម្មត្រូវតែមានក្រមសីលធម៌ហើយយើងមិនគួរភ្លេចដោះស្រាយបញ្ហាសង្គមនៃសហគមន៍ដែលយើងរស់នៅនិងធ្វើអាជីវកម្មនោះទេ។

ខ្ញុំប្តេជ្ញាចំពោះក្តីសុបិន បេសកកម្មនិងគោលដៅនៃ FWTA ដើម្បីខ្ញុំអាចបំផុសអោយមិត្តរួមការងារនិងសហការីរបស់ខ្ញុំយល់ស្របតាមចក្ខុវិស័យនិងបេសកកម្មរបស់ខ្ញុំ ក៏ដូចជាដើម្បីជួយពួកគេក្នុងការរួមជា កម្លាំងរួមគ្នាដើម្បីធ្វើឱ្យក្តីសុបិនរបស់យើងឈានទៅដល់គោលដៅចុងក្រោយ។

យើងត្រូវធ្វើអ្វីដែលយើងស្រលាញ់និងយកចិត្តទុកដាក់បំផុត។ ប្រសិនបើយើងមិនធ្វើតាមដំបូន្មាននេះក្តីសុបិនរបស់យើងនឹងរលាយបាត់ក្នុងពេលឆាប់ៗ។ វាបង្ហាញថាយើងមិនស្រលាញ់ពិតប្រាកដទេ។

យើងត្រូវតែប្លែកពីគេនិងមានគំនិតច្នៃប្រតិដ្ឋក្នុងមុខជំនួញដែលយើងធ្វើហើយវាត្រូវតែមានភាពច្នៃប្រតិដ្ឋ ។

អាជីវកម្មដែលទទួលបានជោគជ័យមិនត្រឹមតែខ្វល់ខ្វាយអំពីផលិតផលនិងភាពជាអ្នកដឹកនាំប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្តោតលើការគ្រប់គ្រងលំហូរសាច់ប្រាក់ និងទទួលស្គាល់ថាការបង្កើតបណ្តាញគឺជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យសេវាកម្មនិងផលិតផលរបស់អ្នកទៅដល់ក្រុមជនគោលដៅរបស់អ្នក។

គ្មាននរណាម្នាក់ល្អឥតខ្ចោះទេ ហើយបញ្ហាប្រឈមនិងបរាជ័យទាំងអស់គួរតែត្រូវបានគេមើលឃើញថាជាមេរៀនដ៏មានតម្លៃនិងជាឱកាសរៀនសូត្រ។ ក្នុងការធ្វើជំនួញអ្នកត្រូវបន្តការរៀនសូត្រនិងកំណត់ចក្ខុវិស័យរយៈពេលវែងព្រោះវាគឺជាការបំផុសគំនិតសម្រាប់ខ្លួនឯង ក្រុមការងារនិងយុទ្ធសាស្ត្រជំនួញរបស់អ្នក។

*តើអ្វីខ្លះជាហានិភ័យធំៗ មួយចំនួនដែលលោកស្រីបានជួបប្រទះនៅក្នុងអាជីពរបស់លោកស្រី ? តើលោកស្រីដោះស្រាយបញ្ហានេះដោយរបៀបណា ?*

មិនមែនតែខ្ញុំទេសហគ្រិនជាច្រើនបានធ្វើការប្រថុយប្រហាក់ប្រហែលគ្នាដូចដែលខ្ញុំបានធ្វើកន្លងមកដែរ។ ខ្ញុំចាប់ផ្តើមធ្វើអាជីវកម្មនៅពេលខ្ញុំកំពុងជាប់បំណុលហើយខ្ញុំខ្ចីប្រាក់ប្អូនស្រីរបស់ខ្ញុំដើម្បីចាប់ផ្តើមអាជីវកម្មរបស់ខ្ញុំ។ ខ្ញុំក៏បានខ្ចីប្រាក់ពីធនាគារដើម្បីទិញផ្ទះក្នុងពេលតែមួយ។ ស្វាមីខ្ញុំនិងខ្ញុំបានធ្វើការយ៉ាងលំបាកដើម្បីរកលុយឱ្យបានគ្រប់គ្រាន់ដើម្បីបង់ថ្លៃចំណាយរបស់យើងរួមទាំងការប្រាក់លើកម្ចីផងដែរ។ ពេលខ្លះយើងជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុនៅពេលដែលការលក់សេវារបស់យើងបានធ្លាក់ចុះនិងបរាជ័យក្នុងការសម្រេចគោលដៅរបស់យើង។ ទាំងនេះគឺជាពេលវេលាដ៏លំបាកសម្រាប់យើងនៅពេលយើងតស៊ូដើម្បីរក្សាក្រុមហ៊ុនរបស់យើងឱ្យនៅរស់និងលូតលាស់ទៅមុខ។

ទោះជាយ៉ាងណាក៏ដោយបញ្ហាប្រឈមទាំងនេះគឺជិតចប់ហើយ យើងកំពុងរស់នៅធម្មតាដោយនៅពេលនេះកាតព្វកិច្ចសងកម្ចីរបស់យើងជិតចប់ហើយ។ ជាសំណាងល្អយើងមានផលិតផលល្អៗ ដើម្បីផ្តល់ជូនដល់អតិថិជនរបស់យើងនៅទីផ្សារ។ ឥឡូវនេះយើងត្រូវបង្កើនលក្ខណៈពិសេសរបស់ផលិតផលយើងនិងធ្វើឱ្យពួកគេមានលក្ខណៈដោយឡែកនិងទូលំទូលាយដើម្បីទាញយកអត្ថប្រយោជន៍ពីទីផ្សារប្រកួតប្រជែង។

FWTA បានរីកលូតលាស់អស់រយៈពេលជិត ៦ ឆ្នាំមកហើយ ហើយឥឡូវនេះយើងមានផលិតផលចម្បងចំនួន៤ នៅក្នុងការថែទាំសុខភាពនិងការគ្រប់គ្រងមន្ទីរពេទ្យ។ យើងបានពង្រីក FWTA ពីក្រុមមនុស្ស៥ នាក់រួមទាំងខ្ញុំផង ទៅក្រុមការងារមួយមានគ្នាជិត៣០ នាក់ដែលមានការគាំទ្រពីអតិថិជនជាង ២០០ នាក់ពីគម្រោងមុននិងបច្ចុប្បន្ន។

បទពិសោធន៍រៀនសូត្រមួយទៀតដែលយើងបានទទួលគឺពេលប្តីខ្ញុំ និងខ្ញុំបានសម្រេចបោះបង់ការងារដែលមានសុវត្ថិភាពនិងប្រាក់ខែច្រើនដើម្បីចាប់ផ្តើមអាជីវកម្មរបស់យើង។ ជួនកាលវានាំឱ្យមានការឈ្លោះប្រកែកគ្នាដោយសារតែបញ្ហាហិរញ្ញវត្ថុ។ ក្នុងពេលជាមួយគ្នានេះយើងបានរកឃើញដំណោះស្រាយចំពោះបញ្ហានេះនិងបញ្ហាជាច្រើនដែលយើងប្រឈមមុខ។

ដោយសារការស្រលាញ់ ការប្តេជ្ញាចិត្ត និងចំណង់ចំណូលចិត្តក្នុងក្តីសុបិនរបស់យើង យើងមានះប្រឈមជាមួយបញ្ហារបស់យើង ហើយបន្តរៀនពីបញ្ហាទាំងអស់នៅក្នុងអាជីវកម្ម។ ទាំងនេះគឺជាមេរៀនមួយចំនួនដែលខ្ញុំបានរៀននិងវិធីដែលយើងបានបង្វែរមេរៀនទាំងនោះទៅជាឱកាស។

*តើអ្វីដែលធ្វើឱ្យវប្បធម៌កម្ពុជាមានលក្ខណៈដោយឡែកពីគេ ហើយតើលោកស្រីគិតថាប្រទេសកម្ពុជាអាចរីកចម្រើនដោយសារសហគ្រិនភាពនិងភាពជាអ្នកដឹកនាំយ៉ាងដូចម្តេច ?*

ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសក្រីក្រនៅក្នុងតំបន់ប៉ុន្តែវាមានលក្ខណៈប្លែកពីគេ ច្រើន។ ប្រជាជនកម្ពុជាមានចំនួនជាង១៦លាននាក់ហើយជាតំបន់ដ៏ស្រស់ស្អាតដែលមានធម្មជាតិនិងប្រាសាទជាប្រវត្តិសាស្ត្រ។ សព្វថ្ងៃនេះប្រទេសកម្ពុជាពិតជាអាចចាត់ទុកថាជាប្រទេសវ័យក្មេងដោយសារតែវាមានប្រជាជនវ័យក្មេងច្រើន។ ហើយប្រជាជនវ័យក្មេងទាំងនេះអាចជាកម្លាំងជំរុញនៅក្នុងប្រទេសកម្ពុជានិងជួយអភិវឌ្ឍវាទៅថ្ងៃមុខ។

ពិភពលោកកំពុងតែបើកទូលាយកាន់តែច្រើន ហើយបច្ចេកវិទ្យាបាននិងកំពុងជំរុញសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននៅក្នុងនិងទូទាំងពិភពលោក។ ដូច្នេះកម្ពុជាចាំបាច់ត្រូវរៀបចំប្រជាជនវ័យក្មេងរបស់ខ្លួននិងផ្តល់ឱ្យពួកគេនូវជំនាញដើម្បីបំពេញតាមតម្រូវការទីផ្សារនៅក្នុងសម័យឌីជីថលនេះ។

ប្រទេសកម្ពុជាគួរតែពិចារណាផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការអភិវឌ្ឍប្រព័ន្ធគាំទ្រសហគ្រិនភាពដែលមានដំណើរការល្អដើម្បីជួយដល់ការចាប់ផ្តើមអាជីវកម្មថ្មីប្រកបដោយភាពច្នៃប្រតិដ្ឋនិងទំនើបកម្មរបស់មនុស្សជំនាន់ក្រោយ ជាពិសេសសហគ្រិនវ័យក្មេងដើម្បីឱ្យពួកគេអាចប្រើប្រាស់គំនិតនិងអាជីវកម្មរបស់ពួកគេដើម្បីធ្វើឱ្យមានផលដែលមានឥទ្ធិពលទៅលើសហគមន៍របស់ពួកគេ។ ប្រជាជនវ័យក្មេងជាច្រើននៅក្នុងប្រទេសនេះកំពុងតែចង់ធ្វើតាមគំនិត របស់ពួកគេដើម្បីនាំមកនូវឥទ្ធិពលវិជ្ជមានប៉ុន្តែពួកគេប្រឈមនឹងបញ្ហាក្នុងការទទួលបានការគាំទ្រផ្នែកបញ្ញានិងហិរញ្ញវត្ថុពីមូលនិធិឯកជននិងរដ្ឋាភិបាល។

ខណៈពេលដែលប្រទេសកម្ពុជាត្រូវបានគេស្គាល់ថាជាប្រទេសកសិកម្មក៏ដោយ ក៏យើងត្រូវបង្កើតវិធីថ្មីនៃការធ្វើពាណិជ្ជកម្មតាមរយៈការដាក់បញ្ចូលបច្ចេកវិទ្យាដើម្បីអភិវឌ្ឍនិងបំពេញតាមតម្រូវការនៃបច្ចេកវិទ្យាសកល។

ដើម្បីឆ្លើយតបទៅនឹងសេដ្ឋកិច្ចឌីជីថលនេះដែលត្រូវបានរៀបចំឡើងដោយផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ប្រទេសកម្ពុជាយើងត្រូវផ្តោតការយកចិត្តទុកដាក់និងការវិនិយោគលើធនធានមនុស្សតាមរយៈការអប់រំនិងសុខភាពពីព្រោះវាគឺជាតម្រូវការចាំបាច់ដើម្បីលើកតម្កើងនិងអភិវឌ្ឍប្រទេសជាតិពីប្រទេសអភិវឌ្ឍន៍តិចតួចបំផុត ទៅជាប្រទេសឧស្សាហកម្មនៅក្នុងរយៈពេលមធ្យមនិងវែង។ ឧទាហរណ៍ប្រទេសកូរ៉េខាងត្បូង ឥណ្ឌានិងសិង្ហបុរីបានលើកកម្ពស់ពលរដ្ឋរបស់ខ្លួនពីភាពក្រីក្រដូចសព្វថ្ងៃនេះដោយសារតែការវិនិយោគទៅលើប្រជាជនរបស់ពួកគេក្នុងរយៈពេល៥០ឆ្នាំចុងក្រោយនេះ។

*លោកស្រីមានដំបូន្មានអ្វីខ្លះសម្រាប់សហគ្រិននារីកម្ពុជា ?*

ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងនាមជាសហគ្រិនស្ត្រី ខ្ញុំសូមចែករំលែកដំបូន្មានដូចខាងក្រោមៈ

១ ការធ្វើជំនួញមិនត្រឹមតែអំពីប្រាក់និងប្រាក់ចំណេញប៉ុណ្ណោះទេ តែអាជីវកម្មត្រូវតែដោះស្រាយបញ្ហា របស់សហគមន៍និងពិភពលោកផងដែរ។

២ ក្មេងស្រីទាំងអស់គួរមានក្តីសុបិនធំសម្រាប់អនាគតរបស់ពួកគេ។ ពួកគេគួរហ៊ានធ្វើការសម្រេចចិត្តសំខាន់ៗហើយគ្រប់គ្រងជោគវាសនាផ្ទាល់ខ្លួនរបស់ពួកគេជាជាងការសម្របខ្លួនតាមអ្នកផ្សេងដូចជាឪពុកម្តាយឬប្តីជាដើម។ ទោះបីយើងគួរពិគ្រោះយោបល់ជាមួយពួកគេ ស្ត្រីវ័យក្មេងគួរតែធ្វើការសម្រេចចិត្តដោយខ្លួនឯង។ អ្នកត្រូវតែធ្វើជាមនុស្សខ្លួនឯងដោយក្តីសុបិនផ្ទាល់ខ្លួនរបស់អ្នក។

៣ ពីភាពបរាជ័យនិងជោគជ័យរបស់ខ្ញុំ ខ្ញុំបានដឹងថាវាមានសារសំខាន់ខ្លាំងណាស់ក្នុងការចូលរួមធ្វើឱ្យបានជិតដល់ ហើយវាមានសារសំខាន់ណាស់ក្នុងការបង្កើតវប្បធម៌និងប្រព័ន្ធការងារដើម្បីធានាថាអ្នកអាចឱ្យក្រុមហ៊ុនរបស់អ្នកដំណើរការដើម្បីបំពេញក្តីសុបិនចុងក្រោយរបស់អ្នក។ ប្រសិនបើអ្នកមិនមែនជាវិស្វករទីមួយនៃវាសនារបស់អ្នកហើយអ្នកអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតរៀបចំវប្បធម៌ធ្វើការរបស់អ្នក អ្នកនឹងបរាជ័យក្នុងការបំពេញតាមគោលដៅរបស់អ្នក។

៤ ត្រូវបង្កើតក្រុមមួយដែលជោគជ័យសម្រាប់អាជីវកម្មរបស់អ្នកជាមុន មុនពេលអ្នកចាប់ផ្តើមអាជីវកម្ម ហើយអ្នកត្រូវចូលរួមគ្រប់ដំណើរការទាំងអស់ដើម្បីធានាថាពួកគេស្របតាមបេសកកម្ម គោលដៅនិងតម្លៃស្នូលរបស់ក្រុមហ៊ុន។

៥ អ្នកត្រូវធ្វើការវិភាគលំហូរសាច់ប្រាក់និងអាចគ្រប់គ្រងហិរញ្ញវត្ថុរបស់អ្នក។ ប្រសិនបើអ្នកមិនអាចគ្រប់គ្រងប្រាក់របស់អ្នក អ្នកចាំបាច់ត្រូវស្វែងរកនរណាម្នាក់ដែលមានសមត្ថភាពជួយអ្នកគ្រប់គ្រងវា។

៦ ប្រតិបត្តិការជោគជ័យទាំងអស់របស់អង្គការណាមួយគឺមិនមែនតែលើមនុស្សម្នាក់នោះទេ អ្នកត្រូវតែបង្កើតជាក្រុម។ ដូចជាក្នុងការសំដែងល្ខោនល្អមួយ តួសម្តែងមួយមិនអាចលេងតួអង្គទាំងអស់បានទេ។ ត្រូវមានតារាសម្តែងផ្សេងៗគ្នា សម្រាប់តួអង្គផ្សេងៗគ្នា តួសម្តែងម្នាក់អាចសមនឹងលេងតួរពីរប្រសិនបើអ្នកចង់កាត់បន្ថយការចំណាយ។

អ្វីដែលខ្ញុំបានចែករំលែកនេះគឺជាមេរៀនដែលខ្ញុំបានរៀនកន្លងមក។ បច្ចុប្បន្នខ្ញុំមិនអាចចាត់ទុកខ្លួនឯងជាសហគ្រិនដែលទទួលបានជោគជ័យនៅឡើយទេ ពីព្រោះខ្ញុំនៅមានផ្លូវវែងឆ្ងាយទៀតដើម្បីសម្រេចគោលដៅរបស់ខ្ញុំ។

woomentum

KONRAD ADENAUER STIFTUNG